# ទន្លេបីកំពុងទទួលការគំរាមកំហែង



ការយល់ដឹងពីការគម្រាមកំហែង និងបញ្ហាប្រឈមថ្មីៗ ចំពោះជីវចម្រុះ និងសិទ្ធិរបស់សហគមន៍នៅក្នុងតំបន់ទន្លេបី ដែលកើតឡើងដោយសារការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី

ខែ មេសា ឆ្នាំ២០១២

សិក្សាដោយ **ម៉ាក គ្រីមស្ឌីជ**

3S Rivers Protection Network

INTERNATIONAL RIVERS
people • water • life



# ទន្លេបីកំពុងរងការគំរាមកំហែង

*ការយល់ដឹងពីការគម្រាមកំហែង និងបញ្ហាប្រឈមថ្មីៗ ចំពោះជីវចម្រុះ*

*និងសិទ្ធិរបស់សហគមន៍នៅក្នុងតំបន់ទន្លេបី*

*ដែលកើតឡើងដោយសារការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី*

ខែ មេសា ឆ្នាំ២០១២

សិក្សាដោយ **ម៉ាក គ្រីមស្ទីដ**

3S Rivers Protection Network

INTERNATIONAL RIVERS
people • water • life

## អំពីបណ្តាញការពារទន្លេបី (3SPN)

អំពីបណ្តាញការពារទន្លេបី គឺជាអង្គការសង្គមស៊ីវិលក្នុងស្រុកមួយ ដែលធ្វើការដើម្បីគាំទ្រសហគមន៍ទាំងឡាយ ណាដែលទទួលរងនូវផលប៉ះពាល់ និងការគំរាមកំហែងផ្សេងៗដោយសារការសាងសង់ទំនប់វារីអគ្គិសនីនៅតាម ដងទន្លេសេសានស្រែពក និងសេកុង នៅភាគ ឦសានប្រទេសកម្ពុជា។

## អំពីអង្គការទន្លេអន្តរជាតិ (IR)

អង្គការទន្លេអន្តរជាតិ ជាអង្គការមិនមែនរដ្ឋាភិបាលមួយដែលការពារទន្លេ និងសិទ្ធិសហគមន៍ ដែលរស់នៅអាស្រ័យលើទន្លេ។ អង្គការទន្លេអន្តរជាតិ ធ្វើការងារដើម្បីបញ្ឈប់នូវរាល់គំរោង ទំនប់ទាំងឡាយណាដែលបង្កវិនាសកម្ម និងជំរុញឲ្យមានដំណោះស្រាយចំពោះទឹក និងថាមពល ដើម្បីឲ្យពិភពលោក មួយមាននិរន្តរភាព និងយុត្តិធម៌។


## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ អាចរៀបរាងបាន ដោយសារការគាំទ្រយ៉ាងមុតមាំពីសំណាក់អង្គការ Oxfam Australia។ សូម ថ្លែងអំណរគុណជាពិសេសដល់ Oxfam-Brett Eloff, LICADHO, Foundation Towards Ecological Recovery និង Regional Alliance (TERRA) ដែលបានអនុញ្ញាតឲ្យ ប្រើប្រាស់នូវរូបភាព និងផែនទីរបស់ពួកគេ។



## និពន្ធដោយ

ម៉ាក គ្រីមស្ឌីជ

markgrimsditch@gmail.com



**© រក្សាសិទ្ធិ ២០១២ បណ្តាញការពារទន្លេបី (3SPN) និងអង្គការទន្លេអន្តរជាតិ (IR)**



**បោះពុម្ពដោយបណ្តាញការពារទន្លេបី (3SPN) និងអង្គការទន្លេអន្តរជាតិ (IR)**

**បណ្តាញការពារទន្លេបី (3SPN)**

ប្រអប់សំបុត្រលេខ ៨៩០០៧

ភូមិ ៤ ក្រុងបានលុង ខេត្តរតនគីរី ប្រទេសកម្ពុជា

ទូរស័ព្ទលេខ៖ +៨៥៥ ៧៥ ៩៧៤ ១១២

គេហទំព័រ៖ www.3spn.org

**អង្គការទន្លេអន្តរជាតិ (IR)**

២១៥០ Allston Way, Suite ៣០០ Berkeley, CA ៩៤៧០៤១៣៧៨ សហរដ្ឋអាមេរិក

ទូរស័ព្ទលេខ៖ +១ ៥១០ ៨៤៨ ១១៥៥

គេហទំព័រ៖ www.internationalrivers.org

កែសម្រួល និងរចនាដោយ Wanida Press ប្រទេសថៃ

រូបភាពគ្របខាងមុខ និងគ្របខាងក្រោយ៖ Oxfam-Brett Eloff


3 S Rivers Protection Network

INTERNATIONAL RIVERS
people • water • life

# មាតិកា


បញ្ជីពាក្យកាត់ ........ ៤

ខ្លឹមសារសង្ខេប ........ ៧

សេចក្តីផ្តើម ........ ១៧

ផ្នែកទី ១ ៖ ថាមពលពីវារីអគ្គិសនីជាជំរើសដើម្បីផ្គត់ផ្គង់ថាមពលក្នុងតំបន់ ........ ២៣
- ១.១ ប្រទេសកម្ពុជា ........ ២៤
- ១.២ ប្រទេសវៀតណាម ........ ២៨
- ១.៣ ប្រទេសឡាវ ........ ៣២
- ១.៤ កម្មវិធីមហាអនុតំបន់ទន្លេមេគង្គ ........ ៣៣

ផ្នែកទី ២ ៖ ការប្រែប្រួលរបស់ទន្លេបី ក្នុងប្រទេសកម្ពុជា ........ ៣៦
- ២.១ ទំនប់វារីអគ្គិសនីសេសានក្រោម២ ........ ៣៧
- ២.២ ទំនប់សេសានក្រោម៣ ........ ៥៥
- ២.៣ ទំនប់សេសានក្រោម១/៥ ........ ៦០
- ២.៤ ទំនប់ស្រែពកក្រោម ៣ និងស្រែពកក្រោម៤ ........ ៦៣
- ២.៥ ទំនប់សេកុងក្រោម ........ ៧០
- ២.៦ ខ្សែបញ្ជូនអគ្គិសនី ........ ៧០

ផ្នែកទី៣ ៖ ស្ថាប័នដែលដើរតួនាទីដ៏សំខាន់ៗ
ក្នុងការជំរុញឲ្យមានការអភិវឌ្ឍន៍វារីអគ្គិសនីក្នុងតំបន់ ........ ៧៨
- ៣.១ ធនាគារអភិវឌ្ឍន៍អាស៊ី ........ ៧៨
- ៣.២ ធនាគារពិភពលោក ........ ៩៤
- ៣.៣ ការផ្តួចផ្តើមគំនិតថ្នាក់តំបន់ និងទ្វេភាគី ........ ១០០

សេចក្តីសន្និដ្ឋាន ........ ១០៩

ឯកសារយោង ........ ១១៣

## បញ្ជីពាក្យកាត់

| | |
|---|---|
| ទន្លេបី | ទន្លេសេសាន, ទន្លេស្រែពក និងទន្លេសេកុង |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| BOT | សាងសង់ ដំណើរការ និងផ្ទេរ |
| CNMC | គណកម្មាធិកាទន្លេមេគង្គកម្ពុជា |
| SCG | ក្រុមហ៊ុនតបណ្តាញចរន្តអគ្គិសនីចិនភាគខាងត្បូង |
| CTL | ក្រុមហ៊ុនតបណ្តាញអគ្គិសនីកម្ពុជា |
| CUPL | ក្រុមហ៊ុនចែកចាយអគ្គិសនីកម្ពុជា |
| DTA-CLV | ផែនការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា, ឡាវ, វៀតណាម |
| EDC | អគ្គិសនីកម្ពុជា |
| EDL | អគ្គិសនីឡាវ |
| EIA | ការវាយតំលៃ ហេតុផលប៉ះពាល់ បរិស្ថាន |
| EMP | ផែនការគ្រប់គ្រងបរិស្ថាន |
| EVN | អគ្គិសនីវៀតណាម |
| EVNI | ក្រុមហ៊ុន ភាគហ៊ុនអគ្គិសនីអន្តរជាតិវៀតណាម |
| GMS | ផែនការមហាអនុតំបន់ទន្លេមេគង្គ |
| HSAP | ការសិក្សាពីគោលនយោបាយនៃនិរន្តរភាពវាមពលអគ្គិសនី |
| IEE | ការសិក្សាវាយតំលៃហេតុប៉ះពាលបរិស្ថាន បឋម |
| IRC | អនុគណកម្មកាដោះស្រាយសំណង |
| JICA | អង្គការ សហប្រតិបត្តិកាអន្តរជាតិជប៉ុន |
| KCC | អ្នកប្រឹក្សាឯករាជ្យកម្ពុជា |
| MIME | ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល |
| M-IWRM | គំរោងសមាហរណកម្មគ្រប់គ្រងធនធានទឹកមេគង្គ |
| MoE | ក្រសួងបរិស្ថាន |
| MOU | កិច្ចព្រមព្រាង នៃ អនុសារណៈយោគយល់គ្នា |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NMC | គណកម្មកាជាតិទន្លេមេគង្គ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |

| | |
|---|---|
| NTFP | អនុផលព្រៃឈើ |
| PECC1 | ក្រុមហ៊ុនសហប្រតិបត្តិការពិគ្រោះយោបល់ ឯករាជ្យ១ |
| PID | ឯកសារ ព័ត៌មានគំរោង |
| RCC | សម្ព័ន្ធទន្លេកម្ពុជា |
| RPTCC | គណកម្មការសម្របសម្រួលទីផ្សារឋាមពលតំបន់ |
| SIDA | សហប្រតិបត្តិការ ការអភិវឌ្ឍន៍អន្តរជាតិ ស៊ុយអែត |
| TA | ជំនួយបច្ចេកទេស |
| WUP | គំរោងចែកចាយទឹក |
| | |
| Ha | ហិកតា |
| Km | គីឡូម៉ែត្រ |
| Kv | គីឡូវុល |
| Kwh | គីឡូវ៉ាតម៉ោង |
| MW | មេកាវ៉ាត់ |

## ខ្លឹមសារសង្ខេប

បច្ចុប្បន្ននេះ ទន្លេសេសាន ទន្លេស្រែពក និងទន្លេសេកុង (ទន្លេបី) កំពុងស្ថិតក្នុងចំណុចមួយដ៏ចម្រូងចម្រាស់។ ក្រៅពីទំនប់ជាង ២០ ដែលបានសាងសង់រួច និងកំពុងសាងសង់នៅតាមដងទន្លេទាំងបីនេះទៅ ក៏នៅមានផែនការសង់ទំនប់ចំនួន ២៦ ទៀត ដែលនឹងគម្រាមកំហែងដល់បណ្ដាប្រទេសដែលទន្លេទាំងបីនេះហូរកាត់ រួមមានប្រទេសវៀតណាម កម្ពុជា និងប្រទេសឡាវ។ គិតរហូតមកដល់បច្ចុប្បន្ននេះ ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីរបស់ប្រទេសវៀតណាម គឺមានទ្រង់ទ្រាយធំជាងគេ និងបានកំពុងតែបំផ្លិចបំផ្លាញទន្លេសេសាន និងទន្លេស្រែពកនៅតំបន់ខ្ពង់រាបកណ្ដាលនៃប្រទេសវៀត-ណាម និងប៉ែកឦសានក្នុងប្រទេសកម្ពុជា។ ទោះបីជាគម្រោងអភិវឌ្ឍន៍ទាំងនេះបានបង្កឲ្យមានផលប៉ះពាល់ដល់ជីវចម្រុះតាមដងទន្លេ ប៉ះពាល់ដល់ជលផល និងប៉ះពាល់ដល់ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនរាប់សិបពាន់នាក់ក៏ដោយ ក៏បច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងតែព្យាយាមជម្រុញនូវផែនការរបស់ខ្លួនក្នុងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅតាមដងទន្លេទាំងបីនេះដដែល។ ចំណែកឯប្រទេសឡាវវិញ ក៏កំពុងតែអភិវឌ្ឍសមត្ថភាពផលិតថាមពលអគ្គិសនីរបស់ខ្លួននៅតាមដងទន្លេសេកុងផងដែរ។

ប្រព័ន្ធទន្លេបី គឺជាដៃដ៏សំខាន់របស់ទន្លេមេគង្គ ហើយតំបន់អាងទន្លេនេះ ត្រូវបានគេទទួលស្គាល់ថាមានសារសំខាន់ដល់ផ្នែកជីវសាស្ត្រ បរិស្ថាន និងជាផ្លូវដ៏សំខាន់សម្រាប់ត្រីធ្វើចរាចរ។ មានប្រជាជនរាប់លាននាក់កំពុងផ្សារភ្ជាប់ជីវិត និងការរស់នៅរបស់ពួកគេជាមួយនឹងប្រព័ន្ធទន្លេនេះ។ ជាមួយគ្នានេះផងដែរ ធនធានធម្មជាតិដ៏សម្បូរបែបរបស់ទន្លេទាំងបីនេះ ក៏កំពុងតែជួយដល់អ្នកនេសាទ កសិករ និងសហគមន៍ដទៃទៀតដែលរស់នៅពឹងផ្អែកលើការប្រមូលអនុផលព្រៃឈើ។ ច្រើនជាង ២០% នៃតំបន់អាងទន្លេនេះ ត្រូវបានចាត់ទុកថាជាតំបន់ការពារ ក្នុងនោះមានដូចជាដែនជម្រកសត្វព្រៃលំផាត់ និងឧទ្យានជាតិវីរៈជ័យរបស់ប្រទេសកម្ពុជា។ លើសពីនេះទៅទៀត អន្លង់ជ្រៅៗជាច្រើននៅតាមដងទន្លេទាំងនេះ បានក្លាយទៅជាតំបន់អភិរក្សត្រី ដោយសារតែភាពអំណោយផលរបស់វាដល់ការរស់នៅរបស់ត្រីជាច្រើនប្រភេទ និងធនធានក្រោមទឹកដទៃទៀតជាច្រើន។ ប៉ុន្តែផែនការនាពេលបច្ចុប្បន្ន ក្នុងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំរបស់ប្រទេសកម្ពុជា និងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីឥតឈប់ឈរនៅប៉ែកកណ្ដាលនៃប្រទេសវៀតណាម និងប៉ែកខាងត្បូងនៃប្រទេសឡាវ កំពុងគម្រាមកំហែងឲ្យមានការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សនូវប្រព័ន្ធបរិស្ថានរបស់ទន្លេ ដែលការណ៍នេះមានន័យថា ជាការបង្កនូវផលប៉ះពាល់ដ៏ធ្ងន់ធ្ងរទៅដល់សហគមន៍ដែលរស់នៅពឹងអាស្រ័យលើទន្លេ និងធនធាននៅតាមដងទន្លេទាំងនេះ។




ផែនទីអាងទន្លេបី

ប៉ុន្មានឆ្នាំកន្លងទៅនេះ តម្រូវការថាមពលអគ្គិសនីនៅក្នុងប្រទេសវៀតណាម និងប្រទេសថៃបាន កើនឡើងយ៉ាងខ្លាំង ខណៈពេលដែលតម្រូវការនៅក្នុងប្រទេសកម្ពុជា និងប្រទេសឡាវកើនឡើងក្នុង អត្រាមួយយឺត។ ការកើនឡើងនូវតម្រូវការថាមពលនេះ បណ្តាលឲ្យមានការខ្វះខាតថាមពលអគ្គិសនី នៅក្នុងប្រទេសទាំង ៤ ខាងលើ។ ជាមួយគ្នានេះ គេក៏ដឹងផងដែរថា ធនធានទឹកនៅក្នុងប្រទេសឡាវ និងប្រទេសកម្ពុជា អាចនឹងត្រូវយកមកប្រើប្រាស់ ដើម្បីផលិតថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់ក្នុង ស្រុក និងប្រើប្រាស់ក្នុងតំបន់។ ស្របពេលដែលប្រទេសទាំងពីរនេះមានគោលនយោបាយ និងយុទ្ធ សាស្ត្រដើម្បីបំពេញនូវតម្រូវការថាមពលអគ្គិសនីរបស់ខ្លួន និងដើម្បីលក់ថាមពលអគ្គិសនីទៅឲ្យប្រ ទេស ជិតខាងផងនោះ ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនឯកជនជាច្រើន បាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងការ អភិវឌ្ឍន៍វារីអគ្គិសនីនៅក្នុងតំបន់ទាំងនេះ។ ដោយសារមានការខ្វះខាតសមត្ថភាពក្នុងការអភិ- វឌ្ឍន៍វារី អគ្គិសនីទ្រង់ទ្រាយធំ មានក្រុមហ៊ុនឯកជន និងក្រុមហ៊ុនរដ្ឋជាច្រើន បានលេចរូបរាងឡើង និង កំពុងតែ អនុវត្តគម្រោងជាច្រើន ក្រោមរូបភាពសាងសង់-ប្រតិបត្តិការ-ផ្ទេរ (BOT)។ លើសពីនេះទៅ ទៀត ស្ថាប័ នហិរញ្ញវត្ថុអន្តរជាតិមួយចំនួន ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី ក៏កំពុងតែគាំទ្រដល់ការភ្ជាប់ ខ្សែបណ្តាញ ចែកចាយថាមពលនៅក្នុងតំបន់នេះផងដែរ។

ការសាងសង់ និងការដាក់ឲ្យដំណើរការទំនប់វារីអគ្គិសនីខ្នាតធំនៅប៉ែកខាងលើទន្លេបី ក្នុង ប្រទេសវៀតណាម បានបង្កឲ្យមានផលប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់សហគមន៍នៅផ្នែកខាងក្រោមទំនប់ ទាំង ក្នុងប្រទេសវៀតណាម និងទាំងក្នុងប្រទេសកម្ពុជា តាមរយៈការធ្វើឲ្យថយចុះបរិមាណត្រី ការឡើងចុះ

កម្ពស់ទឹកមិនទៀងទាត់ និងការផ្លាស់ប្តូរនូវបរិមាណ និងគុណភាពទឹក។ ផលប៉ះពាល់អវិជ្ជមានទាំងនេះ បានធ្វើឲ្យសហគមន៍នៅផ្នែកខាងក្រោមទំនប់ ជួបនូវការលំបាកក្នុងការធានាឲ្យបាននូវសុវត្ថិភាពស្បៀងអាហារ និងការរកប្រាក់ចំណូលប្រចាំថ្ងៃសម្រាប់គ្រួសារ។ បច្ចុប្បន្ននេះ មានការប្រឈមថ្មីៗទៀតកើតឡើងតាមរយៈគម្រោងសាងសង់ទំនប់វារីអគ្គិសនីបន្ថែមចំនួន ២៦ ទៀត ក្នុងអាងទន្លេបី ដែលនឹង គម្រាមកំហែងដល់តំបន់មិនរងផលប៉ះពាល់មួយចំនួននៃអាងទន្លេនេះ។ ប្រសិនបើទំនប់វារីអគ្គិសនី ទាំងនេះ ត្រូវបានគេសាងសង់មែន វានឹងបំផ្លាញដល់ធនធានធម្មជាតិនៅអាងទន្លេបីនេះ តាមរយៈធ្វើឲ្យមានការផ្លាស់ប្តូរលំហូរទឹកទន្លេ ការប្រែប្រួលគុណភាពទឹក ការប្រែប្រួលក្នុងការប្រើប្រាស់ដីធ្លី និងបម្រែបម្រួលគម្របព្រៃឈើ ជាពិសេសកាត់ផ្តាច់ចរាចររបស់ត្រី បំផ្លាញចំណី និងជម្រកពងកូនរបស់ត្រី។ កត្តានេះ នឹងកាត់ផ្តាច់សហគមន៍ពីការប្រកបរបរចិញ្ចឹមជីវិត និងការគ្រប់គ្រងធនធានធម្មជាតិតាមបែបប្រពៃណី និងបណ្តាលឲ្យមានឥទ្ធិពលមិនល្អនាពេលអនាគតដល់សេដ្ឋកិច្ចសង្គម និរន្តរភាពបរិស្ថាន និងជីវចម្រុះ។ ដោយសារតែមានការហ៊ុំព័ទ្ធពីគម្រោងទាំងនេះចំពោះទន្លេមេគង្គ និងដោយសារតែ ទន្លេបីមានសារសំខាន់ក្នុងការរក្សាឲ្យបាននូវភាពសម្បូរណ៍បែបនៃជលផល និងដីល្បាប់ដ៏មានជីជាតិ ផលប៉ះពាល់របស់គម្រោងទាំងអស់នេះ នឹងបំផ្លាញទៅដល់ដងទន្លេមេគង្គទាំងមូល។

នៅក្នុងប្រទេសវៀតណាម មានទំនប់ជាច្រើនត្រូវបានគេសាងសង់នៅតាមដងទន្លេសេសាន ហើយបើទោះបីជានៅក្នុងប្រទេសកម្ពុជាមិនទាន់មានការសាងសង់ទំនប់នៅតាមដងទន្លេនេះក៏ដោយ ក៏នៅមានគម្រោង២ទៀត បន្ថែមពីលើគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ (៤០០មេហ្គាវ៉ាត់ ទទួលបានការអនុម័តពីរដ្ឋាភិបាលកម្ពុជានៅដើមឆ្នាំ២០១១) កំពុងត្រូវបានគេសិក្សាស្វែងរកលទ្ធភាពសាងសង់ដែរ។ ចំណែកឯទន្លេសេកុង នៅមានលំហូរតាមបែបធម្មជាតិនៅឡើយ ប៉ុន្តែនៅក្នុងប្រទេសឡាវវិញ មានគម្រោងសាងសង់ទំនប់ខ្នាតធំចំនួន ២២ តាមដងទន្លេនេះនាប៉ែកខាងត្បូងនៃប្រទេស។ ស្របពេលជាមួយគ្នានេះផងដែរ នៅចុងឆ្នាំ ២០១១ ប្រទេសកម្ពុជា បានប្រកាសថានឹងធ្វើការពិចារណាលើលទ្ធភាពសង់ទំនប់វារីអគ្គិសនីសេកុងក្រោម ដែលស្ថិតនៅតាមព្រំដែនប្រទេសកម្ពុជា។ ចំពោះទន្លេស្រែពកវិញ មានទំនប់មួយចំនួន កំពុងត្រូវបានគេសាងសង់ក្នុងប្រទេសវៀតណាម និងមានគម្រោងសាងសង់ទំនប់វារីអគ្គិសនីចំនួន២ទៀត កំពុងត្រូវបានគេសិក្សានៅក្នុងប្រទេសកម្ពុជា។

របាយការណ៍នេះ ផ្តោតសំខាន់លើគម្រោងសាងសង់ទំនប់វារីអគ្គិសនី ដែលបានអនុម័តរួចនៅតាមដងទន្លេបីក្នុងប្រទេសកម្ពុជា ដែលគម្រោងទាំងនោះរួមមាន ៖

- គម្រោងសេសានក្រោម២ (មានអានុភាព ៤០០ មេហ្គាវ៉ាត់) គម្រោងសេសានក្រោម ១/៥ (មានអានុភាព ៩៦ មេហ្គាវ៉ាត់) និងគម្រោងសេកុងក្រោម (មានអានុភាព ១៩០ មេហ្គា

វ៉ាត់) ដែលគម្រោងទាំងនេះត្រូវបានអភិវឌ្ឍ ឬសិក្សាដោយក្រុមហ៊ុនរដ្ឋរបស់វៀត ណាម (អគ្គិសនីវៀតណាម)។

- គម្រោងស្រែពកក្រោម៣ (មានអានុភាព ៣០០ មេហ្គាវ៉ាត់) និងគម្រោងស្រែពកក្រោម៤ (មានអានុភាព ២២០ មេហ្គាវ៉ាត់) ដែលគម្រោងទាំង ២ នេះ កំពុងសិក្សាដោយ ក្រុមហ៊ុនរដ្ឋរបស់ចិន (Huadian)
- គម្រោងសេសានក្រោម៣ (មានអានុភាព ៣៧៥ មេហ្គាវ៉ាត់) ដែលកំពុងត្រូវបានសិក្សាដោយក្រុម ហ៊ុនកូរ៉េ ឈ្មោះខូវៀ ខេបល ខូ អិលធីឌី។

សរុបរួម ទំនប់វារីអគ្គិសនីទាំង ៦ ដែលបានលើកឡើងក្នុងរបាយការណ៍នេះ មានសក្តានុពលអាចផលិតអគ្គិសនីបានលើសពី ១,៥០០ មេហ្គាវ៉ាត់។ ជាមួយគ្នានេះផងដែរ ក៏នៅមានទំនប់ខ្នាតតូចមួយចំនួនទៀតត្រូវបានគេគ្រោងនឹងសាងសង់នៅតាមដៃទន្លេទាំងបីនេះ ក្នុងនោះរួមមាន ៖ គម្រោងព្រែកលាំង ១ (មានអានុភាព ៦៤ មេហ្គាវ៉ាត់) និងគម្រោងព្រែកលាំង ២ (មានអានុភាព ៦៤ មេហ្គាវ៉ាត់) ដែលគម្រោងទាំង ២ នេះ មានទីតាំងស្ថិតនៅត្រង់អូរតាបូក តាមដងទន្លេសេសាន។ នៅក្នុងរបាយការណ៍នេះ នឹងមិនលើកយកគម្រោងតូចៗទាំងនេះមកពិភាក្សាទេ។



រូបភាពអង្គការ TERRA: បុរសម្នាក់កំពុងអុំទូកកាត់ទន្លេសេសាន

ព័ត៌មានដែលពាក់ព័ន្ធនឹងទំនប់វារីអគ្គិសនីទាំងអស់ ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ មានការពិបាកក្នុងការស្វែងរកណាស់។ ប៉ុន្តែចំពោះព័ត៌មានដែលពាក់ព័ន្ធនឹងទំនប់សេសានក្រោម ២ គឺមានភាពងាយស្រួលក្នុងការស្វែងរក ព្រោះគម្រោងសាងសង់ទំនប់វារីអគ្គិសនីមួយនេះ ជាប្រធានបទមួយដែលត្រូវបានគេជជែកវែកញែកយ៉ាងផុសផុល ចំណែកឯរបាយការណ៍វាយតម្លៃហេតុប៉ះពាល់

បរិស្ថានរបស់គម្រោងនេះ ក៏ត្រូវបានគេផ្សព្វផ្សាយជាសាធារណៈនៅពាក់កណ្តាលឆ្នាំ២០០៨។ ក្នុងនាមជាគម្រោងសាងសង់ទំនប់វារីអគ្គិសនីមួយដែលមានទ្រង់ទ្រាយធំ និងត្រូវបានអនុញ្ញាតឲ្យសាងសង់នៅប៉ែកឦសាននៃប្រទេសកម្ពុជា ទំនប់វារីអគ្គិសនីសេសានក្រោម២ កំពុងតែធ្វើឲ្យមជ្ឈដ្ឋានទូទៅចាប់អារម្មណ៍យ៉ាងខ្លាំង តាមរយៈផលប៉ះពាល់អវិជ្ជមានដែលនឹងកើតមានឡើងចំពោះបរិស្ថាន និង សង្គម។ គេរំពឹងទុកថាទំនប់វារីអគ្គិសនីមួយនេះនឹងជន់លិចផ្ទៃដីទំហំ ៣៣៤ គីឡូម៉ែត្រក្រឡា និងធ្វើឲ្យប្រជាជនរាប់ពាន់គ្រួសារត្រូវផ្លាស់ប្តូរទីលំនៅ។ តាមសេចក្តីរាយការណ៍បានឲ្យដឹងថា ការអនុម័តលើគម្រោងសេសានក្រោម២ នាដើមឆ្នាំ ២០១១ ត្រូវបានធ្វើឡើងបន្ទាប់ពីរដ្ឋាភិបាលវៀតណាមបាន ជម្រុញឲ្យប្រទេសកម្ពុជាពន្លឿនការអនុម័តលើគម្រោងនេះ។ បច្ចុប្បន្ននេះ ព័ត៌មានពាក់ព័ន្ធនឹងទំនប់ ជាច្រើនទៀតដែលគ្រោងនឹងសាងសង់មិនអាចទទួលបានទេ ព័ត៌មានដែលយើងមាននៅពេលនេះ មួយភាគធំគឺទទួលបានពីបណ្តាញសារព័ត៌មាន ដោយគ្មានឯកសារសំអាងជាផ្លូវការ ព្រោះឯកសារផ្លូវការទាំងនោះ មិនត្រូវបានគេបោះផ្សាយជាសាធារណៈ។ ទោះបីជាយ៉ាងណាក៏ដោយ គេបានដឹងថាទំនប់ វារីអគ្គិសនីសេសានក្រោម ៣ នឹងបង្កឲ្យមានការជន់លិចផ្ទៃដីធំជាងទំនប់សេសានក្រោម២ទៅទៀត (៤២០គីឡូម៉ែត្រក្រឡា) ហើយទំនប់ស្រែពក៣ និងស្រែពក៤ គឺមានទីតាំងស្ថិតក្នុងតំបន់ការពារ (ដែនជម្រកសត្វព្រៃ) និងមានអាងស្តុកទឹកដ៏ធំល្វឹងល្វើយ។ គម្រោងទាំងអស់នេះ នៅមិនទាន់ត្រូវបានគេសិក្សាពីហេតុប៉ះពាល់បរិស្ថាននៅឡើយទេ ហើយក៏នៅមិនទាន់មានការពិគ្រោះយោបល់ណាមួយ ត្រូវបានគេធ្វើឡើងជាមួយនឹងសហគមន៍មូលដ្ឋាននៅឡើយដែរ។

ដោយសារតែគម្រោងទំនប់វារីអគ្គិសនីខ្នាតធំទាំងអស់នៅតាមតំបន់ទន្លេបី មិនទាន់ត្រូវបានគេសាងសង់នៅឡើយ ដូច្នេះគេក៏មិនទាន់ដឹងថាផលប៉ះពាល់ជាក់ស្តែងដែលនឹងកើតមាននាពេលខាងមុខមានទំហំប៉ុណ្ណានៅឡើយដែរ។ ប៉ុន្តែមានករណីសិក្សាមួយចំនួនបានលើកឡើងពីក្តីបារម្ភពីផលប៉ះពាល់របស់គម្រោងទាំងអស់នេះទៅលើបរិស្ថាន និងសង្គម។ គេអាចទស្សន៍ទាយដឹងពីផលប៉ះពាល់ ដែលនឹងកើតមានពីគម្រោងទាំងអស់នេះតាមរយៈបទពិសោធន៍ និងផលប៉ះពាល់ជាក់ស្តែង ដែលបានជួបប្រទះពីទំនប់វារីអគ្គិសនីយ៉ាលី និងទំនប់ដទៃជាច្រើនទៀតដែលបានសាងសង់រួចរាល់ និងកំពុងដំណើរការនៅក្នុងប្រទេសវៀតណាម។ ផលប៉ះពាល់ដែលនឹងអាចកើតឡើងទាំងនេះរួមមាន ៖ ការធ្វើឲ្យថយចុះយ៉ាងឆាប់រហ័សនូវបរិមាណត្រី ការប្រែប្រួលនៃគុណភាពទឹក ការប្រែប្រួលលម្ហូរទឹកទន្លេ និងឧប្បត្តិហេតុនានាដែលធ្វើឲ្យបាត់បង់នូវទ្រព្យសម្បត្តិ និងអាយុជីវិតមនុស្សជាដើម។ រាល់ទំនប់វារីអគ្គិសនីទាំងអស់ដែលគ្រោងសធ្វើឡើងនៅតំបន់ទន្លេបីក្នុងប្រទេសកម្ពុជា មានទីតាំងស្ថិតនៅតំបន់ទំនាប ដែលនេះមានន័យថាអាងស្តុកទឹក នឹងត្រូវលាតសន្ធឹងយ៉ាងធំល្វឹងល្វើយលើតំបន់ទំនាបនេះ។ អាងស្តុកទឹកទាំងនេះនឹងធ្វើឲ្យជន់លិចដីធ្លី ព្រៃឈើ និងជម្រកសត្វព្រៃ។ ការណ៍នេះ បង្កើតឲ្យមានបញ្ហាប្រឈមជាច្រើនចំពោះជីវចម្រុះ និងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជននៅក្នុងតំបន់នេះ។ ជាមួយគ្នានេះផងដែរ វា

ក៏ធ្វើឲ្យជន់លិចដីបង្កបង្កើនផល និងដីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋរាប់ពាន់គ្រួសារ ក្នុងនោះរួមមាន ជនជាតិដើមភាគតិចមួយភាគធំផងដែរ។ ផលប៉ះពាល់ជាក់ស្តែងនៃការបិទចរាចរត្រីនៅទន្លេសេសាន និងស្រែពក នៅមិនទាន់បានគេទទួលស្គាល់ទាំងស្រុងនៅឡើយទេ ប៉ុន្តែជាក់ស្តែងណាស់ ការបិទ ចរាចរត្រី នឹងធ្វើឲ្យប្រភេទត្រីមួយចំនួននៅផ្នែកខាងលើនៃទំនប់ឈានទៅរកការផុតពូជ។ បញ្ហានេះ នឹងជះឥទ្ធិពលដល់ប្រជាជនរាប់សិបពាន់នាក់ ដែលពឹងផ្អែកលើការនេសាទសម្រាប់ចិញ្ចឹមជីវិត ទាំង នៅខាងលើទំនប់ និងនៅខាងក្រោមទំនប់។ មានអ្នកវិទ្យាសាស្ត្រមួយចំនួនបានលើកឡើងថា ទំនប់នេះ នឹងរារាំងទៅដល់ការធ្វើចរាចររបស់ត្រីពីតំបន់ឆ្ងាយៗ ដូចជាពីបឹងទន្លេសាប និងតំបន់ដីសន្ទទន្លេមេគង្គ ក្នុងប្រទេសវៀតណាមជាដើម ប៉ុន្តែការលើកឡើងនេះត្រូវបានបដិសេធចោលដោយរដ្ឋាភិបាលកម្ពុជា។

ដើម្បីរក្សាកំណើនសេដ្ឋកិច្ច និងដើម្បីទាក់ទាញចំណាប់អារម្មណ៍ពីវិស័យឯកជនឲ្យមកវិនិយោគនៅក្នុងប្រទេសកម្ពុជា នីតិវិធីច្បាប់ជាច្រើនត្រូវបានគេមើលរំលង ឬមិនត្រូវបានគេអនុវត្តឲ្យបានពេញលេញ។ នៅក្នុងវិស័យថាមពលវារីអគ្គិសនីទាំងក្នុង និងក្រៅប្រទេស មានឧទាហរណ៍មួយចំនួនបានបង្ហាញឲ្យឃើញថា មានគម្រោងទំនប់វារីជាច្រើន ត្រូវបានគេអនុម័តដោយមិនបានសិក្សាវាយតម្លៃពីហេតុប៉ះពាល់បរិស្ថាន ឬត្រូវបានអនុម័ត ខណៈពេលដែលការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានកំពុងតែដំណើរការ។ មានករណីខ្លះទៀត ឧទាហរណ៍ដូចជាគម្រោងសេសានក្រោម២ ទោះបីជាការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានគេបញ្ចប់ទាន់ពេលវេលាក៏ដោយ តែមានចំណុចជាច្រើននៅក្នុងរបាយការណ៍វាយតម្លៃ បានអនុលោមទៅតាមបទដ្ឋានរបស់ក្រសួងបរិស្ថាន ដែលឃ្លាតឆ្ងាយពីបទដ្ឋានអន្តរជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ នេះគឺជាគម្រោងវិនិយោគពីក្រៅប្រទេសដ៏ធំបំផុតរបស់កម្ពុជា និងដែលត្រូវអនុវត្តដោយក្រុមហ៊ុនដែលមានបទពិសោធន៍រាប់ទសវត្សក្នុងវិស័យថាមពលអគ្គិសនី។ បន្ទាប់ពីក្រុមហ៊ុន បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយនឹងរដ្ឋាភិបាលកម្ពុជា ដើម្បីសិក្សាស្វែងរកលទ្ធភាពរបស់គម្រោងក្នុងឆ្នាំ២០០៧រួចមក ក្រុមហ៊ុនបានឲ្យក្រុមហ៊ុនមួយផ្សេងទៀតធ្វើសិក្សាវាយតម្លៃពីហេតុប៉ះពាល់បរិស្ថាននៅដើមឆ្នាំ២០០៨។ ដំណើរការនៃការពិគ្រោះយោបល់ លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានអង្គការសង្គមស៊ីវិល និងសហគមន៍រងផលប៉ះពាល់ជាច្រើន ធ្វើការរិះគន់ ព្រោះការពិគ្រោះយោបល់នោះ ធ្វើឡើងតែជាមួយនឹងសហគមន៍ដែលស្ថិតនៅក្នុងទីតាំងទំនប់តែប៉ុណ្ណោះ។ ជាមួយគ្នានេះផងដែរ សហគមន៍ដែលត្រូវបានពិគ្រោះយោបល់យល់ថា ពួកគាត់មិនត្រូវបានគេផ្តល់ព័ត៌មានបានគ្រប់គ្រាន់។ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលត្រូវបានផ្សព្វផ្សាយ ជាសាធារណៈក្នុងឆ្នាំ ២០០៨ ត្រូវបានពិនិត្យមើលដោយអ្នកឃ្លាំមើលមួយចំនួន និងបានផ្តល់យោបល់ លើរបាយការណ៍នេះថា មិនបានពិចារណាដល់ផលប៉ះពាល់លើផ្នែកជលផល និងមិនបានពិចារណា បានល្អិតល្អន់លើផលប៉ះពាល់របស់ទំនប់ផ្សេងៗទៀតនៅក្នុងតំបន់នេះ។ បន្ទាប់ពីមានការកែសម្រួល ជាច្រើនលើកច្រើនសាររួចមក របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានេះ ត្រូវបានគេអនុម័តជាផ្លូវ

ការនៅក្នុងខែមិថុនា ឆ្នាំ២០១០ ហើយគម្រោងសាងសង់ទំនប់សេសានក្រោម២ ក៏ត្រូវបានអនុម័តនៅដើមឆ្នាំ ២០១១។



ឧបករណ៍នេសាទលក្ខណៈប្រពៃណីដែលបានប្រើប្រាស់តាមដងទន្លេស្រែពក

ដំណើរការ និងគុណភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងប្រទេសកម្ពុជា បានជួបនូវការរិះគន់អស់ជាច្រើនឆ្នាំ។ ប៉ុន្តែបច្ចុប្បន្ននេះ មានការពិភាក្សាគ្នាជាបន្តបន្ទាប់លើបញ្ហានេះ ហើយក៏មានសកម្មភាពមួយចំនួន កំពុងត្រូវបានគេអនុវត្ត ក្នុងគោលបំណងលើកកម្ពស់សមត្ថភាពរបស់មន្ត្រីពាក់ព័ន្ធ ឲ្យចេះតាមដានលើដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងបង្កើតនូវក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជាលើបញ្ហានេះ។ ទោះបីជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះនៅមានការងារជាច្រើនដែលត្រូវធ្វើ ជាពិសេសការងារពាក់ព័ន្ធនឹងការលើកកម្ពស់ការយល់ដឹងរបស់វិស័យឯកជន របស់មន្ត្រី រដ្ឋាភិបាល និងរបស់ក្រសួងមួយចំនួន ឲ្យយល់ដឹងពីសារសំខាន់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមានគុណភាពខ្ពស់។ តួយ៉ាង ដូចអ្វីដែលបានលើកឡើងដោយប្រធាននាយកដ្ឋាននៃក្រសួងបរិស្ថានថា "តម្រូវ ការឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់ប្រទេសកម្ពុជា គឺជាតម្រូវការ ទី២។ តម្រូវការ ចម្បងរបស់យើងគឺការអភិវឌ្ឍន៍។ ជាឧទាហរណ៍យើងឃើញថា សារសំខាន់នៃការ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មិនទាន់ត្រូវបានគេទទួលស្គាល់ទាំងស្រុងនៅឡើយទេ។ បច្ចុប្បន្ននេះ មាន

ក្រសួងជាច្រើន របស់រដ្ឋកំពុងតែទទួលខុសត្រូវ និងយកចិត្តទុកដាក់លើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ឬការអភិវឌ្ឍន៍ឧស្សាហកម្ម និងកសិកម្ម។"[1]

ក្រៅពីគោលនយោបាយរបស់រដ្ឋាភិបាល និងរបៀបវារៈរបស់អ្នកអភិវឌ្ឍន៍ ដែលបានយកមកពិភាក្សានៅទីនេះ ក៏នៅមានអ្នកពាក់ព័ន្ធមួយចំនួនទៀត ដែលមានចំណែកនៅក្នុងការអភិវឌ្ឍន៍ថាមពលអគ្គិសនីនៅក្នុងតំបន់ទន្លេបីនេះ។ ធនាគារអភិវឌ្ឍន៍អាស៊ី បានភ្ជាប់ខ្លួនទៅនឹងតំបន់ទន្លេមេគង្គអស់រយៈពេលជាច្រើនឆ្នាំ ដែលក្នុងអំឡុងពេលនោះ ធនាគារអភិវឌ្ឍន៍អាស៊ី បានជួយគាំទ្រដល់គម្រោងជាច្រើននៅក្នុងប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសវៀតណាមពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វារីអគ្គិសនី និងការសាងសង់ខ្សែបណ្តាញចែកចាយថាមពលអគ្គិសនី។ ការគាំទ្រនេះរួមមានករណីសិក្សាជាច្រើននៅតំបន់ទន្លេបី ដែលធ្វើឡើងក្នុងឆ្នាំ ១៩៩៩ និង ២០០៨ និងការផ្តល់មូលនិធិគាំទ្រការសិក្សាស្វែងរកលទ្ធភាពរបស់គម្រោងទំនប់សេសាន៣ ក្នុងប្រទេសវៀតណាម។ តាមរយៈកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ ធនាគារអភិវឌ្ឍន៍អាស៊ី កំពុងគាំទ្រដល់ការអភិវឌ្ឍន៍ខ្សែបណ្តាញចែកចាយថាមពលអគ្គិសនី ដើម្បីសម្រួលដល់ការចែករំលែកថាមពលអគ្គីសនីក្នុងតំបន់។ ទាំងនេះ រួមមានការគាំទ្រដល់ការរៀបចំខ្សែបណ្តាញដែលមានកម្លាំងខ្ពស់តភ្ជាប់ពីភាគខាងត្បូងប្រទេសឡាវទៅកាន់ភូមិភាគកណ្តាលនៃប្រទេសវៀតណាម។ ខ្សែបណ្តាញចែកចាយអគ្គិសនីមួយនេះ នឹងតភ្ជាប់គម្រោងទំនប់វារីអគ្គិសនីជាច្រើន ដែលគេបានគ្រោងឡើងនៅភាគខាងត្បូងប្រទេសឡាវ ទៅនឹងតំបន់ខ្ពង់រាបកណ្តាលរបស់ប្រទេសវៀតណាម។ ធនាគារអភិវឌ្ឍន៍ អាស៊ីក៏បានផ្តល់មូលនិធិគាំទ្រលើជំនួយបច្ចេកទេស សម្រាប់ការធ្វើពាណិជ្ជកម្មថាមពលនៅក្នុងតំបន់ ក្នុងគោលបំណងធ្វើបច្ចុប្បន្នកម្មផែនការមេរបស់តំបន់ ពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មថាមពលអគ្គិសនី ក្នុងចំណោមប្រទេសមហាអនុតំបន់ទន្លេមេគង្គ។

ទោះបីជាធនាគារអភិវឌ្ឍន៍អាស៊ី លែងមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងគម្រោងទំនប់វារីអគ្គិសនីនៅក្នុងតំបន់ទន្លេបីតទៅទៀតក៏ដោយ ក៏ការសម្រេចចិត្តគាំទ្រទៅដល់ខ្សែបណ្តាញចែកចាយថាមពលទាំងអស់របស់ខ្លួន បានបង្ហាញយ៉ាងច្បាស់ថា ធនាគារមួយនេះ កំពុងចូលខ្លួនជាមួយនឹងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅក្នុងប្រទេសឡាវ ព្រោះថាបើគ្មានទំនប់ទាំងអស់នេះទេ ក៏មិនចាំបាច់ត្រូវការខ្សែបណ្តាញចែកចាយថាមពលទាំងអស់នោះដែរ ហើយបើគ្មានបណ្តាញចែកចាយថាមពលទាំងអស់នោះទេ លទ្ធភាពក្នុងការសាងសង់ទំនប់វារីអគ្គិសនីទាំងនោះ ក៏មិនអាចកើតមានដែរ។ រហូតមកដល់បច្ចុប្បន្ននេះ ធនាគារពិភពលោក ក៏បានគាំទ្រគម្រោងជាច្រើននៅក្នុងកម្មវិធីមហាអនុតំបន់ទន្លេ មេគង្គដែរ រួមមានការគាំទ្រដល់ខ្សែបណ្តាញចែកចាយថាមពលដែលមានកម្លាំង ២៣០គីឡូវ៉ុល ពីភាគខាងត្បូងប្រទេសឡាវមកប្រទេសកម្ពុជា។ ប៉ុន្តែគម្រោងនេះ ត្រូវបានគេលប់ចោលហើយ។

1 Sam Chamroeun, Dept. of Environmental Planning and Legal Affairs, Ministry of Environment, *Cambodia Water Resource Development: A review of the existing policy and legislative framework*, 2007 (p10).

ក្រៅពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅភាគឦសាននៃប្រទេសកម្ពុជាទៅ ក៏នៅមានសម្បទានរ៉ែ និងសម្បទានសេដ្ឋកិច្ចនៅក្នុងតំបន់ទន្លេទាំងបីនេះ។ សព្វថ្ងៃនេះ វាមិនត្រឹមតែខ្វះខាតព័ត៌មាន និងការយល់ដឹងពីការបង្កផលប៉ះពាល់នៅក្នុងតំបន់ទន្លេបីទេ វាថែមទាំងមានភាពមិនច្បាស់លាស់ ថាតើការអភិវឌ្ឍន៍ឧស្សាហកម្មនេះ នឹងមានផលប៉ះពាល់អ្វីខ្លះនឹងកើតឡើងបន្ថែមពីលើនេះទៀត។ ប្រសិនបើការរុករករ៉ែ និងដីសម្បទានសេដ្ឋកិច្ចដែលមានទ្រង់ទ្រាយធំ ត្រូវបានគេធ្វើឡើងនៅក្នុងតំបន់នេះមែន ធនធានទឹកនឹងត្រូវបានគេរឹតបន្តឹងបន្ថែមទៀត ហើយការបំពុលគឺជាបញ្ហាដែលត្រូវបារម្ភបំផុត។ វាប្រាកដណាស់ថា នៅពេលដែលតំបន់នេះមានភ្លើងប្រើ វានឹងធ្វើឲ្យមានការកើនឡើងនូវការវិនិយោគ។ ទោះបីជាចំណុចនេះវានឹងអាចធ្វើឲ្យប្រសើរឡើងនូវសេដ្ឋកិច្ចក្នុងតំបន់ក៏ពិតមែន តែវាក៏នឹងបង្កើននូវទំនាស់ដីធ្លី ខណៈពេលដែលសម្បទានត្រូវបានគេផ្តល់កាន់តែច្រើនឡើងៗ ហើយគម្រោងអភិវឌ្ឍន៍ផ្សេងៗទៀតត្រូវគេដំណើរការពេញលេញ។ ប្រសិនបើរបាយការណ៍នេះ ត្រូវបានគេប្រើប្រាស់ជាអនុសាសន៍គន្លឹះនោះគេចាំចាប់ត្រូវប្រមូលព័ត៌មានបន្ថែមទៀត ជាពិសេសព័ត៌មានដែលពាក់ព័ន្ធនឹងផលប៉ះពាល់ពេញលេញនៃការអភិវឌ្ឍន៍ទំនប់នៅក្នុងតំនប់ទន្លេបី ហើយព័ត៌មាននេះ ត្រូវបោះផ្សាយជាសាធារណៈ។ អ្នកពាក់ព័ន្ធទាំងអស់ រួមមានសហគមន៍រងផលប៉ះពាល់ អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរជាតិ អ្នកសម្រេចចិត្ត អ្នកវិនិយោគ អ្នកផ្តល់ហិរញ្ញប្បទាន និងសង្គមស៊ីវិល ត្រូវតែយល់ដឹងឲ្យបានស៊ីជម្រៅពាក់ព័ន្ធ នឹងផលប្រយោជន៍ និងគ្រោះថ្នាក់នៃគំរូអភិវឌ្ឍន៍នាពេលបច្ចុប្បន្ននេះ និងចាត់វិធានការសមស្របណា មួយឲ្យបានទាន់ពេលវេលា។

## KEY EXISTING AND PROPOSED DAMS IN THE 3S RIVER BASINS



# សេចក្តីផ្តើម

ទន្លេសេសាន ស្រែពក និងទន្លេសេកុង (ទន្លេបី) គឺជាដៃទន្លេដ៏សំខាន់របស់ទន្លេមេគង្គ និងហូរកាត់ប្រទេសវៀតណាម កម្ពុជា និងប្រទេសឡាវ។ នៅក្នុងប្រទេសកម្ពុជា និងប្រទេសឡាវ មានប្រជាជនជាច្រើនរស់នៅយ៉ាងជិតស្និត និងពឹងអាស្រ័យលើធនធានដ៏សម្បូរបែបរបស់ប្រព័ន្ធទន្លេទាំងនេះ។ មានប្រជាជនជិត ៣.៥ លាននាក់ កំពង់រស់នៅក្នុងតំបន់អាងទន្លេបី ដែលភាគច្រើននៃពួកគេជាជនជាតិដើមភាគតិច។[2] តំបន់ទាំងនេះ ត្រូវបានគេទទួលស្គាល់ថាមានសារប្រយោជន៍ផ្នែកជីវសាស្ត្រ ដោយសារតែប្រព័ន្ធអេកូឡូស៊ីដីទឹក និងដីគោករបស់វា ដោយជាង ២០% នៃតំបន់នេះ ត្រូវបានដាក់ជាតំបន់ការពារដែលរួមមានដែនជម្រកសត្វព្រៃលំផាត់ និងឧទ្យានជាតិវារៈជ័យរបស់កម្ពុជា។ អន្លង់ជ្រៅៗ ដែលមាននៅតាមដងទន្លេទាំងបី ត្រូវបានគេរៀបចំធ្វើ ជាតំបន់អភិរក្សត្រី។ តាមរយៈការសិក្សានានា បានបង្ហាញឲ្យដឹងថា នៅក្នុងទន្លេសេសានមានត្រី ១៣៣ ប្រភេទ នៅទន្លេស្រែពកមានត្រីចំនួន ២០៤ ប្រភេទ និងនៅទន្លេសេកុងមានត្រីចំនួន ២១៤ ប្រភេទ។[3]

ប្រជាជនភាគច្រើននៅក្នុងតំបន់ទន្លេបី ប្រកបរបរនេសាទ កសិកម្ម និងប្រមូលអនុផលព្រៃឈើ[4] ដូច្នេះសុខភាពរបស់ទន្លេ គឺជាចំណុចស្នូលនៃជីវិតរបស់ប្រជាជនទាំងនោះ។ ប៉ុន្តែចុងក្រោយនេះមានការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំនៅតាមដងទន្លេទាំងបី ដែលគម្រាមកំហែងឲ្យមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនូវប្រព័ន្ធបរិស្ថានរបស់ទន្លេ។ ការណ៍នេះ មានន័យថាបង្កនូវផលប៉ះពាល់ដ៏ធ្ងន់ធ្ងរទៅដល់សហគមន៍ដែលរស់នៅពឹងផ្អែកលើទន្លេ និងធនធាននៅតាមដងទន្លេទាំងបីនេះ។ ការសាងសង់ និងការដាក់ឲ្យដំណើរការនូវទំនប់វារីអគ្គិសនីខ្នាតធំចំនួន ២០ នៅប៉ែកខាងលើនៃទន្លេបីក្នុងប្រទេសវៀតណាម បានបង្កឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សហគមន៍មូលដ្ឋានតាមរយៈការធ្វើឲ្យថយចុះនូវបរិមាណត្រី ការឡើងចុះនូវកម្ពស់ទឹកមិនទៀងទាត់ និងការធ្វើឲ្យគុណភាពទឹកថយចុះ ការណ៍នេះបានធ្វើឲ្យប្រជាជនជួបការលំបាកក្នុងការស្វែងរកស្បៀងអាហារ និងប្រាក់ចំណូលគ្រួសារ[5]។ បច្ចុប្បន្ននេះ មានការប្រឈមថ្មីៗទៀតកើតឡើងតាមរយៈគម្រោងសាងសង់ទំនប់វារីអគ្គិសនីបន្ថែមចំនួន ២៦ ទៀត ក្នុងអាងទន្លេទាំងបី ដែលគម្រាមកំហែងដល់ដងទន្លេទាំងមូល ដែលនៅមានលក្ខណៈធម្មជាតិនៅឡើយ។ ប្រសិនបើទំនប់វារីអគ្គិសនីទាំងនេះ ត្រូវបានគេសាងសង់មែននោះ វានឹងបំផ្លាញ ដល់ធនធានធម្មជាតិនៅអាងទន្លេបីនេះ តាមរយៈការផ្លាស់ប្តូរលំហូរទឹកទន្លេ គុណភាព ទឹក

---

2 3S Rivers Protection Network (3SPN), *Civil Society's Reflection of Past and Present Hydropower Development in the 3S Rivers Basin Paves Concern Over Future Development Plans*, 31 May 2010.

3 ADB-RETA 40082, *3S Technical Sheets Key Topic 5 – Biodiversity and natural resources*. http://reta.3sbasin.org/index.php?option=com_docman&Itemid=184&lang=en (accessed November 2011).

4 ADB-RETA 40082, *3S Technical Sheets Key Topic 7 – People and livelihoods, 8a Hydropower Development*. http://reta.3sbasin.org/index.php?option=com_docman&Itemid=184&lang=en (accessed November 2011).

5 Rutkow, E. et al. *Down River: The Consequences of Vietnam's Se San River Dams on Life in Cambodia and Their Meaning in International Law*. NGO Forum Cambodia, December 2005.

ការប្រើប្រាស់ដីធ្លី និងបម្រែបម្រួលគម្របព្រៃឈើ កាត់ផ្តាច់ចរាចររបស់ត្រី និងបំផ្លាញចំណី និងជម្រកពងកូនរបស់ត្រី។ កត្តានេះ នឹងកាត់ផ្តាច់សហគមន៍ពីការប្រកបរបរចិញ្ចឹមជីវិត និងការគ្រប់គ្រង ធនធានធម្មជាតិតាមបែបប្រពៃណី ដែលបណ្តាលឲ្យមានឥទ្ធិពល មិនល្អនាពេលអនាគតដល់សេដ្ឋកិច្ច សង្គម និរន្តរភាពបរិស្ថាន និងជីវចម្រុះនាពេលអនាគត។

រហូតមកដល់បច្ចុប្បន្ននេះ ទំនប់វារីអគ្គិសនីភាគច្រើននៅក្នុងតំបន់ទន្លេបី ត្រូវបានអភិវឌ្ឍនៅក្នុងប្រទេសវៀតណាម នាប៉ែកខាងលើនៃទន្លេសេសាន និងទន្លេស្រែពក ដែលភាគច្រើនត្រូវបានធ្វើឡើងដោយក្រុមហ៊ុនរដ្ឋរបស់ប្រទេសវៀតណាម (អគ្គិសនីវៀតណាម)។ ស្របពេលជាមួយគ្នានេះដែរ មានគម្រោងសាងសង់ទំនប់វារីអគ្គិសនីជាច្រើន ត្រូវបានគេស្នើឡើងនៅក្នុងប្រទេសកម្ពុជា ហើយល្បឿននៃការអនុម័ត និងសាងសង់ទំនប់វារីអគ្គិសនីនៅភាគខាងត្បូងប្រទេសឡាវ ក៏ត្រូវបានគេពន្លឿនផងដែរ។ ក្រៅពីអគ្គិសនីវៀតណាមទៅ ក៏នៅមានក្រុមហ៊ុនខាងក្រៅមួយចំនួនទៀត ដូចជាក្រុមហ៊ុនរដ្ឋរបស់ប្រទេសចិន ក្រុមហ៊ុនឯកជនរបស់កូរ៉េ និងក្រុមហ៊ុនរបស់រុស្សី។ ស្ថាប័នផ្តល់ហិរញ្ញប្បទានអន្តរជាតិមួយចំនួនទៀតក៏បានដើរតួនាទីដ៏សំខាន់ក្នុងការគាំទ្រដល់ការចែកចាយថាមពលក្នុងតំបន់ ក្នុងនោះរួមមានធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ដែលបានផ្តល់ហិរញ្ញប្បទានដល់ការសង់ខ្សែបណ្តាញបញ្ជូនចរន្តដែលមានកម្លាំងខ្ពស់។ ផែនការនេះកំពុងត្រូវបានដំណើរការនៅក្នុងតំបន់ទន្លេបី ដើម្បីភ្ជាប់ពីរោងចក្រផលិតថាមពលវារីអគ្គិសនីដែលបានគ្រោងឡើង ទៅកាន់បណ្តាញបញ្ជូនចរន្តទាំងនោះ។



រូបភាព Oxfam-Brett Eloff: ការចុះងូតទឹករបស់ប្រជាជនក្នុងទន្លេសេសាន

មានការសិក្សាជាច្រើន ត្រូវបានគេធ្វើទៅលើផលប៉ះពាល់របស់ទំនប់វារីអគ្គិសនីមួយចំនួនក្នុងតំបន់ ដែលការសិក្សានោះ បានរកឃើញពីក្តីបារម្ភមួយចំនួនពាក់ព័ន្ធនឹងផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសហគមន៍មូលដ្ឋាន។ ក្នុងរយៈពេលជាង ១ ទសវត្សរ៍កន្លងមក របាយការណ៍នៃការសិក្សាទាំងនេះ បានចងក្រងពីផលប៉ះពាល់ (បង្កឡើងដោយសារទំនប់បន្តកន្ទុយគ្នាចំនួន ៧ នៅប៉ែកខាងលើក្នុងប្រទេសវៀតណាម) ដែលប្រឈមដោយសហគមន៍នៅប៉ែកខាងក្រោមទំនប់ ក្នុងប្រទេសកម្ពុជា។ ដោយសារមានសហគមន៍មូលដ្ឋានជាច្រើននាក់រស់នៅពឹងផ្អែកទាំងស្រុងលើការនេសាទ និងធនធានធម្មជាតិរបស់ទន្លេ ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅតាមដងទន្លេនេះ បានបង្កើនឲ្យមានភាពក្រីក្រ និងការលំបាកជាច្រើនដល់សហគមន៍ ដោយសារតែការធ្វើឲ្យថយចុះនូវបរិមាណត្រី ការឡើងចុះកម្ពស់ទឹកមិនទៀងទាត់ និងការថយចុះនូវគុណភាពទឹក។ ទោះបីជាមានការចងក្រងនូវ ផលប៉ះពាល់បានល្អប្រសើរក៏ដោយ ក៏សហគមន៍នៅក្នុងប្រទេសកម្ពុជា មិនដែលទទួលបានដំណោះស្រាយសមស្រប ណាមួយចំពោះភាពលំបាកវេទនា ដែលគាត់កំពុងប្រឈម ដោយទំនប់វារីអគ្គិសនីនៅប៉ែកខាងលើក្នុងប្រទេសវៀតណាមនៅឡើយទេ។

ទោះបីជាផលប៉ះពាល់ ត្រូវបានគេកំណត់យ៉ាងច្បាស់លាស់នៅពេលធ្វើផែនការ ពេលអនុម័ត និងពេលអនុវត្តគម្រោងវារីអគ្គិសនីដែលមានស្រាប់នៅក្នុងតំនប់ទន្លេបីក៏ដោយ ក៏នៅមានការព្រួយបារម្ភមួយចំនួនដែលថា កំហុសដដែលៗនេះនឹងនៅតែបន្តកើតឡើងទៀតនៅពេលខាងមុខ។ ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះស្រាប់ ការជម្រុញឲ្យមានការអនុម័ត និងការអភិវឌ្ឍន៍គម្រោង គឺមានអាទិភាពខ្ពស់ជាងផលប៉ះពាល់របស់គម្រោងនីមួយៗ ហើយស្ទើរតែមិនមានការយកចិត្តទុកដាក់លើការបង្កផលប៉ះពាល់ដែលកើតឡើងដោយសារគម្រោងទាំង ៤៦ នៅក្នុងតំបន់ទន្លេបី។ ការខ្វះខាតនូវការវិភាគឲ្យបានពេញលេញនេះ រិតតែធ្ងន់ធ្ងរឡើងដោយសារការពិតដែលថា ផែនការ និងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី នៅតែបន្តចោទជាបញ្ហារសើបក្នុងអាងទន្លេ ការពិគ្រោះយោបល់ជាមួយសហគមន៍រងផលប៉ះពាល់នៅខ្សោយ ហើយគេក៏មិនអាចទទួលបាននូវព័ត៌មានលម្អិត និងអាចទុកចិត្តបាន ពាក់ព័ន្ធនឹងផែនការទាំងអស់នេះ។

ឥទ្ធិពលនៃការបាត់បង់តម្លាភាពនេះ កើតឡើងដោយសារតែអ្នកទទួលរងផលប៉ះពាល់ទាំងអស់មានការយល់ដឹងតិចតួចបំផុតពាក់ព័ន្ធនឹងការប្រែប្រួលបែបបទរស់នៅរបស់ពួកគេ និងរាល់ការសម្រេចចិត្តទាំងអស់ ត្រូវធ្វើឡើងដោយមិនមានការចូលរួមរបស់ពួកគេ។ មិនត្រឹមតែសហគមន៍ទេដែលមិនបានដឹងពីផែនការអភិវឌ្ឍន៍នៅក្នុងតំបន់នេះ សូម្បីតែសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានាដែលកំពុងជួយអភិវឌ្ឍន៍សហគមន៍ លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងការពារបរិស្ថាន ក៏មិនបានដឹងឲ្យបានស៊ីជម្រៅពីទំហំនៃ ផលប៉ះពាល់របស់ផែនការអភិវឌ្ឍន៍ទាំងអស់នេះដែរ។ បុគ្គលិកមួយចំនួន មកពី ស្ថាប័នបច្ចេកទេសរបស់រដ្ឋាភិបាល មានដូចជារដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល ក៏កំពុងតែបង្ហាញ ពី

ភាពមិនពេញចិត្ត ដោយសារតែពួកគាត់ មិនត្រូវបានគេពិគ្រោះយោបល់ក្នុងអំឡុងពេលសិក្សា និងពេលអនុម័តផែនការអភិវឌ្ឍន៍ទាំងអស់នេះ។

ដើម្បីយល់ដឹងឲ្យបានកាន់តែប្រសើរ អំពីឧបសគ្គដែលនឹងប្រឈមចំពោះធនធានធម្មជាតិ និងសហគមន៍នៅក្នុងតំបន់ទាំងនេះ ចាំបាច់ត្រូវតែកំណត់ និងវិភាគឲ្យបានច្បាស់លាស់ពីការផ្លាស់ប្តូរដែលកំពុងកើតឡើងនាពេលបច្ចុប្បន្ននេះ ដោយផ្តោតទៅលើអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍន៍នេះ លើកត្តាដែលនាំឲ្យមានការអភិវឌ្ឍន៍ថ្មីៗកើតឡើង និងលើនិន្នាការនៃការធ្វើផែនការទំនប់វារីអគ្គិសនី និងដំណើរការអនុម័តលើផែនការទាំងនោះ។ នៅពេលដែលគេបានយល់ដឹងច្បាស់លាស់ពីបញ្ហាដែលប្រឈមនៅក្នុងតំបន់ ពេលនោះសង្គមស៊ីវិលក៏នឹងអាចដឹងបានកាន់តែច្បាស់ពីចំណុចដែលខ្លួនត្រូវចូលរួមជាមួយអ្នក



ពាក់ព័ន្ធ និងអាចឆ្លើយតបប្រកបដោយប្រសិទ្ធិភាពចំពោះបញ្ហាដែលប្រឈម។ សម្រាប់ប្រទេសកម្ពុជា របាយការណ៍នេះ មានគោលបំណងស្វែងរកឲ្យឃើញនូវអ្នកពាក់ព័ន្ធនៅក្នុងគម្រោងអភិវឌ្ឍន៍ទាំងអស់នេះ និងស្វែងរកឲ្យឃើញពីកត្តាដែលនាំឲ្យមានការកើនឡើងនៃគម្រោងសាងសង់ទំនប់វារីអគ្គិសនី នៅក្នុងតំបន់ទន្លេបីនេះ។ របាយការណ៍ក៏ផ្តល់ជូននូវបច្ចុប្បន្នកម្មនៃគម្រោងដ៏ធំ និងដ៏មានសក្តានុពល ព្រមទាំងផលប៉ះពាល់ចម្បងៗ ដែលគេរំពឹងថា នឹងកើតឡើងពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅក្នុងអាងទន្លេបី។ គេក៏សង្ឃឹមទុកដែរថា របាយការណ៍នេះ នឹងអាចបំពេញបន្ថែមនូវព័ត៌មានសំខាន់ៗ ដែលខ្វះចន្លោះ និងជម្រុញឲ្យមានការពិភាក្សាក្នុងចំណោមអ្នកពាក់ព័ន្ធ រួមមាន ៖ សហគមន៍រងផលប៉ះពាល់ ប្រជាពលរដ្ឋភាគច្រើនរបស់ប្រទេសកម្ពុជា រដ្ឋាភិបាល និងអ្នកសម្រេចចិត្ត អ្នកអភិវឌ្ឍន៍គម្រោង និងសង្គមស៊ីវិល។

## ផ្នែកទី ១៖
## ថាមពលពីវារីអគ្គិសនីជាជំរើសដើម្បីផ្គត់ផ្គង់ថាមពលក្នុងតំបន់

ប្រទេសទាំងបីដែលមានទន្លេបីហូរកាត់ បច្ចុប្បន្ននេះកំពុងជួបប្រទះនូវការខ្វះខាតអគ្គិសនី។ ទាំងប្រទេសកម្ពុជា និងប្រទេសឡាវ នៅមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការផលិត និងចែកចាយចរន្តអគ្គិសនីនៅឡើយទេ ជាក់ស្តែងប្រទេសកម្ពុជា កំពុងតែត្រូវការនូវចរន្តអគ្គិសនីយ៉ាងខ្លាំង ដែលតម្រូវឲ្យប្រទេសនេះនាំចូលនូវចរន្តអគ្គិសនីជាច្រើនមកពីប្រទេសជិតខាង។ ចរន្តអគ្គិសនីមួយចំនួន សម្រាប់ផ្គត់ផ្គង់តម្រូវការនេះ ត្រូវបានផលិតនៅក្នុងស្រុក ដោយប្រើប្រាស់រោងចក្រអគ្គិសនីដើរដោយប្រេងឥន្ធនៈ។ ចំណែកប្រទេសឡាវវិញ បាន និងកំពុងអភិវឌ្ឍន៍សមត្ថភាពផលិតចរន្តអគ្គិសនីរបស់ខ្លួន ហើយថ្មីៗនេះ ក៏បានពន្លឿនការអភិវឌ្ឍន៍នេះនៅប៉ែកខាងត្បូងនៃប្រទេស។ ជាមួយគ្នានេះផងដែរ ប្រទេសកម្ពុជា ក៏កំពុងតែជម្រុញទៅមុខនូវការអភិវឌ្ឍន៍ដ៏ឆាប់រហ័សមួយនៅក្នុងវិស័យវារីអគ្គិសនី ក្នុងគោលបំណងដើម្បីបំពេញនូវតម្រូវការអគ្គិសនី ដែលកំពុងតែកើនឡើងឥតឈប់ឈរក្នុងប្រទេស។ សមត្ថភាពផលិតថាមពលអគ្គិសនីរបស់ប្រទេសវៀតណាម មានការរីកចម្រើនជាងប្រទេសជិតខាងរបស់ខ្លួន ហើយប្រទេសនេះបានសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំជាច្រើន ក្នុងនោះរួមមាន ទំនប់វារីអគ្គិសនីយ៉ាលី ដែលមាន កំលាំងថាមពល ៧២០ម៉េហ្គាវ៉ាត់ ស្ថិតនៅផ្នែកខាងលើនៃទន្លេសេសានក្នុងប្រទេសវៀតណាម។ ប៉ុន្តែការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សនៅក្នុងប្រទេសវៀតណាម ធ្វើឲ្យតម្រូវការអគ្គិសនីរបស់ប្រទេសនេះ កើនឡើងយ៉ាងខ្លាំង រហូតដល់ថាមពលដែលផលិតបានដោយខ្លួនឯងនៅក្នុងស្រុក មិនអាចផ្គត់ផ្គង់បានគ្រប់គ្រាន់។ ឈរលើហេតុផលនេះ ប្រទេសវៀតណាម កំពុងតែមានផែនការផ្តល់មូលនិធិសាងសង់ទំនប់វារីអគ្គិសនីមួយចំនួននៅក្នុងប្រទេសកម្ពុជា និងប្រទេសឡាវ ក្នុងគោលបំណងដើម្បីទាញយកអគ្គិសនីមួយចំនួនមកផ្គត់ផ្គង់តម្រូវការនៅក្នុងស្រុក ហើយអគ្គិសនីដែលនៅសល់នឹងត្រូវនាំចេញទៅកាន់ខ្សែបណ្តាញជាតិវៀតណាម។ ប្រទេសថៃ ក៏បានបង្ហាញឲ្យដឹងថា ប្រទេសខ្លួនក៏មិនមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការផ្គត់ផ្គង់តម្រូវការអគ្គិសនីក្នុងស្រុកបាននៅឡើយដែរ ព្រមទាំងបានចុះកិច្ចព្រមព្រៀងទិញអគ្គិសនី ពីប្រទេសឡាវ[6]។

មានក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនបរទេសជាច្រើន បង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនលើគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅក្នុងប្រទេសកម្ពុជា និងប្រទេសឡាវ ព្រោះប្រទេសទាំងពីរនេះ នៅមិនទាន់មានសមត្ថភាពហិរញ្ញវត្ថុ និងសមត្ថភាពបច្ចេកទេស ក្នុងការសាងសង់ទំនប់ទាំងអស់នេះបានដោយខ្លួន

6 It should be noted that in a 2006 report, it was claimed that the Thai Load Forecast Subcommittee has a "historical and persistent tendency to overestimate future demand". Greacen, C. & Footner, J. *Decentralizing Thai Power: Towards a Sustainable Energy System.* Greenpeace Thailand & Palang Thai, November 2006.

ឯងនៅឡើយទេ។ ភាគច្រើន ក្រុមហ៊ុនទាំងនេះ កំពុងធ្វើការចរចាដើម្បីចុះកិច្ចសន្យាជាលក្ខណៈ BOT ដែលមានរយៈពេល ២៥ឆ្នាំ ឬលើស ២៥ឆ្នាំ។ ដោយសារតែតម្រូវការអគ្គិសនីមានការកើនឡើងយ៉ាងឆាប់រហ័ស ការបង្កើតគម្រោងក្នុងលក្ខណៈ BOT មានសក្តានុពលក្នុងការផ្តល់នូវអត្ថប្រយោជន៍ខ្ពស់។

## ១.១ ប្រទេសកម្ពុជា

សព្វថ្ងៃនេះ វិស័យថាមពលរបស់ប្រទេសកម្ពុជាមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់តម្រូវការអគ្គិសនីនៅក្នុងស្រុកបាននៅឡើយទេ។ មានចរន្តអគ្គិសនីត្រឹមតែ ២៦% ប៉ុណ្ណោះ ដែលទទួលបានពីខ្សែបណ្តាញចែកចាយ ហើយដែលមានតម្លៃថ្លៃ។ នៅតំបន់ប្រជុំជន់ តម្លៃអគ្គិសនីមានតម្លៃស្មើនឹងពីរដងនៃតម្លៃអគ្គិសនីរបស់ប្រទេសជិតខាង ហើយនៅតាមជនបទវិញ អគ្គិសនីក៏មានតម្លៃកាន់តែខ្ពស់ថែមទៀត[7]។ ការប្រើប្រាស់ចរន្តអគ្គិសនីនេះ គឺស្ថិតក្នុងកម្រិតមួយទាបបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ នៅតាមជនបទ គ្រួសារដែលទទួលបានអគ្គិសនីពីខ្សែបណ្តាញចែកចាយ មានចំនួនតិចជាង ១៣%[8] ចំណែកឯនៅទីក្រុងភ្នំពេញវិញ ការប្រើប្រាស់អគ្គិសនីមានរហូតដល់ ៩០% នៃអគ្គិសនីសរុបរបស់ប្រទេស ទោះបីជានៅទីក្រុងមួយនេះ មានចំនួនប្រជាជនប្រហែល ១០% នៃចំនួនប្រជាជនសរុបក៏ដោយ[9]។ ស្ទើរតែគ្រប់តំបន់ទាំងអស់ក្នុងប្រទេសកម្ពុជា ការដាច់ចរន្តអគ្គិសនីកើតឡើងញឹកញាប់បំផុត ហើយការផ្គត់ផ្គង់អគ្គិសនីដ៏មានតម្លៃថ្លៃ និងមិនអាចទុកចិត្តបាននេះ មិនត្រឹមតែប៉ះពាល់ដល់គុណភាពជីវិតរបស់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ វាថែមទាំងបានបង្អាក់ដល់ដំណើការវិនិយោគផងដែរ។

ក្រៅពីកង្វះខាតក្នុងការផ្គត់ផ្គង់ ការផលិតថាមពលអគ្គិសនីបច្ចុប្បន្នរបស់ប្រទេសកម្ពុជា មិនស្អាត ហើយបច្ចុប្បន្ននេះ រោងចក្រអគ្គិសនីភាគច្រើនរបស់ប្រទេសកម្ពុជា ដើរដោយប្រេងឥន្ធនៈ។ យោងតាមសម្តីរបស់មន្ត្រីម្នាក់មកពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានឲ្យដឹងថា អគ្គិសនីជាង ៩០% ដែលបានដាក់ឲ្យប្រើប្រាស់ក្នុងឆ្នាំ ២០០៩ ផលិតដោយរោងចក្រអគ្គិសនីដើរដោយប្រេងឥន្ធនៈ ដែលនាំចូលពីក្រៅប្រទេស[10]។ កង្វះខាតក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនី និងការចំនាយខ្ពស់ទៅលើប្រេងឥន្ធនៈ បានធ្វើឲ្យប្រទេសកម្ពុជានាំចូលអគ្គិសនីជាច្រើនមកពីប្រទេសថៃ និងពីប្រទេសវៀតណាម។ នៅក្នុងឆ្នាំ ២០០៩ ប្រទេសកម្ពុជាបានចំណាយអស់ ៥៩លានដុល្លាអាមេរិក លើការនាំចូលអគ្គិសនីមកពីប្រទេស

7 World Bank website, *Cambodia: Villagers Enjoy Cheaper, Reliable Electricity*, 25 February 2011. http://web.worldbank.org/WBSITE/EXTERNAL/COUNTRIES/EASTASIAPACIFICEXT/CAMBODIAEXTN/0,,contentMDK:22842900~menuPK:293861~pagePK:2865066~piPK:2865079~theSitePK:293856,00.html (accessed November 2011).

8 Presentation by Victor Jona, General Department of Energy of the Ministry of Industry, Mines and Energy, *Cambodia Energy Status and its Development*, 16 March 2011. http://www.cdri.org.kh/oc2011/11energy.pdf (accessed November 2011).

9 Presentation by Chea Piseth, Hydroelectricity Department of the Ministry of Industry, Mines and Energy, *National Power and Hydropower Development Plans in Cambodia*, 16-17 July 2009. http://www.icem.com.au/documents/envassessment/mrc_sea_hp/1.%20inception/presentations/cambodia%20scoping%20workshop/pdf/National%20Power%20and%20Hydropower%20Development%20Plan%20in%20Cambodia.pdf

10 *Ibid.*

ទាំងពីរនេះ[11] ហើយនៅក្នុងឆ្នាំ ២០១០ ការនាំចូលអគ្គិសនី កើនលើសពី ៤០% នៃការផ្គត់ផ្គង់សរុបរបស់ប្រទេស[12]។

តម្រូវការអគ្គិសនី បានកើនឡើងជាបន្តបន្ទាប់នៅក្នុងរយៈពេលពីរបីឆ្នាំកន្លងទៅនេះ ហើយការកើនឡើងនេះ ត្រូវបានគេព្យាករណ៍ថានឹងនៅតែបន្តរហូត ប៉ុន្តែតួលេខពិតប្រាកដនៃតម្រូវការនេះពិបាកនឹងកំណត់ណាស់។ យោងតាមរបាយការណ៍មួយទទួលបានពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានបង្ហាញថា តម្រូវការអគ្គិសនីក្នុងស្រុកសម្រាប់ឆ្នាំ ២០១០ មានចំនួនលើសពី ៤៣០ មេហ្គាវ៉ាត់។ តម្រូវការនេះ ត្រូវបានគេព្យាករណ៍ថានឹងកើនដល់ ១,៣៤៩ មេហ្គាវ៉ាត់ ក្នុងឆ្នាំ ២០១៥ និង ២,៤០១ មេហ្គាវ៉ាត់ ក្នុងឆ្នាំ ២០២០[13]។ យោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី បានព្យាករណ៍ថា តម្រូវការអគ្គិសនីក្នុងឆ្នាំ ២០១០ មានចំនួន ៤៦៧ មេហ្គាវ៉ាត់ ក្នុងឆ្នាំ ២០១៥ មានចំនួន ១,០០៨ មេហ្គាវ៉ាត់ និងក្នុងឆ្នាំ ២០២០ មានចំនួន ១,៦១០ មេហ្គាវ៉ាត់[14]។ វាពិបាកក្នុងការស្វែងយល់ ថាតើ តួលេខទាំងនេះ មានភាពសុក្រិតប៉ុណ្ណា ប៉ុន្តែវាជាក់ស្តែងណាស់ដែលថា ប្រទេសកម្ពុជាត្រូវតែធ្វើឲ្យ ប្រសើរឡើងនូវសមត្ថភាពរបស់ខ្លួនក្នុងការផលិតថាមពលអគ្គិសនី។ ដើម្បីបំពេញនូវតម្រូវការអគ្គិសនី ក្នុងស្រុក កម្ពុជាកំពុងតែព្យាយាមទាក់ទាញក្រុមហ៊ុនឯកជនឲ្យមកបង្កើតរោងចក្រអគ្គិសនី និងរចនា សម្ព័ន្ធចែកចាយថាមពល។ មានរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មមួយចំនួន ត្រូវបានគេអនុម័តឲ្យ សាងសង់នាពេលថ្មីៗនេះ។ ស្របពេលជាមួយគ្នានេះផងដែរ រដ្ឋាភិបាលកំពុងជម្រុញយ៉ាងខ្លាំងក្លាឲ្យ មានការអភិវឌ្ឍន៍លើវារីអគ្គិសនីទាំងអស់ដែលមានសក្តានុពល។ ថ្មីៗនេះ ទំនប់វារីអគ្គិសនីខ្នាតធំមួយ (ទំនប់វារីអគ្គិសនីកំចាយ មានអានុភាព ១៩៣មេហ្គាវ៉ាត់) ត្រូវបានសាងសង់ និងដាក់ឲ្យដំណើរការនៅ ក្នុងខេត្តកំពត។ ជាមួយគ្នានេះក៏នៅមានទំនប់វារីអគ្គិសនីចំនួន ៤ ផ្សេងទៀត កំពុងតែដំណើរការសាង សង់ រួមមាន ៖ ទំនប់វារីអគ្គិសនីស្ទឹងតាតៃ (មានអានុភាព ២៤៦មេហ្គាវ៉ាត់) ក្នុងខេត្តពោធិ៍សាត់ ទំនប់ វារីអគ្គិសនីគិរីរម្យ៣ (មានអានុភាព ១៨មេហ្គាវ៉ាត់) ទំនប់វារីអគ្គិសនីឫស្សីជ្រុំក្រោម (មានអានុភាព ៣៣៨មេហ្គាវ៉ាត់) និងទំនប់វារីអគ្គិសនីស្ទឹងអាតៃ (មានអានុភាព ១២០មេហ្គាវ៉ាត់) ដែលទំនប់ទាំងបីនេះ ស្ថិតនៅក្នុងខេត្តកោះកុង។ ក្រុមហ៊ុនចិនជាអ្នកទទួលខុសត្រូវសាងសង់ទំនប់ទាំង ៥ ខាងលើនេះ ដែល មានតម្លៃសរុប ១.៦៣ពាន់លានដុល្លាអាមេរិក និងមានអានុភាពសរុប ៩០០មេហ្គាវ៉ាត់[15]។

11 Xinhua News Agency, *Cambodia spends 59 mln USD to import electricity in 2009*, 14 March 2010.

12 Presentation by Victor Jona, 16 March 2011.

13 MIME demand forecast, as reported by Economic Consulting Associates, *The Potential of Regional Power Sharing Integration: Greater Mekong Subregion Transmission and Trading Case Study*, January 2010, (p87).

14 Asian Development Bank, *RETA 6440: Facilitating Regional Power Trading and Environmentally Sustainable Development of Electricity Infrastructure in the Greater Mekong Subregion*, Final report - Component 1, Module 1: Update of the GMS Regional Master Plan, executive summary, 15 October 2010 (p25).

15 http://www.investincambodia.com/power.htm (accessed November 2011).




ប្រភពៈ MIME ២០០៨ ផែនទី ទំនប់វារីអគ្គិសនីដែលមានស្រាប់និងគ្រោងសាងសង់នៅប្រទេសកម្ពុជា?

យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ដើរតាមយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល។ បើនិយាយពីអគ្គិសនី យុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជា ចង់បាននូវការផ្គត់ផ្គង់អគ្គិសនីដែលមានតម្លៃថោកក្នុងគោលបំណងរក្សាកំណើនសេដ្ឋកិច្ចជាតិ។

គោលបំណងនេះ អាចសម្រេចទៅបានតាមរយៈការជម្រុញ ឲ្យមានការចូលរួមពីវិស័យឯកជនក្នុងការផលិត និងចែកចាយអគ្គិសនី និងតាមរយៈការគាំទ្រឲ្យមានខ្សែបណ្តាញចែកចាយ ដើម្បីជួយសម្រួលដល់ការនាំចូលចរន្តអគ្គិសនីពីប្រទេសជិតខាង។

យុទ្ធសាស្ត្រនេះ ត្រូវបានគេធ្វើបច្ចុប្បន្នកម្មក្នុងឆ្នាំ ២០០៩ តាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ ដែលបានលើកឡើងសារជាថ្មីថា ការអភិវឌ្ឍន៍វិស័យអគ្គិសនី គឺជាគន្លឹះអាទិភាពមួយ និងដាក់ទិសដៅបង្កើនសមត្ថភាពផ្គត់ផ្គង់អគ្គិសនីដែលមានតម្លៃថោក។ នៅក្នុងអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ រដ្ឋាភិបាលមានបំណង[16] ៖

- បង្កើនសមត្ថភាពផ្គត់ផ្គង់អគ្គិសនី និងកាត់បន្ថយពន្ធនាំចូល ពង្រឹងយន្តការស្ថាប័ន និងសមត្ថភាពក្នុងការគ្រប់គ្រង
- ធានាឲ្យបាននូវការផ្គត់ផ្គង់អគ្គិសនីដែលអាចទុកចិត្តបានដើម្បីជួយសម្រួល និងទាក់ទាញការវិនិយោគ និងដើម្បីជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ

16 Royal Government of Cambodia, National Strategic Development Plan Update 2009-2013, (p149).

- បង្កើតគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តិសម្រាប់វិស័យអគ្គិសនី ដើម្បីធានាឲ្យបាននូវការគ្រប់គ្រង និងការប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពនូវធនធានដែលមាន ដើម្បីអភិ-វឌ្ឍសេដ្ឋកិច្ច និងធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅ និង
- លើកទឹកចិត្តដល់ការប្រើប្រាស់អគ្គិសនីប្រកបដោយប្រសិទ្ធិភាព និងផលប៉ះពាល់តិចបំផុតដល់បរិស្ថាន។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏មានកំណត់ពីតួនាទីរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការបំពេញឲ្យបាននូវតម្រូវការអគ្គិសនី។ កិច្ចការទាំងនេះរួមមាន ៖ ជម្រុញការរុករកប្រភពថាមពល ដូចជាវារីអគ្គិសនី ធានាស្ថិរភាព និងភាពជឿជាក់ក្នុងការផ្គត់ផ្គង់អគ្គិសនី លើកទឹកចិត្តឲ្យមានការប្រើប្រាស់អគ្គិសនីប្រកបដោយប្រសិទ្ធិភាព និងកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន លើកទឹកចិត្ត វិស័យឯកជនឲ្យមកវិនិយោគលើវិស័យអគ្គិសនី និងជម្រុញការធ្វើអាជីវកម្មអគ្គិសនីក្នុងតំបន់ តាមរយៈកិច្ចសហប្រតិបត្តិការពហុ និងទ្វេភាគី[17]។ គោលដៅរបស់រដ្ឋាភិបាលកម្ពុជា គឺដល់ឆ្នាំ ២០២០ ភូមិ ទាំងអស់នៅក្នុងប្រទេស នឹងមានអគ្គិសនីប្រើប្រាស់ និងដល់ឆ្នាំ ២០៣០ យ៉ាងហោចណាស់ ៧០% នៃគ្រួសារទាំងអស់ នឹងមានចរន្តអគ្គិសនីប្រើប្រាស់ ដែលមានគុណភាពដូចចរន្តអគ្គិសនីពីខ្សែបណ្ដាញជាតិ[18]។ ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ គេត្រូវពឹងផ្អែកយ៉ាងខ្លាំងលើទំនប់វារីអគ្គិសនី ហើយចំណុចនេះ ត្រូវបានគេឆ្លុះបញ្ចាំងនៅក្នុងសេចក្ដីថ្លែងការណ៍ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

នៅក្នុងសេចក្ដីថ្លែងការណ៍ប៉ុន្មានឆ្នាំថ្មីៗនេះ សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានសង្កត់ធ្ងន់ទៅលើការគាំទ្រឲ្យមានការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីរបស់កម្ពុជា។ ឧទាហរណ៍ នៅក្នុងសន្ទរកថារបស់សម្ដេច ដែលបានធ្វើឡើងនៅក្នុងខេត្តក្រចេះ ក្នុងឆ្នាំ ២០០៨ បានបង្ហាញថា ៖

> *ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ព្រមទាំងផ្នែកមួយចំនួននៃខេត្តក្រចេះ និង ខេត្តព្រះវិហារអាចក្លាយជាតំបន់សេដ្ឋកិច្ចទី ៤ បន្ទាប់ពីទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និង សៀមរាប។ សក្ដានុពលដែលយើងមាននៅភូមិភាគឦសាននេះ មើលទៅអស្ចារ្យណាស់។ យើងអាចលើកយកសក្ដានុពលមួយមកនិយាយនៅពេលនេះ គឺទំនប់វារីអគ្គិសនី ដែលអាចផ្ដល់ អគ្គិសនីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងអាចលក់ទៅឲ្យប្រទេសជិតខាងក៏បាន[19]។*

17 *Ibid*. (p149-150).

18 Cambodian Government's Rural Electrification Fund website, http://www.ref.gov.kh/eng/index.php?fn=home.htm (accessed November 2011).

19 Cambodia New Vision: Issue 123, April 2008, available at http://www.cnv.org.kh/cnv_archives/cnv_archives.htm (accessed November 2011).

សម្តេចនាយករដ្ឋមន្ត្រីក៏បានបន្ថែមផងដែរថា ការអភិវឌ្ឍន៍វារីអគ្គិសនី នឹងធ្វើឲ្យចរន្តអគ្គិសនីមានតម្លៃថោក និងកាត់បន្ថយការចំណាយក្នុងការធ្វើពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា[20]។ ទិន្នន័យ និងសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីកម្ពុជា បានបង្ហាញឲ្យឃើញថា ផែនការរបស់ប្រទេសនេះគឺមានមហិច្ឆតាធំធេងណាស់។ យោងទៅតាមបទបង្ហាញមួយក្នុងឆ្នាំ ២០០៩ ដែលលើកឡើងដោយក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បានបង្ហាញថា ប្រទេសកម្ពុជាមានបំណងកាត់បន្ថយការពឹងពាក់លើការនាំចូលថាមពលអគ្គិសនីពីក្រៅប្រទេស និងការផលិតថាមពលដោយប្រើប្រាស់ប្រេងឥន្ធនៈ ហើយដល់ឆ្នាំ ២០២០ ប្រទេសកម្ពុជា នឹងអាចផ្គត់ផ្គង់ថាមពលអគ្គិសនីចំនួន ៦,០០០មេហ្គាវ៉ាត់ ដែល ៦៨% នៃអគ្គិសនីនេះ បានមកពីទំនប់វារីអគ្គិសនី[21]។ តាមរយៈការសិក្សាមួយដែលធ្វើឡើងក្នុងឆ្នាំ ២០០៧ ដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុនបានកំណត់ថា ក្រៅពីទំនប់ចំនួន ៤កន្លែង ដែលគម្រោងរបស់វាត្រូវបានគេចាប់ផ្តើមរួចទៅហើយនោះ ក៏នៅមានសក្តានុពលចំនួន ២៩ កន្លែងទៀតសម្រាប់សង់ទំនប់វារីអគ្គិសនី។ ភាគច្រើននៃទីតាំងដែលមានសក្តានុពលទាំងអស់នោះ កំពុងត្រូវបានគេសិក្សាស្វែងរកលទ្ធភាព ហើយក៏មានទីតាំងមួយចំនួន ត្រូវបានគេអនុម័តរួចរាល់ហើយដែរ[22]។

## ១.២ ប្រទេសវៀតណាម

បច្ចុប្បន្ននេះ អ្នកវិនិយោគដ៏ធំបំផុតនៅក្នុងវិស័យវារីអគ្គីសនីក្នុងតំបន់ទន្លេបី គឺប្រទេសវៀតណាម។ ក្នុងចំណោមគម្រោងសាងសង់ទំនប់វារីអគ្គិសនីចំនួន ៦ ដែលនឹងលើកយកមកពិភាក្សានៅក្នុងអត្ថបទនេះ (គម្រោងសេសានក្រោម២ សេសានក្រោម៣ សេសានក្រោម ១/៥ ស្រែពក៣ និងស្រែពក៤) មានគម្រោងចំនួន ៣ ត្រូវបានអភិវឌ្ឍដោយក្រុមហ៊ុនរដ្ឋរបស់វៀតណាម (អគ្គិសនីវៀតណាម)។ ការចាប់អារម្មណ៍របស់ប្រទេសវៀតណាម មកលើវិស័យវារីអគ្គិសនីនៅភាគឦសាននៃប្រទេសកម្ពុជា មិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលទេ ព្រោះបើយើងគិតពីទីតាំងភូមិសាស្ត្រនៃតំបន់ទន្លេបី គឺវាស្ថិតនៅជិតតំបន់ខ្ពង់រាបកណ្តាលរបស់ប្រទេសវៀតណាម។ ដោយសារតែទីតាំងទំនប់នៅក្នុងប្រទេសកម្ពុជា និងនៅប៉ែកខាងត្បូងនៃប្រទេសឡាវ ស្ថិតនៅជាប់នឹងប្រទេសវៀតណាម ដូច្នេះវានាំមកនូវភាពងាយស្រួលក្នុងការនាំចរន្តអគ្គិសនីចេញទៅប្រទេសវៀតណាម។ ប្រទេសវៀតណាម ក៏មានបំណងនយោបាយដ៏ស្អិតរមួតជាមួយនឹងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលប្រទេសឡាវផងដែរ។

---

20 Cambodia New Vision: Issue 149, July 2010, available at http://www.cnv.org.kh/cnv_archives/cnv_archives.htm (accessed November 2011).

21 Presentation by Phallan Pann, Deputy Secretary General, Supreme National Economic Council, *Energy Sector in Cambodia*, September 2009. Available at http://cambodia.usembassy.gov/media2/pdf/energy_sector_in_cambodia.pdf (accessed November 2011).

22 MIME-JICA, internal workshop presentation, *The Master Plan Study of Hydropower Development in Cambodia*, 13 November 2007.

ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងប្រទេសវៀតណាម បានធ្វើឲ្យតម្រូវការថាមពលអគ្គិសនីកើនឡើងយ៉ាងខ្លាំង ហើយនៅចន្លោះឆ្នាំ ១៩៩០ ដល់ឆ្នាំ ២០០៩ ការផលិតថាមពលអគ្គិសនីរបស់ប្រទេសនេះ បានកើនឡើងចំនួន៤ដង។ យោងតាមផែនការអភិវឌ្ឍន៍ថាមពលអគ្គិសនីឆ្នាំ ២០០៦-២០២០ របស់ប្រទេសនេះ ព្យាករណ៍ថា តម្រូវការថាមពលអគ្គិសនីប្រចាំឆ្នាំ នឹងកើនឡើង ១១% ចាប់ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៥ និង ៩% ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០[23]។ យោងតាមអគ្គិសនីវៀតណាម បានដឹងថា នៅក្នុងម៉ោងប្រើប្រាស់ពេញ វៀតណាមខ្វះថាមពលពី១,៥០០មេហ្គាវ៉ាត់ ដល់ ២,០០០ មេហ្គាវ៉ាត់ ដែលនាំឲ្យមានការផ្តាច់ចរន្តជាញឹកញាប់[24]។ កង្វះខាតថាមពលនេះ ត្រូវបានគេ ព្យាករណ៍ថា នឹងនៅតែបន្តកើតឡើងចាប់ពីឆ្នាំ ២០១៣ – ២០១៤[25]។ ការកើនឡើងឥតឈប់ឈរ នូវតម្រូវការថាមពលអគ្គិសនី បានធ្វើឲ្យអ្នកផ្គត់ផ្គង់ថាមពលអគ្គិសនីរដ្ឋរបស់វៀតណាម ជួបនូវការពិបាកជាច្រើន ហើយដើម្បីដោះស្រាយនូវបញ្ហានេះ វៀតណាមបានទិញភ្លើងពីប្រទេសចិន និងព្យាយាមកែលម្អសមត្ថភាពផលិតថាមពលក្នុងស្រុក និងជាមួយប្រទេសជិតខាង។

នៅក្នុងសន្និសិទមួយរបស់អគ្គិសនីវៀតណាម ដែលធ្វើឡើងក្នុងឆ្នាំ ២០១០ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាម បានជម្រុញឲ្យអគ្គិសនីវៀតណាម បង្កើនបរិមាណថាមពលដែលត្រូវផលិត និងត្រូវទិញពីក្រៅប្រទេស ដើម្បីធ្វើយ៉ាងណាបំពេញឲ្យបាននូវសេចក្តីត្រូវការនៅក្នុងប្រទេស[26]។ ប៉ុន្តែរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសវៀតណាម បានជាប់គាំងដោយសារតែខ្វះខាតទឹកជាពិសេសនៅរដូវប្រាំង ដែលកត្តានេះ បង្កឲ្យមានផលប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់សមត្ថភាពផលិតថាមពលវារីអគ្គិសនីរបស់ប្រទេសនេះ ហើយថាមពលដែលបានពីវារីអគ្គិសនី បានផ្គត់ផ្គង់រហូតដល់ ៤០% នៃថាមពលអគ្គិសនីសរុបរបស់ប្រទេស[27]។ នៅក្នុងឆ្នាំ ២០១១ អគ្គិសនីវៀតណាមបានព្យាករណ៍ថា នឹងខ្វះខាតទឹកចំនួន ១២ ពាន់លានម៉ែត្រគូប ក្នុងអាងស្តុកទឹករបស់ទំនប់ទាំងអស់ ដែលអាចបណ្តាលឲ្យខ្វះខាតថាមពលអគ្គិសនីចំនួន ៣ ពាន់លានគីឡូវ៉ាត់ នៅក្នុងឆ្នាំ ២០១១។ នៅក្នុងឆ្នាំដដែលនេះដែរ កម្ពស់ទឹកនៅក្នុងអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនីយ៉ាលី ស្រកចុះទាបជាងឆ្នាំមុនៗ ចំនួន ២០ម៉ែត្រ[28]។ នៅក្នុងខែ មិនា ឆ្នាំ ២០១១ កម្ពស់ទឹកនៅក្នុងអាងស្តុកទឹកទំនប់វារីអគ្គិសនីយ៉ាលី បានធ្លាក់ចុះមកនៅត្រឹមតែ ៦ ម៉ែត្រប៉ុណ្ណោះ ដែលជាការធ្លាក់ចុះទាបបំផុតក្នុងរយៈពេល ៥០ ឆ្នាំ ហើយថាមពលអគ្គិសនីដែលអាចផលិតបានពីទំនប់នេះត្រូវបានគេព្យាករណ៍ថាមានចំនួន ១ ដល់ ១.១ ពាន់លានគីឡូវ៉ាត់ គឺ

23 Economic Consulting Associates, *The Potential of Regional Power Sector Integration: GMS Transmission and Trading Case Study*, January 2010 (p71).

24 Vietnam Financial Review, *Electricity shortfalls: gloom sets in*, 25 March 2011.

25 Thanh Nien News, *Vietnam set to face serious power shortage in 2013*, 6 October 2010.

26 Voice of Vietnam News, *EVN urged to meet high demand for electricity*, 17 January 2010.

27 World Bank website, *Vietnam and Energy*. http://web.worldbank.org/WBSITE/EXTERNAL/COUNTRIES/EASTASIAPACIFICEXT/EXTEAPREGTOPENERGY/0,,contentMDK:20506969~pagePK:34004173~piPK:34003707~theSitePK:574015,00.html (accessed November 2011).

28 Saigon Gai Phong Daily, *Vietnam to face power shortfalls in dry season, EVN says*, 18 January 2011.

ទាបជាងឆ្នាំមុនៗ ដែលអាចផលិតបានពី ១.៨ ដល់ ២ ពាន់លានគីឡូវ៉ាត់[29]។ ទំនប់វារីអគ្គិសនីមួយទៀតរបស់អគ្គិសនីវៀតណាមស្ថិតក្នុងខេត្តឡាមដុង ផលិតថាមពលបាន ៩ លានគីឡូវ៉ាត់ ក្នុង១ថ្ងៃ ខណៈពេលដែលសមត្ថភាពរបស់ទំនប់នេះ អាចផលិតបាន ១៥ លានគីឡូវ៉ាត់ ក្នុង១ថ្ងៃ។ នៅក្នុងប៉ែកខាងត្បូងប្រទេស ទំនប់វារីអគ្គិសនីទ្រីអាន អាចផលិតថាមពលបានត្រឹមតែ ៤០% នៃថាមពលដែលផលិតបានក្នុងឆ្នាំ ២០១០។ មានគម្រោងមួយចំនួន ដែលគេសង្ឃឹមថាអាចបន្តដំណើរការបាន ក៏ត្រូវបានផ្អាកសកម្មភាពដោយត្រូវរងចាំរហូតដល់កម្ពស់ទឹកកើនឡើងវិញ[30]។



ទំនប់យ៉ាលីនៅប្រទេសវៀតណាម

ប៉ុន្មានឆ្នាំកន្លងទៅនេះ ភូមិភាគកណ្តាលរបស់ប្រទេសវៀតណាម បានទទួលរងនូវការខ្វះខាតទឹកដ៏ធ្ងន់ធ្ងរដោយសារតែកត្តាអាកាសធាតុ ប៉ុន្តែការព្រួយបារម្ភត្រូវបានគេលើកឡើងជាបន្តបន្ទាប់ថាការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីរបស់វៀតណាម បាននាំមកនូវភាពរាំងស្ងួតនៅក្នុងតំបន់នេះ។ ជាឧទាហរណ៍គម្រោងសាងសង់ទំនប់វារីអគ្គិសនីកន្ទុំនៅភាគខាងលើ នៅតំបន់ខ្ពង់រាបកណ្តាល បានបង្វែរទឹកពីទន្លេសេសានទៅកាន់ទន្លេដាក់ស្ងេរ (Dac Snghe) ដែលបានកាត់បន្ថយលំហូរទឹកទន្លេនៅតំបន់ទំនាប ប៉ែកខាងក្រោម។ យោងទៅតាម ប្រសាសន៍របស់លោក ង្វៀន ថាន់កៅ ប្រធានសហព័ន្ធវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាក្នុងខេត្តកន្ទុំ បានឲ្យដឹងថា ការធ្វើបែបនេះ បានគម្រាមកំហែងយ៉ាងខ្លាំងដល់ជីវចម្រុះ (ecological diversity) និងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជនតាមដងទន្លេសេសានប៉ែកខាង ក្រោម។ ជាមួយគ្នានេះផងដែរ វានឹងកាត់បន្ថយនូវបរិមាណថាមពល ដែលផលិតបានដោយទំនប់មួយ ចំនួន

29 កាសែត Dantri International ៖ ខ្ពង់រាបកណ្តាលកំពុងជួបនូវគ្រោះរាំងស្ងួតដ៏ធ្ងន់ធ្ងរ , ៣ មិនា ២០១១

30 កាសែត Saigon Gai Phong Daily ៖ កម្ពស់ទឹកក្នុងអាងស្តុកទឹកទំនប់វារីអគ្គិសនីស្រកចុះគួរបារម្ភ , អគ្គិសនីវៀតណាម ២៩ មិនា ២០១១

ទៀតនៅប៉ែកខាងក្រោម[31]។ ទន្ទឹមនឹងនេះផងដែរ នៅមានរបាយការណ៍មួយចំនួនទៀត បាន លើកឡើងថា ទំនប់នៅប៉ែកខាងលើ ការបូមខ្សាច់ដែលគ្មានការគ្រប់គ្រងត្រឹមត្រូវ និងការយកទឹកទៅ ប្រើប្រាស់ក្នុងអាជីវកម្មរ៉ែ នឹងបណ្តាលឲ្យទន្លេជាច្រើននៅតំបន់ខ្ពង់រាបកណ្តាលរបស់ប្រទេសវៀតណាមស្លាប់[32]។ ស្ថានភាពបច្ចុប្បន្នរបស់ប្រព័ន្ធទន្លេនៅភាគកណ្តាលរបស់ប្រទេសវៀតណាម ជាការប្រកាសអាសន្នមួយដល់ប្រទេសកម្ពុជា និងប្រទេស ឡាវអំពីមហន្តរាយដែលនឹងកើតឡើង ដោយការធ្វើផែនការមិនគ្រប់ជ្រុងជ្រោយ ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីយ៉ាងតក់ក្រហល់ និងការអភិវឌ្ឍន៍ឧស្សាហកម្មដទៃទៀតនៅក្នុងតំនប់ទន្លេបីរបស់ប្រទេសទាំងពីរនេះ។

ដើម្បីឆ្លើយតបទៅនឹងកង្វះខាតថាមពលអគ្គិសនី និងការថយចុះបរិមាណថាមពលអគ្គិសនីរបស់រោងចក្រវារីអគ្គិសនីទាំងអស់ ប្រទេសវៀតណាម កំពុងតែព្យាយាមកែលម្អកង្វះខាតនេះ តាមរយៈការនាំចូលអគ្គិសនីពីប្រទេសជិតខាង។ នៅក្នុងឆ្នាំ ២០១០ រដ្ឋាភិបាលវៀតណាម បានបង្គាប់ឲ្យអគ្គិសនីវៀតណាមផ្តួចផ្តើមការចរចារកដំណោះស្រាយរយៈពេលវែង ក្នុងការនាំអគ្គិសនីពីប្រទេសចិន និងពីប្រទេសផ្សេងៗក្នុងតំបន់។ ក្នុងនោះរួមមានការទិញថាមពលតាមបណ្តាញចែកចាយថាមពលដែលមានស្រាប់ ការសិក្សាស្វែងរកលទ្ធភាពតម្លើងបណ្តាញចែកចាយកម្លាំង ៥០០គីឡូវ៉ាត់ ភ្ជាប់ពីប្រទេសចិនមកប្រទេសវៀតណាម ពន្លឿនគម្រោងនានាដើម្បីទទួលបានប្រភពថាមពលវារីអគ្គិសនីពីប្រទេសឡាវ និងប្រទេសកម្ពុជា ព្រមទាំងរួសរាន់សាងសង់បណ្តាញចែកចាយថាមពលរួមមួយ រវាងប្រទេសកម្ពុជា ប្រទេសវៀតណាម និងប្រទេសឡាវ[33]។ ក្រៅពីទំនប់វារីអគ្គិសនីដែលបានគ្រោងឡើងដោយវៀតណាមក្នុងប្រទេសកម្ពុជា នៅមានទំនប់យ៉ាងតិចចំនួន១៦ទៀត ត្រូវបានគ្រោងឡើងនៅក្នុងប្រទេសឡាវ[34]។ របាយការណ៍ពិគ្រោះយោបល់របស់ធនាគារពិភពលោក ឆ្នាំ ២០១០ បង្ហាញថា ដល់ឆ្នាំ ២០២៥ សមត្ថភាពផលិតថាមពលអគ្គិសនីទាំងអស់របស់វៀតណាម នឹងត្រូវស្រូបយកអស់ដោយតម្រូវការថាម ពលក្នុងស្រុក ដែលនឹងជម្រុញឲ្យប្រទេសនេះ បង្កើតនូវជម្រើសថ្មីៗទៀតក្នុងការផលិត និងការនាំចូលថាមពលពីក្រៅប្រទេស។[35]

អគ្គិសនីវៀតណាម បាន និងកំពុងទិញថាមពលដ៏ច្រើនពីប្រទេសចិន ហើយយោងតាមសារព័ត៌មានវៀតណាមបានឲ្យដឹងថា នៅក្នុងរយៈពេល ២ខែ ដើមឆ្នាំ ២០១១ វៀតណាមបានទិញថាមពល

31 Saigon Gai Phong Daily, *Hydropower plants depleting rivers*, 27 May 2011.

32 Saigon Gai Phong Daily, *Central Highlands rivers dying*, 26 May 2011.

33 The Saigon Times, *EVN told to start talks for long-term power import*, 5 September 2010.

34 Cambodia-Laos-Vietnam Development Triangle Portal, *Vietnam, Laos strengthen hydropower cooperation*, 25 November 2010. http://clv-triangle.vn/portal/page/portal/clv_en/819084/823229?p_page_id=819084&pers_id=823688&folder_id=&item_id=8380772&p_details=1 (accessed November 2011).

35 Asian Development Bank, *RETA 6440: Facilitating Regional Power Trading and Environmentally Sustainable Development of Electricity Infrastructure in the Greater Mekong Subregion*, Final report - Component 1, Module 1: Update of the GMS Regional Master Plan, executive summary, 15 October 2010 (p25).

អគ្គិសនីចំនួន ៩៥៦ លានគីឡូវ៉ាត់ពីប្រទេសចិន គឺកើនឡើង ២៨% បើធៀបនឹងឆ្នាំ ២០១០។[36] វៀតណាម ក៏មានចុះអនុសារណៈយោគយល់គ្នាជាមួយនឹងប្រទេសឡាវ ក្នុងការនាំថាមពលអគ្គិសនីពីប្រទេស នេះផងដែរ និងដោយមានការគាំទ្រពីធានាគារអភិវឌ្ឍន៍អាស៊ី វៀតណាមមានផែនការកសាងបណ្តាញចែកចាយក្នុងប្រទេសឡាវ និងប្រទេសកម្ពុជា បន្ទាប់មកភ្ជាប់ចូលខ្សែបណ្តាញជាតិវៀតណាម។ យោងទៅតាមក្រសួង ឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាមបានឲ្យដឹងថា ប្រទេសនេះ មានផែនការវិនិយោគដែលមាន ទឹកប្រាក់ជិត ៥០ ពាន់លានដុល្លា លើវិស័យថាមពលសម្រាប់រយៈពេល ១០ឆ្នាំ។ ពីរភាគបីនៃទឹកប្រាក់នេះ នឹងត្រូវប្រើប្រាស់សម្រាប់សាងសង់ទំនប់វារីអគ្គិសនី ហើយទឹកប្រាក់ដែល នៅសល់នឹងត្រូវប្រើប្រាស់សម្រាប់កសាងបណ្តាញចែកចាយ។[37]

## ១.៣ ប្រទេសឡាវ

ប្រទេសឡាវ មានសក្តានុពលគ្រប់គ្រាន់នៅក្នុងវិស័យវារីអគ្គិសនី (តាមការព្យាករណ៍របស់រដ្ឋាភិបាលឡាវ ប្រទេសនេះមានសក្តានុពលសរុបចំនួន ១៨,០០០ ម៉េហ្គាវ៉ាត់) ប៉ុន្តែក្នុងរយៈពេល ៣០ឆ្នាំមកនេះ គេអាចទាញយកថាមពលមកប្រើប្រាស់បានត្រឹមតែ ២% នៃសក្តានុពលដែលមាន។[38] យោងតាមឯកសាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីបង្ហាញថា មានទីតាំងសក្តានុពលចំនួន ៣៣ កន្លែង ត្រូវបានគេកំណត់ និងវាយតម្លៃ ដែលក្នុងចំណោមទីតាំងទាំងនោះមានទីតាំងចំនួន ១១ កន្លែង ត្រូវបានគេរំពឹងទុកថានឹងអភិវឌ្ឍក្នុងរយៈ ១៥ឆ្នាំ ទៀត និងមានថាមពលសរុបចំនួន ៤,០០០ ម៉េហ្គាវ៉ាត់។ អាស្រ័យដោយមានការខ្វះខាតនូវសមត្ថភាព និងធនធានហិរញ្ញវត្ថុក្នុងស្រុក ប្រទេសឡាវ កំពុងតែជម្រុញលើកទឹកចិត្តដល់វិស័យឯកជន និងក្រុមហ៊ុនបរទេសឲ្យធ្វើការវិនិយោគ និងអភិវឌ្ឍន៍គម្រោងវារីអគ្គិសនីទាំងនេះ។[39] ប្រទេសឡាវមានចំនួនប្រជាជនតិច ហើយតម្រូវការថាមពលអគ្គិសនីក្នុងស្រុកគឺស្ថិតនៅទាបជាង ៦០០ ម៉េហ្គាវ៉ាត់ ជាមួយនឹងការព្យាករណ៍ថានឹងកើនដល់ ២,៩០០ ម៉េហ្គាវ៉ាត់ នៅចន្លោះឆ្នាំ ២០១៥ ដល់ ២០២០។[40] ដូច្នេះថាមពលដែលនឹងផលិតបាន ភាគច្រើននឹងនាំចេញទៅក្រៅប្រទេស។

ប្រទេសឡាវ បានចុះកិច្ចព្រមព្រៀងជាមួយនឹងប្រទេសថៃក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនីចំនួន ៥,០០០ ម៉េហ្គាវ៉ាត់ រហូតដល់ឆ្នាំ ២០១៥ និងយ៉ាងហោចណាស់ ២,០០០ ម៉េហ្គាវ៉ាត់បន្ទាប់ពីឆ្នាំ

36 Saigon Gai Phong Daily, *Water level of hydropower reservoirs alarmingly low: EVN*, 29 March 2011.

37 Wall Street Journal Online, *Vietnam plans to raise $48.8 billion for power projects in 2011-2020*, 5 August 2011.

38 See Powering Progress website, maintained by the Laos Department of Energy Promotion and Development (EPD): *The Energy Sector in Lao PDR*, http://www.poweringprogress.org/index.php?option=com_content&view=article&id=55&Itemid=27 (accessed November 2011).

39 Asian Development Bank, *Project 41450: Preparing the Ban Sok-Pleiku Power Transmission Project in the Greater Mekong Subregion*, August 2008 (para 2).

40 Vientiane Times, *More power plants needed to meet predicted demand surge*, 27 May 2011.

២០១៥។[41] នៅក្នុងឆ្នាំ ២០០៨ រដ្ឋាភិបាលវៀតណាម បានចុះកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនីពីប្រទេសឡាវចំនួន ៥,០០០ ម៉េហ្គាវ៉ាត់ ដល់ឆ្នាំ ២០២០។[42] ប្រទេសកម្ពុជាក៏មានកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនីពីប្រទេសឡាវផងដែរ។ កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងក្នុងឆ្នាំ ២០០៧ ដែលចែងថា អគ្គិសនីឡាវនឹងផ្គត់ផ្គង់អគ្គិសនី ១០ ម៉េហ្គាវ៉ាត់ ពីខ្សែបណ្តាញភាគខាងត្បូងរបស់ខ្លួនកាត់តាមព្រំដែនមកបំពេញតម្រូវការក្នុងស្រុករបស់កម្ពុជា។ ជាមួយគ្នានេះផងដែរ ក៏នៅមានកិច្ចសន្យាបន្ថែមទៀតរវាងរដ្ឋាភិបាលប្រទេសទាំង ២ ក្នុងការផ្គត់ផ្គង់ថាមពល ២០០ ម៉េហ្គាវ៉ាត់ មកឲ្យប្រទេសកម្ពុជានៅក្នុងឆ្នាំ ២០២០ ផងដែរ។[43]

ទោះបីជាគម្រោងទំនប់វារីអគ្គិសនីខ្នាតធំជាច្រើន កំពុងបន្តអភិវឌ្ឍក៏ដោយ ក៏នៅមានតំបន់ជាច្រើនរបស់ប្រទេសឡាវ ជួបនូវការខ្វះខាតថាមពលអគ្គិសនីប្រើប្រាស់ ហើយដើម្បីបំពេញនូវតម្រូវការនេះ ប្រទេសឡាវត្រូវទិញថាមពលអគ្គិសនីមកពីប្រទេសថៃ។ នៅក្នុងឆ្នាំ ២០១១ ក្រសួងឧស្សាហកម្ម និងថាមពលបានថ្លែងថា "ចាំបាច់ត្រូវតែសង់ទំនប់វារីអគ្គិសនីបន្ថែមទៀត ដើម្បីបំពេញតម្រូវការអគ្គិសនីនៅក្នុងស្រុក"។[44]

## ១.៤ កម្មវិធីមហាអនុតំបន់ទន្លេមេគង្គ

ដោយមានការភ្ជាប់ទំនាក់ទំនងតាំងពីឆ្នាំ ១៩៩២ មក សមាជិករបស់មហាអនុតំបន់ទន្លេមេគង្គរួមមាន ៖ ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសភូមា ប្រទេសថៃ ប្រទេសវៀតណាម និងខេត្តយូណាន និងតំបន់ស្វយ័តគ័ងស៊ីហ្សួន របស់ប្រទេសចិន។ យុទ្ធសាស្ត្ររបស់មហាអនុតំបន់ទន្លេមេគង្គ គ្របដណ្តប់លើផ្នែកចំនួន ៥ សំខាន់ៗ ៖ ពង្រឹងការភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ សម្រួលការធ្វើពាណិជ្ជកម្ម ការវិនិយោគ និងទេសចរណ៍ឆ្លងដែន លើកកម្ពស់ការចូលរួម និងការប្រកួតប្រជែងរបស់វិស័យឯកជន ការការពារ បរិស្ថាន និងជម្រុញឲ្យមានការប្រើប្រាស់ធនធានធម្មជាតិរួមគ្នាប្រកបដោយចិរភាព និងការអភិវឌ្ឍ សមត្ថភាពជំនាញ និងធនធានមនុស្ស។[45]

ក្រៅពីគោលនយោបាយរបស់ប្រទេសនីមួយៗ កិច្ចព្រមព្រៀងទ្វេភាគី និងកិច្ចព្រមព្រៀងក្នុងតំបន់ កម្មវិធីមហាអនុតំបន់ទន្លេមេគង្គ ក៏ត្រូវបានទទួលស្គាល់ដោយអ្នកឃ្លាំមើលមួយចំនួនផងដែរថាជាសមាសធាតុគន្លឹះនៃការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅក្នុងតំបន់នេះ។ តាមរយៈកម្មវិធីមហាអនុតំបន់ទន្លេ

41 Nam Theun 2 Power Company (NTPC) website: http://www.namtheun2.com/index.php?option=com_content&view=article&id=54&Itemid=60 (accessed November 2011).

42 Asian Development Bank, *Project 41450: Preparing the Ban Sok-Pleiku Power Transmission Project in the Greater Mekong Subregion*, August 2008 (para 3).

43 http://www.poweringprogress.org/index.php?option=com_content&view=article&id=49&Itemid=53 (accessed November 2011).

44 Vientiane Times, *More power plants needed to meet predicted demand surge*, 27 May 2011.

45 ADB-GMS, *Strategy and Action Plan for the Greater Mekong Subregion Southern Economic Corridor*, 2010 (p1).

មេគង្គ ធនាគារអភិវឌ្ឍន៍អាស៊ី បានគាំទ្រដល់គម្រោងវារីអគ្គិសនីមួយចំនួន និងរចនាសម្ព័ន្ធចែកចាយថាមពលក្នុងតំបន់ និងបន្តដើរតួនាទីដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍បរិក្ខាផលិតថាមពលអគ្គិសនី និងការទំនាក់ទំនងគ្នាទៅវិញទៅមកក្នុងតំបន់។

កម្មវិធីមហាអនុតំបន់ទន្លេមេគង្គ ផ្តោតការយកចិត្តទុកដាក់ជាចម្បងទៅលើវិស័យអគ្គិសនី ក្នុងនោះ គោលបំណងរបស់កម្មវិធីនេះ ចង់បង្កើនឲ្យមាននូវទីផ្សារអគ្គិសនីដែលមានការចូលរួមនៅក្នុងតំបន់ និងទីផ្សារដែលមានការប្រកួតប្រជែង ដែលនឹងទាញយកនូវប្រភពថាមពលមកប្រើប្រាស់ឲ្យអស់លទ្ធភាពសម្រាប់មហាអនុតំបន់ទន្លេមេគង្គ និងជួយសម្រេចបាននូវទិសដៅអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រទេសមហាអនុតំបន់ទន្លេមេគង្គ។[46] គេរំពឹងទុកថា ការអភិវឌ្ឍន៍ពាណិជ្ជកម្មអគ្គិសនីនៅក្នុងតំបន់ នឹងនាំមកនូវការផ្គត់ផ្គង់ថាមពលអគ្គិសនីដែលអំណោយផល និងមានស្ថិរភាព និងកាត់បន្ថយចំណាយលើការវិនិយោគ។ ទាំងអស់នេះ អាចសម្រេចទៅបានតាមរយៈគោលនយោបាយនៃការអភិវឌ្ឍន៍ និងក្របខ័ណ្ឌស្ថាប័នក្នុងការចែករំលែកថាមពលអគ្គិសនី និងការទទួលយកនូវផែនការមេសម្រាប់ការទំនាក់ទំនងគ្នាទៅវិញទៅមក។[47] មានគម្រោងមួយរបស់កម្មវិធីមហាអនុតំបន់ទន្លេមេគង្គ គឺគម្រោងតភ្ជាប់ខ្សែបណ្តាញចែកចាយពីភាគខាងត្បូងប្រទេសឡាវទៅកាន់ប្រទេសវៀតណាម ដែលគម្រោងនេះ គាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងគម្រោងភ្ជាប់ខ្សែបណ្តាញចែកចាយពីប្រទេសឡាវមកប្រទេសកម្ពុជា ដែលគាំទ្រដោយធនាគារពិភពលោក នឹងត្រូវបានគេលើកយកមកពិភាក្សានៅក្នុងរបាយការណ៍នេះ។ តាមរយៈកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ សមាជិកទាំងអស់មានគោលបំណងគាំទ្រការបង្កើតឲ្យមានខ្សែបណ្តាញក្នុងតំបន់ បង្រួបបង្រួមវិស័យថាមពលក្នុងតំបន់ និងបើកចំហរ វិស័យអគ្គិសនីក្នុងតំបន់សម្រាប់ការវិនិយោគឯកជន។[48]

ដូចដែលបង្ហាញជូននៅក្នុងរបាយការណ៍នេះ គេអាចដឹងថា ខ្សែបណ្តាញចែកចាយដែលមានកម្លាំងខ្លាំង មានសារសំខាន់យ៉ាងខ្លាំង ក្នុងការធ្វើឲ្យសម្រេចបាននូវការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំ។ នៅក្នុងប្រទេសកម្ពុជា និងប្រទេសឡាវ (ដែលមានការអភិវឌ្ឍន៍ទាបជាងប្រទេសវៀតណាម) ខ្សែបណ្តាញចែកចាយ គឺជាតម្រូវការដ៏ចាំបាច់មួយ សម្រាប់ធ្វើការចែកចាយថាមពលអគ្គិសនីក្នុងស្រុក និងសម្រាប់តភ្ជាប់ពីទីតាំងទំនប់វារីអគ្គិសនីចូលទៅទីប្រជុំជន។ លើសពីនេះទៅទៀត ខ្សែចែកចាយ ដែលមានកម្លាំងខ្ពស់ ក៏ជាតម្រូវការដ៏ចាំបាច់មួយផ្សេងទៀត ដើម្បីនាំចរន្តអគ្គិសនីដែលលើសតម្រូវការ ចេញទៅប្រទេសជិតខាង រួមមានប្រទេសវៀតណាម និងប្រទេសថៃជាដើម។ បើយើងគិតឲ្យសាមញ្ញ ដោយ

46 ADB-GMS overview brochure, 2010.

47 *Ibid*.

48 For more see: Both Ends Environmental and Development Service, *The ADB Support for Hydropower Dams and Power Grid – ADB and the Greater Mekong Subregion Program*. http://www.bothends.org/uploaded_files/hydropower-FINAL-1.pdf (accessed November 2011).

កុំគិតពីការអភិវឌ្ឍន៍ទំនប់នៅប៉ែកខាងត្បូងប្រទេសឡាវ និងនៅក្នុងប្រទេសកម្ពុជា យើងឃើញថា គេមិនចាំបាច់ត្រូវការឲ្យមានខ្សែចែកចាយកម្លាំងខ្លាំងនោះទេ ហើយបើមិនមានខ្សែចែកចាយទាំងនោះ ការនាំចរន្តអគ្គិសនីចេញក៏មិនអាចធ្វើទៅរួចដែរ។ ហេតុដូច្នេះ ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងតែដើរតួនាទី ដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វារីអគ្គិសនីនៅក្នុងតំបន់ទន្លេបី។

បើប្រៀបធៀបជាមួយនឹងប្រទេសជិតខាង ប្រទេសកម្ពុជាគឺជាប្រទេសថ្មីដែលទើបនឹងចូលប្រឡូកក្នុងវិស័យវារីអគ្គិសនីនេះ តាមរយៈការដាក់ឲ្យប្រើប្រាស់ទំនប់វារីអគ្គិសនីខ្នាតធំរបស់ខ្លួន នៅក្នុងខេត្តកំពត នាខែធ្នូ ឆ្នាំ ២០១១ កន្លងទៅនេះ។ ការសិក្សារបស់ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន បានបង្ហាញឲ្យដឹងថា នៅក្នុងប្រទេសកម្ពុជា មានសក្តានុពលសម្រាប់សាងសង់វារីអគ្គិសនីខ្នាតធំចំនួន ២៩ កន្លែង ក្នុងនោះ ៩ កន្លែង ស្ថិតនៅក្នុងតំបន់ទន្លេបី។[49] នៅក្នុងផ្នែកបន្ទាប់នេះ នឹងមានការពិភាក្សាលម្អិតពីទំនប់វារីអគ្គិសនីចំនួន ៥ កន្លែង ក្នុងចំណោមទំនប់ដែលបានគ្រោងឡើងទាំងនេះ និង ១ កន្លែងទៀតស្ថិតនៅព្រំដែនកម្ពុជា-វៀតណាម។



រូបភាពទំនប់វារីអគ្គិសនីកំចាយក្នុងខេត្តកំពត ប្រទេសកម្ពុជា។ ថតដោយ Mark Grimsditch

49 The potential sites are: Lower Sekong, Lower Sesan 2 and Lower Srepok 2 (these have since been combined into a single dam), Lower Sesan 3, Lower Srepok 3, Lower Srepok 4, Prek Liang 1, Prek Liang 1A, and Prek Liang 2.

## ផ្នែកទី ២ ៖
## ការប្រែប្រួលរបស់ទន្លេបី
## ក្នុងប្រទេសកម្ពុជា

នៅក្នុងផ្នែកនេះ នឹងពិពណ៌នាពីសវតារបស់គម្រោងទំនប់វារីអគ្គិសនីសំខាន់ៗមួយចំនួន ដែលបានគ្រោងឡើងនៅក្នុងតំបន់ទន្លេបី ក្នុងនោះរួមមានព័ត៌មានលម្អិតរបស់គម្រោង ស្ថានភាពរបស់គម្រោង ដំណើរការអនុម័ត និងដំណើរការពិគ្រោះយោបល់ដែលបានធ្វើកន្លងមក និងព័ត៌មានពាក់ព័ន្ធនឹងអ្នកអភិវឌ្ឍន៍ដែលបានចូលរួមនៅក្នុងគម្រោងទាំងអស់នេះ។ ទំនប់ទាំងនោះរួមមាន ៖ ទំនប់ សេសានក្រោម២ សេសានក្រោម៣ សេសានក្រោម ១/៥ ស្រែពកក្រោម៣ និងស្រែពកក្រោម៤ និងទំនប់សេកុងក្រោម។[50] នៅក្នុងផ្នែកនេះ ក៏មានពិពណ៌នាពីព័ត៌មានដែលទទួលបានពាក់ព័ន្ធនឹងខ្សែ បណ្តាញសំខាន់ៗ តភ្ជាប់ទំនប់ទាំងអស់នេះទៅនឹងខ្សែបណ្តាញជាតិ និងជាមួយប្រទេសជិតខាង។

នៅក្នុងឆ្នាំ ២០០៣ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលកម្ពុជា ជាមួយនឹងគណៈកម្មការទន្លេមេគង្គជាតិ បានរៀបចំក្រុមការងារថ្នាក់ជាតិមួយ ដើម្បីពិនិត្យលើការងារវារីអគ្គិសនី ដែលក្នុងនោះក្រុមការងារបានកំណត់ទីតាំងសក្តានុពលសម្រាប់អភិវឌ្ឍន៍ទំនប់វារីអគ្គិសនីចំនួន ៦០ កន្លែង។ ការសិក្សាប្រហាក់ប្រហែលគ្នានេះក៏បានឲ្យដឹងផងដែរថា អានុភាពសរុបរបស់ប្រទេសនេះ មានចំនួន ១០,០០០ ម៉េហ្គាវ៉ាត់ ដែល ៥០% ស្ថិតនៅតាមដងទន្លេមេគង្គ ៤០% ស្ថិតនៅតាមដៃទន្លេមេគង្គ និង ១០% ទៀតស្ថិតនៅប៉ែកនិរតីនៃប្រទេស។ នៅក្នុងចំណោមសក្តានុពលទាំង ៦០ កន្លែងនោះ គម្រោងទំនប់វារី អគ្គិសនីសេសានក្រោម២ សេសានក្រោម៣ និងស្រែពកក្រោម៣ គឺជាគម្រោងដែលមានអាទិភាព ជាងគេ។[51]

ការសង្ខេបអំពីគម្រោងទាំងនេះ នៅមានចំណុចខ្វះចន្លោះច្រើន។ ទោះបីជាយើងមានឯកសារសំអាងផ្លូវការមួយចំនួនក៏ដោយ ក៏ការបំពេញព័ត៌មានខ្វះចន្លោះទាំងនេះ ត្រូវបានធ្វើឡើងដោយទទួលបានឯកសារភាគច្រើនពីបណ្តាញសារព័ត៌មាន។ វាគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ដែលយើងមិនអាចទទួលបានឯកសារផ្លូវការពេញលេញនោះ ព្រោះបញ្ហានេះវាបានក្លាយជារឿងសាមញ្ញទៅហើយក្នុងការទទួលព័ត៌មានពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅក្នុងប្រទេសកម្ពុជា។ ប្រសិនបើប្រទេសកម្ពុជាចង់ឲ្យមានការអភិវឌ្ឍន៍ថាមពល ក្នុងមធ្យោបាយមួយដែលជួយបង្កើនការផលិតថាមពលឲ្យដល់កម្រិត អតិបរមា និងកាត់បន្ថយផលប៉ះពាល់ចំពោះបរិស្ថាន និងសហគមន៍ឲ្យស្ថិតក្នុងកម្រិតអប្បរមា នោះគេចាំបាច់ត្រូវពង្រឹងតម្លាភាពឲ្យបានរឹងមាំ។

---

50 For the sake of clarity, the dams on 3S rivers inside Cambodia all use the prefix “lower”, and in Laos and Vietnam “upper”.

51 Cambodia National Mekong Committee (prepared by MIME), *National Sector Review 2003: Hydropower*, June 2003 (p5, 8-9).

## ២.១ ទំនប់វារីអគ្គិសនីសេសានក្រោម២

**ទំនប់សេសានក្រោម២ ៖ ព្រឹត្តិការណ៍**

ស្ថិតនៅតាមដងទន្លេសេសាន ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ចម្ងាយ ១.៥ គីឡូម៉ែត្រ ពីចំណុចប្រសព្វរវាងទន្លេសេសាន និងទន្លេស្រែពក ក្នុងប្រទេសកម្ពុជា។ ទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវបានអនុម័តក្នុងខែ មករា ឆ្នាំ ២០១១ ដោយចាប់ដំណើរការសាងសង់ក្នុងឆ្នាំ ២០១២ និងបញ្ចប់ក្នុងឆ្នាំ ២០១៦។ ទំនប់វារីអគ្គិសនីនេះនឹងធ្វើប្រតិបត្តិការក្នុងឆ្នាំ ២០១៧។

| | |
|---|---|
| សមត្ថភាព ៖ | ៤០០ ម៉េហ្គាវ៉ាត់ |
| ទំហំទំនប់ ៖ | កម្ពស់ ៧៥ ម៉ែត្រ និងបណ្តាយ ៦ គីឡូម៉ែត្រ |
| ទំហំអាងស្តុកទឹក ៖ | ៣៤០+ គីឡូម៉ែត្រការ៉េ |
| តម្លៃប៉ាន់ស្មាន ៖ | ៨១៦ លានដុល្លា |
| ថាមពលផលិតបាន ៖ | សម្រាប់ប្រទេសកម្ពុជា និងនាំចេញទៅប្រទេសវៀតណាម |

**អ្នកអភិវឌ្ឍន៍គម្រោង ៖**

- ក្រុមហ៊ុនវារីអគ្គិសនីកម្ពុជា-វៀតណាម ជាការសហការគ្នារវាងអគ្គិសនីវៀតណាម (EVN) ជាមួយក្រុមហ៊ុន (EVNI) និងក្រុមហ៊ុនរ៉ូយាល់គ្រុបរបស់កម្ពុជា
- សិក្សាស្វែងរកលទ្ធភាព លើកផែនការផ្លាស់ទីលំនៅ និងអភិវឌ្ឍន៍គម្រោងដោយក្រុមហ៊ុន PECC1
- សិក្សាហេតុប៉ះពាល់បរិស្ថានដោយ ក្រុមហ៊ុនឃី ខនសាល់ធេន ខេមបូឌា (KCC)

### <u>សាវតារ</u>

ដោយសារតែទំនប់សេសានក្រោម២ គឺជាទំនប់ដែលធំជាងគេនៅក្នុងតំបន់ទន្លេបី គម្រោងសាងសង់ទំនប់នេះ ត្រូវបានគេលើកយកមកពិភាក្សា និងជជែកវែកញែកអស់រយៈពេលជាច្រើនឆ្នាំ។ ទំនប់មួយនេះមានទីតាំងស្ថិតនៅតាមដងទន្លេសេសាន ក្បែរចំណុចប្រសព្វទន្លេសេសានជាមួយនឹងទន្លេស្រែពក ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលមានចម្ងាយប្រហែល ២៥ គីឡូម៉ែត្រពីទីប្រជុំជនខេត្តស្ទឹងត្រែង។ នៅក្នុងឆ្នាំ ២០០៧ មានអនុស្សារណៈយោគយល់មួយត្រូវបានធ្វើឡើង រវាងអគ្គិសនីវៀតណាមជាមួយនឹងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលកម្ពុជា ដោយឲ្យអគ្គិសនីវៀតណាមជាអ្នកសិក្សាស្វែងរក

លទ្ធភាពសង់ទំនប់។ ហេតុប៉ះពាល់បរិស្ថាន ត្រូវបានគេសិក្សាចប់សព្វគ្រប់នៅចន្លោះខែ កមរា ដល់ខែ មិថុនា ក្នុងឆ្នាំ ២០០៨ និងត្រូវបានគេអនុម័តក្នុងខែ មិថុនា ឆ្នាំ ២០១០។[52]

ទំនប់នេះមានអានុភាពអគ្គិសនី ៤០០ ម៉េហ្គាវ៉ាត់ ដែលនឹងត្រូវយកមកបំពេញតម្រូវការនៅក្នុងស្រុក និងនាំចេញទៅប្រទេសវៀតណាម។ ក្នុងតម្លៃ ៨១៦ លានដុល្លា គម្រោងនេះនឹងផ្តល់ការងារដល់កម្មករ ៣,០០០ នាក់ និងរំពឹងទុកថានឹងប្រើប្រាស់បានរយៈ ១០០ឆ្នាំ។ ទស្សនវិស័យដំបូងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានបង្ហាញថា ទំនប់នេះមានកម្ពស់ ៧៥ ម៉ែត្រ លើនីវ៉ូទឹកសមុទ្រ គឺប្រហែល ៤០ម៉ែត្រ ពីកម្ពស់ច្រាំងទន្លេ។[53] យោងទៅតាមការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានឲ្យដឹងថា អាងស្តុកទឹករបស់ទំនប់នេះមានទំហំ ៣៣៥ គីឡូម៉ែត្រក្រឡា។[54] ប៉ុន្តែយោងទៅតាមការសែតសែហ្កុនថៃមបានរាយការណ៍ថា ដោយយោងទៅតាមរបាយការណ៍ចុងក្រោយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបានឲ្យដឹងថា ទំនប់នេះនឹងមានប្រវែង ៦ គីឡូម៉ែត្រ និងផ្ទៃលិចទឹក ៤០០ គីឡូម៉ែត្រក្រឡា។[55]




ផែនទីទំនប់សេសានក្រោម២ និងអាងស្តុកទឹក

ក្រុមហ៊ុនដែលអភិវឌ្ឍន៍គម្រោងនេះ ជាក្រុមហ៊ុនវារីអគ្គិសនីកម្ពុជា-វៀតណាម ដែលជាកិច្ចសហការរួមគ្នារវាងភាគហ៊ុនមួយផ្នែករបស់អគ្គិសនីវៀតណាម ជាមួយក្រុមហ៊ុនរ៉ូយាល់គ្រុបរបស់កម្ពុជា។ អគ្គិសនីវៀតណាម មានប្រវត្តិការងារយ៉ាងយូរនៅក្នុងការអភិវឌ្ឍន៍គម្រោងទំនប់វារីអគ្គិសនី ប៉ុន្តែសម្រាប់

52 PECC1 & KCC, *Environmental Impact Assessment for Feasibility Study of Lower Sesan 2 Hydropower Project, Stung Treng Province*, Cambodia, October 2008 (pS-1).

53 *Ibid*. (pS-2)

54 *Ibid*. (pS-2)

55 The Saigon Times, *Sesan 2 hydropower plant behind schedule*, 9 August 2011.

ក្រុមហ៊ុនរ៉ូយាល់គ្រុប គឺជាក្រុមហ៊ុនថ្មីមួយដែលចូលប្រឡូកក្នុងវិស័យនេះ។ ក្រុមហ៊ុនទាំង ២ នេះនឹង ត្រូវលើកយកមកពិភាក្សាកាន់តែលម្អិត នៅផ្នែកខាងក្រោមនេះ។

ដូចដែលបានលើកឡើងនៅខាងដើមថា អនុសារណៈយោគយល់ក្នុងការសិក្សាស្វែងរកលទ្ធភាពគម្រោង ត្រូវបានចុះហត្ថលេខារវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលកម្ពុជា ជាមួយនឹងអគ្គិសនី វៀតណាមនៅក្នុងខែ មិថុនា ឆ្នាំ ២០០៧។ យោងតាមអនុសារណៈនេះ អគ្គិសនីវៀតណាមក៏បានជួល ក្រុមហ៊ុនដែលជាភាគហ៊ុនរបស់ខ្លួន (PECC1) ឲ្យសិក្សាស្វែងរកលទ្ធភាពរបស់គម្រោង។ អគ្គិសនីវៀតណាម ជាម្ចាស់ភាគហ៊ុនដ៏ធំរបស់ក្រុមហ៊ុន PECC1។[56] ការសិក្សាស្វែងរកលទ្ធភាព ត្រូវបានធ្វើឡើងនៅចន្លោះ ឆ្នាំ ២០០៨ និងឆ្នាំ ២០០៩ ហើយក្រុមហ៊ុន PECC1 បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ឃីខនសាល់ ធេន ខេមបូឌា (KCC) ឲ្យសិក្សាវាយតម្លៃពីហេតុប៉ះពាល់បរិស្ថាន ដែលជាផ្នែកមួយនៃការសិក្សាស្វែងរកលទ្ធភាពរបស់គម្រោង។ អគ្គិសនីវៀតណាម នឹងអភិវឌ្ឍន៍គម្រោងនេះតាមរយៈក្រុមហ៊ុនដែលជាភាគហ៊ុនរបស់ខ្លួន គឺ EVN International Joint Stock Company (EVNI) ក្នុងកិច្ចព្រមព្រៀង BOT ដែលមាន រយៈពេល ៣០ឆ្នាំ។[57]

នៅដើមឆ្នាំ ២០១១ មានការប្រកាសជាសាធារណៈពីការរួមបញ្ចូលគ្នារវាងក្រុម ហ៊ុន EVNI ជាមួយនឹងក្រុមហ៊ុនរ៉ូយាល់គ្រុបដើម្បីអភិវឌ្ឍន៍គម្រោងសេសានក្រោម២នេះ។ តាមការឲ្យដឹងពីប្រធានក្រុមហ៊ុនរ៉ូយាល់គ្រុប ឧកញ៉ា គិត ម៉េង អគ្គិសនីវៀតណាមមានភាគហ៊ុន ៥១% និងក្រុមហ៊ុនរ៉ូយាល់គ្រុបមានភាគហ៊ុន ៤៩%។[58] ការរួមបញ្ចូលគ្នារវាងក្រុមហ៊ុនទាំង ២ ត្រូវបានធ្វើឡើងជាផ្លូវការ ក្នុងឆ្នាំ ២០១១ និងដាក់ឈ្មោះក្រុមហ៊ុនចម្រុះនេះថា "ក្រុមហ៊ុនវារីអគ្គិសនីកម្ពុជា-វៀតណាម"។ មិនយូរប៉ុន្មានបន្ទាប់ពីការដាក់បញ្ចូលគ្នានេះ ក្រុមហ៊ុនរ៉ូយាល់គ្រុបក៏បានប្រកាសថា ទំនប់វារីអគ្គិសនីសេសានក្រោម ២ នឹងអាចធ្វើប្រតិបត្តិការបានក្នុងឆ្នាំ ២០១៧។[59]

យោងទៅតាមរបាយការណ៍របស់បណ្តាញសារព័ត៌មានមួយ ដែលរាយការណ៍ក្នុងខែ កក្កដា ឆ្នាំ ២០១១ បានឲ្យដឹងថា ប្រទេសកម្ពុជាបានព្រមព្រៀងទិញអគ្គិសនី ៥០% ដែលផលិតដោយទំនប់សេសានក្រោម២។ អត្ថបទកាសែតនេះបានសរសេរថា ភាគីទាំង២ កំពុងតែចរចាគ្នាលើតម្លៃចរន្តអគ្គិសនី និងលើកិច្ចព្រមព្រៀងទិញចរន្តអគ្គិសនីនេះ។ អគ្គិសនីវៀតណាម ក៏មានផែនការកសាងខ្សែបណ្តាញមួយ ដែលនឹងត្រូវតភ្ជាប់ជាមួយនឹងខ្សែបណ្តាញជាតិរបស់វៀតណាម ដើម្បីលក់ចរន្តអគ្គិសនី ៥០%

56 PECC1 Website, *Formation and development history*, http://www.pecc1.vn/History_269.aspx (accessed November 2011).
57 EVN, *Summary Report: Lower Sesan 2 hydropower project*, 23 January 2010. http://www.evni.vn/Home/News/tabid/54/TopicId/54/language/en-US/Default.aspx (accessed November 2011).
58 Phnom Penh Post, *Construction nears for Sesan 2*, 24 January 2011.
59 Phnom Penh Post, *Sesan dam to proceed this year*, 25 April 2011; see also, Vietnam Business News, *Investment to Cambodia from Vietnam Increases*, April 2011.

ទៀតដែលនៅសល់ទៅឲ្យប្រទេសវៀតណាម។[60] យោងតាមរបាយការណ៍មួយ ដែលបានចុះផ្សាយនៅលើគេហទំព័ររបស់អគ្គិសនីវៀតណាមបានឲ្យដឹងថា នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០០៨ ក្រុមហ៊ុនបានចុះអនុសារណៈយោគយល់មួយជាមួយនឹងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការសាងសង់ខ្សែបណ្ដាញកម្លាំង ២២០ គីឡូវ៉ាត់ តភ្ជាប់ពីទីតាំងទំនប់មកកាន់ទីប្រជុំជនខេត្តស្ទឹងត្រែង។ ខ្សែបណ្ដាញមួយនេះក៏នឹងត្រូវលាតសន្ធឹងពីទំនប់សេសាន២ ឆ្លងកាត់ខេត្តរតនគិរី និងបន្តទៅអនុស្ថានីយ៍របស់ទំនប់សេសាន ១/៥ នៅឯព្រំដែនកម្ពុជា-វៀតណាម។ ក្រោយមក នៅក្នុងឆ្នាំ ២០០៨ ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាម ក៏បានអនុម័តផែនការសាងសង់ខ្សែបណ្ដាញកម្លាំង ២២០គីឡូវ៉ាត់តភ្ជាប់ពីអនុស្ថានីយនេះទៅកាន់ខ្សែបណ្ដាញជាតិរបស់វៀតណាម។[61] ចំណុចនេះ នឹងត្រូវពិភាក្សាលម្អិតនៅក្នុងផ្នែក ២.៦ ស្ដីពីការអភិវឌ្ឍន៍ខ្សែបណ្ដាញចែកចាយ។

ចាប់ពីខែ កុម្ភៈ រហូតដល់ខែ មេសា ឆ្នាំ ២០០៨ ការពិគ្រោះយោបល់មួយត្រូវបានគេធ្វើឡើងនៅក្នុងតំបន់ក្បែរទីតាំងទំនប់ និងនៅក្នុងតំបន់អាងស្ដុកទឹករបស់ទំនប់។ ការពិគ្រោះយោបល់លើកទី២ ត្រូវបានធ្វើឡើងនៅក្នុងខែ ឧសភា ឆ្នាំ ២០០៨ ដោយបានពិគ្រោះយោបល់ជាមួយនឹងតំណាងសហគមន៍រងផលប៉ះពាល់ មន្ទីរពាក់ព័ន្ធថ្នាក់ខេត្ត អង្គការមិនមែនរដ្ឋាភិបាល ម្ចាស់ដីសម្បទានសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ សហគមន៍ភាគច្រើននៅប៉ែកខាងលើ និងប៉ែកខាងក្រោមទំនប់ មិនត្រូវបានគេពិគ្រោះយោបល់ទេនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៨ អគ្គិសនីវៀតណាមបានដាក់ជូនរបាយការណ៍បឋមស្ដីការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅឲ្យក្រសួងបរិស្ថានពិនិត្យ។ នៅក្នុងខែ កក្កដា ឆ្នាំ ២០០៩ ក្រសួងបរិស្ថានបានស្នើឲ្យអគ្គិសនីវៀតណាមធ្វើការសិក្សាបន្ថែមទៀត លើការធ្វើបំលាស់ទីរបស់ត្រី ហើយការសិក្សាបន្ថែមនេះ ត្រូវបានសិក្សារួចរាល់ និងដាក់ជូនរដ្ឋបាលជលផលពិនិត្យក្នុងខែ សីហា ឆ្នាំ ២០០៩។ រដ្ឋបាលជលផលក៏បានអនុម័តលើរបាយការណ៍នេះ បន្ទាប់មករបាយការណ៍នេះក៏ត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ នៅក្នុងខែ ឧសភា ឆ្នាំ ២០០៩ ក្រសួងបរិស្ថាន ក៏បានស្នើឲ្យមានការសិក្សាបន្ថែមទៀតលើលំហូរទឹកទន្លេ ដែលរបាយការណ៍នេះត្រូវបានបញ្ចប់ និងដាក់ជូនឲ្យគេពិនិត្យនៅក្នុងខែ តុលា ឆ្នាំដដែល។ បន្ទាប់មក របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានចុងក្រោយ ត្រូវបានគេដាក់ជូនទៅក្រសួងបរិស្ថាន និងត្រូវបានគេអនុម័តក្នុងខែ មិថុនា ឆ្នាំ ២០១០។[62]

---

60 Vietnam News Agency, *EVN unit speeds up work on Lao, Cambodian dams*, 8 July 2011.

61 EVN, *Summary Report: Investment Project of the Transmission Line Connecting Lower Sesan 1/Sesan 5 hydropower Projects into the Power Grid*, 23 January 2010. http://www.evni.vn/Home/News/tabid/54/TopicId/54/language/en-US/Default.aspx (accessed November 2011).

62 Letter from Prime Minister Samdech Hun Sen, *Letter N°31: Clarification to the request by HE Son Chhay, Phnom Penh Parliamentarian, for delay in the implementation of the Hydropower Project of Lower Sesan II of the Vietnamese Company EVN in joint venture with the Royal Group Company*, 28 July 2011.

មិនយូរប៉ុន្មាន មានសេចក្តីរាយការណ៍ថា នាយករដ្ឋមន្ត្រីវៀតណាម លោក ង្វៀន តាន់ដុង បានស្នើនាយករដ្ឋមន្ត្រីកម្ពុជា សម្តេច ហ៊ុន សែន ឲ្យពន្លឿនការអនុម័តលើគម្រោងនេះ។ ព័ត៌មាននេះ ត្រូវបានបញ្ជាក់ដោយរដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កញ្ញារិទ្ធិ។ លោកត្រូវបានដកស្រង់សម្តីនៅក្នុងកិច្ចប្រជុំរវាងនាយករដ្ឋមន្ត្រីទាំង២ នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១០ ថា "ប្រទេសវៀតណាមបានស្នើប្រទេសកម្ពុជាឲ្យជួយពន្លឿនគម្រោងនេះ ហើយសម្តេច ហ៊ុន សែន ក៏បានស្នើឲ្យរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លោក ស៊ុយ សែម ជម្រុញនូវដំណើរការនេះ"។[63] គម្រោងសាងសង់ទំនប់សេសានក្រោម២ ទទួលបានការអនុម័តចុងក្រោយ ក្នុងខែ មករា ឆ្នាំ ២០១១។

សារព័ត៌មានរបស់វៀតណាមបានរាយការណ៍ថា នៅថ្ងៃទី ២ មិថុនា ២០១១ មានការប្រជុំមួយធ្វើឡើងនៅទីក្រុងភ្នំពេញដោយមានការចូលរួមពីថ្នាក់ដឹកនាំខេត្ត និងថ្នាក់ដឹកនាំមូលដ្ឋាន។ ក្នុងនោះ តំណាងរបស់ក្រុមហ៊ុន EVNI បានធ្វើបទបង្ហាញពីផែនការផ្លាស់ប្តូរទីលំនៅ និងគោលការណ៍សំណង និងបានពិភាក្សាបង្កើតគណៈកម្មការផ្លាស់ប្តូរទីលំនៅ និងទូទាត់សំណង និងក្រុមការងារមួយ ដែលដឹកនាំដោយមន្ត្រីកម្ពុជា។ អគ្គនាយករងក្រុមហ៊ុន EVNI បានថ្លែងថាគាត់សង្ឃឹមថាគណៈកម្មការ និងក្រុមការងារមួយនេះនឹងចាប់អនុវត្តការងាររបស់ខ្លួនក្នុងខែ តុលា ឆ្នាំនេះ។[64] ក្រោយមក មានអ្នកពិគ្រោះយោបល់ម្នាក់បានប្រកាសប្រាប់គណៈកម្មការអន្តរក្រសួងស្តីពីការផ្លាស់ប្តូរទីលំនៅ នៅក្នុងសិក្ខាសាលាមួយ ដែលរៀបចំឡើងដោយសម្ព័ន្ធទន្លេកម្ពុជាថា ការផ្លាស់ប្តូរទីលំនៅគួរតែដោះស្រាយដោយអគ្គិសនីកម្ពុជា។ នៅពេលដែលមានសំណួរពាក់ព័ន្ធនឹងការផ្លាស់ប្តូរការទទួលខុសត្រូវនេះ អនុរដ្ឋលេខាធិការក្រសួងបរិស្ថានម្នាក់បានថ្លែងថា ផែនការផ្លាស់ប្តូរទីលំនៅនេះ ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់គណៈកម្មការអន្តរក្រសួងស្តីពីការផ្លាស់ប្តូរទីលំនៅ។ នៅពេលមានការចោទសួរទៅនាយកដ្ឋានផែនការ និងយុទ្ធសាស្ត្ររបស់អគ្គិសនីកម្ពុជា និងលោកអភិបាលស្រុកសេសាន ក្នុងខេត្តស្ទឹងត្រែង បានឲ្យដឹងថា ពួកគេមិនបានដឹងថា បច្ចុប្បន្ននេះ អគ្គិសនីកម្ពុជាទទួលខុសត្រូវដោះស្រាយការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជននោះទេ។[65]

បច្ចុប្បន្ននេះ គេនៅមិនទាន់ដឹងច្បាស់ពីដំណោះស្រាយផ្លូវច្បាប់ និងដំណើរការផ្លូវការណាមួយពាក់ព័ន្ធនឹងការទូទាត់សំណង និងការផ្លាស់ប្តូរទីលំនៅនេះនៅឡើយទេ។ ច្បាប់នៅក្នុងប្រទេសកម្ពុជាការពារដល់សិទ្ធិស្របច្បាប់លើកម្មសិទ្ធិដីធ្លីរបស់កម្មសិទ្ធិករ និងសហគមន៍ជនជាតិដើមភាគតិច ដូច្នេះការផ្លាស់ប្តូរទីលំនៅត្រូវធ្វើឡើងទៅតាមនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់នេះ។ ដើម្បីធានាដល់ការគោរពសិទ្ធិអ្នករងផលប៉ះពាល់ពីគម្រោង វាជាការសំខាន់ណាស់ដំណោះស្រាយផ្លូវច្បាប់ សម្រាប់ការដក

63 Cambodia Daily, *VN Premiere Asks for Quick Dam Approval*, November 16, 2010.
64 Vietnam News Agency, *EVN boosts hydroelectric power in Cambodia*, 3 June 2011.
65 The Cambodia Daily, *Sesan resettlement in hands of power utility*, 1 June 2011.

ហូត និងការផ្លាស់ប្តូរទីលំនៅ ត្រូវធ្វើឡើងដោយមានភាពច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋាន ហើយផែនការសំណង និងការតាំងទីលំនៅថ្មី ត្រូវធ្វើឡើងដោយសាធារណៈ។

**លទ្ធភាពសេដ្ឋកិច្ច និងប្រសិទ្ធិភាពរបស់ទំនប់វារីអគ្គិសនីសេសានក្រោម២**

សហគមន៍រងផលប៉ះពាល់ និងសង្គមស៊ីវិលបានលើកឡើងក្តីបារម្ភដ៏ខ្លាំង ដែលថាទំនប់សេសានក្រោម២ នឹងផលប៉ះពាល់អវិជ្ជមានដល់សហគមន៍ និងបរិស្ថាន។ ក្រៅពីដែលនឹងកើតមាននាពេលខាងមុខទាំងនេះទៅ អ្នកឃ្លាំមើលមួយចំនួនបានចោទជាសំណួរអំពីការប្រើប្រាស់ និងលទ្ធភាពសេដ្ឋកិច្ចរបស់គម្រោងទំនប់វារីអគ្គិសនីមួយនេះ។ បើនិយាយពីការប្រើប្រាស់ ទំនប់វារីអគ្គិសនីសេសានក្រោម២ ស្ថិតនៅក្នុងដៃទន្លេមួយដែលមានទំនប់វារីអគ្គិសនីយ៉ាងច្រើននៅប៉ែកខាងលើ។ ដូចដែលបានពិភាក្សានៅក្នុងផ្នែក ១.២ ទំនប់ជាច្រើននៅផ្នែកខាងលើក្នុងប្រទេសវៀតណាមកំពុងជួបនូវការលំបាកក្នុងការផលិតចរន្តអគ្គិសនីសម្រាប់បំពេញតម្រូវការក្នុងស្រុក ដោយសារតែការរាំងស្ងួតដែលបង្កឡើងដោយសារការគ្រប់គ្រងមិនបានល្អទៅលើប្រតិបត្តិការរបស់ទំនប់នៅផ្នែកខាងលើ និងដោយសារតែកត្តាអាកាសធាតុដែលមិនអាចព្យាករណ៍បាន។ ជាក់ស្តែង ទំនប់វារីអគ្គិសនីកន្ទុំលើ ដែលបច្ចុប្បន្ននេះកំពុងត្រូវបានសាងសង់ នៅចំណុចព្រំដែនប្រទេសវៀតណាម ត្រង់ក្បាលទន្លេសេសាន និងកំពុងត្រូវបានគេបង្វែរទឹកចេញពីទន្លេនេះ។[66] សំណង់មួយនេះ ត្រូវបានគេរាយការណ៍ថាបានធ្វើឲ្យលំហូរទឹកទន្លេនៅផ្នែកខាងក្រោមថយចុះ និងធ្វើឲ្យប៉ះពាល់ដល់គម្រោងវារីអគ្គិសនីផ្សេងទៀតរបស់អគ្គិសនីវៀតណាម ក្នុងប្រទេសវៀតណាម។

នៅមានសំណួរជាច្រើនទៀត ត្រូវបានគេលើកឡើងពាក់ព័ន្ធនឹងតម្លៃរបស់គម្រោងវារីអគ្គីសនីសេសានក្រោម២នេះ។ ការព្យាករណ៍លើការចំណាយរបស់គម្រោងមួយនេះ មានតម្លៃលើសពី ៨០០ លានដុល្លា និងមានអានុភាព ៤០០ ម៉េហ្គាវ៉ាត់ ថែមទាំងធ្លាក់មកនៅត្រឹម ១០០ ម៉េហ្គាវ៉ាត់ ក្នុងរដូវប្រាំង។[67] ទន្ទឹមនឹងនេះ មានករណីសិក្សាមួយដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី ធ្វើឡើងក្នុងឆ្នាំ ១៩៩៩ បានរកឃើញថា ទំនប់វារីអគ្គិសនីសេសានក្រោម២ ដែលគ្រោងឡើងនេះ មិនមានភាពទាក់ទាញផ្នែកហិរញ្ញវត្ថុទេ ហើយផ្តល់ផលចំណេញមកវិញតិចតួចតែប៉ុណ្ណោះ។ នៅក្នុងការសិក្សាមួយទៀតដែលមានទ្រង់ទ្រាយធំជាងមុន ធានាគារអភិវឌ្ឍន៍អាស៊ីបានជួលអ្នកពិគ្រោះយោបល់ ១ក្រុម ឲ្យសិក្សាលើទំនប់វារីអគ្គិសនីចំនួន ២ គឺទំនប់សេសានក្រោម២ និងស្រែពកក្រោម២។ ទំនប់ស្រែពកក្រោម២ ស្ថិតនៅចម្ងាយប្រហែល ២គីឡូម៉ែត្រ ខាងលើចំណុចប្រសព្វទន្លេទាំង២ ហើយទំនប់សេសានក្រោម២ មានចម្ងាយ ៥ គីឡូម៉ែត្រ ខាងលើចំណុចប្រសព្វទន្លេទាំង២ ដោយទំនប់ទាំង២នេះអានុភាពត្រឹមតែ ២០០ ម៉េហ្គាវ៉ាត់ប៉ុណ្ណោះ។ ប៉ុន្តែក្រោយមក គម្រោងទាំង២ នេះត្រូវបានដូរមកជាគម្រោងតែ ១ វិញ

66 International Rivers, *International Rivers Comments on the Thuong Kon Tum Hydropower Project (Vietnam) to Project Validator, TÜV NORD CERT GmbH (Former RWTÜV Systems GmbH)*, 2 June 2011.
67 NGO Forum Cambodia, *Lower Sesan 2 Hydro Project EIA Review*, August 2009 (p2).

ដោយមានចម្ងាយ ១.៥ គីឡូម៉ែត្រនៅខាងលើចំណុចប្រសព្វ។ ទោះបីជាទីតាំងទំនប់នេះខុសពីទីតាំងមុនបន្តិចក៏ដោយ ក្ដីបារម្ភដែលបានលើកឡើងក្នុងឆ្នាំ ១៩៩៩ គឺដូចគ្នាទៅនឹងក្ដីបារម្ភដែលបានលើកឡើងនាពេលបច្ចុប្បន្ននេះ ជាពិសេស ពាក់ព័ន្ធទៅនឹងផលប៉ះពាល់នៃអាងស្ដុកទឹកដ៏ធំរបស់ទំនប់នេះ ព្រមទាំងផលប៉ះពាល់ទៅលើការផ្លាស់ទីលំនៅ និងទៅលើជលផល។[68]

នៅក្នុងឆ្នាំ ២០០៨ ធនាគារអភិវឌ្ឍន៍អាស៊ីបានសិក្សាពីការអភិវឌ្ឍន៍អាងទន្លេសេសាន ស្រែពក និងសេកុង[69] ដែលបានពិនិត្យមើលទិដ្ឋភាពផ្សេងៗ នៃការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅក្នុងតំបន់ទន្លេបីនេះ។ ឯកសារបច្ចេកទេសមួយដែលបង្កើតឡើងដោយការសិក្សានេះ បានធ្វើការប្រៀបធៀបគម្រោង វារីអគ្គិសនីផ្សេងៗគ្នានៅក្នុងតំបន់ទន្លេបី និងឲ្យចំណាត់ថ្នាក់គម្រោងទាំងនោះទៅតាមលក្ខណៈវិនិច្ឆ័យ ខុសៗគ្នា។ លក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងអស់ គឺការប៉ាន់ប្រមាណពីចំនួន ម៉េហ្គាវ៉ាត់ដែលអាចផលិតបានក្នុង ១គីឡូម៉ែត្រក្រឡានៃអាងស្ដុកទឹក។ ការប៉ាន់ប្រមាណ នឹងអាចត្រូវបានប្រើប្រាស់បង្ហាញពីការថ្លឹងថ្លែងរវាងបរិមាណថាមពល ដែលបានផលិតជាមួយនឹងបម្រែបម្រួលនៃការប្រើប្រាស់ដី។ ប្រសិនបើចំនួនម៉េហ្គាវ៉ាត់ដែលផលិតបានក្នុង ១គីឡូម៉ែត្រក្រឡានៃអាងស្ដុកទឹកកាន់តែច្រើន នោះមានន័យថាប្រសិទ្ធិភាពរបស់ទំនប់នោះក៏កាន់តែខ្ពស់។ ប្រសិនបើគម្រោងនេះអាចផលិតបាន ១០ ម៉េហ្គាវ៉ាត់ ក្នុង ១គីឡូម៉ែត្រក្រឡានៃអាងស្ដុកទឹក គេចាត់ទុកថាគម្រោងនោះជាគម្រោងល្អ ប្រសិនបើគម្រោងនេះអាចផលិតបានពី ៥ ដល់ ១០ ម៉េហ្គាវ៉ាត់ ក្នុង ១គីឡូម៉ែត្រក្រឡានៃអាងស្ដុកទឹក គេចាត់ទុកថាគម្រោងនោះជាគម្រោងមធ្យម ហើយប្រសិនបើគម្រោងនេះអាចផលិតបានតិចជាង ៥ ម៉េហ្គាវ៉ាត់ក្នុង១គីឡូម៉ែត្រក្រឡានៃអាងស្ដុកទឹក គម្រោងនោះត្រូវវាយតម្លៃឡើងវិញឲ្យបានម៉ត់ចត់។ សម្រាប់គម្រោងសេសានក្រោម២ អាចផលិតបានថាមពលត្រឹមតែ ១.១ ម៉េហ្គាវ៉ាត់ក្នុង ១ គីឡូម៉ែត្រក្រឡានៃអាងស្ដុកទឹកប៉ុណ្ណោះ។ ឯកសារនេះក៏បានផ្ដល់ចំណាត់ថ្នាក់ដល់គម្រោងវារីអគ្គិសនី ៤ ផ្សេងទៀត ដែលនឹងត្រូវលើកយកមកពិភាក្សានៅពេលក្រោយក្នុងរបាយការណ៍នេះ រួមមាន ៖ ទំនប់សេសានក្រោម៣ (០.៤ ម៉េហ្គាវ៉ាត់/១គីឡូម៉ែត្រក្រឡា) ទំនប់ស្រែពកក្រោម៣ និងស្រែពកក្រោម៤ (០.៣ ម៉េហ្គាវ៉ាត់/១គីឡូម៉ែត្រក្រឡា)។[70] ការទទួលបានចំណាត់ថ្នាក់ទាបរបស់គម្រោងទាំងនេះ បានបង្កើតឲ្យ មានបញ្ហាចោទពាក់ព័ន្ធនឹងប្រសិទ្ធិភាពរបស់វា។ លើសពីនេះទៅទៀត តួលេខទាំងនេះ ក៏បានចោទជាបញ្ហាដល់ភាពស្រស់បំព្រងរបស់គម្រោងផងដែរ។ គេបានដឹងថា អាងស្ដុកទឹកធំៗនៅតំបន់ត្រូពិច នឹងនាំមកនូវការប្រែប្រួលអាកាសធាតុ ដោយសារតែកម្ទេចកម្ទីស្អុយរលួយនៅក្នុងតំបន់ទាំងនោះ។ ការទទួល

68 Asian Development Bank, *Se Kong - Se San and Nam Theun Basins Hydropower Study Final Report*, 1999.

69 Asian Development Bank, *TA6367 Sesan, Sre Pok, and Sekong River Basins Development Study in Kingdom of Cambodia, Lao People's Democratic Republic, and Socialist Republic of Vietnam*. Project Information Document: http://pid.adb.org/pid/TaView.htm?projNo=40082&seqNo=01&typeCd=2 (accessed November 2011).

70 ADB-RETA 40082, *3S Technical Sheets Key Topic 8 – Large scale infrastructure development in the 3Ss, 8a Hydropower Development*. http://reta.3sbasin.org/index.php?option=com_docman&Itemid=184&lang=en (accessed November 2011).

បានពិន្ទុទាប ក៏បានបង្ហាញឲ្យឃើញផងដែរថា ថាមពលដែលផលិតបាន មិនអាចលប់បំបាត់គុណវិបត្តិនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ឡើយ។



រូបភាព Oxfam-Brett Eloff: បុរសម្នាក់បានយកជ័រទឹកពីដើមឈ្មោះជ័រទៅបិទទូកនៅភូមិក្បាល

## សក្តានុពលនៃផលប៉ះពាល់

ការសិក្សាជាច្រើន រួមទាំងការធ្វើ EIA (ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន) ដោយ KCC បានបង្ហាញពីចំនុចសំខាន់ៗជាច្រើន ហើយនិងផលប៉ះពាល់យ៉ាងទូលំទូលាយដល់បរិស្ថាន និងសង្គម ប្រសិនបើគំរោងទំនប់វារីអគ្គិសនីសេសានក្រោម២ នៅតែបន្តរទៅមុខតាមដូចអ្វីដែលបានស្នើ។ ទំនប់នេះ នឹងមានអាងស្តុកទឹកទំហំជាង៣៤០km$^2$ ហើយបើតាមរបាយការណ៍សិក្សា EIA ឆ្នាំ២០០៨ ដែលបានរៀបចំដោយ KCC អាងស្តុកទឹកនេះ នឹងធ្វើឲ្យប្រជាពលរដ្ឋចំនួន ៤,៧៨៥ នាក់ ត្រូវផ្លាស់ទីលំនៅ (១,០៥៩ ខ្នងផ្ទះ) ប្រជាពលរដ្ឋទាំងនោះមកពី៧ភូមិ ត្រូវជា៤ឃុំ។ ទីតាំងចំនួន៦កន្លែង ត្រូវបានស្នើសុំសំរាប់ប្រជាពលរដ្ឋដែលបានផ្លាស់ប្តូរទីលំនៅដោយសារអាងស្តុកទឹក និងការសាងសង់ ទោះបីជាយ៉ាងណាក៏ដោយ របាយការណ៍ EIA បានបញ្ជាក់ថា មានតំបន់តាំងទីលំនៅថ្មីជាច្រើន ដែលបានស្នើសុំនោះ វាត្រូវបានអនុញ្ញាតិរួចហើយឲ្យទៅជាតំបន់ដីព្រៃសម្បទាន ដែលនឹងអាចទៅជាប្រធានបទមួយដើម្បី ពិចារណាពីការរំខានក្នុងពេលបច្ចុប្បន្ន និងអនាគត់[71]។ របាយការនោះបន្ថែមថា តំបន់ដែលបានស្នើសុំទាំងអស់សំរាប់ការតាំងទីលំនៅថ្មីជាង ៤,០០០ហិកតា គឺស្ថិតនៅព្រំប្រទល់នៃព្រៃសម្បទាន និងដីបំរុង[72]។ ផ្ទៃអាងទឹក នឹងលិចដីកសិកម្មជាង១,២០០ហិកតា ដែលវាត្រូវនឹង២៤%នៃផ្ទៃដីកសិកម្ម

71 PECC1 & KCC, *Environmental Impact Assessment for Feasibility Study of Lower Sesan 2*
72 KCC, *Key Facts Sesan II for NGO meeting*, June 27, 2008.

ក្នុងស្រុកសេសាន ហើយវានឹងត្រូវបានជំនួសដោយដីនៅក្នុងតំបន់តាំងទីលំនៅថ្មី ដែលត្រូវបានទទួលស្គាល់ថាវានឹងតំរូវឲ្យមានការកាប់សំអាតព្រៃឈើ[73]។

បន្ថែមទៅលើផលប៉ះពាល់ចំពោះដីលំនៅឋាន និងដីកសិកម្ម អាងស្តុកទឹក នឹងបំផ្លាញដីព្រៃច្រើនជាង៣ម៉ឺនហិកតា បូករួមទាំងដីព្រៃសម្បទានឯកជនជាង១ម៉ឺនហិកតា[74]។ បន្ថែមទៅលើតំបន់សម្បទានផ្សេងៗ ដែលអាចមានផលប៉ះពាល់ ដោយយោងទៅលើរបាយការណ៍ដែលបានដាក់បញ្ចូលក្នុងគេហទំព័ EVNI ក្នុងចំនោមផ្ទៃដីចំនួន ១៧,៨០០ ហិកតានៃដីព្រៃរដ្ឋ គឺស្ថិតនៅក្នុងតំបន់គំរោង[75]។ ក៏ដូច្នេះដែរ គំរោងទំនប់វារីអគ្គិសនីនេះ មិនបានប៉ះពាល់ផ្ទាល់ទៅដល់តំបន់ព្រៃការពារនានា ឬដែនជំរកសត្វព្រៃ តែវានឹងជៀសមិនរួចក្នុងការប៉ះពាល់ទៅលើជីវចំរុះក្នុងតំបន់។ EIA ទទួលស្គាល់ថាមានការបាត់បង់ទីជំរកនៃពពួកសត្វគ្រប់ប្រភេទ ហើយនិងរុក្ខជាតិផ្សេងៗដោយសារទឹកជន់លិច ហើយនិងតាមរយៈការផ្លាស់ប្តូរ ក្នុងការប្រើប្រាស់ដីធ្លី ដោយសាការតាំទីលំនៅថ្មីនៃប្រជាពលរដ្ឋ និងការកសាងផ្លូវ។

ការផ្លាស់ប្តូរជលវិទ្យានៃទន្លេ នឹងអាចប៉ះពាល់ដល់ពូជត្រី និងគុណភាពទឹក។ KCC បានប៉ាន់ប្រមាណថា៦៦%នៃប្រភេទត្រីទន្លេ បានផ្លាស់ទីឡើងចុះត្រង់ទីតាំងនៃទំនប់ ហើយបន្ទាប់ពីទំនប់សាងសង់រួច ការផ្លាស់ទីរបស់ត្រីជាច្រើនប្រភេទ នឹងត្រូវកាត់ផ្តាច់ពីផ្នែកខាងក្រោមនៃទំនប់[76]។ EIA ទទួលស្គាល់ថា*ផលប៉ះពាល់សេដ្ឋកិច្ចសង្គម ដែលបានមកពីការបាត់បង់ត្រី នឹងអាចជាលទ្ធផលតែមួយធំបំផុតដោយសារទំនប់*[77]។ ផលប៉ះពាល់លើវិស័យជលផល នឹងអាចជាការព្រួយបារម្ភរបស់សហគមន៍កំពុងរស់នៅផ្នែកខាងលើតាមដងទន្លេសេសាន ស្រែពក ដែលពួកគាត់ពឹងផ្អែកលើការនេសាទត្រីសំរាប់ចិញ្ចឹមជីវិត។ KCC ប៉ាន់ប្រមាណថា មានប្រជាពលរដ្ឋ ៤ម៉ឺននាក់ ដែលរស់នៅផ្នែកខាងលើ ពឹងផ្អែកទាំងស្រុងលើធនធានជលផល[78]។ របាយការណ៍ EIA បង្ហាញថា មានប្រភេទត្រីជាច្រើនត្រូវបានកត់សំគាល់ឃើញថា ធ្វើការផ្លាស់ទីពីបឹងទន្លេសាប និងទន្លេមេគង្គ ចូលទៅទន្លេសេសាន ស្រែពក ហើយជាប្រភេទត្រី ដែលធ្លាប់បានផ្លាស់ទីឆ្ងាយៗក្នុងដីសណ្តរទន្លេមេគង្គ[79]។ ការលើកឡើងនេះ ជាលទ្ធផលមួយដែលរកឃើញថា ផលប៉ះពាល់លើវិស័យជលផល នឹងអាចជាការព្រួយបារម្ភក្នុងប្រទេសទាំងមូល និងសូម្បីតែប្រទេសជិតខាង គឺមិនត្រឹមតែរបស់ប្រជាពលរដ្ឋដែលរស់នៅផ្នែកខាងលើនៃទំនប់ប៉ុណ្ណោះទេ។ របាយការណ៍ EIA មាននិយាយតិចតួចបំផុតចំពោះផលប៉ះពាល់ផ្នែកជលផលនៅផ្នែកខាងក្រោមនៃទំនប់ ដូច្នេះហើយ តំលៃនៃផលប៉ះពាល់សំរាប់សហគមន៍នៅផ្នែកខាងក្រោម មិនត្រូវបានធ្វើការប៉ាន់ស្មាន ហើយគ្មានកញ្ចប់ថវិកាសំណងសំរាប់សហគមន៍នៅផ្នែកខាងក្រោមដែលរងគ្រោះ ដោយសារទិន្នផលនេសាទរបស់ពួកគាត់មានការថយចុះ។

73 PECC1 & KCC, *Environmental Impact Assessment for LS2*, October 2008 (pS-5).
74 *Ibid*.
75 EVN, *Summary Report, Lower Sesan 2 hydropower project*, 23 January 2010.
76 PECC1 & KCC, Environmental Impact Assessment for LS2, October 2008 (pS-4).
77 Ibid. (pS-4)
78 Ibid. (pS-5)
79 Ibid. (pS-4)




រូបភាព ប៉ុស្តិ៍ជលសាស្រ្តរបស់ទំនប់សេសានក្រោម២ក្បែរទីតាំងទំនប់

មានការសិក្សាឯករាជ្យជាច្រើន ត្រូវបានធ្វើលើផ្នែកជលផលតាមដងទន្លេសេសាន ស្រែពកក្នុងប្រទេសកម្ពុជា ដែលបានរកឃើញថា មានចំនួនត្រីពូជជាច្រើនធ្វើការផ្លាស់ទីតាមដងទន្លេទាំងនេះទៅកាន់ទន្លេមេគង្គ។ ករណីសិក្សាមួយបានបង្ហាញថា នៅក្នុងរដូវក្តៅ យ៉ាងហោចណាស់មានត្រី៣២ប្រភេទធ្វើការផ្លាស់ទីពីបឹងទន្លេសាបផ្នែកកណ្តាលនៃប្រទេសកម្ពុជា ឡើងទៅទន្លេមេគង្គ ហើយបន្តទៅទន្លេសេសាន និងស្រែពក[80]។ លោក Baird បញ្ជាក់ថា ក្នុងចំនោមប្រភេទត្រីទាំងនោះ នឹងមានការរាំងស្ទះក្នុងការធ្វើចរាចរផ្លាស់ទី ដែលពួកវាជាប្រពន្ធ័អេកូឡូស៊ីដ៏ចំបងនៃទន្លេទាំងនេះ ហើយពួកវាក៏ជាវារីជាតិដ៏សំខាន់សំរាប់អ្នកបរិភោគ ហើយពួកវាក៏ជាធនធានចំណី អាហារដ៏សំខាន់សំរាប់ប្រភេទត្រីជាច្រើនដែលស៊ីសាច់ជាអាហារ។ ទោះបីជាយ៉ាណាក៏ដោយ ការបាត់បង់ត្រីទាំងនេះវាក៏អាចធ្វើឲ្យថយចុះនូវចំនួនត្រីផ្សេងៗ ហើយនិងប្រភេទសត្វព្រៃមួយចំនួនផងដែរ[81]។ ការសិក្សាមួយទៀត ដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានជាតិនៃវិទ្យាសាស្រ្តសង្គម ក្នុងឆ្នាំ២០១២ គេប៉ាន់ប្រមាណថា ការសាងសង់ទំនប់នេះ ដែលបានស្នើឡើងនៅក្នុងអាងទន្លេមេគង្គ ផ្នែកខាងក្រោមគឺជាគំរោងដ៏ការអាក្រក់តែមួយ គត់ចពោះជីវិតត្រីគ្រប់ប្រភេទ។ ការសិក្សាទាំងនោះ បានរកឃើញថា ទំនប់សេសានក្រោម២ អាចជា មូលហេតុនៃការធ្លាក់ចុះ៩.៣%នៃអំបូរត្រីទាំងអស់ ហើយអាចធ្វើឲ្យមានការគំរាមគំហែង និងបង្កគ្រោះ ថ្នាក់

---

80 Baird, I.G., M.S. Flaherty & B. Phylavanh 2003. *Rhythms of the river: Lunar phases and migrations of small carps (Cyprinidae) in the Mekong River*. Natural History Bulletin of the Siam Society 51(1):5-36.
81 *See Baird, Ian G. 2009 Best practices in Compensation and Resettlement for Large Dams: The Case of the Planned Lower Sesan Dam 2 Hydropower Project in Northeast Cambodia. Rivers Coalition in Cambodia, Phnom Penh (p39).*

ទៅដល់ពូជត្រីប្រហែល៥៦ប្រភេទផ្សេងទៀត[82]។ ការផ្លាស់ប្តូរគុណភាពទឹកនៅផ្នែកខាងក្រោមនៃទំនប់ និងលំហូរទឹកមិនទៀងទាត់ អាចផ្តល់ផលអវិជ្ជមានដល់ពពួកត្រីទាំងឡាយ ទាំងប្រភេទត្រីដែលចរាចរ ផ្លាស់ទី និងមិនផ្លាស់ទី។ ការបើកទឹកហូរដោយគំហ៊ុក វាអាចជាមូលហេតុធ្វើឲ្យសឹក រិចរិលច្រាំងទន្លេ ហើយនិងប៉ះពាល់អន្លង់ជ្រៅៗ ដែលជាជំរករបស់ត្រីអំឡុងពេលរដូវទឹកស្រកនៃខែប្រាំង[83]។

ផែនការសកម្មភាពបរិស្ថាន ដែលបានរៀបចំដោយអ្នកអភិវឌ្ឍន៍ បានដាក់ចេញនូវសំណង សំរាប់ប្រជាពលរដ្ឋដែលបាត់បង់ដីធ្លី ផ្ទះ និងធនធានជលផល ហើយបន្ថែមលើការផ្តល់ដីសំរាប់ការ សាងសង់លំនៅឋានឡើងវិញ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ ត្រូវទទួលបានសំណងចំពោះការបាត់ បង់ទ្រព្យសម្បត្តិផ្សេងៗទៀត មានដូចជា៖ ស្រែចំការ ដើមឈើ សួនច្បារ ផ្ទះ ហើយនិងបាត់បង់ធន ធានជលផល។ ថ្វីបើខ្វះការពិចារណា និងថវិកា សំរាប់ផលប៉ះពាល់អ្នកនៅផ្នែកខាងក្រោមនៃទំនប់ ក៏ដោយរបាយការណ៍បឋមរបស់ EIA បានប៉ាន់ប្រមាណនូវតំលៃនៃការសម្រាលទៅដល់គំរោងប៉ះ ពាល់អវិជ្ជមានក្នុងតំលៃ១២៧លានដុល្លាសហរដ្ឋអាមេរិក[84]។ ទោះបីជាតួរលេខនេះ បញ្ជាក់ច្បាស់ ក៏ដោយក៏នៅតែមានការព្រួយបារម្ភជាច្រើន ទាក់ទងទៅនិងផលប៉ះពាល់លើវិស័យជលផល ពីព្រោះវា ត្រូវទទួលស្គាល់យ៉ាងទូលំទូលាយថា គ្មានចំនួនទឹកលុយណាមួយ អាចមកសម្រួលទៅនឹងការបង្ខាំង ត្រីមិនឲ្យធ្វើចរាចរនោះទេ។ ផែនការគ្រប់គ្រងបរិស្ថាន ដែលមានជាភាសារអង់គ្លេស ត្រូវបានបង្ហាញ ចេញក្នុងឆ្នាំ២០០៨ ប៉ុន្តែត្រូវបានរិះគន់ចំពោះការមិនបានរៀបរាប់លំអិតអំពីថវិកាជាក់លាក់ ដែលត្រូវ ទូទាត់សំណង និងសកម្មភាពបន្ធូរបន្ថយផ្សេងៗទៀត និងមិនមានចែងច្បាស់ពីតួនាទី និងការទទួល ខុសក្នុងការត្រួតពិនិត្យ និងការប្រតិបត្តិ[85]។

---

82 *Ziv, G., Baran, E., Nam, S., Rodriguez-Iturbe, I. & Levin, S. A., Trading-off fish biodiversity, food security, and hydropower in the Mekong River Basin, Proceedings of National Academy of Sciences. USA, 2012. http://www.pnas.org/cgi/doi/10.1073/pnas.1201423109 (accessed March 2012).*
83 *Baird, Ian G. 2009 (p54-55).*
84 NGO Forum, *Lower Sesan 2 Hydro Project EIA Review*, August 2009 (p7).
85 Rivers Coalition of Cambodia, Comments on Chapter VIII Environment Management Plan of the Lower Sesan 2 Draft Environmental Impact Assessment by Key Consultants Cambodia, 22 July 2008. See also: Baird, Ian G. (p29-38).



រូបភាព Oxfam-Brett Eloff: ការនេសាទត្រីតាមដងទន្លេសេសាន

ក្នុងខែមិថុនា ២០១១ អ្នកតាក់តែងច្បាប់របស់គណបក្សប្រឆាំង បានសរសេរលិខិតមួយទៅនាយករដ្ឋមន្ត្រីកម្ពុជា ដោយបានលើកឡើងពីការព្រួយបារម្ភ ដែលទាក់ទងទៅនិងគំរោងសាងសង់ទំនប់វារីអគ្គិសនី ហើយនិងសួររកសុំសេចក្តីបញ្ជាក់ពីយន្តការបន្ធូរបន្ថយ ដែលនិងត្រូវដាក់ចូលទៅក្នុងផលប៉ះពាល់អវិជ្ជមានរបស់ទំនប់។នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានឆ្លើយតបមកវិញក្នុង ខែកក្កដា ២០១១ ហើយភ្លាមៗនោះ លិខិតនៃការឆ្លើយរបស់នាយករដ្ឋមន្ត្រីត្រូវបានផ្សព្វផ្សាយជាសាធារណៈ[86]។ ក្នុងលិខិតនោះបានបញ្ជាក់ថា ទំនប់នេះវានឹងលិចផ្ទៃដីចំនួន ៣៤,៣០៧ ហិកតា និងប៉ះពាល់ដល់ប្រជាពលរដ្ឋចំនួន ៤,៦២០នាក់ (គឺតិចជាងចំនួនដែលមាននៅក្នុង EIA ២០០៨)។ តំបន់តាំងទីលំនៅថ្មី ត្រូវបានរៀបចំ និងផ្តល់ដោយមានការផ្គត់ផ្គង់អគ្គិសនី ហើយនិងលើកកំពស់ជីវភាពរស់នៅ ប្រៀបធៀបនិងតំបន់ដែលពួកគាត់រស់ពីមុន។ ប្រភេទដីដែលត្រូវលិចទឹកដោយសាគំរោងមានដូចជា៖

- ដីលំនៅឋានចំនួន ៨៣ ហិកតា
- ដីកសិកម្មចំនួន ៩១០ ហិកតា
- ដីវាលចំនួន ៣០៧ ហិកតា
- ដីព្រៃរបស់រដ្ឋចំនួន ១៧,៨០៦ ហិកតា
- ដីដែលសំរាប់ផ្តល់ឲ្យសម្បទានឯកជនចំនួន ១០,៥៦៤ ហិកតា

86 Letter from Prime Minister Samdech Hun Sen, 28 July 2011.

❖ ដីព្រៃបឹង ទន្លេ ចំនួន ៤,៦៣៨ ហិកតា

លិខិតនោះបញ្ជាក់ថា សំណើរនេះត្រូវបានធ្វើដើម្បីឲ្យក្រុមហ៊ុនកក់ប្រាក់ចំនួន ៨.២៧ភាគរយ នៃតំលៃសរុបរបស់គំរោង សំរាប់ការចំណាយជាមួយផលប៉ះពាល់ដោយសាគំរោង ក្នុងនោះតំលៃសរុបរបស់គំរោងមានចំនួន ៨១៦លានដុល្លាសហរដ្ឋអាមេរិក ដូច្នេះ ៨.២៧ភាគរយ វាត្រូវនិង ៦៧.៥ លានដុល្លាសហរដ្ឋអាមេរិក។ គួរកត់សំគាល់ថា តួរលេខនេះ គឺប្រហែលជាពាក់កណ្តាលនៃថវិកា ដែល បានប៉ាន់ប្រមាណក្នុងរបាយការណ៍ EIA ២០០៨ (១២៧លានដុល្លាសហរដ្ឋអាមេរិក) ហើយដែលសមល្មមសំរាប់បន្ធូបន្ថយដល់ផលប៉ះពាល់របស់គំរោង។ លើសពីនេះទៀត ក្រុមហ៊ុននឹងវិនិយោគនូវទឹក ប្រាក់ប្រហែល ១៤.៥ លានដុល្លាសហរដ្ឋអាមេរិក ដើម្បីសំអាតដីក្នុងអាងស្តុកទឹក មុនពេលត្រូវបានបង្ហូរទឹកចូល ដើម្បីកាត់បន្ថយផលប៉ះពាល់លើគុណភាពទឹក។ លិខិតរបស់នាយករដ្ឋមន្ត្រី ក៏បានស្តែងចេញផងដែរជាមួយការព្រួយបារម្ភ ទាក់ទងនិងផលប៉ះពាល់លើវិស័យជលផល។ ក្នុងលិខិតនោះ បាន បញ្ជាក់ថា ដោយយោងទៅលើការសិក្សាជាច្រើនដែលបានធ្វើកន្លងមក ទន្លេសេសាន និងស្រែពក មិន មែនជាប្រភពសំរាប់ត្រីពង ឬជាប្រភពត្រីសំរាប់ប្រទេសទាំងមូលនោះទេ ហើយផលប៉ះពាល់ នឹងប៉ះ ពាល់តែចំពោះពពួកត្រីដែលរស់នៅក្នុងទន្លេទាំងពីរតែប៉ុណ្ណោះ។ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ទាំង នោះ ត្រូវមានផែការរៀបចំជាមជ្ឈមណ្ឌលស្រាវជ្រាវភ្ញាស់កូនត្រី ចញ្ចឹមត្រី ដើម្បីលែងកូនត្រីចូលទៅ ក្នុងអាងស្តុកទឹក និងផ្នែកខាងក្រោមនៃទំនប់វិញ។

ទាំងនេះ ជាការញែកចេញពីគ្នាយ៉ាងសំខាន់រវាងការអះអាងរបស់រាជរដ្ឋាភិបាល ដែលថាវិស័យជលផល នឹងមិនរងផលប៉ះពាល់ បើទោះបីជាទន្លេទាំងពីរទទួលរងផលប៉ះពាល់ ហើយមានការសិក្សាជាច្រើនបានធ្វើឡើងអំពីបញ្ហាទាំងនេះក៏ដោយ។ ក្នុងឆ្នាំ១៩៩៩ ធនាគារអភិវឌ្ឍន៍អាស៊ី បានធ្វើការសិក្សា លំអិតជាលើកដំបូងអំពីទំនប់ត្រង់ចំនុចប្រសព្វរបស់ទន្លេសេសាន ស្រែពក ហើយបានរកឃើញថា ទន្លេទាំងពីរនេះ ជាផ្លូវដ៏សំខាន់សំរាប់ត្រីធ្វើចរាចរចូលទៅក្នុងអាងទន្លេសេសានផ្នែកខាងលើ និងទន្លេមេគង្គ។ ហេតុដូចនេះ ទំនប់នឹងធ្វើឲ្យស្ទះផ្លូវធ្វើចរាចរដ៏សំខាន់ ហើយនឹងអាចមានផលប៉ះពាល់មិនល្អទៅដល់វិស័យជលផលនាផ្នែកខាងក្រោម និងផ្នែកកណ្តាលនៃអាង[87]។ ដូចដែលបានកត់សំគាល់នៅខាងលើ របាយការណ៍របស់គំរោងដែលមានក្នុង EIA ២០០៨ ក៏បានកត់សំគាល់ផងដែរថា ផលប៉ះពាល់ដល់ចរាចរត្រីពីទន្លេមេគង្គ និងបឹងទន្លេសាប មានដូចគ្នានឹងករណីសិក្សាអំពីជលផល ដែលត្រូវធ្វើដោយរដ្ឋបាលជលផលកម្ពុជា ហើយបានភ្ជាប់ទៅនិងរបាយការណ៍ EIA។ ការសិក្សានេះ បានបង្ហាញថា ផលប៉ះពាល់មួយដែលអាចកើតមានដោយសាទំនប់នោះ គឺប៉ះពាល់ធនធានជលផល បឹងទន្លេសាប ជាទូទៅលើផ្លូវចរាចររបស់ពពួកត្រីគ្រប់ប្រភេទ ដែលពពួកត្រីទាំងនោះរកចំណីអាហារ និងរីកធំលូតលាស់នៅតាមដងទន្លេមេគង្គភាគខាងក្រោម និងបឹងទន្លេសាប ហើយបម្លាស់ទីទៅផ្នែកខាងលើ

87 Asian Development Bank, Se Kong - Se San and Nam Theun Basins Hydropower Study Final Report, Volume 4, 1999 (p11-29).

សំរាប់រដូវពងកូន និងបំពេញវដ្តនៃជីវិតរបស់ពួកវា។ អំឡុងពេលនៃការសិក្សានេះ អ្នកស្រាវជ្រាវ បាន សង្កេតឃើញ៤កន្លែងឆ្ងាយៗដែលពពួកត្រីទាំងនោះធ្វើការផ្លាស់ទី គឺអាចធ្វើការផ្លាស់ទី រវាងបឹង ទន្លេសាប ឬទន្លេមេគង្គផ្នែកខាងក្រោម ហើយនិងតំបន់ទីតាំងគំរោង។ ទាក់ទងនឹងការបន្ធូរបន្ថយផល ប៉ះពាល់ដោយសាទំនប់វារីអគ្គិសនីលើបំលាស់ទីរបស់ត្រីឆ្លងកាត់ទីតាំងទំនប់ ការសិក្សាផ្នែកជលផល ក្នុងរបាយការណ៍ EIA បានបញ្ជាក់ថា "គ្មានលទ្ធភាពណា ដែលបំលាស់ទីរបស់ត្រី អាចធ្វើឲ្យប្រសើ ឡើងខ្លាំងដល់ឥទ្ធពលបង្សាំងរបស់ទំនប់វារីអគ្គិសនីលើការធ្វើចរាចររបស់ត្រីឡើយ"[88]។

ការសិក្សាក្នុងឆ្នាំ ២០០៩ ដោយសម្ពន្ធ័ទន្លេកម្ពុជា (RCC) បានទាមទារថា ផលប៉ះពាល់ផ្នែក ខាងលើនៃទំនប់ ហាក់ដូចជាធ្ងន់ធ្ងរជាងការប៉ាន់ស្មាននៅក្នុងរបាយការណ៍ EIA ក្នុងនោះ ប្រជាពលរដ្ឋ យ៉ាងតិច ៧៨,០០០នាក់ ប្រឈមនឹងការបាត់បង់ប្រភពត្រីរបស់ពួកគាត់។ ទាំងនេះ រួមបញ្ចូលទាំង ៨៦ភូមិ ដែលនៅតាមបណ្តោយដងទន្លេសេសាន ស្រែពក ហើយនិង៨៧ភូមិផ្សេងទៀត ដែលរស់នៅ អាស្រ័យផលលើទន្លេទាំងពីរនេះផងដែរ និងភាគច្រើន ជាប្រជាពលរដ្ឋជនជាតិដើមភាគតិច។ របាយ ការណ៍ក៏បានរកឃើញផងដែរថា ប្រជាពលរដ្ឋច្រើនជាង ២២,៧០០នាក់ នឹងរងឥទ្ធិពលនៅផ្នែកខាង ក្រោមទំនប់ ដោយសាការផ្លាស់ប្តូរអេឡូស៊ីរបស់ទន្លេ ដែលអាចធ្វើឲ្យប៉ះពាល់ទៅដល់វិស័យជលផល និងការផ្គត់ផ្គង់ទឹក។ សំខាន់ជាងនេះទៀត របាយការណ៍នេះ បានលើកឡើងពីការបារម្ភរបស់ប្រជា ពលរដ្ឋនៅទូទាំងប្រទេស និងក្នុងប្រទេសជិតខាងផងដែរ ជុំវិញផលប៉ះពាល់របស់គំរោង។ វាក៏បាន លើកឡើងដែរថា ប្រជាពលរដ្ឋដែលស្ថិតនៅឆ្ងាយរហូតដល់បឹងទន្លេសាប នៅភាគកណ្តាលប្រទេស កម្ពុជា ដីសណ្តរទន្លេមេគង្គស្ថិតក្នុងប្រទេសវៀតណាម និងភាគកណ្តាល នៃទន្លេមេគង្គស្ថិតក្នុងប្រទេស ឡាវ អាចទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមាន ដោយសារការបង្អាក់ដល់ការធ្វើចរាចររបស់ត្រីក្នុង តំបន់[89]។

សក្តានុពលនៃផលប៉ះពាល់ផ្សេងទៀត ដែលទទួលបានការយកចិត្តទុកដាក់តិចតួចនោះ គឺប្រ សិទ្ធិភាពនៃលំហូរទឹករបស់ទំនប់។ យោងតាមមជ្ឈមណ្ឌលគ្រប់គ្រងបរិស្ថានអន្តរជាតិទីក្រុងហាណូយ ទំនប់សេសានក្រោម២ នឹងឃាំងជិតពាក់កណ្តាលនៃលំហូរកករសរុប ពីតំបន់ទន្លេបីចូលទៅក្នុងទន្លេ មេ គង្គ។ បន្ទាប់មក គេបានប៉ាន់ប្រមាណទៀតថា ការឃាំងនេះ នឹងកាត់បន្ថយចំនួនកករទឹកសរុបក្នុង ទន្លេ មេគង្គពី ៦% – ៨%។ នេះអាចស្តែងឲ្យឃើញពីការថយលំនឹងនៃបណ្តាញទន្លេក្នុងដីសណ្តរទន្លេ មេគ ង្គ បង្កើនការសិករិចរិល និងបន្ថយផលិតផលនៃប្រពន្ធ័ជលជាតិដែលដុះក្នុងទន្លេ និងដីកសិកម្មក្នុងតំបន់ ទឹកលិចទន្លេមេគង្គ និងបឹងទន្លេសាប[90]។

88 Huot, V. et al., Faculty of Fisheries of Royal University of Agriculture, Assessment on Fisheries Natural Resources for Lower Sesan 2 Hydropower Plant Project, August 2009 (p8, 19, 27).
89 Baird, Ian G. 2009.
90 Cambodia Daily, The battle for the 3S Rivers, 10-11 September 2011.

ជំហររបស់រាជរដ្ឋាភិបាលកម្ពុជាគឺថា ការស្រាវជ្រាវត្រូវបានធ្វើគ្រប់គ្រាន់សមល្មម ហើយថា អត្ថប្រយោជន៍នៃការអភិវឌ្ឍន៍ទំនប់ខ្នាតធំក្នុងតំបន់ មានទំហំធំជាងផលប៉ះពាល់ជាអវិជ្ជមាន។ ទាំងនេះ គឺវាឆ្លុះបញ្ចាំងទៅលើការយល់ព្រមថ្មីៗនៃទំនប់សេសានក្រោម២ ហើយនិងមានការការពារគំរោងយ៉ាងខ្លាំងក្លាពីសំណាក់មន្ត្រីរដ្ឋាភិបាលកម្ពុជា ហើយនិងនាយករដ្ឋមន្ត្រីផ្ទាល់។ យ៉ាងណាក៏ដោយ មានអ្នកសង្កេតជាច្រើននៅតែប្រកាន់ជំហរការព្រួយបារម្ភជាខ្លាំងថា ផលប៉ះពាល់រយៈពេលវែងនៃគោលបំណងអភិវឌ្ឍន៍ទំនប់ក្នុងតំបន់ទន្លេបី នៅមិនទាន់បានធ្វើការអង្កេតគ្រប់គ្រាន់នៅឡើយទេ ហើយនេះជាភាពខ្វះខាតការយល់ដឹងនៃផលប៉ះពាល់ដោយសារទំនប់ទាំងនេះ ព្រមទាំងទំនប់ផ្សេងទៀតក្នុងតំបន់ទន្លេបីក្នុងប្រទេសឡាវ និងវៀតណាម។

**ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងការចូលរួមជាសាធារណៈ**



ការដង្ហែរក្បួនរបស់សហគមន៍ដើម្បីតវ៉ាចំពោះសេសានក្រោម២កាលនៅខែកុម្ភៈឆ្នាំ២០១២

បន្ថែមពីលើការព្រួយបារម្ភ ជុំវិញផលប៉ះពាល់ដោយសាទំនប់ទាំងនោះ វាក៏ជាករណីដ៏រឹងមាំមួយដើម្បីនិយាយថា ការពិគ្រោះយោបល់ជាសាធារណៈ មិនត្រូវបានធ្វើគ្រប់គ្រាន់នៅឡើយទេ ហើយរហូតមកដល់ពេលនេះ វាមិនមានឱកាសគ្រប់គ្រាន់ សំរាប់ប្រជាពលរដ្ឋកម្ពុជាចូលរួមពិភាក្សាឲ្យបានសមរម្យផងដែរអំពីការសំរេចចិត្តចំពោះការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំ។ របាយការណ៍របស់សម្ព័ន្ធទន្លេកម្ពុជា ដែលយោងទៅលើការរកឃើញដំបូងបង្ហាញថា ប្រជាពលរដ្ឋក្នុងតំបន់ នៅទីបំផុត ពួកគាត់មិនសប្បាយចិត្តទៅនិងដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ហើយបានបង្ហាញពីភាពទោមនស្សជាមួយនិងការតាំងទីលំនៅថ្មី និងការផ្តល់សំណង។ ម្យ៉ាងទៀត ប្រជាពលរដ្ឋដែលបានសំភាសន៍ បានបង្ហាញថា ពួកគាត់បានជំទាស់ទៅនិងគំរោងសាងសង់នេះ។ អ្នករៀបរាងរបាយការណ៍នេះ បានលើកឡើងថា ទោះបីជាមានការទទួលស្គាល់ក៏ដោយ ផលប៉ះពាល់នៅតំបន់ដែលឆ្ងាយពីទីតាំងនៃទំនប់ និងផលប៉ះពាល់ឆ្លងដែន មិនបានធ្វើការប៉ាន់ប្រមាណឲ្យបានត្រឹមត្រូវនៅឡើយ ហើយក៏មិនមានផែនការ

សំរាប់បង្ការនៅនិងកន្លែងផងដែរ។ សំខាន់ជាងនេះទៀត ដំណើរការវាយតំលៃហេតុប៉ះពាល់ បរិស្ថាន ត្រង់ផ្នែកដែលសំខាន់បំផុត បានពិគ្រោះតែជាមួយប្រជាពលរដ្ឋដែលរស់នៅផ្ទាល់ក្នុងតំបន់នៃ ផ្ទៃអាង ស្តុកទឹក និងនៅក្បែរៗ ទីតាំងនៃទំនប់តែប៉ុណ្ណោះ[91]។

ការពិគ្រោះយោបល់ជាសាធារណៈ ត្រូវធ្វើឡើងក្នុងខែកុម្ភៈ ឆ្នាំ២០០៨ ដោយក្រុមហ៊ុនវាយតំលៃហេតុប៉ះពាល់បរិស្ថាន KCC ជាមួយសហគមន៍ ដែលនឹងត្រូវទទួលរងផលប៉ះពាល់ខ្លាំងបំផុតពី គំរោង។ នៅចុងបញ្ចប់នៃការប្រជុំ ៨៥% នៃអ្នកចូលរួមទាំងនោះ បាននិយាយថា *មិនយល់ព្រមចំពោះផែនការនេះទេ*។ ការពិគ្រោះយោបល់លើកទីពីរ ត្រូវបានធ្វើឡើងក្នុងខែមេសា ២០០៨ ពេលនោះគឺត្រូវបានធ្វើឡើងដោយ PECC1។ ក្នុងការប្រជុំនេះ បានបង្ហាញថា ៩៤% នៃប្រជាពលរដ្ឋ បានយល់ស្របទៅនឹងគំរោង។ ការប្រែក្រឡាស់នេះ ធ្វើឲ្យមានការចាប់អារម្មណ៍ ហើយបានចោទជាសំនួរថា ហេតុអ្វីបានជាការឆ្លើយតបរបស់ប្រជាពលរដ្ឋ មានភាពខុសគ្នានៅក្នុងការប្រជុំពិគ្រោះយោបល់ទាំងពីរ នេះ។ ការប្រជុំលើកទី៣ បានធ្វើឡើងនៅក្រុងស្ទឹងត្រែងក្នុងខែឧសភា ២០០៨ ដែលមានការចូលរួមពីតំណាងសហគមន៍ អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នរដ្ឋាភិបាលក្នុងមូលដ្ឋាន វិស័យឯកជន ក្រសួង បរិស្ថាន និងក្រសួងឧស្សាហ៍កម្ម រ៉ែ និងថាមពល។ KCC និង PECC1 បានចែកចាយបទបង្ហាញ ហើយអ្នកចូលរួមមួយចំនួន ត្រូវបានរាយការណ៍ថា បានចោទសួរសំនួរខ្លះៗនៅក្នុងអង្គប្រជុំ[92]។

ការពិនិត្យមើលឡើងវិញនូវរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ក្នុងឆ្នាំ២០០៩ ដែលធ្វើឡើងដោយវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) បានលើកឡើងពីក្តីបារម្ភជាច្រើនជាមួយនិងឯកសាវាយតំហេតុប៉ះពាល់បរិស្ថាន និងបានបរិយាយថា ការពិគ្រោះយោបល់ជាសាធារណៈ មិនបានធ្វើឲ្យគ្រប់គ្រាន់។ ថ្វីបើការប៉ាន់ស្មានក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់ បរិស្ថានថា គំរោងនេះ នឹងជះឥទ្ធិពលដល់ប្រជាពលរដ្ឋចំនួន៤០,០០០នាក់ ដែលរស់នៅផ្នែកខាង លើនៃទំនប់ក៏ដោយ មានតែប្រជាពលរដ្ឋពី៣០០-៤០០នាក់ប៉ុណ្ណោះ ដែលបានពិគ្រោះយោបល់។ តាមរយៈស្តង់ដាជាច្រើននេះ យើងមិនអាចទទួលយកបានទេ[93]។ យោបល់ពីតំណាងក្រុមប្រជាពលរដ្ឋដែលរងផលប៉ះពាល់ មានសារៈសំខាន់ណាស់ ដើម្បីធានាឲ្យមានការពិចារណាគ្រប់ជ្រុងជ្រោយទៅលើផលប៉ះពាល់ទាំងអស់។ ការពិគ្រោះយោបល់ទាំងនោះ គួតែបានពិចារណានៅក្នុងការធ្វើសេចក្តី សំរេចចិត្តចុងក្រោយ ថាតើត្រូវគាំទ្រ ឬប្រឆាំងនឹងគំរោង ហើយបន្ទាប់មក ត្រូវជូនដំណឹងពីការរៀបចំ វិធានការបន្ធូរបន្ថយ និងការតាមដានត្រួតពិនិត្យឲ្យបានត្រឹមត្រូវ។

មានសកម្មភាពជាច្រើន ត្រូវបានដាក់ចេញ ដើម្បីព្យាយាមបន្ធូបន្ថយការខាតបង់ធនធានជលផល រួមមានការបង្កាត់ពូជ និងភ្ញាស់កូនត្រីសំរាប់ពូជត្រីធ្វើបំលាស់ទី ការទូទាត់សំណងសម្រាប់ការបាត់បង់

91 Baird, Ian G. 2009.
92 PECC1 & KCC, Environmental Impact Assessment for Feasibility Study of Lower Sesan 2 Hydropower Project, Stung Treng Province, Cambodia, October 2008 (pS-8).
93 NGO Forum on Cambodia, Lower Sesan 2 Hydro Project EIA Review, August 2009 (p5).

ចំណូល និងការគាំទ្រទៅដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់។ ទោះបីជាយ៉ាងណាក៏ដោយ ការបារម្ភនៅតែបានលើកឡើងជាមួយនិងសេចក្តីសន្និដ្ឋានថា អ្នកអនុវត្តគំរោង ត្រូវទទួលខុសត្រូវពេញលេញក្នុងការងារកាត់បន្ថយផលប៉ះពាល់ដោយសារទំនប់ ជាពិសេស ដូចក្នុងករណីបរាជ័យរបស់ EVN ក្នុងការបន្ធូរបន្ថយគ្រោះអន្តរាយពីទំនប់ទៅលើទន្លេសេសាន និងស្រែពកផ្នែកខាងលើជាដើម។ បទពិសោធន៍ក្នុងតំបន់ បានបង្ហាញថា ការប៉ុនប៉ងស្តារឡើងវិញនូវការបាត់បង់មុខរបរចិញ្ចឹមជីវិត និងសន្តិសុខស្បៀង អាចមានការលំបាកខ្លាំងបំផុត ត្រូវចំណាយច្រើន ហើយ EVN ធ្លាប់បានទទួលការចោទប្រកាន់ជាច្រើនករណីកាលពីទសវត្សកន្លងទៅ ពីបទខ្វះការទទួលខុសត្រូវចំពោះការអភិវឌ្ឍន៍តាមដងទន្លេសេសាន និងស្រែពករបស់ខ្លួន ហើយនិងមិនបានធ្វើការងារគ្រប់គ្រាន់ លើការបន្ធូរបន្ថយផលប៉ះពាល់នៅផ្នែកខាងក្រោមដោយសារគំរោងទំនប់វារីអគ្គិសនី។ ប្រសិនបើក្រុមហ៊ុនមានការធូរលង់ក្នុងការអនុវត្តវិធានការណ៍ការបន្ធូរបន្ថយ ការទទួលខុសត្រូវ នឹងធ្លាក់ទៅលើអាជ្ញាធរកម្ពុជាដែលពួកគេទាំងនោះ មិនមានបទពិសោធន៍ក្នុងការគ្រប់គ្រងផលប៉ះពាល់រយៈពេលវែង នៃគំរោងខ្នាតធំដូចនេះទេ។

**អគ្គិសនីវៀតណាម** (EVN)

អគ្គិសនីវៀតណាម (EVN) គឺជាកម្មសិទ្ធិផ្ទាល់របស់រដ្ឋាភិបាលវៀតណាម ដែលមានគំរោងជាតំណាក់កាល ការផ្ទេរ ហើយនិងការចែកចាយអគ្គិសនី[94]។ EVN គឺជាក្រុមហ៊ុនថាមពលដ៏ធំមួយក្នុងប្រទេសវៀតណាម ហើយគឺជាសហគ្រាសធំទី៣ក្នុងប្រទេស។ ក្រុមហ៊ុននេះ ដំណើរការបានតាមរយៈក្រុមហ៊ុនធំៗ រួមមាន EVNI (អ៊ីវីអិន ចញស្តុកខុមភីនី) និង PECC1 (ផូយវើ អ៊ិនជីណឺរីង ខុនសាលធីង ចញស្តុក ខុមភីនី) ដែលក្រុមហ៊ុនទាំងពីរនេះ មានសកម្មភាពនៅក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុននេះ កំពុងអភិវឌ្ឍន៍ទំនប់សេសានក្រោម២ សេសានក្រោម១ សេសានក្រោម៥ និងទំនប់សេកុងក្រោម នៅក្នុងតំបន់ទន្លេ៣នៃប្រទេសកម្ពុជា។ ក្រុមហ៊ុន EVN ក៏បានអភិវឌ្ឍន៍ទំនប់ជាច្រើនតាមដងទន្លេសេសាន និងស្រែពកក្នុងប្រទេសវៀតណាម និងមានផែនការអភិវឌ្ឍន៍ទំនប់មួយចំនួនទៀតនៅតាមព្រំប្រទល់ទន្លេមេគង្គភាគខាងត្បូងប្រទេសឡាវ។

ធ្វើបើកំពុងក្លាយជាក្រុមហ៊ុនថាមពលធំបំផុតក្នុងប្រទេសវៀតណាមក៏ដោយ របាយការណ៍សារព័ត៌មានឆ្នាំ២០១១បានបង្ហាញថា EVN កំពុងជួបប្រទះផលលំបាកផ្នែកហិរញ្ញវត្ថុ។ ក្រុមហ៊ុននេះ បានជំពាក់បំណុលទៅក្រុមហ៊ុនរដ្ឋផ្សេងទៀតរបស់វៀតណាម រួមមាន ក្រុមហ៊ុន Petrol Vietnam (ផេទត្រូលវៀតណាម) ៤០០ លានដុល្លាសហរដ្ឋអាមេរិក និងក្រុមហ៊ុនរ៉ែដ៏ធំមួយទៀត ឈ្មោះ VinaComin (វីណាខូមិន) ក្នុងទឹកប្រាក់ប្រហែល ៧៧លានដុល្លាសហរដ្ឋអាមេរិក។ ក្រុមហ៊ុនទាំងពីរនេះ ធ្លាប់បានសរសេរលិខិតសំណើរទៅរដ្ឋាភិបាលវៀតណាមឲ្យជួយជំរុញ EVN សងបំណុលទាំងអស់នេះ។ Hiep

94 See company website: http://www.evn.com.vn/

Phuoc Power Co. Ltd ដែលមានមូលដ្ឋាននៅក្រុងហូជីមិញ ក៏បានគំរាមកាត់ផ្តាច់ ការផ្គត់ផ្គង់ថាមពលទៅដល់ EVN ប្រសិនបើមិនសងទឹកប្រាក់ចំនួន ៣៦ លានដុល្លាសហរដ្ឋអាមេរិក ដែលបានជំពាក់[95]។

សារព័ត៌មានវៀតណាម ក៏បានរាយការណ៍ផងដែថា ព្រោះតែខ្វះខាតថវិកា EVN បានពន្យាពេល និងបានបន្ថយចំនួននៃគំរោងវារីអគ្គិសនី ហើយបានកាត់ថវិកាវិនិយោគជាង ១២ សែនកោដដុង ឬប្រហែល ៥៨៣ លានដុល្លាសហរដ្ឋអាមេរិក (ធៀបនិងអត្រាប្តូរប្រាក់ក្នុងខែវិច្ឆិកា ឆ្នាំ២០១១)។ ឥឡូវនេះក្រុមហ៊ុនកំពុងតស៊ូដើម្បីឲ្យថវិកាវិនិយោគមានការកើនឡើងសំរាប់គំរោងនានា។ ក្នុងការរៀបចំតាមដែលអាចធ្វើទៅបាន ដើម្បីកុំឲ្យទន់ថវិកាធ្លាក់ចុះ ក្រុមហ៊ុនបានស្នើរទៅកាន់រដ្ឋាភិបាលវៀតណាមក្នុងខែកក្កដា ឆ្នាំ២០១១ សុំឲ្យអនុញ្ញាតិដំឡើងថ្លៃថាមពលអគ្គិសនី[96]។ យោងទៅលើសំដីរបស់ប្រធាននាយកប្រត្តិបតិ EVN ក្នុងឆ្នាំ២០១០ ក្រុមហ៊ុនបានខាតបង់គិតជាទឹកប្រាក់មានចំនួន៨សែនកោដដុង (ប្រហាក់ប្រហែល ៣៨៤លានដុល្លាសហរដ្ឋអាមេរិក អត្រាប្តូរប្រាក់ ក្នុងខែវិច្ឆកា ឆ្នាំ២០១០) [97]។ ក្នុងខែកញ្ញា ឆ្នាំ២០១១ EVN បានខាងបង់ក្នុងកំរិត ៥៦២ លានដុល្លាសហរដ្ឋអាមេរិក[98]។

**រ៉ូយ៉ាល់គ្រុប** (Royal Group)

រ៉ូយ៉ាល់គ្រុប ជាបណ្តុំក្រុមហ៊ុនមួយដែលមានទីតាំងនៅទីក្រុងភ្នំពេញ ក្នុងប្រទេសកម្ពុជា ដែលមានលោក**ឧកញ៉ា គិត ម៉េង** ជាប្រធាន។ ក្រុមហ៊ុននេះ មានសាខាជាច្រើន ដែលសហការរកស៊ីអភិវឌ្ឍន៍លើទ្រព្យសម្បត្តិ មានទូរគមនាគមន៍ ធនាគារ ព័ត៌មាន សណ្ឋាគារ និងកន្លែងកំសាន្ត និងកសិកម្ម[99]។ នៅដើមឆ្នាំ២០១១ មានលិចធ្លាយជាសាធារណៈថា រ៉ូយ៉ាល់គ្រុបបានចូលរួមហ៊ុនជាមួយ EVN ដើម្បីអភិវឌ្ឍន៍គំរោងទំនប់វារីអគ្គិសនីសេសានក្រោម២។ រហូតមកដល់ពេលនេះ រ៉ូយ៉ាល់គ្រុបមិនធ្លាប់បានចូលរួមក្នុងគំរោងទំនប់វារីអគ្គិសនីណាមួយនោះទេ ថ្វីបើគេហទំព័ររបស់ក្រុមហ៊ុនបានសរសេរថា: *"ពួកយើងសព្វថ្ងៃ និងទៅអនាគត កំពុងរុករកឱកាសវិនិយោគលើប្រេង ឧស្ម័ន រ៉ែ ទេសចរណ៍ ការអភិវឌ្ឍន៍លើអចលនទ្រព្យ ទីផ្សារសម្រាប់អ្នកប្រើប្រាស់ និងឈ្មួញថ្នាក់កណ្តាល ម្ហូបអាហារ និងភោជនីយដ្ឋាន សេវាសុខភាព សេវាកម្មធនាគារ អាហារ និងភេសជ្ជ និងថាមពល"*[100]។ ដៃគូមួយដ៏ល្អរបស់រ៉ូយ៉ាល់គ្រុបគឺការសហការរកស៊ីរួមគ្នាមួយជាមួយធនាគារអូស្ត្រាលី *Australia និង New Zealand Banking*

95 Vietnam Tuoitrenews, PetroVietnam urges EVN to repay debt, 13 July 2011.
96 Thanh Nien News, Vietnam power utility EVN request price hike, 6 July 2011.
97 VietnamNetBridge, Giant EVN trying to negotiate for delay to pay its debts, 28 April 2011.
98 Reuters, Vietnam’s major state firms face big losses, 9 September 2011.
99 See company website: http://www.royalgroup.com.kh
100 Royal Group website: http://www.royalgroup.com.kh/our-portfolio/growth-and-opportunities.php (accessed November 2011).

*Group (ANZ)* [101]។ ការសហការរកស៊ីរួមគ្នានេះ ធនាគារអូស្រ្តាលីមានទុន៥៥% ចំណែកឯ រូយ៉ាល់គ្រុបមានទុន៤៥%[102]។

## ២.២ ទំនប់សេសានក្រោម៣

### សេសានក្រោម៣: ព័ត៌មានពិត

ស្ថិតនៅតាមដងទន្លេសេសាន ចំងាយ១២ km ទៅ ១៥ km ភាគខាងក្រោមនៃទីរួមស្រុកតាវែង ស្ថិតនៅក្នុងទឹកដីស្រុកតាវែង និងវ៉ឺនសៃ ខេត្តរតនគិរី។ ការសិក្សាពីភាពអាចធ្វើទៅបាន ត្រូវបានដាក់បញ្ជូនកាន់រដ្ឋាភិបាលកម្ពុជានៅចុងឆ្នាំ២០០៩ ហើយកំពុងរង់ចាំការអនុញ្ញាតិមុនពេលដំណើរការគំរោង ដើម្បីសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

| | |
|---|---|
| សមត្ថភាព: | ៣២៥មេហ្គាវ៉ាត់ |
| កម្ពស់ទំនប់: | ៧៥ម៉ែត្រ |
| ទំហំប៉ាន់ស្មាននៃអាងស្តុកទឹក: | ៤២.៧០០ ហិកតា (៤២៧ $km^2$) |
| តំលៃប៉ាន់ស្មាន: | ៧០០លានដុល្លាសហរដ្ឋអាមេរិក |
| ប្រត្តិបតិការថាមពល: | មិនទាន់ដឹង |

អ្នកអភិវឌ្ឍន៍:

- ក្រុមហ៊ុនកូរ៉េ KTC Cable Co.Ltd

ទំនប់សេសានក្រោម៣ មានទីតាំងជិតទីរួមស្រុកតាវែង ក្នុងខេត្តរតនគិរី និងកំពុងស្ថិតក្រោមការសិក្សាពីលទ្ធភាពដែលអាចធ្វើបានដោយក្រុមហ៊ុនកូរ៉េខាងត្បូង KTC Cable Co. Ltd។ យោងទៅលើអត្ថបទរបស់ភ្នំពេញប៉ុស្តិ៍កាលពីខែតុលា ២០០៩ ទំនប់នេះ អាចមានលទ្ធភាពផ្តល់ថាមពលរហូតដល់ ៣២៥ មេហ្គាវ៉ាត់ ហើយត្រូវចំណាយទឹកប្រាក់អស់ ៧០០ លានដុល្លាសហរដ្ឋអាមេរិក។ ក្រុមហ៊ុននេះបានបញ្ជូនរបាយការណ៍នេះទៅកាន់ក្រសួងឧស្សាហ៍កម្ម រ៉ែ និងថាមពលនៅចុងឆ្នាំ ២០០៩ ប៉ុន្តែការសិក្សាវាយតំលៃហេតុប៉ះពាល់បិរស្ថាននៅមិនទាន់ធ្វើនៅឡើយទេ។ ការសៃតដដែលនេះ ក៏បានរាយការណ៍ទៀតថា ប្រធានក្រុមហ៊ុន KTC លោក គឹម ម៉ីយ៉ុងអ៊ីល បានជួបនាយករដ្ឋមន្ត្រីកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជូ ហ៊ុន សែន កាលពីខែតុលា ឆ្នាំ២០០៩ ដើម្បីពិភាក្សាពីផែនការរបស់ក្រុមហ៊ុន[103]។

101 ANZ website: http://www.anz.com/personal/
102 ANZ Royal website: http://www.anzroyal.com/en/About-Us/Our-Company/
103 Phnom Penh Post, South Korea's KTC Cable weighs $700m Ratanakiri dam project, 15 October 2009.

ទំនប់ និងផ្ទៃអាងស្តុកទឹករបស់វា គ្របដណ្តប់លើឃុំចំនួន៧ និងស្រុកចំនួន៣ ដែលស្ថិត នៅក្បែរព្រំប្រទល់ស្រុកតាវែង និងវ៉ឺនសៃ។ ទីរួមស្រុកតាវែង អាចត្រូវជន់លិចបាត់ដោយសារអាងស្តុក ទឹកខណៈដែលផ្ទៃដីលិចទឹកមានដល់ ៤២,៧០០ហិកតា (៤២៧km$^2$)។ ៦៥% នៃតំបន់លិចទឹក បច្ចុប្បន្នត្រូវបានប្រើប្រាស់សំរាប់វិស័យកសិកម្ម ហើយ១៧% គឺជាព្រៃឈើតូចៗ។ ភូមិចំនួន៣៨ ស្ថិតនៅក្នុងផ្ទៃអាងស្តុកទឹក រួមបញ្ចូលទាំងចំនួនក្រុមប្រជាពលរដ្ឋជាជនជាតិដើមភាគតិច ហើយទំនប់ នេះ អាចនាំឲ្យមានការតាំងទីលំនៅថ្មីនូវសហគមន៍យ៉ាងហោចណាស់ ២៤សហគមន៍ ដែលមានរហូត ដល់ជាង ៨,០០០នាក់[104]។



រូបភាព Oxfam-Brett Eloff: ទីក្រុងតាវែងតាមដងទន្លេសេសាន

តំបន់ទឹកជន់លិច រាប់បញ្ចូលទាំងដីកសិកម្មចំនួន ២៧,៦៦០ហិកតា ដែលប្រជាពលរដ្ឋកម្ពុជារាប់ពាន់នាក់ កំពុងពឹងពាក់សំរាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់នាពេលបច្ចុប្បន្ននេះ។ ប្រសិនបើគំរោងនេះ ត្រូវបានអនុញ្ញាតិដោយមិនមានការកែប្រែជាដុំកំភួននោះទេ វាហាក់បីដូចជាសឲ្យឃើញពីការលំបាកស្វែងរកដីជំនួសណាមួយដែលសមរម្យ សំរាប់អ្នកដែលបានផ្លាស់ទីកន្លែង ហើយនិងសំរាប់ប្រជាកសិករដែលបានបាត់បង់ដីទៅក្នុងអាងស្តុកទឹក។ ដោយសារតែតំបន់នោះ មានព្រៃឈើយ៉ាងក្រាស់ និងជាតំបន់សម្បទានកសិកម្មដែលរដ្ឋផ្តល់នៅលើដីដាំដុះ ទីកន្លែងដែលត្រូវផ្លាស់ទៅ ប្រាកដជានឹងត្រូវឈូសឆាយសំអាតព្រៃ ដើម្បីច្នៃទៅជាដីសំរាប់ដំណាំកសិកម្ម។ នេះជានិន្នាការមួយ ដែលត្រូវបានគេ

104 3SPN & PRCF, Scoping Study of Environmental and Social Impacts of the Proposed Lower Sesan 3 Dam, Ratanakiri, Cambodia (DRAFT), June 2010. [It should be noted that this report is still in draft form, and due to the lack of public information available, an overview of the project has been taken from older sources that may since have become dated. The ESIA draws on recent Japan International Cooperation Agency (JICA) documents released during 2007- 09, when the agency was developing the since abandoned master plan for Cambodia's hydropower development.]

អង្កេតកាន់តែច្រើនឡើងក្នុងប្រទេសកម្ពុជា នៅពេលដែលប្រជាពលរដ្ឋបាត់បង់ដីធ្លីរបស់ពួកគេ ហើយបន្ថែមទៅលើផលប៉ះពាល់បរិស្ថាន នៅពេលគេទុកឲ្យប្រជាពលរដ្ឋគ្មានការការពារ និងងាយរងគ្រោះថ្នាក់ ខណៈដែលសកម្មភាពកាប់ឆ្ការរុករានដីព្រៃរបស់ពួកគាត់ ទំនងជាខុសច្បាប់ ហើយការកាន់កាប់ដីរបស់ពួកគាត់ មិនត្រូវបានទទួលស្គាល់ដោយអាជ្ញាធរ។ ទំនប់ សណ្ដូកខ្លួនទៅខាងត្បូងឧទ្យានជាតិ វិរៈជ័យ ហើយមានការបារម្ភថា ការសំអាតព្រៃឈើអាចប៉ះពាល់លើតំបន់នេះ។ អាងស្តុកទឹក នឹងជន់ លិចទំហំ ១,៥៦០ ហិកតា នៃវាលស្មៅលិចទឹកតាមរដូវកាល វាលភក់ និងវាលល្បាប់ភក់ ដែលជាតំបន់សំបូរទៅដោយជីវចំរុះគ្រប់ប្រភេទ។ លំហូរទឹកផ្លាស់ប្ដូរ ទំនងជាប៉ះពាល់ដល់តំបន់ដីសើមនៅផ្នែកខាងក្រោមនៃទំនប់ផងដែរ ហើយដីព្រៃប្រមាណជា ១០,០០០ ហិកតា ត្រូវបានគេគិតថានឹងបាត់បង់ដោយសារអាងស្តុកទឹក។

មិនទាន់មានការសើបអង្កេតណាមួយ ត្រូវបានធ្វើនៅឡើយទេ ជុំវិញផលប៉ះពាល់លើធនធានជលផល ថ្វីបើគេរំពឹងថា នឹងមានផលប៉ះពាល់អវិជ្ជមានដល់ការបំលាស់ទីរបស់ត្រី ក្នុងតំបន់ទីតាំងទំនប់ក៏ដោយ។ បន្ថែមលើការដាក់កំរិតចំពោះការធ្វើចរាចររបស់ត្រី និងផលប៉ះពាល់លើគុណភាពទឹក ការព្រួយបារម្ភដ៏ខ្លាំងមួយទៀតនោះ គឺការកើនឡើងនូវកករទឹកនៅក្នុងអន្លង់ទឹកជ្រៅៗ ដែលជាតំបន់ត្រីពឹងអាស្រ័យសំរាប់ការរស់រានពេលរដូវទឹកស្រកនៅតាមដងទន្លេសេសាន។

មានសំណួរសំខាន់ៗជាច្រើនបានលើកឡើង អំពីប្រសិទ្ធិភាពនៃគំរោងនេះ ជុំវិញចំនួនថាមពលសរុបរបស់ទំនប់ ដែលនឹងត្រូវផលិតចេញពីអាងស្តុកទឹកដ៏ធំមួយនេះ។ ដូចដែលបានពិភាក្សាខាងលើ គំរោងនេះ ត្រូវបានគេវិនិច្ឆ័យមិនសូវល្អ នៅក្នុងឯកសារបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយបានគណនាចំនួនសរុបនៃថាមពលផលិត ធៀបនិងទំហំអាងស្តុកទឹកគិតជាគីឡូម៉ែត្រការេ ដែលវាស្មើរនិង ០.៤ មេហ្គាវ៉ាត់ ក្នុង១$km^2$ គឺពន្ទុទាបបំផុតក្នុងចំណោមគំរោងដែលបានស្ទាបស្ទង់ទាំងអស់។ ទំនប់វារីអគ្គិសនី ដូចជាទំនប់សេសានក្រោម៣ មានទីតាំងក្នុងតំបន់ដីរាបស្មើ ជាទូទៅត្រូវមានអាងស្តុកទឹកដ៏ធំ។ អាងស្តុកទឹកធំៗបែបនេះ មានជាប់ពាក់ព័ន្ធនឹងការកើនឡើងនៃការភាយចេញនូវឧស្ម័នផ្ទះកញ្ចក់ ជាដំបូងកើតចេញពីការពុកផុយនៃកាកសំណល់រុក្ខជាតិ និងរូបធាតុសរីរាង្គ និងការបំលែងប្រពន្ធ័អេកូឡូស៊ីរឹងទៅជារាវ។

***KTC Cable Co. Ltd., Kyung An Cable Co. Ltd. & Taihan Electric Wire Co. Ltd.***
**(ខេធីស៊ី ខេបប៊ល ខូអិលធីឌី, គ្យុងអាន ខេប៊ល ខូអិលធីឌី. & ថៃហាន អ៊ីលីកទ្រិក វ៉ាយ ខូអិលធីឌី)**

ខេធីស៊ី ខេបប៊ល ខូអ៊ិលធីឌី គឺជាក្រុមហ៊ុនកូរ៉េ មានបច្ចេកទេសក្នុងការផលិត និងចែកចាយ ខ្សែកាបអេឡិចត្រូនិច[105]។ ខេធីស៊ី ត្រូវបានស្ថាបនាក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ២០០៥ ហើយបានបើករោង

105 KTC websites: http://www.ktc.com.kh/ (English), http://www.ktccable.co.kr/ (Korean)

ចក្រខ្សែកាបនៅជាយក្រុងភ្នំពេញក្នុងឆ្នាំ២០០៦។ ក្រុមហ៊ុននេះ មានភាពជិតស្និទជាមួយក្រុមហ៊ុន គ្យុងអាន ខេប៊ល ខូអ៊ិលធីឌី( Kyung An Cable Co. Ltd)។

ខេធីស៊ី ត្រូវបានចុះបញ្ជីក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុនថៃហាន[106] ជាសាខាដ៏ធំនៅក្រៅប្រទេសរបស់ក្រុមហ៊ុនខ្សែភ្លើងអគ្គិសនី ថៃហាន ខូអ៊ិលធីឌី (*Taihan Electric Wire Co. Ltd*) ។ *ថៃហាន* ជាក្រុមហ៊ុនដែលបានកសាងឡើងដ៏ល្អមួយរបស់ប្រទេសកូរ៉េ ហើយបានចាប់ផ្តើមប្រត្តិបតិការនៅអំឡុងឆ្នាំ១៩៥០។ ក្រុមហ៊ុននេះ មានចំនួនភាគហ៊ុនក្រៅប្រទេសជាច្រើន ហើយនិងមានការិយាល័យជុំវិញពិភពលោក រួមមាន អាហ្រ្វិកខាងត្បូង វៀតណាម ចិន ម៉ុងហ្គូលី ខូបៃ អូស្រា្តលី សហរដ្ឋអាមេរិក និងកាណាដា[107]។

គេហទំព័ររបស់ខេធីស៊ីបានបង្ហាញថា ក្នុងឆ្នាំ២០០៧ និងក្នុងឆ្នាំ២០០៨ ខេធីស៊ី បានឈ្នះការដេញថ្លៃពីរលើកជាប់ៗគ្នា នូវគម្រោងកែលម្អបណ្តាញបញ្ជូនចរន្តអគ្គិសនីជាតិកម្ពុជា ដែលផ្តល់មូលនិធិដោយធនាគារពិភពលោក ដែលមានទឹកប្រាក់ ៥លានដុល្លាសហរដ្ឋអាមេរិក និង៣លានដុល្លាសហរដ្ឋអាមេរិក[108]។ គេហទំព័រនេះ មិនបានបញ្ជាក់ឲ្យច្បាស់ថាតើគំរោងមួយណានោះទេ ប៉ុន្តែតាម ព័ត៌មានពីគេហទំព័រធនាគារពិភពលោកបង្ហាញថា ក្រុមហ៊ុនប្រទេសកូរ៉េ គ្យុងអាន ខេប៊ល (Kyung An Cable) បានចុះកិច្ចសន្យាចំនួន៤ ក្នុងចន្លោះខែ កញ្ញា ២០០៧ និងខែមករា ២០១១ ធ្វើការផ្គត់ផ្គង់សំភារៈអគ្គិសនី[109] ដែលមានទឹកប្រាក់៥.៥លានដុល្លាសហរដ្ឋអាមេរិក។ ក្នុងឆ្នាំ២០០៨ *គ្យុងអាន* បាន ទទួលគម្រោងមួយ ដែលមានតម្លៃ២.៦លានដុល្លាសហរដ្ឋអាមេរិក ពីធនាគារពិភពលោក ដើម្បីធ្វើការ ផ្គត់ផ្គងសំភារៈ ក្រោមសំណើររួមគ្នាជាមួយក្រុមហ៊ុន ហេនប៉ែកខូអ៊ិលធីឌី (Han Baek Co. Ltd) [110]។

គម្រោងខាងលើ ត្រូវបានផ្តល់ទៅឲ្យក្រុមហ៊ុនគ្យុងអាន ខេប៊ល ខូអ៊ិលធីឌី (Kyung An Cable Co. Ltd) ដូចបានរៀបរាប់ខាងលើ វាជាគម្រោងដែលមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយក្រុមហ៊ុន ខេធីស៊ី។ ទោះបីជាការទំនាក់ទំនងស្មុគស្មាញនោះ នៅមិនទាន់ច្បាស់ក៏ដោយ គ្យុងអាន ខេប៊ល ខូអ៊ិលធីឌី និង ខេធីស៊ី ពួកគេទាំងពីរមាននាយកប្រត្តិបតិតែមួយ គឺលោក **គឹម ម៉្យុងអឺល** ហើយនៅក្នុងទំព័រប្រវត្តិសាស្រ្តនៃគេហទំព័ររបស់ហ៊ុន គ្យុងអាន បានបង្ហាញថា ខ្លួនបានកសាងរោងចក្រ ខេធីស៊ី (KTC)

106 See, for example: Taihan Electric Wire Co. Ltd. Annual Report 2009.
107 Taihan website: http://www.taihan.com/eng1/company/c_016-1.asp (accessed November 2011).
108 KTC website.
109 World Bank website, Contracts Awarded: http://web.worldbank.org/external/default/main?menuPK=293893&theSitePK=293856&piPK=64027241&pagePK=64027244&Supplierid=159620 (accessed November 2011).
110 World Bank website, Contracts Awarded: http://web.worldbank.org/external/default/main?pagePK=64027236&piPK=64027233&theSitePK=293856&menuPK=293893&contractid=1276867 (accessed November 2011).

ក្នុងប្រទេសកម្ពុជា។ ស្រដៀងគ្នាដែរ នៅលើគេហទំព័រក្រុមហ៊ុន ខេធីស៊ី (KTC) *គ្យុងអាន* ត្រូវបានពិពណ៌នាថាជាផ្នែកមួយនៃ ខេធីស៊ី[111]ផងដែរ។

នៅមិនទាន់មានព័ត៌មានជាផ្លូវការណាមួយ (យ៉ាងហោចណាស់ជាភាសារអង្គគ្លេស) បង្ហាញថា ក្រុមហ៊ុនទាំងពីរ ខេធីស៊ី និងគ្យុងអាន ឬ ថៃហាន មានបទពិសោធន៍ក្នុងការអភិវឌ្ឍន៍គំរោងទំនប់ វារីអគ្គិសនី។ យ៉ាងណាក៏ដោយ ក្រៅពីទំនប់សេសានក្រោម៣ ក្រុមហ៊ុន ខេធីស៊ី (KTC) ក៏មានជាប់ ពាក់ព័ន្ធជាមួយការអភិវឌ្ឍន៍គំរោងទំនប់វារីអគ្គិសនី៦ផ្សេងទៀត ក្នុងប្រទេសកម្ពុជាផងដែរ ដែលមានឈ្មោះដូចជា៖ ព្រែកលៀង១ (៦៤មេហ្គាវ៉ាត់) ព្រែកលៀង២ (៦៤មេហ្គាវ៉ាត់)ក្នុងខេត្តរតនគិរី ឬស្សីជ្រុំលើ (៣២មេហ្គាវ៉ាត់) និងឫស្សីជ្រុំកណ្តាល (១២៥មេហ្គាវ៉ាត់) ក្នុងខេត្តកោះកុង បាត់ដំបង១ (២៤ មេហ្គាវ៉ាត់) និងបាត់ដំបង២ (៣៦មេហ្គាវ៉ាត់) ក្នុងខេត្តបាត់ដំបង[112]។ គម្រោងទាំងអស់នេះ ទំនងជា ស្ថិតនៅក្នុងដំណាក់កាលនៃការសិក្សាពីលទ្ធភាពដែលអាចធ្វើទៅបាននៅឡើយ។




*សន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងពិធីបើកឲ្យដំណើរការរោងចក្រ ខេធីស៊ី ខេប៊ល*[113]

ខេធីស៊ី បានពង្រីកខ្លួនអភិវឌ្ឍន៍គម្រោងសាងសង់តំបន់សំរាកលំហែរកាយ និងទូរគមនាគមន៍ថែមទៀត។ ក្រុមហ៊ុនខេធីស៊ី ឡេស៊ី ខូអ៊ិលធីឌី (KTC Leisure Co. Ltd) វិនិយោគលើផ្ទៃដី ២០០ហិកតា ក្នុងទឹកប្រាក់ ១៥០លានដុល្លាសហរដ្ឋអាមេរិក ដោយកសាងកន្លែងកម្សាន្តប្រណិតៗ និង ទីលាន

111 Kyung An website: http://www.kyungan.co.kr/eng/pro_eng_history.htm (accessed November 2011).
112 Presentation by Chea Piseth, 16-17 July.
113 KTC website.

វាយកូនហ្គោលក្នុងខេត្តសៀមរាប។ ក្រុមហ៊ុននេះ បានស្តែងចេញឲ្យឃើញពីទំនាក់ទំនងល្អជា មួយលោក នាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលជាអ្នកបើកឲ្យដំណើរការទីលានវាយកូនហ្គោល ក្នុងខែ មករា ឆ្នាំ ២០០៩[114]។ ក្នុងបទសំភាសន៍មួយជាមួយនាយកប្រត្តិបតិ លោក គឹម ម៉្យុងអ៊ិល បង្ហាញថា សម្តេច នាយក រដ្ឋមន្ត្រី **ហ៊ុន សែន** មានទំនាក់ទំនងយ៉ាងខ្លាំងក្នុងការទាក់ទាញ ខេធីស៊ី មកវិនិយោគ ក្នុងប្រទេសកម្ពុជា[115]។ ក្នុងឆ្នាំ២០០៩ ប្រធានាធិបតីកូរ៉េ **លី ម៉្យុងបាក់** បានអញ្ជើញទស្សនាជាផ្លូវការនៅរោងចក្រ ខេធីស៊ី ក្នុងប្រទេសកម្ពុជា[116]។

ក្នុងខែតុលា ២០១០ សាខាថ្មីមួយទៀតឈ្មោះ ខេធីស៊ី តេឡេខុម (KTC Telecom) ទទួលបានភាគហ៊ុន ១០០% ពីក្រុមហ៊ុនទូរសព្ទ័ដ៏ធំរបស់ប្រទេសកម្ពុជា គឺក្រុមហ៊ុន កាំមីុនតែល[117]។ ខេធីស៊ី ជាអ្នកឧបត្ថម្ភក្រុមបាត់ ទាត់ជំរើសជាតិកម្ពុជា[118] ព្រមទាំងបានវិនិយោគទឹកប្រាក់ចំនួន ៨លានដុល្លា សហរដ្ឋអាមេរិក ក្នុងការកែលម្អរប្រពន្ធ័ទឹកស្អាតក្នុងខេត្តសៀមរាប ហើយនឹងលក់ទឹកស្អាតនេះទៅឲ្យ រដ្ឋករទឹកខេត្តសៀមរាប[119]។

ខេធីស៊ី ក៏មានការចាប់អារម្មណ៍ក្នុងវិស័យធនាគារផងដែរ ហើយបានចូលហ៊ុនក្នុងធនាគារ កូកមិុនប៉ែងខាំបូឌែរ (Kookmin Bank Cambodia)។ កូកមិុនប៉ែងខាំបូឌែរ ជាពាណិជ្ជកម្មរួមរវៀងធនាគារ ខេប៊ី កូកមិុនប៉ែង (KB Kookmin Bank) និង ខ្មែរយូនៀនប៉ែង (Khmer Union Bank) [120]។ ខេប៊ី កូកមិុន (KB Kookmin Bank) មានភាគហ៊ុន ចំនួន៥៣% ហើយភាគហ៊ុនដែលនៅសល់ ជា កម្មសិទ្ធិរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័កូរ៉េ រួមមាន ខេធីស៊ី (KTC) តៃហាន(Taihan) និង ផូស្កូ អុិនជីណឺរីង អេន ខុនស្រ្តាក់សុិន (Posco Engineering and Construction) [121]។ ខេប៊ី កូកមិុនប៉ែង (KB Kookmin Bank) ជាធនាគារធំជាងគេបំផុតក្នុងប្រទេសកូរ៉េខាងត្បូង និងជាសាខារបស់ ក្រុមហ៊ុន (KB Financial Group) ។

## ២.៣ ទំនប់សេសានក្រោម១/៥

### សេសានក្រោម១/៥: ព័ត៌មានពិត

ទំនប់នេះ ស្ថិតនៅត្រួតស៊ីគ្នាត្រង់ព្រំប្រទល់ប្រទេសវៀតណាម និងកម្ពុជា ក្នុងស្រុកឌុកកូ នៃខេត្តយ៉ាឡាយ ប្រទេសវៀតណាម និងស្រុកអូយ៉ាដាវ នៃខេត្តរតនគិរី ប្រទេសកម្ពុជា។ ការសិក្សាពីភាព

114 Invest in Cambodia website, http://www.investincambodia.com/golf.htm (accessed November 2011).
115 Cambodia Association of Travel Agents website, http://www.catacambodia.com/news_details.php?id=33 (accessed November 2011).
116 Koreanet, President Lee Wraps Up State Visit to Cambodia, 23 October 2009.
117 KTC Telecom website: http://www.camintel.com/ (accessed November 2011).
118 ASEAN Football Association website, http://www.aseanfootball.org/?p=2550 (accessed November 2011).
119 http://cambodiastockmarket.info/siem-reap-set-to-raise-commercial-water-rate/ (accessed November 2011).
120 According to KB Financial Group Annual Report 2010.
121 Phnom Penh Post, South Korea's largest bank launches in Cambodia, 8 May 2009.

ដែលអាចសាងសង់បាន ត្រូវបានធ្វើរួចរាល់ហើយ ប៉ុន្តែមកដល់ពេលនេះ មិនទាន់មានការពិគ្រោះយោបល់ជាសាធារណៈនៅឡើយទេ។

សមត្ថភាព: ៩៦មេហ្គាវ៉ាត់
កម្ពស់ទំនប់: ២៨ម៉ែត្រ
ទំហំផ្ទៃអាងស្តុកទឹក: ៧៦១ហិកតា ក្នុងដីវៀតណាម, ៨៦៨ហិកតា ក្នុងដីកម្ពុជា
តំលៃប៉ាន់ស្មាន: ៩០លានដុល្លាសហរដ្ឋអាមេរិក
ប្រតិបត្តិការថាមពល: ប្រទេសវៀតណាម និងកម្ពុជា
អ្នកអភិវឌ្ឍន៍:

- អគ្គិសនីវៀតណាម (EVN)
- ការសិក្សាពីលទ្ធភាពដែលអាចធ្វើបាន និងរៀបចំគំរោងដោយ: PECC2 (Power Engineering Consulting Joint Stock Company No2)។

សំណើរស្នើសុំទីតាំងសំរាប់ទំនប់សេសានក្រោម១/៥ លាតសន្ធឹងឆ្លងកាត់ទន្លេសេសាន ចន្លោះពីព្រំដែនវៀតណាម និងកម្ពុជា។ ហេតុដូច្នេះហើយ ពាក់កណ្តាលនៃទំនប់នេះ ស្ថិតនៅក្នុងប្រទេស កម្ពុជា និងពាក់កណ្តាលទៀត ស្ថិតក្នុងទឹកដីវៀតណាម (ទំនប់នេះ សំដៅដល់ទំនប់សេសានក្រោម១ ក្នុងទឹកដីកម្ពុជា និងទំនប់សេសានក្រោម៥ ស្ថិតក្នុងទឹកដីវៀតណាម)។ ទំនប់សេសានក្រោម១/៥ ជា គំរោងផ្សេង១ទៀតរបស់អគ្គិសនីវៀតណាម (EVN) ហើយក្នុងរបាយការណ៍ PECC1 ឆ្នាំ២០០៦ ទំនប់សេសាន១/៥ ត្រូវបានដាក់ជាគំរោងអាទិភាព (បន្ថែមពីលើទំនប់សេសានក្រោម២ និងសេសាន ក្រោម៣)។ អនុសារណៈយោគយល់គ្នា (MOU) ស្តីពីការសិក្សាពីលទ្ធភាពដែលអាចសាងសង់បាន ត្រូវបានរៀបចំ រវៀងក្រសួងឧស្សាហ៍កម្ម រ៉ែ និងថាមពល ជាមួយអគ្គិសនីវៀតណាម (EVN) ក្នុង ឆ្នាំ២០០៧[122]។ គំរោងនេះ ទំនងជាបានឆ្លងកាត់ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានរួចហើយ ប៉ុន្តែវានៅមិនទាន់អាចផ្សព្វផ្សាយជាសាធារណៈបាននៅឡើយ ដោយសារតែវាស្ថិតក្នុងដំណាក់កាល នៃការសរសេរ។

យោងទៅលើឯសារសង្ខេបដែលបានមកពីគេហទំព័រអគ្គិសនីវៀតណាម (EVN) គំរោងនេះ នឹងផលិតថាមពលដើម្បីផ្គត់ផ្គង់ទៅដល់ប្រទេសទាំងពីរ គឺវៀតណាម និងកម្ពុជា។ ឯសារនោះបានបង្ហាញថា គំរោងនេះនឹងធ្វើឡើងស្របទៅតាមតំរូវការថាមពលដែលកើនឡើងនៅក្នុងតំបន់ ទាំងនៅកម្ពុជា និងប្រទេសវៀតណាម។ យោងទៅលើឯសារនេះ ទំនប់សេសានក្រោម១/៥ នឹងអាចតភ្ជាប់ទៅខ្សែរកាបរបស់វៀតណាម ក្នុងកំលាំងបញ្ជូន ២២០គីឡូវ៉ាត់[123]។ អគ្គិសនីវៀតណាម មានអនុសារណៈយោគ

122 EVN, Summary Report: Lower Sesan 1/Sesan 5 hydropower project, 30 January 2010. http://www.evni.vn/Home/News/tabid/54/TopicId/54/language/en-US/Default.aspx (accessed November 2011).
123 Ibid.

យល់គ្នាទាំងពីរ គឺទាំងវៀតណាម និងកម្ពុជា ដើម្បីតភ្ជាប់ខ្សែរកាបថាមពលពីទំនប់សេសានក្រោម១/៥ ទៅកម្ពុជា និងវៀតណាម[124]។

របាយការណ៍សង្ខេបបានបង្ហាញទៀតថា ទំនប់នឹងធ្វើឲ្យលិចផ្ទៃដីជាង៩០០ហិកតាក្នុងប្រទេសវៀតណាម និង១,០០០ហិកតាក្នុងប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណានេះក្តី ក្នុងឯកសារបានបង្ហាញថា មិនមាននរណាម្នាក់ត្រូវបានផ្លាស់ទីលំនៅនោះទេ ថ្វីបើដីកសិកម្មរបស់ប្រពលរដ្ឋចំនួន ៤៧គ្រួសារ ឬ ២៧៤នាក់ អាចនឹងរងផលប៉ះពាល់ក៏ដោយ។ ចំនួនសរុបទំហំព្រៃដែលស្ថិតក្នុងតំបន់ទីតាំងទំនប់មានចំនួន ១,៣៨២ហិកតា[125]។



រូបភាពល្បាក់ទឹកហ្សូរក្បៀទំនប់សេសានក្រោម១/៥ ក្នុងស្រុកអូរយ៉ាដាវ ប្រទេសកម្ពុជា

ជាមួយទំនប់សេសានក្រោម២ មានការព្រួយបារម្ភជាច្រើនជុំវិញប្រសិទ្ធិភាព និងការអនុវត្តរបស់ទំនប់នេះ។ ទីមួយ វាអាចជាការពិតដែលថា ទំនប់សេសានក្រោម១/៥ អាចទប់ស្កាត់ផលប៉ះពាល់ ពីទំនប់រក្សាលំនឹងទឹក សេសាន៤A ក្នុងប្រទេសវៀតណាម។ ទំនប់សេសាន៤A ត្រូវបានកសាងឡើងក្នុងគោលបំណងបម្រើឲ្យមានលំនឹងទឹកមកពីទំនប់ ដើម្បីឆ្លើយតបចំពោះក្តីព្រួយបារម្ភអំពីផលប៉ះពាល់

124 EVN, Summary Report: Investment Project of the Transmission Line Connecting Lower Sesan 1/Sesan 5 hydropower Projects into the Power Grid, 23 January 2010.
125 EVN, Summary Report: Lower Sesan 1/Sesan 5 hydropower project, 30 January 2010.

ឆ្លងដែននៃគំរោងវារីអគ្គិសនីវៀតណាមនៅទន្លេសេសានភាគខាងលើ ថ្វីបើមានការបារម្ភទៀតថា គំរោងនេះ មានទិសដៅផលិតអគ្គិសនីជាជាងរក្សាលំនឹងទឹកហូរក៏ដោយ[126]។

ក្នុងឆ្នាំ២០០៦ ការសិក្សាវាយតំលៃផលប៉ះពាល់មួយ ត្រូវបានធ្វើឡើងនៅផ្នែកខាងក្រោម នៃទំនប់ដែលរងឥទ្ធិពលដោយសារទំនប់វារីអគ្គិសនីរបស់វៀតណាម ដោយបានរកឃើញចំនួនផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរជាច្រើននៅផ្នែកខាងក្រោម។ វិធានការណ៍បន្ធូរបន្ថយមួយ ដែលត្រូវអនុវត្តបន្ទាប់ពីការវាយតំលៃនេះ គឺត្រូវសាងសង់ទំនប់មួយដើម្បីរក្សាលំនឹងទឹកដែលហូរធ្លាក់ចុះទៅទន្លេសេសានផ្នែកខាងក្រោមក្នុងប្រទេសកម្ពុជា ដើម្បីកាត់បន្ថយផលប៉ះពាល់នានា ពេលទឹកឡើង និងពេលទឹកប្រែប្រួលមិនទៀងទាត់[127]។ ទំនប់សេសានក្រោម១/៥ នឹងត្រូវកសាងឡើងក្នុងចំងាយត្រឹមតែ៣-៤គីឡូម៉ែត្រប៉ុណ្ណោះខាងក្រោមទំនប់រក្សាលំនឹងទឹក ហេតុដូច្នេះហើយ វាអាចបង្កគ្រោះថ្នាក់ដល់ប្រតិបត្តិការរបស់ទំនប់ ក្នុងការរក្សាលំនឹងទឹកហូរទៅផ្នែកខាងក្រោម។

ជាងនេះទៀតសោត ទំនប់នេះ ធ្លាប់ត្រូវបានគេបដិសេធម្តង ដោយសារតែកង្វះការគាំទ្រលើការវាយតម្លៃផ្នែកសេដ្ឋកិច្ច។ ក្នុងខែសីហា ឆ្នាំ២០០៩ សារព័ត៌មានវៀតណាមបានដកស្រង់សំដី **ឧបនាយករដ្ឋមន្ត្រីវៀតណាមថា** គំរោងនេះមិនទទួលបានការគាំទ្រទេ ដោយសារការធ្លាក់ចុះទាបនៃសេដ្ឋកិច្ច[128]។ ថ្វីបើមានការបដិសេធបែបនេះក៏ដោយ ក្នុងខែកក្កដា ២០១១ មានសេចក្តីរាយការណ៍មកថា ការសិក្សារកលទ្ធភាពដែលអាចធ្វើបានសំរាប់គំរោងនេះ ត្រូវធ្វើរួចរាល់[129] ទោះបីជារហូតដល់ សព្វថ្ងៃនេះ ការពិគ្រោះយោបល់ជាសាធារណៈ នៅមិនទាន់ត្រូវបានធ្វើនៅឡើយក្តី។

## ២.៤ ទំនប់ស្រែពកក្រោម ៣ និងស្រែពកក្រោម៤

### ទំនប់ស្រែពកក្រោម ៣ និងស្រែពកក្រោម៤៖ ព័ត៌មានពិត

ស្រែពកក្រោម៣ ស្ថិតក្នុងស្រុកលំផាត់ លាតសន្ធឹងកាត់ដងទន្លេពីភ្នំ ភូដៀង ទៅភ្នំភូហៃនខាវ ខេត្តរនគិរី។

ស្រែពកក្រោម៤ ស្ថិតក្នុងខេត្តមណ្ឌលគិរី ស្រុកកោះញែក ឃុំ ស្រែហ៊ុយ។

ក្រុមហ៊ុន បានចុះអនុសារណៈយោគយល់គ្នារួចហើយ ដើម្បីធ្វើការសិក្សារកលទ្ធភាពដែលអាចធ្វើបាន សំរាប់គំរោងទាំងពីរនេះ។ ការសិក្សាសាកល្បង កំពុងដំណើរការសំរាប់ស្រែពកក្រោម៣ ថ្វីបើមិនទាន់ច្បាស់ថាតើមានការសិក្សារកលទ្ធភាពដែលអាចធ្វើបានសំរាប់ស្រែពកក្រោម៤ហើយ ឬនៅ។

សមត្ថភាពរបស់ទំនប់ស្រែពកក្រោម៣: ៣០០មេហ្គាវ៉ាត់

---

126 Earthrights International's Mekong Legal Advocacy Network (MLAI), Mekong River Dams: National Laws to Address Environmental and Human Rights Issues, and Obstacles to Enforcement, December 2009. http://www.earthrights.org/sites/default/files/publications/Mekong-River-Dams-MLAI_0.pdf (accessed April 2012).
127 Probe International, Reclaiming the Sesan – Restoring natural flows by modifying hydropower dam operations, 3 November 2008.
128 VNBusinessNews, Se San 5 hydropower project suspended, 17 August 2009.
129 VNA, EVN unit speeds up work on Lao, Cambodian dams, 8 July 2011

| | |
|---|---|
| ទំហំទំនប់: | កម្ពស់៥៣ម៉ែត្រ និងប្រវែង១០km |
| ទំហំផ្ទៃអាងស្តុកទឹក: | ៧៥៨ $km^2$ |
| តំលៃប៉ាន់ស្មាន: | មិនទាន់ដឹង |
| សមត្ថភាពរបស់ទំនប់ស្រែពកក្រោម៤: | ២២០ មេហ្គាវ៉ាត់ |
| ទំហំទំនប់: | កម្ពស់ ៧០ ម៉ែត្រ |
| ទំហំផ្ទៃអាងស្តុកទឹក: | ៥៤០ $km^2$ |
| តំលៃប៉ាន់ស្មាន: | មិនទាន់ដឹង |
| ប្រត្តិបតិការថាមពល: | មិនទាន់ដឹង |

អ្នកអភិវឌ្ឍន៍:

- ក្រុមហ៊ុន ហ្កាន់ស៊ី ហ្គីខ្វៀន អ៊ីឡិចត្រិច ផូយវ៉ឺ ខុមផេនី ខូអ៊ិលធីឌី (Guangxi Guiquan Electric Power Company Co. Ltd) ជាសាខារបស់ក្រុមហ៊ុនមកពីប្រទេសចិនឈ្មោះ ដាតាំង ខុបភឺរេសិន (Datang Corperation) បានចុះអនុសារណៈយោគយល់សំរាប់ការសិក្សារកលទ្ធភាពដែលអាចធ្វើបានក្នុងខែមិថុនា ២០០៨។
- ក្នុងខែវិច្ឆិកា ឆ្នាំ២០១០ អនុសារណៈយោគយល់លើកទី២ ត្រូវបានចុះកិច្ចសន្យាជាមួយសហគ្រាសមួយផ្សេងទៀតឈ្មោះ ហាវដៀន ខុបភឺរេសិន (Huadian Corperation) សំរាប់ការសិក្សារកលទ្ធភាពដែលអាចធ្វើបានរបស់គំរោង។

ទំនប់ស្រែពកក្រោម៣ និងស្រែពកក្រោម៤ ស្ថិតក្នុងខេត្តរតនគិរី និងមណ្ឌលគិរី ហើយត្រូវបានសិក្សារកលទ្ធភាពដែលអាចធ្វើបានមុនគេដោយក្រុមហ៊ុនចិនឈ្មោះ ហ្កាន់ស៊ី ហ្គីខ្វៀន អ៊ីឡិចត្រិច ផូយវ៉ឺ ខុមផេនី ខូអ៊ិលធីឌី (Guangxi Guiquan Electric Power Company Co. Ltd)។ អនុសារណៈយោគយល់ដំបូងសំរាប់ការសិក្សារកលទ្ធភាពដែលអាចធ្វើបានដំបូង ត្រូវចុះហត្ថលេខាក្នុងខែមិថុនា ឆ្នាំ ២០០៨[130]។ វាស្តែងឲ្យឃើញថា ក្រុមហ៊ុននេះ គ្រាន់តែបានទាក់ទាញគំរោងពីដំបូងតែប៉ុណ្ណោះ ហើយបន្ទាប់មក ត្រូវបានជំនួសដោយក្រុមហ៊ុនថាមពលរបស់ប្រទេសចិនផ្សេងទៀត។

130 Xinhua, Chinese company to conduct feasibility study on dams in Cambodia, 14 August 2008.



មន្ត្រីរដ្ឋាភិបាលកម្ពុជា និងប្រធានវិស្វករក្រុមហ៊ុន *Guangxi Guiguan* បានចុះអនុសារណៈយោគយល់ ក្នុងខែមិថុនា ២០០៨[131]

អនុសារណៈយោគយល់សំរាប់ការសិក្សារកលទ្ធភាពដែលអាចធ្វើបាន ត្រូវបានចុះហត្ថលេខា ក្នុងវិច្ឆិកា ឆ្នាំ២០១០ ពេលដែលនាយករដ្ឋមន្ត្រីកម្ពុជា បានជួបជាមួយគណៈប្រតិភូចិន គឺលោកប្រធានសមាជជាតិប្រជាជនចិន ហើយបានចុះហត្ថលេខាលើការសិក្សារកលទ្ធភាពដែលអាចធ្វើបាននៃទំនប់ចំនួន៤ រួមបញ្ចូលទាំង ស្រែពកក្រោម៣ (៣០០មេហ្គាវ៉ាត់) និងស្រែពកក្រោម៤ (២២០មេហ្គាវ៉ាត់)។ អនុសារណៈនេះ បានព្រមព្រៀងគ្នាជាមួយសហគ្រាសរបស់ប្រទេសចិនផ្សេងទៀត គឺ ហ័រទៀន ខុបភឺរេសិន (Huadian Corpe-ration) ដែលត្រូវបានជូនដំណឹងថា ក្រុមហ៊ុនហ្កាន់ស៊ី ហ្គីខ្វៀន (Guanxi Guiguan) បានរុញគំរោងនេះឲ្យ[132]។ ក្នុងខែមេសា ប្រធាននាយកនៃក្រុមហ៊ុន ហ័រទៀន (Huadian) បានធ្វើដំណើរចុះទៅទីតាំងនៃទំនប់នៅទន្លេស្រែពក ក្នុងការពិនិត្យហើយនិងប្រុងប្រៀប រៀបចំដំណើរការការងារ[133]។

131 Guangxi Guiguan Electric Power Co. website, Guangxi Guiguan to expand business in Southeast Asia to develop international hydropower business, 9 June 2008. http://www.ggep.com.cn/news_detail.asp?id=18 (accessed November 2011).
132 China Low-Carbon Media Network, Wu Baoguo witnesses Cambodia Srepok hydropower signing ceremony, 9 November 2010. http://www.cndtcm.com/news/7/6323.html (accessed November 2011). See also: China Huadian
133 Corporation website, MOU Signing Ceremony in Cambodia, 8 November 2010. http://eng.chd.com.cn/news.do?cmd=show&id=6499 (accessed November 2011).



*ខែ វិច្ឆិកា ២០១០ ការចុះហត្ថលេខាលើអនុសារណៈយោគយល់សំរាប់ការសិក្សារកលទ្ធភាពដែលអាចធ្វើបានចំពោះទំនប់ ស្រែពកក្រោម៣ និងស្រែពកក្រោម៤*[134]




*ទស្សនកិច្ចទីតាំងនៃទំនប់របស់ប្រធាននាយកក្រុមហ៊ុន ហាវដៀន (Huadian) ខែមេសា ២០១១*[135]

134 China Low-Carbon Media Network, Wu Baoguo witnesses Cambodia Srepok hydropower signing ceremony, 9 November 2010.
135 China Power, Huadian Corporation arrives in Cambodia to conduct research on Srepok hydropower project, 15 April 2011.

ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈចំពោះគំរោងទាំងនេះ នៅមានកំរិត ទោះបីជាយ៉ាងនេះក្តី មានការទទួលបានព័ត៌មានតិចតួចអំពីការអភិវឌ្ឍន៍ទំនប់ស្រែពក៣ បន្ទាប់ពីសមាជិកសហគមន៍ បានសួរបុគ្គលិកក្រុមហ៊ុន ដែលបានមកធ្វើការសិក្សាស្រាវជ្រាវជាលើកដំបូងក្នុងតំបន់នោះ។ អំឡុងខែធ្នូ ឆ្នាំ ២០១០ និងខែមករា ឆ្នាំ២០១១ តំណាងសហគមន៍ក្នុងស្រុកលំផាត់ ខេត្តរតនគិរី បានសង្កេតមើលបុគ្គលិកក្រុមហ៊ុនចិននៅកន្លែងធ្វើការរបស់ពួកគេ អំឡុងពេលដែលពួកគេខួង និងយកសំណាកដី។ ការពិភាក្សាជាមួយក្រុមនេះ បានបង្ហាញថា ក្រុមការងារគេ បានយកដីយកទៅធ្វើការវិភាគ ហើយនិងអាចត្រលប់មកធ្វើការសិក្សាម្តងទៀតចន្លោះខែមិនា-មិថុនា ឆ្នាំ២០១១។ ពេលដែលតំណាងសហគមន៍ទាក់ទងទៅអាជ្ញាធរមូលដ្ឋានចង់បានព័ត៌មានបន្ថែម ពួកគាត់បានរកឃើញថា មន្ត្រីថ្នាក់មូលដ្ឋានមិនបានដឹងពីសកម្មភាពទាំងនេះទេ[136]។

បន្ទាប់ពីពិភាក្សាចង់ដឹងពីព័ត៌មានលំអិតពីគំរោង ជាមួយនិងប្រធានក្រុមការងាររបស់ក្រុមហ៊ុន តំណាងសហគមន៍បានប្រាប់ឲ្យដឹងថា ទំនប់នេះសាងសង់លាតសន្ធឹងកាត់ទន្លេ ចាប់ពីភ្នំភូដៀវ ដល់ភ្នំភូហែនខាវ ក្នុងចំងាយប្រមាណជា១០គីឡូម៉ែត។ ក្រុមហ៊ុនបានបង្ហាញទៀតថា ទំនប់នេះមានកម្ពស់ប្រមាណ ៥៣ម៉ែត្រ ហើយវាត្រូវបានគេគិតថា នឹងអាចផលិតអគ្គិសនីបាន ៣០០ មេហ្គាវ៉ាត់[137]។ ការសិក្សាមួយដែលបានធ្វើដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងតំបន់ផ្ទៃរាងស្តុកទឹកទន្លេ៣ (បានពិភាក្សាច្រើនក្នុងផ្នែក ៣.១) បានប៉ាន់ស្មានពីផ្ទៃអាងស្តុកទឹករបស់ទំនប់ស្រែពកក្រោម៣ ថាមានទំហំរហូតដល់ ៧៥៨ $km^2$ ឬ ៧៥.៨០០ ហិកតា[138]។

អ្នកសារព័ត៌មានជនជាតិចិនបានធ្វើដំណើរទៅកាន់តំបន់នោះ ដើម្បីស៊ើបអង្កេតពីគំរោង ហើយបានឃើញសំភារៈផ្សេងៗរបស់ក្រុមហ៊ុនចិន ដែលបានទុកនៅក្រោមផ្ទះរបស់អ្នកភូមិ។ ដែលមានស្លាកសំគាល់ក្រុមហ៊ុនថា *ឆាយណា សាវធើន ផូយវ៉ឺ ហ្គ្រីដ (China Southern Power Grid)* ដែលអាចសន្មត់បានថាក្រុមហ៊ុននេះ បានចុះកិច្ចសន្យាដោយក្រុមហ៊ុន ហ័រទៀន (Huadian) ដើម្បីធ្វើការសិក្សា រកលទ្ធភាពដែលអាចធ្វើបាន ឫក៏យ៉ាងហោចណាស់ ជាផ្នែកណាមួយនៃការសិក្សានេះ។ រូបភាពនៃសំភារៈទាំងនោះ ត្រូវបង្ហោះតាមបណ្តាញសារព័ត៌មាន[139]។ រហូតដល់បច្ចុប្បន្ននេះ CSG (ឆាយណា សាវធឺន ផូយវ៉ឺ ហ្គ្រីដ) ត្រូវបានភ្ជាប់ទៅនិងគំរោងទំនប់វារីអគ្គិសនី៦ផ្សេងទៀតក្នុងប្រទេសកម្ពុជា រួមបញ្ចូលទាំងទំនប់សំបូរតាមដងទន្លេមេគង្គ។ អ្វីដែលគួឲ្យចាប់អារម្មណ៍នោះគឺ ក្រុមហ៊ុនបានប្រកាសថា ក្រុមហ៊ុនបានសម្រេចចិត្តលប់ចោលនូវគំរោង ដែលមានសក្តានុពលទាំងអស់របស់ខ្លួនក្នុងប្រទេសកម្ពុជា

---

136 Information from personal blog of 3SPN Advocacy Program Coordinator, http://www.wpiggy.blogspot.com/ (accessed November 2011).
137 Ibid.
138 ADB-RETA 40082, 3S Technical Sheets Key Topic 8 – Large scale infrastructure development in the 3Ss, 8a Hydropower Development (p12). http://reta.3sbasin.org/index.php?option=com_docman&Itemid=184&lang=en (accessed November 2011).
139 http://zhanghong.blog.caixin.cn/archives/23408#comment_top (accessed November 2011).

ព្រោះតាមការរាយការណ៍មក ថាមានការព្រួយបារម្ភជាច្រើនអំពីផលប៉ះពាល់បរិស្ថាន និងសង្គមដោយសាគំរោងទាំងនោះ[140]។

ប្រសិនបើការសាងសង់ទំនប់ស្រែពកក្រោម៣ត្រូវបានអនុញ្ញាតិ វានឹងមានទីតាំងត្រឹមតែ៣០០-៤០០ម៉ែត្រប៉ុណ្ណោះ ភាគខាងលើភូមិថ្មី ស្ថិតក្នុងដែនជំរកសត្វព្រៃលំផាត់ ខេត្តរតនគិរី ហើយទំហំ ៧៥៨km² ទំនងជាមានផលប៉ះពាល់លាតសន្ធឹងលើតំបន់ការពារនេះ។ ព័ត៌មានតែបន្តិចបន្តួចប៉ុណ្ណោះ ដែលអាចត្រូវបានដឹងជាសាធារណៈ ចំពោះព័ត៌មានលំអិតស្តីពីទំនប់ស្រែពក៤ ទោះបីជាយ៉ាងនេះក្តី គេដឹងថា ទំនប់នេះមានទីតាំងក្នុងតំបន់ព្រៃការពារមណ្ឌលគិរី ហើយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានប៉ាន់ ប្រមាណថាសក្តានុពលនៃទំហំផ្ទៃអាងស្តុកទឹក អាចគ្របដណ្តប់លើ ៥៤០ km²[141]។ តំបន់ទាំងពីរមានដែនជំរកសត្វព្រៃលំផាត់ ហើយនិងតំបន់ព្រៃការពារមណ្ឌលគិរី ត្រូវរៀបចំដោយសហពន្ធ័អន្តរជាតិសំរាប់ការអភិរក្សធម្មជាតិ (IUCN) ហើយតំបន់ទាំងពីរ នឹងទទួលរងគ្រោះពីការជន់លិច ប្រសិនបើ គំរោងផែនការទាំងនេះនៅតែបន្តរទៅមុខ។

វាដូចករណីនៅទន្លេសេសានដែរ ការនេសាទជាប្រភពចិញ្ចឹមជីវិតដ៏សំខាន់មួយ របស់ប្រជាជនដែលកំពុងរស់នៅក្បែរដងទន្លេស្រែពក ហើយទំនប់ដែលមានទំហំធំៗក្នុងតំបន់នេះ វាបានធ្វើឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរលើធនធានជលផល។ មានករណីសិក្សាជាច្រើនបានរកឃើញថា ត្រីបានធ្វើចរាចរពីទន្លេមេគង្គទៅទន្លេសេកុង និងទន្លេស្រែពក ហើយទន្លេស្រែពកមានតំបន់សំខាន់ៗជាច្រើន សំរាប់ត្រីពងកូន[142]។

**ក្រុមហ៊ុនថាមពលអគ្គីសនី** Guangxi Guiguan **ខូអិលធីឌី និងសាជីវកម្ម** Datang **ចិន**

ក្រុមហ៊ុន **ថាមពលអគ្គីសនី** Guangxi Guiguan **ខូអិលធីឌី** ជាក្រុមហ៊ុនរបស់ប្រទេសចិនដែលធ្វើការផ្តោតសំខាន់លើការផលិត និងចែកចាយអគ្គិសនីដើដោយចរន្តទឹក និងកំដៅនៅក្នុងប្រទេស ចិន[143]។ ក្រុមហ៊ុន ហ្កាន់ស៊ី ហ្គីខ្វៀន ជាភាគហ៊ុនមួយផ្នែកនៃក្រុមហ៊ុន ឆាណា ដាតាំង ខុបភីរេសិន ដែលជាក្រុមហ៊ុនរបស់រដ្ឋ ហើយក៏ជាក្រុមហ៊ុនថាមពលដ៏ធំមួយក្នុងប្រទេសចិនផងដែរ[144]។

ក្នុងឆ្នាំ ២០០៨ ហ្កាន់ស៊ី ហ្គីខ្វៀន បានចុះអនុសារណៈជាមួយក្រសួងឧស្សាហ៍កម្មរ៉ែ និងថាមពល ដើម្បីសិក្សាលើទំនប់ស្រែពកក្រោម៣ និងស្រែពកក្រោម៤ក្នុងប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ថ្វីបើមិនមានការបញ្ជាក់ជាផ្លូវការណាមួយនៅពេលកំពុងសរសេរនេះក៏ដោយ ក្រុមហ៊ុន

140 http://zhanghong.blog.caixin.cn/archives/23408#comment_top (accessed November 2011).
141 ADB-RETA 40082, 3S Technical Sheets Key Topic 8 – Large scale infrastructure development in the 3Ss, 8a Hydropower Development (p12). Available at http://reta.3sbasin.org/index.php?option=com_docman&Itemid=184&lang=en (accessed November 2011).
142 WWF Greater Mekong – Cambodia Country Programme, Consultancy Report: Fish Abundance Survey and Installation of Fish Monitoring System on the Srepok River, June 2008.
143 See company website: http://www.ggep.com.cn/
144 China Datang Corporation website: http://www.china-cdt.com/en/index.html, Guangxi Branch website: http://www.dtgx.cn/index.php (accessed November 2011).

ហ្កាន់ស៊ី ហ្គីខ្វៀន ឥឡូវនេះបានប្រានចោលគំរោងអភិវឌ្ឍន៍ទាំងពីរនេះ។ ឯកសារយុទ្ធសាស្ត្ររបស់ ដាតាំង (Datang) កាលពីខែតុលា ឆ្នាំ២០១០ បានស្នើសុំឲ្យបញ្ចប់ការសិក្សារកលទ្ធភាពដែលធ្វើបាននៃគំរោងឲ្យបានឆាប់បំផុត ដើម្បីឲ្យក្រុមហ៊ុនអាចសំរេចចិត្តថា តើគួរធ្វើការវិនិយោគដោយផ្ទាល់ ឬក៏ត្រូវមានការចូលរួម[145]។ មានសេចក្តីរាយការណ៍ក្រោយមកទៀតថា មានក្រុមហ៊ុនចិនផ្សេងទៀត បាន ចុះអនុសារណៈដើម្បីសិក្សាគំរោងទាំងពីរនេះ ដោយលើកឡើងថា ក្រុមហ៊ុន ហ្កាន់ស៊ី ហ្គីខ្វៀន (Guanxi Guiquan) ពិតជាបានសំរេចចិត្តថាត្រូវការការសហការបន្ថែម ហើយបានប្រានចោលនូវ គំរោងនេះ។

**សាជីវកម្ម ហ័រទៀន របស់ប្រទេសចិន *(China Huadian Corporation)***

អនុសារណៈលើកទីពីរ ត្រូវបានចុះហត្ថលេខាសំរាប់ទំនប់ស្រែពកក្រោម៣ និងស្រែពកក្រោម៤ ពេលដែលនាយករដ្ឋមន្ត្រីកម្ពុជាបានជួបគណៈប្រតិភូចិនក្នុងខែវិច្ឆកា ឆ្នាំ២០១០។ អនុសារណៈបានចុះហត្ថលេខាជាមួយលោក **វ៉ូ បាងហ្គួរ** ប្រធាន និងជាអគ្គលេខាធិការបក្សនៃគណៈកម្មាការអចិន្ត្រៃសមាជជាតិប្រជាជនចិន ក្នុងនាមតំណាងឲ្យភាគហ៊ុនសាជីវកម្មហ័រទៀន (Haudian Corperation) [146]។ ក្នុងខែមេសា ឆ្នាំ២០១១ ប្រធាននាយកប្រតិបត្តិនៃ ហ័រទៀន បានធ្វើដំណើរទៅកាន់តំបន់ទីតាំងនៃ ទំនប់ដើម្បីត្រួតពិនិត្យ និងប្រុងប្រៀបរៀបចំការងារ ដែលអនុវត្តដោយ ហ័រទៀន (Huadian) [147]។

ហ័រទៀន (Huadian) បានចុះហត្ថលេខារួចហើយ ទាក់ទងនិងប្រតិបត្តិការថាមពលផ្សេងទៀត ក្នុងប្រទេសកម្ពុជា រួមបញ្ចូលទាំងកិច្ចសន្យាអភិវឌ្ឍន៍ស្ថានីយ៍ទំនប់វារីអគ្គិសនីឫស្សីជ្រុំក្នុងខេត្តកោះកុង ក្រោមកិច្ចសន្យា BOT ៣០ឆ្នាំ (សាងសង់ ប្រត្តិបតិការ ការផ្ទេរ)។ គំរោងនេះ មានទំហំទឹកប្រាក់ចំនួន ៥៥៨លានដុល្លាសហរដ្ឋអាមេរិក ហើយមានសមត្ថភាពផលិត ៣៣៨ មេហ្កាវ៉ាត់[148]។ ធនាគារនាំចេញ និងនាំចូលរបស់ប្រទេសចិន (China Export-Import Bank) ជាអ្នកផ្តល់មូលនិធិដល់គម្រោងនេះ ហើយយោងតាមក្រុមហ៊ុនច្បាប់ដែលផ្តល់ប្រឹក្សាដល់ធនាគារ (China-Eximbank) ឲ្យដឹងថា កិច្ចព្រមព្រៀងនេះ "នឹងក្លាយជាគំរូសំរាប់ការវិនិយោគនាពេលអនាគតដោយធនាគារ (China Eximbank) និងអ្នកអភិវឌ្ឍន៍ជនជាតិចិនផ្សេងទៀត ក្នុងប្រទេសកម្ពុជា លើវិស័យថាមពល"[149]។

ក្រុមហ៊ុន ហ័រទៀន (Huadian) ក៏បានចូលរួមចំនែកក្នុងការអភិវឌ្ឍន៍ចំនួនរោងចក្រថាមពលធ្យូងថ្មក្នុងប្រទេសកម្ពុជា ដោយចាប់ដៃគូជាមួយក្រុមហ៊ុនម៉ាឡេស៊ីផងដែរ។

145 Datang Guangxi Website, Datang Guangxi Branch Development Study, http://www.dtgx.cn/article_detail.php?aid=703 (accessed November 2011).
146 China Low-Carbon Media Network, Wu Baoguo witnesses Cambodia Srepok hydropower signing ceremony, 9 November 2010.
147 China Power, Huadian Corporation arrives in Cambodia to conduct research on Srepok hydropower project, 15 April 2011.
148 Global Times, China Huadian HK to build hydropower station in Cambodia, 1 April 2010.
149 Herbert Smith website, Herbert Smith's Singapore energy team advises China Eximbank on US$412m project financing of a greenfield hydropower plant in Cambodia, 13 July 2010. http://www.herbertsmith.com/News/news130710.htm (accessed November 2011).

## ២.៥ ទំនប់សេកុងក្រោម

**ទំនប់សេកុងក្រោមៈ ព័ត៌មានពិត**

ទំនប់សេកុងក្រោម មានទីតាំងប្រហែលជា ២0km ភាគខាងលើក្រុងស្ទឹងត្រែង។ អគ្គិសនីវៀតណាម (EVN) បានចុះហត្ថលេខាលើអនុសារណៈដើម្បីធ្វើការសិក្សាលទ្ធភាពដែលអាចធ្វើបាន។

សមត្ថភាព: ១៩០ មេហ្គាវ៉ាត់
កម្ពស់ទំនប់: មិនទាន់ដឹង
ទំហំអាងស្តុកទឹក: មិនទាន់ដឹង
តំលៃប៉ាន់ស្មាន: ៤០៧លានដុល្លាសហរដ្ឋអាមេរិក
ប្រត្តិបតិការថាមពល: មិនទាន់ដឹង
អ្នកអភិវឌ្ឍន៍:

- អគ្គិសនីវៀតណាម (EVN)

ក្នុងខែកក្កដា ឆ្នាំ២០១១ មានសេចក្តីរាយការណ៍ក្នុងសារព័ត៌មានវៀតណាមថា អគ្គិសនីវៀតណាម បានចុះហត្ថលេខាលើអនុសារណៈយោគយល់ជាមួយក្រសួងឧស្សាហ៍កម្ម រ៉ែ និងថាមពល ដើម្បីចូលរួមធ្វើការសិក្សាលើទំនប់វារីអគ្គិសនីសេកុងក្នុងកំលាំងថាមពល ១៩០ មេហ្គាវ៉ាត់ដែលត្រូវការ វិនិយោគក្នុងទឹកប្រាក់ ៤០៧លានដុល្លាសហរដ្ឋអាមេរិក[150]។ ទំនប់នេះ មានទីតាំងប្រហែលជា២0km ផ្នែកខាងលើនៃក្រុងស្ទឹងត្រែង ប៉ុន្តែក្រៅពីនេះ មានព័ត៌មានតិចតួចបំផុតទាក់ទងនិងគំរោងនេះ ដែលទៅដល់ដៃសាធារណៈជនទូទៅ។

## ២.៦ ខ្សែរបញ្ជូនអគ្គិសនី

ប្រទេសកម្ពុជា ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា មានសមត្ថភាពទាបក្នុងការផលិតថាមពល ដើម្បីបំពេញទៅដល់តំរូវការក្នុងស្រុក ហេដ្ឋារចនាសម្ពន្ធ័សំរាប់បញ្ជូនថាមពលក្នុងប្រទេសនេះ ក៏មិនគ្រប់គ្រាន់ ហើយតំលៃភ្លើងអគ្គីសនីមានតម្លៃខ្ពស់កប់ពពក ដែលទាំងអស់នេះ សុទ្ធសឹងជាផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាជាច្រើន ហើយវាក៏ជាឧបសគ្គដ៏ធំមួយ ទៅដល់ការអភិវឌ្ឍន៍ជាតិដែរ។ ទោះបីជាយ៉ាងណាក៏ដោយ វានៅមិនច្បាស់ថាតើបច្ចុប្បន្ននេះ ដើម្បីបំពេញតម្រូវការអគ្គិសនីក្នុងស្រុក ថាមពលចំនួនប៉ុន្មានដែលត្រូវផលិតចេញពីទំនប់វារីអគ្គិសនីក្នុងតំបន់ទន្លេ៣ និងមានថាមពលចំនួនប៉ុន្មាន ដែលនឹងត្រូវលក់ចេញទៅខាងក្រៅ។ វាក៏មិនទាន់ច្បាស់ផងដែរថាតើតំបន់ណាដែលនឹងទទួលអត្ថប្រយោជន៍ ពីការផលិតថាមពលនេះ ហើយតើនឹងមានផលប៉ះពាល់អ្វីខ្លះ

150 VNA, EVN unit speeds up work on Lao, Cambodian dams, 8 July 2011.

លើតំលៃអគ្គិសនីដែលអតិថិជនត្រូវបង់។ នេះប្រហែលព្រោះតែមានសេចក្តីថ្លែងការណ៍មិនចុះសម្រុងគ្នារវាងមន្ត្រីរដ្ឋាភិបាល និងតំណាងក្រុមហ៊ុន ហើយនិងមួយផ្នែកទៀតប្រហែលដោយសារខ្វះការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។ ព័ត៌មានផ្សេងៗ ដែលអាចរក និងប្រើប្រាស់បាននៅពេលថ្មីៗនេះ មានសង្ខេបដូចខាងក្រោម។

អគ្គិសនីវៀតណាម បានចុះអនុសារណៈជាមួយរដ្ឋាភិបាលវៀតណាម និងកម្ពុជា ដើម្បីភ្ជាប់ទំនប់សេសានក្រោម២ និងទំនប់សេសាក្រោម១/៥ ទៅកាន់ប្រព័ន្ធបណ្តាញថាមពលកម្ពុជា និងវៀតណាម។ យោងលើអនុសារណៈនេះ ទំនប់សេសានក្រោម២ នឹងភ្ជាប់ជាមួយអនុស្ថានីយ៍ក្នុងទីរួមខេត្តស្ទឹងត្រែង តាមរយៈខ្សែរបញ្ជូនចរន្ត២ខ្សែរ មានកំលាំង ២២០គីឡូវ៉ុល។ ទំនប់នេះ នឹងត្រូវតភ្ជាប់ទៅអនុស្ថានីយ៍នៅសេសានក្រោម១/៥តាមរយៈខ្សែរបញ្ជូនចំងាយ ១៧២km ក្នុងកំលាំងថាមពលដូចគ្នា។ តាមផ្លូវទៅទំនប់សេសានក្រោម១/៥ ខ្សែរបណ្តាញនេះ នឹងរត់កាត់ក្រុងបានលុង ខេត្តរតនគិរី ដែលជាកន្លែងអនុស្ថានីយ៍ថ្មីមួយត្រូវសាងសង់។ ទំនប់សេសានក្រោម១/៥ នឹងត្រូវតភ្ជាប់បន្តទៅខ្សែរកាបរដ្ឋរស់ប្រទេសវៀតណាម ក្នុងកំលាំងថាមពល ២២០គីឡូវ៉ុល។ ឯកសាររបស់អគ្គិសនីវៀតណាម បានបង្ហាញថា ទំបន់សេសានក្រោម១/៥ នឹងបំពេញបានតាមតំរូវការអគ្គិសនីដែលចេះតែកើនឡើងនៅក្នុងតំបន់ទីតាំងគំរោង ទាំងខាងប្រទេសវៀតណាម និងប្រទេសកម្ពុជា ទោះបីជា នៅមិនទាន់ច្បាស់ថាតើមានថាមពលចំនួនប៉ុន្មាននឹងត្រូវផ្គត់ផ្គង់ក្នុងមូលដ្ឋានក៏ដោយ ហើយអ្វីដែលគួឲ្យកត់សំគាល់នោះគឺថាទំនប់នេះ ស្ថិតនៅចំតំបន់ព្រំដែនដាច់ស្រយាល ដែលបច្ចុប្បន្នតំរូវការអគ្គិសនីនៅតិចតួចនៅឡើយ[151]។

កាលពី ២-៣ឆ្នាំកន្លងទៅ សេចក្តីថ្លែងការណ៍ជុំវិញការចែកចាយថាមពល ដែលផលិតដោយទំនប់សេសានក្រោម២ មានលក្ខណៈស្រពិចស្រពិល ហើយមានការប្រឆាំងជំទាស់ជាច្រើន។ នៅក្នុងឆ្នាំ២០១១ គេបានរាយការណ៍ថា ៥០% នៃថាមពល អាចត្រូវបានទិញដោយប្រទេសកម្ពុជា ហើយចំនួនដែលនៅសល់ នឹងត្រូវនាំចេញទៅវៀតណាម[152]។ អ្នកសង្កេតការជាច្រើន បានចោទជាសំណួរទៅលើការអះអាងទាំងឡាយដែលថា ចំនួនថាមពលទាំងអស់នៃទំនប់សេសាក្រោម២ នឹងប្រើប្រាស់ក្នុងប្រទេសកម្ពុជា។ មិនមានហេតុផលសំខាន់ៗ ដែលបង្ហាញពី សមត្ថភាពបញ្ជូនថាមពលហួសពីភាគព្យសាន ហើយតំរូវការថាមពលនៅក្នុងភូមិភាគព្យសានដែលមានមនុស្សរស់នៅតិចតួច មានកំរិតទាបជាងឆ្ងាយពីសមត្ថភាពផលិតថាមពលរបស់ទំនប់។

ក្នុងសិក្ខាសាលាមួយដែលដឹកនាំដោយអង្គការមិនមែនរដ្ឋាភិបាល ក្នុងខែមិថុនា ឆ្នាំ២០១១ នៅពេលដែលមានការសង្កត់ធ្ងន់ពីទីកន្លែងដែលថាមពលអគ្គិសនីនឹងត្រូវចែកចាយ មន្ត្រីម្នាក់មកពីក្រសួងបរិស្ថានបានបញ្ជាក់ថា ក្រសួងបរិស្ថានបានធ្វើការសង្កេតស្ថានការណ៍យ៉ាងម៉ត់ចត់បំផុត មានតែថាមពលដែលនៅសល់ពីការប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងតំបន់ប៉ុណ្ណោះ ដែលនឹងត្រូវលក់ទៅឲ្យប្រទេស

151 EVN, Summary Report: Lower Sesan 1/Sesan 5 hydropower project, 30 January 2010.
152 VNA, EVN unit speeds up work on Lao, Cambodian dams, 8 July 2011.

វៀតណាម[153]។ ចុងខែកក្កដា ឆ្នាំ២០១១ នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានមានប្រតិកម្មទៅនិងការលើកឡើងថា ទំនប់សេសានក្រោម២ នឹងមិនផ្គត់ផ្គង់ដល់ប្រទេសកម្ពុជា ហើយបានបញ្ជាក់ថា ១០០% នៃថាមពល នឹងយកមកប្រើប្រាស់ក្នុងប្រទេសកម្ពុជា[154]។ ទោះបីជាយ៉ាងនេះក្តី នេះវាផ្ទុយពីសេចក្តីថ្លែងការណ៍របស់វៀតណាមដែលថា ខ្លួនបានព្រមព្រៀងជាមួយកម្ពុជា នឹងនាំចេញថាមពលអគ្គិសនីចំនួន៥០%ពីទំនប់នេះ ទៅប្រទេសវៀតណាម។ មិនមាននការជាប់ពាក់ព័ន្ធទៅនិងការពិនិត្យមើលឡើងវិញពីវិស័យថាមពលវារីអគ្គិសនីថ្នាក់ជាតិ ឆ្នាំ២០០៣ ដែលរៀបចំឡើងដោយក្រសួងឧស្សាហ៍កម្ម រ៉ែ និងថាមពល ដែលបានអះអាងថា ទំហំនៃគំរោងទំនប់វារីអគ្គិសនីលើដងទន្លេមេគង្គ ព្រមទាំងគំរោងធំៗដ៏ទៃទៀតនៅតាមដៃទន្លេមេរបស់វា មានលក្ខណៈធំខ្លាំងពេករហូតដល់មិនអាចធ្វើការអភិវឌ្ឍន៍ បើគ្រាន់តែផលិតដើម្បីតែផ្គត់ផ្គង់ក្នុងស្រុកតែមួយមុខ។ ប្រសិនបើអភិវឌ្ឍន៍ ថាមពលដែលផលិតបានប្រាកដជាត្រូវនាំចេញទៅវៀតណាមខាងត្បូង ឬប្រទេសថៃ ជាទីកន្លែងដែលមានឱនភាពថវិកាក្នុងការផលិតថាមពលអគ្គិសនី[155]។

ទំនប់សេសានក្រោម២ ត្រូវបានព្យាករថា នឹងមិនដំណើរការរហូតដល់ឆ្នាំ ២០១៧ទេ ហើយជាការសន្មត់ ការសាងសង់ខ្សែបណ្តាញចែកចាយ នឹងត្រូវធ្វើឡើងព្រមគ្នាជាមួយការសាងសង់ទំនប់។ ដើម្បីប្រើប្រាស់ថាមពលផលិតពីទំនប់សេសានក្រោម២ ឲ្យបានជិត៥០% (តាមពិត ថាមពល ១០០% ត្រូវបានស្នើរដោយនាយករដ្ឋមន្ត្រី) បណ្តាញបញ្ជូនភ្លើងអគ្គិសនីដែលមានកំលាំងខ្លាំង នឹងត្រូវសាងសង់ដើម្បីតភ្ជាប់ពីទំនប់ទៅកាន់ទីរួមខេត្តផ្សេងៗ និងទៅរាជធានីភ្នំពេញ។ កម្ពុជា មានផែនការអភិវឌ្ឍន៍បណ្តាញបញ្ជូនភ្លើងអគ្គិសនីដែលមានកំលាំងខ្លាំង ដែលផ្នែកខ្លះត្រូវបានអភិវឌ្ឍន៍រួចហើយ។ គំរោងវារីអគ្គិសនីក្នុងតំបន់ទន្លេ៣ អាចត្រូវបានដឹងមុនថា នឹងត្រូវភ្ជាប់ជាមួយបណ្តាញនេះ។ ទោះបីជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ វានៅមិនទាន់ច្បាស់ទេ ថាតើមានថវិកាគ្រប់គ្រាន់ សំរាប់ធ្វើការអភិវឌ្ឍន៍បណ្តាញទាំងអស់នេះ ហើយវាក៏មិនទាន់ច្បាស់ផងដែរថា តើមានការវាយតំលៃផលប៉ះពាល់អ្វីខ្លះដែលបានធ្វើរួចហើយមកដល់ពេលនេះ។ ខាងក្រោមនេះ គឺជាគំរោងស្នើរសុំ ដើម្បីពង្រីកបណ្តាញបញ្ជូនថាមពលក្នុងប្រទេសកម្ពុជា ចូលទៅកាន់ភាគឦសាន ដែលតាមទ្រឹស្តី អាចភ្ជាប់គំរោងវារីអគ្គិសនីតំបន់ទន្លេ៣ ទៅកាន់តំបន់ផ្សេងៗទៀតប្រទេស៖

- **ខេត្តស្ទឹងត្រែង** - **ក្រចេះ៖** ដោយស្ថិតនៅភាគខាងត្បូងខេត្តស្ទឹងត្រែង និងតាមផ្លូវទៅភ្នំពេញ ក្រចេះ គឺជាទីរួមខេត្តបន្ទាប់។ ធនាគារអេហរណ នីហរណប្រទេសឥណ្ឌា បានផ្តល់ថវិកាចំនួន ១៥លានដុល្លាសហរដ្ឋអាមេរិក ដើម្បីពង្រឹងខ្សែបញ្ជូនចរន្តដែលមានកំលាំង ២៣០គីឡូវ៉ាត់[156] ទៅកាន់ខេត្តទាំងពីរ។ បទបង្ហាញរបស់ក្រសួងឧស្សាហ៍កម្ម រ៉ែ និងថាមពល ស្តីពីផែនការ

153 Phnom Penh Post, Electricity for Vietnam, 1 June 2011.
154 Letter from Prime Minister Hun Sen, 28 July 2011.
155 Cambodia National Mekong Committee (prepared by MIME), National Sector Review 2003: Hydropower, June 2003 (p8).
156 Export-Import Bank of India, Press Release: Exim Bank to Assist Transmission Line Project in Cambodia, 5 March 2010.

អភិវឌ្ឍន៍ថាមពល និងវារីអគ្គិសនីជាតិ បានលើកឡើងថា ខេត្តស្ទឹងត្រែងនឹងតភ្ជាប់ទៅខេត្តក្រចេះ តាមរយៈខ្សែរបញ្ជូនចរន្តកំលាំងភ្លើង ២៣០គីឡូវ៉ុលនៅត្រឹមឆ្នាំ ២០១២[157]។

- **ខេត្តក្រចេះ - ខេត្តកំពង់ចាម៖** យោងទៅលើផែនការអភិវឌ្ឍន៍ថាមពលរបស់ក្រសួងឧស្សាហ៍កម្ម រ៉ែ និងថាមពល ខេត្តក្រចេះ ត្រូវតភ្ជាប់ទៅខេត្តកំពង់ចាមតាមខ្សែរបញ្ជូនចរន្តកំលាំង២៣០គីឡូវ៉ុល នៅត្រឹមឆ្នាំ២០១២។ ក្រុមហ៊ុនដែលត្រូវទទួលខុសត្រូវសំរាប់ខ្សែរបណ្តាញនេះ គឺ ខាំបូឌៀរ យូធីលីធី ភីធីអ៊ី អ៊ិលធីឌី (Cambodia Utilities Pte. Ltd)[158] ដែលមានភាគហ៊ុនរបស់ក្រុមហ៊ុនម៉ាឡេស៊ី *លីដឺ យូនីវើសល ហូលឌីង* (LEADER Universal Holdings) [159]។ ទោះបីជាយ៉ាងណាក៏ដោយ គេហទំព័រ និងរបាយការប្រចាំឆ្នាំរបស់ LEADER មិនបានបញ្ជាក់អំពី គំរោងនេះទេ។ សន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្នាំ២០១០ បានបញ្ជាក់ថាប្រទេសកម្ពុជា កំពុងតែស្វែងរកថវិកាសំរាប់ខ្សែរបណ្តាញនេះ[160]។
- **ខេត្តកំពង់ចាម - រាជធានីភ្នំពេញ** ៖ ក្នុងខែមករា ឆ្នាំ២០១០ រដ្ឋាភិបាលកម្ពុជាបានអនុម័តគំរោង តភ្ជាប់បណ្តាញបញ្ជូនចរន្តកំលាំង២៣០គីឡូវ៉ុល ពីខេត្តកំពង់ចាមទៅរាជធានីភ្នំពេញ។ អ្នក អភិវឌ្ឍន៍ គឺក្រុមហ៊ុន ខាំបូឌា ត្រេនស្មីសិន អ៊ិលធីឌី (Cambodia Transmission Ltd) ដែលជាម្ចាស់ភាគហ៊ុនទាំងមូលរបស់ក្រុមហ៊ុនម៉ាឡេស៊ី ឈ្មោះ *លីដឺ យូនីវើសល ហូលឌីង* (LEADER Universal Holdings)[161] ។

ខ្សែបញ្ជូនចរន្ត និងអនុស្ថានីយ៍ពាក់ព័ន្ធ នឹងត្រូវអភិវឌ្ឍន៍ក្រោមកិច្ចសន្យា BOT (សាងសង់ ប្រតិបត្តិការ ផ្ទេរ) រយៈពេល២៥ឆ្នាំ ក្នុងទឹកប្រាក់ ១០៧.៦លានដុល្លាសហរដ្ឋអាមេរិក។ ក្រុមហ៊ុន ខាំបូឌា ត្រេនស្មីសិន (CTL) នឹងរៀបចំគំរោង ផ្តល់ហិរញ្ញវត្ថុ សាងសង់ ដំណើរការ និងថែរក្សាក្នុងអំឡុងពេលនៃកិច្ចសន្យា។ គំរោងស្នើរសុំចាប់ផ្តើមពីខែកក្កដា ២០១២ ហើយនិងបញ្ចប់នៅចុងឆ្នាំ២០១៣។ យោងទៅលើកិច្ចសន្យារបស់គំរោង គំរោងនេះ នឹងបំពេញផ្នែកមួយ នៃផែនការអភិវឌ្ឍន៍ប្រព័ន្ធចែកចាយអគ្គិសនីកម្ពុជា និងជួយព្រងីកបណ្តាញចែកចាយ កំលាំង ២៣០ គីឡូវ៉ុល នៅពេលអនាគត ទៅដល់ផ្នែកផ្សេងៗទៀតនៃប្រទេសជុំវិញបឹងទន្លេសាប ដែលជាបឹងទឹកសាបធំបំផុតនៅអាស៊ីអាគ្នេយ៍ស្ថិតក្នុងខេត្តសៀមរាប ប្រទេសកម្ពុជា[162]។

157 Presentation by Victor Jona, 16 March 2011.
158 Ibid.
159 See LEADER's annual reports: http://www.leaderuniversal.com/investor_centre/annualReports.asp
160 Speech by Prime Minister Hun Sen, Selected Comments at the Groundbreaking of the Construction of Russei Jrum Hydropower in the District of Mondul Seima, Koh Kong Province, 28 December 2010, http://www.cnv.org.kh/2010_releases/28dec10_russeijrum-hydro-power_comments.html (accessed November 2011).
161 See LEADER's annual reports: http://www.leaderuniversal.com/investor_centre/annualReports.asp
162 LEADER Universal Holdings announcement, Signing of power transmission agreement, implementation agreement and lease agreement for 230 kilovolt power transmission system project from Phnom Penh to Kampong Cham, Cambodia

ជាងនេះទៀតសោត បទបង្ហាញរបស់ក្រសួងឧស្សាហ៍កម្ម រ៉ែ និងថាមពល ឆ្នាំ២០១១ យោងតាមការបង្ហាញខាងលើ បានបញ្ជាក់ថា ខ្សែបញ្ជូនចរន្តចាស់ ពីខេត្តកំពុងចាម ទៅរាជធានីភ្នំពេញ នឹងត្រូវកែលម្អឲ្យទៅជាបណ្តាញដែលមានកំលាំង២៣០គីឡូវ៉ុល ដើម្បីមានសមត្ថភាពអាចបញ្ជូនថាមពល ពីទំនប់សេសានក្រោម២ និងទំនប់ស្រែពកក្រោម៣បាន។ ការបង្កើនកំលាំងថាមពលនេះ ត្រូវបានព្យាករថា នឹងអាចប្រតិបត្តិបានត្រឹមឆ្នាំ២០១៧ ជាឆ្នាំដែលទំនប់ សេសានក្រោម២ សាងសង់រួចរាល់តាមពេលកំណត់[163]។

- **ខេត្តកំពង់ចាម - កំពង់ធំ - សៀមរាប៖** ក៏មានផែនការបញ្ជូនថាមពល ២៣០គីឡូវ៉ុល ភ្ជាប់ពីខេត្តកំពង់ចាម ទៅខេត្តសៀមរាប ឆ្លងកាត់ខេត្តកំពង់ធំផងដែរ។ ក្រុមហ៊ុនកូរ៉េ KTC ជាអ្នកអភិវឌ្ឍន៍បណ្តាញបញ្ជូនចរន្ត និងសាងសង់អនុស្ថានីយ៍ពាក់ព័ន្ធ[164]។ ការសិក្សាពីលទ្ធភាពដែលអាចធ្វើបានរបស់បណ្តាញនេះ ត្រូវបានធ្វើឡើងដោយក្រុមហ៊ុន ខេធីស៊ី (KTC) និង អូអ៊ិក អ៊ិនជី ណើរីង (OX Engineering) ក្នុងឆ្នាំ ២០០៧[165]។
- **ប្រទេសឡាវ - ខេត្តស្ទឹងត្រែង - ប្រទេសវៀតណាម៖** ដោយសារចំនុចនេះ នឹងត្រូវពិភាក្សាបន្ទាប់ នៅក្នុងផ្នែក ៣.១ ក៏មានការពិភាក្សាផងដែរអំពីបណ្តាញបញ្ជូនថាមពលកំលាំង ៥០០ គីឡូវ៉ុល ភ្ជាប់ពីភាគខាងត្បូងប្រទេសឡាវ ទៅខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា មុនពេលបន្តភ្ជាប់ទៅភាគកណ្តាលនៃប្រទេសវៀតណាម។ មានព័ត៌មានតិចតួចបំផុត ដែលអាចដឹងជាសាធារណៈទាក់ ទងនិងបណ្តាញបញ្ជូនចរន្តនេះ។

ថ្វីបើបច្ចុប្បន្ននេះ ប្រទេសកម្ពុជាត្រូវការនាំចូលអគ្គិសនីពីប្រទេសជិតខាង ដើម្បីឲ្យគ្រប់ទៅនិងតំរូវការក៏ដោយ ក្រសួងឧស្សាហ៍កម្ម រ៉ែ និងថាមពល ធ្លាប់បានបង្ហាញថា ប្រទេសកម្ពុជានឹងមានថាមពលខ្លួនឯងគ្រប់គ្រាន់ត្រឹមឆ្នាំ២០១២ និងអាចនាំចេញថាមពលចំនួន ១,000 មេហ្គាវ៉ាត់នៅត្រឹមឆ្នាំ ២០១៦[166] និងនាំចេញជាង ៤,000មេហ្គាវ៉ាត់ត្រឹមឆ្នាំ២០២០[167]។ ទំនប់ចំនួន៥ ដែលកំពុងសាងសង់នៅភាគខាងត្បូង និងនិរតិនៃប្រទេស (សូមមើលនៅផ្នែក ១.១) នឹងជួយកម្ពុជាខិតទៅរកគោលដៅនេះ ហើយដូចដែលបានឃើញស្រាប់ ប្រសិនបើផែនការសកម្មភាព ដែលបានដាក់ចេញដោយក្រសួងឧស្សាហ៍កម្ម រ៉ែ និងថាមពល ដើរបានដោយសំរួលនោះ ទាំងនេះគឺជាសក្តានុពលសំរាប់ការតភ្ជាប់ ទំនប់ក្នុងតំបន់ទន្លេ៣ ទៅខ្សែបណ្តាញចែកចាយជាតិកម្ពុជា និងខ្សែបណ្តាញចែកចាយវៀតណាម។

163 Presentation by Victor Jona, 16 March 2011.
164 Presentation by Victor Jona, 16 March 2011.
165 KTC Cable & OX Engineering, available online at: http://www.authorstream.com/Presentation/kim3532-220876-feasibility-study-transmission-line-electricity-cambodia-230kv-business-finance-ppt-powerpoint/ (accessed
166 Phnom Penh Post, Electricity exports expected by 2016, says govt official, 30 March 2009.
167 Presentation by Victor Jona, 16 March 2011.




ផែនទីគំរោងបណ្តាញចែកចាយអគ្គិសនីកម្ពុជា[168]

ទោះបីជាយ៉ាងណាក៏ដោយ វាមិនទាន់ច្បាស់ថា បណ្តាញបញ្ជូនចរន្តដែលបានស្នើរឡើងទាំងអស់ មានថវិកា ឬក៏អត់ដើម្បីសាងសង់ ហើយវានៅតែត្រូវបានគេមើលឃើញថាតើ លទ្ធផលគំរោងតំបន់ទន្លេ៣ និងត្រូវបានប្រើប្រាស់ចុងក្រោយយ៉ាងដូចម្តេច។

មកដល់បច្ចុប្បន្ននេះ មិនទាន់មានព័ត៌មានជាសាធារណៈណាមួយដែលអាចយកជាកាបាន ពីថាតើ ថាមពលដែលផលិតចេញពីទំនប់សេសានក្រោម៣ ស្រែពកក្រោម៣ និងស្រែពកក្រោម៤ ឬទំនប់សេកុងក្រោម នឹងត្រូវបានប្រើបាស់ដូចម្តេច។

**ការពិគ្រោះយោបល់ជាសាធារណៈ**

ជាញឹកញាប់ វាជាការពិតក្នុងប្រទេសកម្ពុជា ដែលគំរោងផែនការអភិវឌ្ឍន៍ខ្នាតធំទាំងអស់ ត្រូវបានស្នើរឡើង សិក្សា និងអនុម័តនៅក្នុងបន្ទប់ដែលបិទជិត។ ដំណើរការដេញថ្លៃ តែងតែមិនត្រូវបានផ្សព្វផ្សាយ ប្រសិនបើវាត្រូវបានគេរៀបចំឡើងមែននោះ។ ជាញឹកញាប់ ប្រភពព័ត៌មានផ្សេងៗ អាចទទួលបានពីសារព័ត៌មានក្នុងស្រុក និងបរទេស ជាជាងទទួលបានពីមន្ត្រីរដ្ឋាភិបាលកម្ពុជា។ ក្នុងករណីខ្លះ សូម្បីតែអាជ្ញាធរមូលដ្ឋាន ក៏មិនបានដឹងផែនការដែលដាក់ចេញមកពីថ្នាក់ជាតិ មកលើតំបន់របស់ពួកគាត់ផង។ ក្នុងករណីរទំនប់ស្រែពកក្រោម៣ គឺមានន័យដូចខាងលើ មន្ត្រីមូលដ្ឋានគ្មានយោបល់អី

168 Presentatioin by Victor Jona, 16 March 2011

បន្តិចសោះ បុគ្គលិកក្រុមហ៊ុនចិន បានប្រគល់អាជ្ញាប័ណ្ណដើម្បីធ្វើការស្រាវជ្រាវនៅក្នុងតំបន់ ជាផ្នែកមួយនៃការសិក្សារកលទ្ធភាពដែលអាចធ្វើបានសំរាប់សំណើរអភិវឌ្ឍន៍ទំនប់។

ជាញឹកញាប់ ឱកាសលើកទី១ដែលសហគមន៍អាចដឹងពីព័ត៌មានលំអិតអំពីគំរោង និងអាចបង្ហាញការព្រួយបារម្ភរបស់ពួកគេ គឺក្នុងអំឡុងពេលដំណើរការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA)។ ការពិគ្រោះយោបល់សាធារណៈ គឺជាតំរូវការផ្លូវច្បាប់ ហើយដូចមានចែងក្នុងអនុក្រិតស្តីពី ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានគួតែ "លើកទឹកចិត្តឲ្យមានការចូលរួមជាសាធារណៈ ក្នុងដំណើរការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន ហើយត្រូវយកយោបល់ និងសំណូមពរផ្សេងៗរបស់ពួកេគ ទៅពិចារណាក្នុងដំណើរការអនុម័តគំរោង"[169]។ ច្បាប់ព្រៃឈើបង្ហាញថា ច្បាប់គួរតែត្រូវ "អនុវត្តដើម្បីធានាឲ្យមានការចូលរួមជាសាធារណៈ នៅក្នុង ការសំរេចចិត្តនានារបស់រដ្ឋាភិបាល ដែលអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋទូទៅ ការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន និងបាត់បង់ធនធានព្រៃឈើក្នុងព្រះរាជាណាចក្រកម្ពុជា"។ ច្បាប់នេះ បានបញ្ជាក់បន្ថែមទៀតថា "ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវតែមានការរៀបចំ ចំពោះសកម្មភាពពាក់ព័ន្ធនិងប្រពន្ធ័អេកូឡូស៊ីព្រៃឈើសំខាន់ៗ ដែលអាចបង្កមហន្តរាយដល់បរិស្ថាន និងសង្គម។ ឯកសារការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គួរតែត្រូវបានធ្វើឡើងដោយបញ្ចេញយោបល់ពីសាធារណៈជន[170]។ យោងទៅលើច្បាប់ព្រៃឈើ ប្រសិនបើគំរោងវារីអគ្គសនីភាគ ច្រើន ដែលស្នើឡើងក្នុងតំបន់ទន្លេ៣ មានផលប៉ះពាល់ដល់ព្រៃឈើ ការសិក្សាវាយតំលៃហេតុផលប៉ះពាល់បរិស្ថាន គួរតែស្នើរឲ្យមានការបញ្ចេញយោបល់ពីសាធារណៈជនទូទៅ នៅពេលការសិក្សានោះ បានបញ្ចប់។

ជាការពិត គេអាចមើលឃើញថា ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ជាញឹកញាប់ត្រូវបានមើលឃើញថា វាមានន័យទូលំទូលាយជាងដំណាក់កាលនៃការអនុម័តគំរោង ហើយរិតតែសំខាន់ វាជាឱកាសដ៏ពិសេសពិសាលមួយ ដើម្បីធ្វើការសើបអង្កេតយ៉ាងល្អិតល្អន់ទៅលើផលប៉ះពាល់ផ្សេងៗ ជាឱកាសបង្ហាញលទ្ធផលទៅដល់អ្នកពាក់ពន្ធ័ទាំងអស់ និងជាឱកាសដើម្បីបានស្តាប់ឮពីអ្នកដែលអាចរងគ្រោះដោយសារគំរោង។ មានឧទាហរណ៍ច្រើន នៃគំរោងអភិវឌ្ឍន៍ធំៗដែលគ្មានធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានអ្វីទាំងអស់ ហើយមានគំរោងផ្សេងទៀត ដែលការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានបានធ្វើចប់ ក្រោយពេលដែលគំរោងទទួលបានការអនុម័តរួចរាល់ ឬបន្ទាប់ពីគំរោងចាប់ផ្តើមសាងសង់ ឬប្រតិបត្តិការ។ ជាឧទាហរណ៍៖ ក្នុងខែវិច្ឆកា ឆ្នាំ២០១១ ការសិក្សាវាយតំលៃហេតុប៉ះ ពាល់បរិស្ថានសំរាប់ទំនប់កំចាយ ស្ថិតនៅភាគខាងត្បូងទីរួមខេត្តកំពត នៅមិនទាន់បានអនុម័តជាចុង ក្រោយ ខណៈដែលការសាងសង់ត្រូវបានដំណើរការ៥ឆ្នាំមកហើយ ហើយគំរោង នឹងត្រូវបញ្ចប់ក្នុងខែធ្នូ ២០១១។

169 Sub-decree on Environmental Impact Assessment 1999, Article 1.
170 Forestry Law 2002, Article 4.

គំរោងវារីអគ្គិសនីតែមួយគត់ក្នុងតំបន់ទន្លេ៣ ដែលមានការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានយ៉ាងទូលំទូលាយនោះ គឺគំរោងទំនប់សេសានក្រោម២ ហើយមានការព្រួយបារម្ភជាច្រើនត្រូវបានលើកឡើង ជុំវិញនិតិវិធីនៃការធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងលទ្ធផលរបស់វាដូចមានបញ្ជាក់លំអិតក្នុងផ្នែក ២.១ ខាងលើ។ ទំនប់សេសានក្រោម១/៥ ប្រហែលជាធ្លាប់បានធ្វើការសិក្សា ប៉ុន្តែអត់មានការពិគ្រោះយោបល់ជាសាធារណៈទេ ហើយក៏គ្មានព័ត៌មានណាមួយ ត្រូវបានផ្សព្វផ្សាយជាសាធារណៈផងដែរ។

ការរីករាលដាលនូវផលប៉ះពាល់ពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី នៅតំបន់ទន្លេ៣ ក្នុងប្រទេសកម្ពុជា និងផលប៉ះពាល់ផ្សេងៗបណ្ដាលពីការអភិវឌ្ឍន៍ក្នុងតំបន់ នៅតែមិនមានភាពច្បាស់លាស់។ ភាគច្រើន អាស្រ័យលើថាតើមានទំនប់អគ្គិសនីចំនួនប៉ុន្មាន ដែលត្រូវអនុម័ត តើគំរោងទាំងអស់បានរៀបចំយ៉ាងដូចម្ដេច ហើយថាតើមានវិធានការណ៍អ្វីខ្លះ ដើម្បីបន្ធូរបន្ថយផលប៉ះពាល់។ ប្រទេសនីមួយៗ មិនត្រឹមតែពង្រឹងឆន្ទះរបស់ខ្លួន ដើម្បីធ្វើការសិក្សាឲ្យបានពេញលេញអំពីផលប៉ះពាល់ និងដើម្បី ពិភាក្សាជាមួយសហគមន៍ក្នុងតំបន់សាងសង់គំរោងប៉ុណ្ណោះទេ ពួកគេក៏ត្រូវតែយកចិត្តទុកដាក់ឲ្យបាន ខ្ពស់ជាងមុនផងដែរ នូវផលប៉ះពាល់ជាយថាហេតុនៅផ្នែកខាងក្រោមនៃទំនប់ និងផលប៉ះពាល់ឆ្លង ដែន។ ប្រពន្ធ័អេកូឡូស៊ីដែលងាយខូចខាតក្នុងតំបន់ ធនធានជលផល និងសត្វព្រៃ សុទ្ធសឹងតែមាន អន្តរអំពើជាមួយគ្នាទៅវិញទៅមក ហើយការកាត់ផ្ដាច់ខ្សែសង្វាក់ទំនាក់ទំនងនេះ អាចធ្វើឲ្យអន្តរាយ ដល់ការចិញ្ចឹមជីវិត និងសន្តិសុខស្បៀងរបស់មនុស្សរដ្ឋរាប់រយរាប់ពាន់នាក់។

# ផ្នែកទី៣ ៖
# ស្ថាប័នដែលដើរតួនាទីដ៏សំខាន់ៗ
# ក្នុងការជំរុញឲ្យមានការអភិវឌ្ឍន៍វារីអគ្គិសនីក្នុងតំបន់

ទោះបីជារាជរដ្ឋាភិបាលកម្ពុជា ជាអ្នកទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយ ដែលជួយតំរង់ទិសការអភិវឌ្ឍន៍វិស័យថាមពលក្នុងប្រទេស ជាអ្នកអនុម័តយល់ព្រម ឬជាអ្នកបដិសេធគំរោងអភិវឌ្ឍន៍ក៏ដោយ តួរអង្គដែលមានឥទ្ធិពលជាច្រើនផ្សេងទៀត ក៏មានជាប់ពាក់ព័ន្ធចូលរួមផងដែរក្នុង រូបភាពដ៏ស្មុគស្មាញ ដែលបច្ចុប្បន្ននេះកំពុងត្រូវបានគេលាភពណ៌នៅក្នុងតំបន់ទន្លេ៣។ ផ្នែកខាងក្រោមនៃរបាយការណ៍នេះ នឹងផ្តោតសំខាន់លើ តួរអង្គមួយចំនួនដែលដើរតួនាទីក្នុងការអភិវឌ្ឍន៍នៃវិស័យថាមពលវារីអគ្គិសនីក្នុងតំបន់។ នៅក្នុងផ្នែកនេះ នឹងមាននិយាយអំពីព័ត៌មានជុំវិញកម្មវិធីរបស់ស្ថាប័នផ្តល់ហិរញ្ញបទានអន្តរជាតិ ដែលធ្វើការយ៉ាងសកម្មក្នុងតំបន់ និងគំនិតផ្តួចផ្តើមទ្វេរភាគី និងថ្នាក់តំបន់ដែលបានជុំរុញឲ្យមានការអភិវឌ្ឍន៍ថាមពលក្នុងតំបន់។

## ៣.១ ធនាគារអភិវឌ្ឍន៍អាស៊ី

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានបំពេញការងារក្នុងតំបន់ទន្លេមេគង្គជាយូរឆ្នាំណាស់មកហើយ ហើយធនាគារមួយនេះ ក៏បានគាំទ្រគំរោងអភិវឌ្ឍន៍វារីអគ្គិសនី និងគំរោងបញ្ជូនចរន្តជាច្រើន ផងដែរ នៅក្នុងប្រទេសដែលស្ថិតក្នុងតំបន់ទន្លេ៣។ ក្នុងឆ្នាំ១៩៩៩ ធនាគារអភិវឌ្ឍ៍អាស៊ី បានធ្វើការសិក្សាពីលទ្ធភាពគំរោងវារីអគ្គិសនីក្នុងទន្លេសេកុង សេសាន និងអាងស្តុកទឹកណាមធឿន ដែលសំដៅ ដល់របាយការណ៍របស់ក្រុមហ៊ុន Halcrow បន្ទាប់ពីក្រុមហ៊ុននេះបានធ្វើការសិក្សារួច[171]។ ធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានគាំទ្រដល់ការសិក្សាពីលទ្ធភាពដែលអាចធ្វើបានសំរាប់ទំនប់សេសាន៣A ក្នុងប្រទេសវៀតណាមក្នុងឆ្នាំ ១៩៩៩ ផងដែរ[172]។

ក្នុងឆ្នាំ២០០៦ ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់ជំនួយបច្ចេកទេស ដើម្បីសិក្សាពីការអភិវឌ្ឍន៍វារីអគ្គិសនីក្នុងតំបន់ទន្លេ៣ទាំងមូល ក្នុងគោលបំណងបង្កើនកិច្ចសហការឆ្លងដែន នៅក្នុងការគ្រប់គ្រងផ្ទៃអាងទឹកទន្លេ៣។ ក្នុងដំណាក់កាលចាប់ផ្តើមនៃគំរោង រដ្ឋាភិបាលទាំង៣ និងធនាគារអភិវឌ្ឍន៍អាស៊ីបានរកឃើញថា ការអភិវឌ្ឍន៍ធនធានក្នុងតំបន់នេះ អាចចូលរួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រក្នុងតំបន់ និងលើកទឹកចិត្តដល់ការអភិវឌ្ឍន៍ក្នុងតំបន់ ប្រសិនមានការគ្រប់គ្រងបានត្រឹមត្រូវ។ ឯកសាគំរោង បានបញ្ជាក់ផងដែរថា អាងស្តុកទឹក និងធនធាននៅក្នុងនោះ កំពុងទទួលរងសម្ពាធយ៉ាងធ្ងន់ធ្ងរ ហើយដែលសំពាធនេះ ទំនងជាបន្តកាន់តែធ្ងន់ធ្ងរឡើងៗ ប្រសិនបើនិន្នាការអភិវឌ្ឍន៍បច្ចុប្បន្ននៅ

171 Asian Development Bank, *TA-5697 REG: Se Kong-Se San and Nam Theun River Basins Hydropower Development Study*, project documents available at: http://www.adb.org/projects/project.asp?id=30003 (accessed November 2011).
172 Asian Development Bank, TA-3222 VIE: Preparing the Se San 3 Hydropower Project, project documents available at: http://www.adb.org/Projects/project.asp?id=31362 (accessed November 2011).

តែបន្ត។ ដូចបានបង្ហាញក្នុងរបាយការណ៍ជំនួយការបច្ចេកទេស ដែលរៀបរាងក្រោមការសិក្សានេះ បានឲ្យដឹងថា៖ "ផលប្រយោជន៍ដ៏មានសក្តានុពល និងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់អាងទឹក ត្រូវបាត់បង់ នៅពេលដែលការធ្វើផែនការ ស្ថិតក្នុងបរិបទតូចចង្អៀត តាមប្រទេស ឬតាមវិស័យ ដោយគ្មានការពិគ្រោះយោបល់គ្រប់គ្រាន់ជាមួយអ្នកពាក់ពន្ធ័[173]។ ដើម្បីទម្លាយជញ្ជាំងនេះបាន ធនាគារអភិវឌ្ឍន៍អាស៊ុ ត្រូវតែពង្រឹងវេទិកាជជែកពិភាក្សាក្នុងតំបន់ កិច្ចសហប្រតិបត្តិការ និងការចែករំលែកព័ត៌មាន និងត្រូវបង្កើតផែនទីបង្ហាញផ្លូវ សំរាប់ការអភិវឌ្ឍន៍ធនធានក្នុងផ្ទៃអាងនាពេលអនាគត។ គេសង្ឃឹមថា ផែនទីបង្ហាញផ្លូវនេះ នឹងបង្កើតបានជាមូលដ្ឋានមួយសំរាប់ការបន្តគាំទ្រតទៅអនាគតរបស់ធនាគារអភិវឌ្ឍន៍អាស៊ុ លើវិស័យនេះ។

ការសិក្សាក្នុងតំបន់ទន្លេ៣របស់ធនាគារអភិវឌ្ឍន៍អាស៊ុ ត្រូវបានគេវាយតម្លៃថាទទួលបានជោគជ័យដោយអន្លើតែប៉ុណ្ណោះ ហើយបច្ចុប្បន្ននេះ ធនាគារអភិវឌ្ឍន៍អាស៊ុ មិនទាន់បានផ្សព្វផ្សាយជា សាធារណៈពីផែនការរបស់ខ្លួន ដើម្បីគាំទ្រគំរោងវារីអគ្គិសនីនាពេលអនាគត ក្នុងតំបន់ទន្លេ៣នៅឡើយទេ។ ទោះបីជាយ៉ាងណាក៏ដោយ ធនាគារអភិវឌ្ឍន៍អាស៊ុ នៅតែបន្តការគាំទ្ររបស់ខ្លួនសំរាប់ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័ សំរាប់ការចែកចាយថាមពលក្នុងតំបន់ ដែលអាចភ្ជាប់ដោយផ្ទាល់ទៅកាន់គំរោងអភិវឌ្ឍន៍វារីអគ្គិសនីក្នុងប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសវៀតណាម ព្រមទាំងក្នុងតំបន់អាងស្តុកទឹកទន្លេ៣។ ខ្សែបណ្តាញថាមពលទាំងនេះ នឹងតភ្ជាប់ទៅទំនប់ធំៗមួយចំនួន ដែលបានស្នើឡើង ឬកំពុងតែសាងសង់នៅក្នុងតំបន់ទន្លេ៣ ហើយភាគច្រើន ទទួលបាននូវការរិះគន់ជាច្រើនដោយសារតែខ្វះការពិគ្រោះយោបល់សមស្រប និងការគិតគូរពិចារណាអំពីផលប៉ះពាល់នៅផ្នែកខាងក្រោមនៃទំនប់។ ខាងក្រោមនេះ ជាសេចក្តីសង្ខេបនៃការសិក្សា និងខ្លឹមសារពីថាតើផែនការគាំទ្រការចែកចាយថាមពលក្នុងតំបន់ របស់ធនាគារអភិវឌ្ឍន៍អាស៊ីពេលបច្ចុប្បន្ន អាចប៉ះពាល់ដល់តំបន់ទន្លេ៣យ៉ាងដូចម្តេច។

## ការសិក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងតំបន់ទន្លេ៣

ក្នុងឆ្នាំ២០០៦ តាមសំណើររបស់គណកម្មាធិការជាតិទន្លេមេគង្គ (NMC) ប្រទេសកម្ពុជា ឡាវ និងប្រទេសវៀតណាម ធនាគារអភិវឌ្ឍន៍អាស៊ុ បានបង្កើតផែនការជាច្រើន ដើម្បីគាំទ្រដល់ការសិក្សាមួយ ដែលមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងដែន ក្នុងការគ្រប់គ្រងអាងទន្លេសេសាន ស្រែពក និងសេកុង។ ក្នុងខែធ្នូ ឆ្នាំ២០០៦ ជំនួយដែលមានទឹកប្រាក់ ៩៨០,០០០ដុល្លាសហរដ្ឋអាមេរិក ត្រូវបានគេអនុម័តគាំទ្រដើម្បីជាជំនួយបច្ចេកទេស ដល់ការសិក្សាការរបស់ធនាគារ អភិវឌ្ឍន៍អាស៊ុ ស្តីពីការអភិវឌ្ឍន៍អាងទន្លេសេសាន ស្រែពក និងសេកុង ក្នុងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋ

173 Asian Development Bank, Technical Assistance Report: Project 40082, Sesan, Sre Pok, and Sekong River Basins Development Study in Kingdom of Cambodia, Lao People's Democratic Republic, and Socialist Republic of Vietnam, December 2006, (para 4).

ប្រជាមេនិតឡាវ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម (នេះសំដៅដល់ការសិក្សាក្នុងតំបន់ទន្លេ៣)។ ជំនួយបច្ចេកទេស បានចាប់ផ្តើមក្នុងខែមេសា ឆ្នាំ២០០៨ និងបានបញ្ចប់ក្នុងខែ កក្កដា ឆ្នាំ២០១០ [174]។

របាយការណ៍ជំនួយបច្ចេកទេសលើកដំបូង បានបញ្ជាក់ថា តំបន់ទន្លេ៣មានសក្តានុពលខ្លាំងសំរាប់ការអភិវឌ្ឍន៍ ហើយបានបញ្ជាក់ទៀតថា ប៉ុន្តែប្រសិនបើមិនមានផែនការច្បាស់លាស់ និងការពិគ្រោះយោបល់ក្នុងចំនោមអ្នកពាក់ពន្ធ័ឲ្យបានពេញលេញ ការអភិវឌ្ឍន៍ទាំងនោះ នឹងក្លាយទៅជាការ ខាតបង់ឥតប្រយោជន៍។ ការអភិវឌ្ឍន៍វារីអគ្គិសនី ត្រូវបានគេជ្រើសរើសជាឧទាហរណ៍នៃវិស័យមួយដែលការធ្វើផែនការ បានផ្តោតសំខាន់ទៅលើ "**ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចក្នុងកម្រិតអតិបរិមា ប៉ុន្តែខ្វះ ការគិតគូរដល់ ការគ្រប់គ្រងទីជំរាលផ្នែកខាងលើ ឬផលប៉ះពាល់នៅផ្នែកខាងក្រោមទៅលើលំហូរទឹក។ ជាលទ្ធផល វាបានបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានឥតព្រៀងទុកទៅលើសហគមន៍នៅផ្នែកខាងក្រោមទំនប់**"[175]។ របាយការណ៍នេះបានបញ្ជាក់បន្ថែមទៀតថា ការអភិវឌ្ឍន៍ដែលមិនមានការសម្របសម្រួលនឹងបង្កមហន្តរាយដល់អាងទន្លេធម្មជាតិ និងកាន់តែវិនាសហិនហោច[176]។ ដោយទុករឿងនេះក្នុងចិត្ត ជំនួយបច្ចេកទេស មានទិសដៅពង្រឹងសមត្ថភាពការធ្វើផែនការអភិវឌ្ឍន៍ឆ្លងដែន និងអន្តរវិស័យ ក្នុងតំបន់អាងទន្លេ៣ និងដើម្បីពិនិត្យមើលឡើងវិញពីការអភិវឌ្ឍន៍ទាំងឡាយ ដែលបានរៀបចំផែនការរួច និងដែលកំពុងដំណើរការ ដោយរួមបញ្ចូលផលប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច និងសង្គម។

លទ្ធផលសំខាន់មួយនៃជំនួយបច្ចេកទេស គឺការចែករំលែកព័ត៌មានដែលមានលក្ខណៈប្រសើរជាងមុន និងការទទួលបានព័ត៌មានទូលំទូលាយជាងមុនរបស់អ្នកពាក់ពន្ធ័។ តាមរយៈជំនួយបច្ចេកទេសនេះ គេហទំព័រមួយ ត្រូវបានបង្កើតឡើងដើម្បីប្រមូល និងចែករំលែកព័ត៌មាន ដើម្បីសម្របសម្រួលឲ្យមានការជជែកពិភាក្សា និងបទវិភាគផ្សេងៗ[177]។ ឯកសារទាំងនោះ ត្រូវបានធ្វើដោយជោគជ័យ ហើយអាចមើលឃើញបានក្នុងគេហទំព័រ http://www.3sbasin.org/iucn/។ គេហទំព័រនេះ មាន ឯកសារពាក់ព័ន្ធលទ្ធផលនៃការសិក្សាក្នុងតំបន់ទន្លេ៣ ឯកសារ របាយការណ៍ ទិន្ន័យ និងសំភារៈមានប្រយោជន៍ផ្សេងៗទៀត។ របាយការណ៍ចុងក្រោយសំរាប់ការសិក្សាក្នុងតំបន់ទន្លេ៣ បានពិពណ៌នាគេហទំព័រនេះថាជា ជំហ៊ានសាកល្បងមួយ "**ដែលជួយត្រួសត្រាយផ្លូវទៅបង្កើតមធ្យោបាយផ្សេងៗ ដើម្បីធ្វើការចែករំលែកព័ត៌មាន**"[178]។

ជំនួយបច្ចេកទេសនេះ ក៏បានជួយគាំទ្រផងដែរ ដល់ការជជែកពិភាក្សាផ្សេងៗ។ ឆ្ពោះទៅរកចុងបញ្ចប់ *លំហាត់មើលឆ្ពោះទៅមុខ* ត្រូវបានគេធ្វើជាមួយអ្នកពាក់ពន្ធ័ ដើម្បីក្រឡេកមើលស្ថានភាព ពេលបច្ចុប្បន្ន និន្នាការផ្សេងៗ និងឥទ្ធពលរបស់វា និងទស្សនវិស័យ ទៅអនាគត។ ការពិគ្រោះយោបល់ទាំង

174 Asian Development Bank, Final Report: TA6367 Sesan, Sre Pok, and Sekong River Basins Development Study in Kingdom of Cambodia, Lao People’s Democratic Republic, and Socialist Republic of Vietnam, July 2010 (p10).
175 Asian Development Bank, Technical Assistance Report: Project 40082, Sesan, Sre Pok, and Sekong River Basins Development Study in Kingdom of Cambodia, Lao People’s Democratic Republic, and Socialist Republic of Vietnam, December 2006, (para 4).
176 Ibid. (para 9)
177 ADB, Final Report: TA6367, July 2010 (p12).
178 Ibid.

នេះ ត្រូវបានគេធ្វើឡើងនៅក្នុងសិក្ខាសាលាជាច្រើនក្នុង តំបន់អាងទឹកនីមួយៗ ហើយដែលក្រោយ មកមានសិក្ខាសាលាកម្រិតជាតិ និងចុងក្រោយជាសិក្ខាសាលាឆ្លងដែន ដែលសុទ្ធសឹងមានការចូលរួម ពីអ្នកតំណាងសហគមន៍ អង្គការក្រៅរដ្ឋាភិបាល សាស្ត្រាចារ្យ និងអ្នកសារព័ត៌មាន[179]។ មានការបារម្ភ ជាច្រើនត្រូវបានលើកឡើងអំឡុងពេលការពិគ្រោះយោបល់ រួមមានការថយចុះលំហូរទឹកក្នុងរដូវប្រាំង លំហូរទឹកមិនទៀងទាត់ ការថយចុះគុណភាព និងបរិមាណទឹក និងការកើនឡើងសម្ពាធលើធនធាន ទឹក។ របាយការណ៍សិក្សាចុងក្រោយ បានបង្ហាញថា មតិយោបល់ចេញពីការពិភាក្សាបានចង្អុលបង្ហាញ យ៉ាងច្បាស់ថា «**មានការយល់ជាទូទៅថា តំបន់ទន្លេ៣កំពុងតែខិតជិតទៅរកវិបត្តិទឹក និងជួបប្រទះនូវ បញ្ហាធំៗជាច្រើន ពាក់ព័ន្ធជាមួយនិន្នាការនៃការប្រើប្រាស់ទឹកពេលបច្ចុប្បន្ន ដែលគំរាមកំហែងដល់ មហិច្ឆតានៃការអភិវឌ្ឍន៍រយៈពេលវែង**»[180]។ របាយការណ៍នេះ បានបន្តទៀតថា «**ក្នុងប្រទេសទាំងអស់ សុទ្ធតែមានការយល់ឃើញរៀងៗខ្លួននៅក្នុងចំណោមអ្នកពាក់ព័ន្ធ ល្បឿននៃការផ្លាស់ប្តូរ មានលក្ខណៈ ឆាប់រហ័សបំផុត ហើយក្នុងករណីខ្លះ វាបានផ្តល់ផលប្រយោជន៍ពិតប្រាកដជាច្រើន ប៉ុន្តែពេលខ្លះ វាក៏ បានបំផ្លិចបំផ្លាញធនធានទឹក (តំបន់ទីជំរាល) និងធ្វើឲ្យមានការកើនឡើងសម្ពាធលើធនធានទាំងនេះ ផងដែរ ការណ៍នេះបង្ហាញពីរូបភាពអស់សង្ឃឹមទៅថ្ងៃអនាគត**»[181]។

សមាសធាតុសំខាន់មួយនៅក្នុងការសិក្សាតំបន់ទន្លេ៣ គឺការកំណត់ទំហំ និងការទទួលខុសត្រូវ សំរាប់ការវាយតំលៃហេតុប៉ះពាល់ត្រួតគ្នា (CIA) នាពេលអនាគត។ ដំណើរការនេះ រួមមានការចុះទៅ មូលដ្ឋាននៅក្នុងប្រទេសទាំង៣ ការប្រមូលទិន្នន័យ ការប្រជុំនៅកំរិតខុសៗគ្នា និងការរៀបចំព័ត៌ខេត្ត។ ការប្រជុំទាំងនេះ និង *លំហាត់មើលឆ្ពោះទៅមុខ* ដែលមានបញ្ជាក់នៅខាងលើ ត្រូវបានគេប្រើជាធាតុផ្សំ នៅក្នុងការពិគ្រោះយោបល់ជាមួយអ្នកពាក់ពន្ធ័ ដើម្បីបង្កើតជាការវាយ តំលៃហេតុប៉ះពាល់ត្រួតគ្នា។ ព័ត៌មានប្រមូលបានអំឡុងវគ្គសិក្សា ត្រូវបានរក្សាទុកក្នុងកំណត់ហេតុសង្ខេបបច្ចេកទេសនៃគំរោង ក្នុងតំបន់ទន្លេ៣ ដែលក្រោយមកត្រូវបានគេប្រើដើម្បីកំណត់បញ្ហាសំខាន់ៗ និងកំណត់ទំហំ និងការទទួលខុសត្រូវ ក្នុងការសិក្សាវាយតំលៃហេតុប៉ះពាល់ត្រួតគ្នា (CIA) ពេញលេញមួយ នៅពេលក្រោយ[182]។

លទ្ធផលសំខាន់ៗមួយនៃការសិក្សាតំបន់ទន្លេ៣ គឺជាពង្រាងផែនទីមួយ សំរាប់ការអភិវឌ្ឍន៍ធនធានទឹកក្នុងតំបន់ទន្លេ៣នាថ្ងៃអនាគត។ ផែនទីបង្ហាញផ្លូវនេះ រួមមានការត្រួតពិនិត្យស្ថានភាព និងនិន្នាការក្នុងតំបន់ ការប៉ាន់ប្រមាណផលប៉ះពាល់ និងអត្ថប្រយោជន៍នៃការអភិវឌ្ឍន៍ដែលមានផែនការច្បាស់លាស់ ការគ្រប់គ្រង និងត្រួតពិនិត្យការអភិវឌ្ឍន៍ និងការកសាងស្ថាប័ន។ យោងលើរបាយការណ៍ចុងក្រោយនៃការសិក្សាក្នុងតំបន់ទន្លេ៣ «**ផែនទីបង្ហាញផ្លូវនេះ ជាផលិតផលសំខាន់ចុងក្រោយនៃការសិក្សាតំបន់ទន្លេ៣ និងអាចជាមូលដ្ឋានគ្រឹះសំរាប់ការបន្តគាំទ្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅ បណ្តា**

179 Ibid. (p13)
180 Ibid. (p19)
181 Ibid. (p4)
182 Ibid. (p16-17)

**លប្រទេសផ្សេងៗទៀតនៅពេលអនាគត**"[183]។ ពង្រាងផែនទីបង្ហាញផ្លូវនេះ ដាក់បញ្ចូល សកម្មភាពជាច្រើនសំរាប់រយៈពេល១០ឆ្នាំក្រោយ។ នៅក្នុងផែនទីបង្ហាញផ្លូវ ក៏មានផែនការបង្កើតក្រុម ការងារតាមប្រទេសធ្វើការវាយតំលៃហេតុប៉ះពាល់ត្រួតគ្នា (CIA) កសាងសមត្ថភាពស្ថាប័នជាតិ និងធ្វើ ការវាយតំលៃហេតុប៉ះពាល់ត្រួតគ្នាពេញលេញមួយ (CIA) សំរាប់ការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនីក្នុងតំបន់ទន្លេ៣ទាំងមូល។ ផែនទីបង្ហាញផ្លូវ ក៏មានផែនការជ្រើសរើសបញ្ជីអាទិភាព នៃគំរោងទំនប់វារី អគ្គិសនី និងការវាយតម្លៃពួកវា ដោយប្រើប្រាស់ពិធីសារវាយតំលៃនិរន្តរភាពថាមពលវារីអគ្គិសនី (HSAP)។ សកម្មភាពផ្សេងៗទៀតជាច្រើន ក៏ត្រូវបានដាក់បញ្ចូលដែរ រួមមាន៖ ពង្រឹងការចែករំលែក ព័ត៌មាន បន្តការត្រួតពិនិត្យគំរោង ការត្រួតពិនិត្យលំហូរ និងគុណភាពទឹក និងការកសាងប្រព័ន្ធប្រកាស អាសន្នទឹកជំនន់។ ផែនការនេះ ក៏មានចក្ខុវិស័យទៅលើប្រព័ន្ធទិន្នន័យការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ខ្នាតធំក្នុងតំបន់ដែលគេធ្វើបច្ចុប្បន្នកម្មយ៉ាងទៀងទាត់ផងដែរ[184]។

រាយការណ៍សិក្សាចុងក្រោយក្នុងតំបន់ទន្លេ៣បង្ហាញថា ការសិក្សានេះ បានបណ្តាលឲ្យមានកិច្ចព្រមព្រៀងដ៏ទូលាយមួយលើគោលការណ៍ចែករំលែកសំខាន់ៗ។ ចំនុចនេះរួមបញ្ចូលកិច្ចព្រមព្រៀមដែលការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការប្រើប្រាស់ធនធានក្នុងអាងទឹកទាំង៣ តម្រូវឲ្យមានការទទួលស្គាល់ថា៖[185]

- តុល្យភាពរវាងការអភិវឌ្ឍន៍ និងការការពារធនធាន ការធានាឲ្យមានប្រយោជន៍ទៅវិញទៅមក សំរាប់ប្រទេសទាំង៣ និងការចែករំលែកផលប្រយោជន៍ដោយសមធម៌ទៅដល់ប្រជាពលរដ្ឋ ជាគោលការណ៍សំខាន់សំរាប់ទស្សនវិស័យក្នុងតំបន់អាងទឹកទន្លេ៣។
- ធ្លាប់មានការប្រែប្រួលដ៏សំបើមនៅក្នុងតំបន់អាងទឹកទន្លេ៣ កាលពី ២០-៣០ឆ្នាំកន្លងទៅ។ ការផ្លាស់ប្តូរទេសភាព និងគ្រឹះធនធានធម្មជាតិ ត្រូវបានគេមើលឃើញថាកើតមាន នៅក្នុងផ្នែកខ្លះនៃអាងទឹក ជាពិសេសបំផុតនោះ ក្នុងប្រទេសវៀតណាម ហើយការផ្លាស់ប្តូរប្រហាក់ប្រហែលគ្នានេះ កំពុងចាប់ផ្តើមបន្តកើតមានទៀតនៅទី កន្លែងផ្សេងនៃផ្ទៃអាងទឹក។
- ការផ្លាស់ប្តូរទាំងនោះ បាននាំមកនូវអត្ថប្រយោជន៍ជាច្រើន ព្រមទាំងធ្វើឲ្យប្រសើរឡើងដល់សុខុមាលភាព និងការចិញ្ចឹមជីវិតសំរាប់ប្រពលរដ្ឋ។ ប៉ុន្តែ ប្រជាពលរដ្ឋជាច្រើននាក់ទៀត នៅស្ថិតក្នុងភាពក្រីក្រនៅឡើយ បើយោងតាមសុចនាករសំខាន់ៗមួយចំនួន ដូចជា៖ សន្តិសុខស្បៀង សុខភាព និងការទទួលបានទឹកស្អាតប្រើប្រាស់។
- អាងទឹកនេះ កំពុងខិតទៅរកការធ្វើសេចក្តីសម្រេចចិត្តដ៏សំខាន់មួយ។ ជាមួយនិងការកើនឡើងនូវសម្ពាធលើធនធានទឹក និងការកើនឡើងនូវតម្រូវការអាហារ ថាមពល ការប្រើប្រាស់ក្នុង

183 Ibid. (p33)
184 Ibid. (p36)
185 Ibid. (p8)

ស្រុក និងនៅតាមទីប្រជុំជន ការបំពេញឲ្យបានតាមគោលបំណងការអភិវឌ្ឍន៍រយៈពេលយូ ត្រូវពឹងអាស្រ័យលើការគ្រប់គ្រងទឹក និងធនធានដី ប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល។

- ដើម្បីកែលម្អរដំណើរការការធ្វើផែនការ និងការប្រតិបត្តិសម្រាប់គម្រោងអភិវឌ្ឍន៍ និងដើម្បីការកែលម្អរ ដំណើរការឲ្យតំលៃធនធានដី និងធនធានទឹក ចាំបាច់ត្រូវធ្វើការអភិរក្ស និងប្រើប្រាស់។

ថ្វីបើជាការពិតថា ការសិក្សាបាននេះ បានសម្រេចឈានទៅដល់ការព្រមព្រៀងលើបញ្ហា និងគោលការណ៍សំខាន់ៗក៏ដោយ នៅពេលដែលរបាយការណ៍ជំនួយបច្ចេកទេសពេញលេញ ត្រូវបានបង្ហោះទៅក្នុងគេហទំព័រ កាលពីខែសីហា ឆ្នាំ២០១១ គំរោងនេះ ត្រូវបានគេកម្រិតថាទទួលបានជោគជ័យដោយអន្លើៗតែប៉ុណ្ណោះ។ យោងទៅលើរបាយកាណ៍នេះ លទ្ធផលនៃជំនួយការបច្ចេកទេស "មិនបានសំរេចពេញលេញទេ ពីព្រោះមិនមានការរៀបចំកិច្ចសហប្រតិបត្តិការផ្លូវការថ្មីណាមួយ ត្រូវបានបង្កើតឡើងក្នុងតំបន់ទន្លេ៣។ ទោះបីជាជំនួយបច្ចេកទេស ត្រូវបានវាយតម្លៃថាបានជោគជ័យ ក្នុងការពង្រីកការផ្លាស់ប្តូរព័ត៌មាន រវាងអ្នកពាក់ពន្ធ័ និងបានលើកកម្ពស់ការយល់ដឹងពីបញ្ហាសំខាន់ៗក៏ដោយ វានៅតែមិនទទួលបានជោគជ័យ ក្នុងការកសាងស្ថាប័នមើលការខុសត្រូវអាងទឹកជាក់លាក់មួយដើម្បីធ្វើឲ្យមាននិរន្តរភាពដល់គំនិតផ្តួចផ្តើមដែលគាំទ្រដោយជំនួយបច្ចេកទេស។ ដោយសារតែគ្មានស្ថាប័នណាមួយ ត្រូវបានកសាងឡើងដើម្បីបន្តគំនិតផ្តួចផ្តើមទាំងនោះ ទើបផែនទីបង្ហាញផ្លូវ នៅតែស្ថិតក្នុងទម្រង់ជាផែនទីព្រៀង និងមិនអាចយកទៅអនុវត្តបាន។ ទោះបីជាយ៉ាងណាក៏ដោយ កម្មវិធីជាច្រើនត្រូវបានស្នើឡើង ឬកំពុងអនុវត្តដោយស្ថាប័នផ្សេងៗ ដែលផ្អែកលើការសហការដែលបង្កើតឡើងតាម រយៈការសិក្សាក្នុងតំបន់ទន្លេ៣។ ទាំងនេះរួមបញ្ចូលគំរោង មេគង្គ IWRM ដែលផ្តល់មូលនិធិដោយធនាគារពិភពលោក (មានពិភាក្សាក្នុងផ្នែក ៣.២ ខាងក្រោម)។ សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) ក៏មានគំរោងពង្រឹងកិច្ចសហការឆ្លងដែន និងការចែករំលែកព័ត៌មានផងដែរ ដោយរួមបញ្ចូលការថែរទាំងគេហទំព័រតំបន់ទន្លេ៣ ដែលបានបង្កើតឡើងដោយជំនួយបច្ចេកទេស (TA)[186]។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនមានកត្តាណាមួយដែលបង្ហាញថា ធនាគារអភិវឌ្ឍន៍អាស៊ី នឹងបន្តតាមដានលើគំរោងនាពេលអនាគត ដែលផ្អែកលើការអនុវត្តផែនទីបង្ហាញផ្លូវក្នុងតំបន់ទន្លេ៣។

### *ធនគារអភិវឌ្ឍន៍អាស៊ី គាំទ្រគម្រោងខ្សែបញ្ជូនថាមពលកំលាំង៥០០គីឡូវ៉ុល ពីភាគខាងត្បូងប្រទេសឡាវ ទៅភាគកណ្តាលប្រទេសវៀតណាម*

ដូចដែលបានពិភាក្សានៅខាងដើម ទំនប់តាមដងទន្លេសេសាន ក្នុងខ្ពង់រាបភាគកណ្តាលប្រទេសវៀតណាម បានបង្កវិនាសកម្មយ៉ាងធំធេងដល់បរិស្ថាន និងសង្គម ហើយក៏មានផលប៉ះពាល់ឆ្លង

186 Asian Development Bank, *Technical Assistance Completion Report, TA 6367-REG: Sesan, Srepok and Sekong River Basins Development Study in Cambodia, Lao PDR and Vietnam*, August 2011.

ដែនដ៏ធ្ងន់ធ្ងរដល់ប្រទេសកម្ពុជាផងដែរ។ ភាគខាងជើងនៃប្រទេសកម្ពុជាក្នុងទឹកដីប្រទេសឡាវ មាន គំរោងសាងសង់ទំនប់វារីអគ្គិសនីជាច្រើនតាមដងទន្លេសេកុង។ កង្វល់ប្រហាក់ប្រហែលគ្នា បានលើកឡើងអំពីផលប៉ះពាល់អវិជ្ជមានដ៏ធ្ងន់ធ្ងរដល់ផ្នែកខាងក្រោមទំនប់ ទៅលើទន្លេ និងសហគមន៍ក្នុងប្រទេសកម្ពុជា ហើយមានការរិះគន់ថា មិនមានការពិចារណាឲ្យបានមត់ចត់ អំពីផលប៉ះពាល់ឆ្លងដែនដែលបណ្តាលពីការសាងសង់ទំនប់ទាំងនោះ។ ថ្វីបើមានការព្រួយបារម្ភបែបនេះក្តី បច្ចុប្បន្ននេះ ធនាគារអភិវឌ្ឍន៍អាស៊ី កំពុងធ្វើការជាមួយរដ្ឋាភិបាលនៃប្រទេសទាំងពីរ ដើម្បីគាំទ្រទៅដល់ការអភិវឌ្ឍន៍បណ្តាញបញ្ជូនចរន្តអគ្គិសនី ដែលតភ្ជាប់ពីទំនប់ក្នុងភាពខាងត្បូងប្រទេសឡាវ ទៅកាន់បណ្តាញ អគ្គិសនីជាតិរបស់វៀតណាម។

ក្នុងឆ្នាំ២០០៨ រដ្ឋាភិបាលឡាវ និងវៀតណាម បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងលក់ថាមពលរហូតដល់ ៥,០០០មេហ្គាវ៉ាត់ត្រឹមឆ្នាំ២០២០។ ឥឡូវនេះ ផែនការជាច្រើនកំពុងដំណើរការទៅមុខ ដើម្បីអភិវឌ្ឍន៍បណ្តាញបញ្ជូនចរន្តទៅកាន់ប្រទេសទាំង២[187]។ បណ្តាញបញ្ជូនចរន្តនេះ ជាផ្នែកមួយដ៏សំខាន់នៃផែនការពាណិជ្ជកម្មថាមពលថ្នាក់តំបន់ អនុតំបន់ទន្លេមេគង្គ (GMS) ហើយវានឹងផ្តល់ការភ្ជាប់គ្នារវាងស្ថានីយផលិតថាមពលអគ្គិសនីនៅភាគខាងត្បូងប្រទេសឡាវ និងស្ថានីយអគ្គិសនីនៅខ្ពង់រាបភាគកណ្តាលនៃប្រទេសវៀតណាម។

ឆ្នាំ២០០៩ ធនាគារអភិវឌ្ឍន៍អាស៊ី បានអនុម័តផ្តល់ជំនួយបច្ចេកទេស ដើម្បីរៀបចំគំរោងបណ្តាញបញ្ជូនចរន្ត *បាន់ សុក - ផ្លៃគូ* ក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS)[188]។ ជំនួយការបច្ចេកទេស នេះ មានតំលៃសរុប ១,៣០០,០០០ដុល្លាសហរដ្ឋអាមេរិក ដែលក្នុងនោះ ទឹកប្រាក់ចំនួន ១លានដុល្លាសហរដ្ឋអាមេរិក បានមកពីធនាគារអភិវឌ្ឍន៍អាស៊ី និង១៥០,០០០ដុល្លាសហរដ្ឋអាមេរិក ជាប្រាក់ បដិភាគពីរដ្ឋាភិបាល ទាំងពីរ វៀតណាម - ឡាវ។ គំរោងបណ្តាញបញ្ជូនចរន្តនេះ នឹងតភ្ជាប់ពីទំនប់វារីអគ្គិសនីនៅភាគខាងត្បូងប្រទេសឡាវ ទៅកាន់ប្រទេសវៀតណាម ហើយយោងតាមឯកសារដំបូងរបស់ធនាគារអភិវឌ្ឍន៍ គម្រោងនេះត្រូវប្រត្តិបតិការ និងថែរទាំដោយក្រុមហ៊ុន *អេឡិចត្រិច ឌុយ ឡាវ (EdL)* ហើយ និងក្រុមហ៊ុន *ណាស់ស៊ិនណល ទ្រេនស្មីសិន ខុមភេនី (NTC)* ដែលជាក្រុមហ៊ុន មាន ភាគហ៊ុន ១០០% របស់អគ្គិសនីវៀតណាម *(EVN)*[189]។ របាយការណ៍សារព័ត៌មានឆ្នាំ២០១០ បង្ហាញថា សាជីវកម្ម *សុង ដា ខុបភឺរេស៊ិន (Song Da Corpera-tion)* ជាអ្នកទទួលខុសត្រូវសាងសង់បណ្តាញបញ្ជូនចរន្តនេះ [190]។

187 *Asian Development Bank, Project 41450: Preparing the Ban Sok-Pleiku Power Transmission Project in the Greater Mekong Subregion, August 2008 (para 3).*

188 *ADB Website, Project Information Document, TA6481: Preparing the Ban Sok-Pleiku Power Transmission Project in the Greater Mekong Subregion http://pid.adb.org/pid/TaView.htm?projNo=41450&seqNo=01&typeCd=2 (accessed April 2012).*

189 *Asian Development Bank, Project 41450: Preparing the Ban Sok-Pleiku Power Transmission Project in the Greater Mekong Subregion, August 2008 (para 2).*

190 *The Saigon Times, Vietnam-Laos power line ready by 2015, 21 July 2010.*

**សុងដា ខុបភឺរេស៊ិន** (Song Da Corperation)

សុងដា ខុបភឺរេស៊ិន គឺជាសហគ្រាសរបស់រដ្ឋ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្មវៀតណាម។ ថ្វីបើវាមិនមាន ភាគហ៊ុនរបស់អគ្គិសនីវៀតណាម *សុងដា* បានសាងសង់ទំនប់ជាច្រើន ឲ្យក្រុមហ៊ុន ហើយអគ្គិសនីវៀតណាម ត្រូវបានចុះបញ្ជីជាក្រុមហ៊ុនដៃគូនៅក្នុងគេហទំព័រក្រុមហ៊ុន[191]។ *សុងដា* កំពុងសាងសង់ទំនប់ ស៊ីកាមែន១ (Xe Kaman1) ដែលវាហាក់ដូចជាគំរោងទី១ដើម្បីតភ្ជាប់ទៅនិងបណ្តាញបញ្ជូនចរន្ត[192]។ នៅក្នុងសន្ទរកថារបស់ឧបនាយករដ្ឋមន្ត្រីវៀតណាម ក្នុងពិធីបើកការដ្ឋានថា គំរោងនេះគឺជាគំរោងវិនិយោគក្រៅប្រទេសដ៏ធំមួយរបស់ប្រទេសវៀតណាម ហើយត្រូវបានគេចាត់ទុកជានិមិត្តរូបនៃការសហការគ្នារវាងប្រទេសទាំងពីរ។ លោកឧបនាយករដ្ឋមន្ត្រី ក៏បានបង្ហាញផងដែរថា គំរោងនេះ នឹងជួយត្រួសត្រាយផ្លូវសំរាប់គំរោងផ្សេងៗជាច្រើនទៀត និងចូលរួមចំណែក ជួយដល់យុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការរបស់ប្រទេសទាំង២ ដើម្បីសម្រេចឲ្យបាន ៥,០០០មេហ្គាវ៉ាត់ត្រឹមឆ្នាំ២០២០។ យោងតាមសារព័ត៌មានវៀតណាម *សុងដា* កំពុងធ្វើការសិក្សារកលទ្ធភាពដែល អាចធ្វើបាន សំរាប់គម្រោងទំនប់វារីអគ្គិសនីចំនួន៦បន្ថែមទៀត ក្នុងភាគខាងត្បូងប្រទេសឡាវ [193]។

សកម្មភាពជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី រួមមានការរៀបចំបណ្តាញបញ្ជូនចរន្តពិនិត្យ និងកែតម្រូវបញ្ហាហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរបស់គំរោង រៀបចំសិក្សាវាយតំលៃហេតុប៉ះពាល់ បរិស្ថាន ផែនការតាំងទីលំនៅថ្មី និងផែនការគ្រប់គ្រងបរិស្ថាន (EMP) សំរាប់អនុស្ថានីយ៍ និងបណ្តាញ ថាមពល។ សកម្មភាពជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមួយទៀត គឺត្រូវប៉ាន់ស្មាន និង ពង្រាងឯកសារច្បាប់សំរាប់ការធ្វើពាណិជ្ជកម្មរួមគ្នាសំរាប់ប្រតិបត្តិការគ្រឿងបរិក្ខាផ្សេងៗ[194]។

ឯកសារព័ត៌មានគំរោង (PID) លើគេហទំព័រធនាគារអភិវឌ្ឍន៍ ត្រូវបានធ្វើបច្ចុប្បន្នកម្ម ខែមិនាឆ្នាំ២០១២ ហើយបង្ហាញថា ការរៀបចំគំរោងបណ្តាញបញ្ជូនចរន្តកំលាំង៥០០គីឡូវ៉ុល តឡូវត្រូវបានព្រមព្រៀងរវាងរដ្ឋាភិបាលឡាវ និងវៀតណាម ហើយនិងធនាគារអភិវឌ្ឍន៍អាស៊ី[195]។ ទោះបីជាយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ មិនមានការផ្សព្វផ្សាយព័ត៌មានជាសាធារណៈទេ ពាក់ព័ន្ធផ្លូវបញ្ជូនចរន្តចុងក្រោយ តំលៃ និងផលប៉ះពាល់ផ្សេងៗបណ្តាលពីគំរោងនេះ។ រហូតដល់ឯកសារចេញជាសាធារណៈ ហើយក្តី ព័ត៌មាននៅតែមានចន្លោះប្រហោងដដែរ ហើយសេចក្តីសង្ខេបខាងក្រោម គឺផ្អែកទៅលើ

191 *Song Da website, Company history: http://www.songda.vn/info/en/tabid/179/ItemID/1/View/Details/Default.aspx; Song Da partners: http://www.songda.vn/info/en/tabid/179/ItemID/6/View/Details/Default.aspx (accessed November 2011).*
192 Song Da website, http://songda.com.vn/info/en/Detail/tabid/181/ItemID/1805/View/Details/Default.aspx (accessed November 2011).
193 Vietnam News, Work starts on Laos hydropower plant, 7 March 2011.
194 ADB website, Project Information Document: Preparing the Ban Sok-Pleiku Power Transmission Project in the Greater Mekong Subregion, http://pid.adb.org/pid/TaView.htm?projNo=41450&seqNo=01&typeCd=2 (accessed April 2012).
195 Ibid.

ព័ត៌មានដែលទទួលយកបានក្នុងពេលថ្មីៗ។ ម្យ៉ាងទៀត ជំនួយបច្ចេកទេសដែលបានពិភាក្សានៅទីនេះ ពាក់ព័ន្ធតែជាមួយ «**ការរៀបចំ**» បណ្តាញបញ្ជូនចរន្តប៉ុណ្ណោះ ហើយវានៅមិនទាន់ច្បាស់ថាតើធនាគារអភិវឌ្ឍន៍អាស៊ី តាំងចិត្តគាំទ្របន្ថែមទៀត ដល់ការសាងសង់បណ្តាញបញ្ជូនចរន្តនេះដែរ ឬអត់។

យោងទៅលើឯកសារគំរោងដំបូងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គំរោងអភិវឌ្ឍន៍បណ្តាញបញ្ជូនចរន្ត នឹងជាប់ទាក់ទងជាមួយការសាងសង់បណ្តាញបញ្ជូនចរន្តចំងាយ៦៥km កំលាំង ៥០០គីឡូវ៉ុល ពីអនុស្ថានីយ៍ *បានសុក* ក្នុងប្រទេសឡាវ ទៅព្រំប្រទល់ប្រទេសវៀតណាម ហើយនិងការសាងសង់ បណ្តាញបញ្ជូនចរន្តមួយខ្សែទៀត ចំងាយ ១០០km កំលាំង៥០០គីឡូវ៉ុលពីព្រំប្រទល់ប្រទេសឡាវ ទៅអនុស្ថានីយ៍ *ផ្លេគូ* ក្នុងប្រទេសវៀតណាម។ ទាំងនេះ នឹងតំរូវឲ្យមានការសាងសង់អនុស្ថានីយ៍នៅ *បានសុក* និងការពង្រីកអនុស្ថានីយ៍ចាស់នៅ *ផ្លេគូ*។ ផ្លូវនៃបណ្តាញបញ្ជូនចរន្ត ត្រូវថាបានផ្លាស់ប្តូរ (ចំនុចនេះ នឹងត្រូវពិភាក្សាថែមទៀតនៅខាងក្រោម)។ ឯកសាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០១០ ស្តីពីពាណិជ្ជកម្មថាមពលក្នុងតំបន់បង្ហាញថា ថាមពល១,០០០ មេហ្កាវ៉ាត់ នឹងអាចនាំចេញទៅប្រទេសវៀតណាមតាមរយៈបណ្តាញបញ្ជូនចរន្តនេះ [196]។

បណ្តាញចែកចាយអគ្គិសនី ត្រូវបានគ្រោងនឹងតភ្ជាប់ទៅទំនប់សេកាម៉ាន១ (៤៨៨មវ) ទំនប់សេកុងលើ៣ (១៥២មវ) សេកុងក្រោម៣ (៩៦មវ) និងទំនប់វារីអគ្គិសនីដាក់អ៊ីមូលនៅភាគខាងត្បូងនៃប្រទេសឡាវ (១៣៨មវ)។ ឯកសារគម្រោងរបស់អេឌីប៊ី ADB បង្ហាញថា ទំនប់វារីអគ្គិសនីចំនួន១១ ត្រូវបានគ្រោងនៅក្នុងភាគខាងត្បូងប្រទេសឡាវ ដែលមានសមត្ថភាពផលិតថាមពលចំនួន ១,៣០០មវ ដែល១,០០០មវ នឹងត្រូវនាំចេញតាមបណ្តាញចែកចាយអគ្គិសនី *បានសុក-ផ្លេគូ*។ ផ្អែកលើឯកសារនេះ «**គម្រោងទំនប់វារីអគ្គិសនីនីមួយៗ នឹងត្រូវបង្កើតបណ្តាញថាមពលបញ្ជូនទៅស្ថានីយ៍ *បានសុក* ទាំងអស់**»។[197] មានឯកសារថ្មីៗជាច្រើន បង្ហាញថា ឥឡូវនេះបណ្តាញ បញ្ជូនចរន្តដែល បានគ្រោងទុកនោះ ត្រូវបានផ្លាស់ប្តូរហើយ គឺប្តូរមកតភ្ជាប់ទៅ ទំនប់វារីអគ្គិសនីសេកាម៉ាន១ ណាម ខង១ (២២៩មវ) សេកុង៤ (៤៦៤មវ) និងសេកុង៥ (៣៨៨មវ)។[198]

196 Asian Development Bank, RETA 6440: Facilitating Regional Power Trading and Environmentally Sustainable Development of Electricity Infrastructure in the Greater Mekong Subregion, Final report - Component 1, Module 1: Update of the GMS Regional Master Plan, executive summary, 15 October 2010 (p51).

197 ធនាគារ ADB, គម្រោង៤១៤៥០៖ គម្រោងរៀបចំបណ្តាញថាមពលបានសុកផ្លេគូ នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ, ខែសីហា ឆ្នាំ២០០៨ (កថាខ័ណ្ឌទី៦)

198 គេហទំព័ររបស់ធនាគារ ADB, ឯកសារព័ត៌មានគម្រោង៖ គម្រោងរៀបចំបណ្តាញថាមពលបានសុកផ្លេគូ នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ, http://pid.adb.org/pid/TaView.htm?projNo=41450&seqNo=01&typeCd=2 (ចេញផ្សាយខែមេសា ឆ្នាំ២០១២)




ផ្លេគូដែលទទួលបានពីឯកសារគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី *ADB*[199]

ឯកសារជំនួយបច្ចេកទេសដំបូង បានបង្ហាញថា គម្រោងទំនប់វារីអគ្គិសនីសេកាម៉ាន ១ នឹងចាប់ផ្តើមដំណើរការនៅពាក់កណ្តាលឆ្នាំ២០១៣។ មានឯកសារដ៏ដែរនេះបានបញ្ជាក់ផងដែរថា បណ្តាញបញ្ជូនចរន្ត *បានសុក-ផ្លេគូ* និងអនុស្ថានីយ៍ពាក់ព័ន្ធ នឹងត្រូវបានបញ្ចប់ ព្រមទាំងដាក់ឲ្យដំណើរការនៅចុងឆ្នាំ២០១២។[200] ទោះជាយ៉ាងណាក៏ដោយ យោងតាមរបាយការណ៍សារព័ត៌មាន ខែកក្កដា ឆ្នាំ ២០១០ មន្ត្រីដែលមកពីអ៊ីលិត្រិចស៊ីតេ ឌុយឡាវ បាននិយាយថា បណ្តាញបញ្ជូនចរន្តនឹងមិនអាចកើតមាន និងដំណើរការបានទេ ទាល់តែដល់ឆ្នាំ២០១៥។ យោងតាមព័ត៌មានជាផ្លូវការមួយ បានឲ្យដឹងទៀតថា អ្នកអភិវឌ្ឍន៍គម្រោងគឺ ក្រុមហ៊ុនវៀតណាម សុង ដា ខូជីរេសិន "ហើយធនាគារ អភិវឌ្ឍន៍អាស៊ី ADB គឺអាចជាអ្នកផ្តល់ទុន និងបច្ចេកទេសសម្រាប់ការអភិវឌ្ឍន៍គម្រោងមួយនេះ។"[201] យោងតាមគេ

199 ធនាគារ ADB, គម្រោង៤១៤៥៩៖ គម្រោងរៀបចំបណ្តាញថាមពលបានសុកផ្លេគូ នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ, ខែសីហា ឆ្នាំ២០០៨

200 អាយប៊ិត Ibid (កថាខ័ណ្ឌទី៧)

201 សារព័ត៌មានសាយហ្គោនធេម, បណ្តាញថាមពលវៀតណាម និងឡាវ នឹងរួចរាល់ក្នុងឆ្នាំ២០១៥, ចុះផ្សាយថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០

ហទំព័ររបស់រដ្ឋាភិបាលឡាវបានឲ្យដឹងថា ទំនប់វារីអគ្គិសនីសេកាម៉ាន ស្ថិតក្នុងដំណាក់ សាងសង់ ហើយនឹងចាប់ផ្តើមក្នុងឆ្នាំ២០១៣។[202]

របាយការណ៍វាយតម្លៃវិស័យថាមពលរបស់ប្រទេសឡាវឆ្នាំ២០១០ របស់ធនាគារ ADB បាន បញ្ជាក់ថា គម្រោងកំពុងមានដំណើរការទៅមុខយឺតយ៉ាវ គឺមានតែទំនប់វារីអគ្គិសនីសេកាម៉ាន១ ប៉ុណ្ណោះ ដែលឋិតនៅក្នុងដំណាក់កាលសាងសង់ “**ក្រៅពីនោះគឺមានដំណើរការទៅមុខតិចតួចបំផុត សម្រាប់គម្រោងទំនប់វារីអគ្គិសនីផ្សេងទៀត**”។[203] ឯកសារមួយផ្សេងទៀតរបស់ធនាគារ ADB បាន បង្ហាញថា គម្រោងនេះត្រូវបានពន្យាពេល ហើយបញ្ជាក់ទៀតថា “**ករណីសិក្សាមួយចំនួនលើបណ្តាញ បញ្ជូនចរន្តអាទិភាព មិនបានជម្រុញឲ្យមានការទទួលយក ដោយសារមិនមានគម្រោងទំនប់វារីអគ្គិសនី ណាមួយ ដែលប្រើប្រាស់បណ្តាញបញ្ជូនចរន្តនេះ។ ទោះជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍន៍គម្រោង ទំនប់ វារីអគ្គិសនីនៅភាគខាងត្បូងប្រទេសឡាវ អាចជំរុញឲ្យមានការអភិវឌ្ឍន៍បណ្តាញថាមពល** ***បាន ហាត់សាន-កន្ទុំ*** (**ពីមុនហៅបានសុក-ផ្លេគូ**)”[204]។ សេចក្តីថ្លែងបែបនេះ បានបង្ហាញយ៉ាងច្បាស់ពី គម្រោងនេះ មានភាពចំណុះគ្នាទៅវិញទៅមក ក្នុងការអភិវឌ្ឍន៍គម្រោងទំនប់វារីអគ្គិសនីនៅភាគខាង ត្បូងប្រទេសឡាវ។ គួរបញ្ជាក់ផងដែរថា ការផ្លាស់ប្តូរឈ្មោះស្ថានីយ៍ពី ***“បានសុក-ផ្លេគូ”*** មក ***“បាន ហាត់ សាន-កន្ទុំ”*** បញ្ជាក់ច្បាស់ថា ផ្លូវបណ្តាញបញ្ជូនចរន្ត ក៏ត្រូវផ្លាស់ប្តូរដែរ។ យោងតាមធនាគារ ADB ឲ្យ ដឹងទៀតថា ការផ្លាស់ប្តូរផ្លូវនៃការតភ្ជាប់បណ្តាញបញ្ជូនចរន្តនេះ គឺដោយសារភាពខ្វះខាតដីនៅក្នុង តំបន់ស្ថានីយ៍ *បានសុក*។

---

202 http://www.poweringprogress.org/index.php?option=com_content&view=article&id=49&Itemid=53 (ចេញផ្សាយខែវិច្ឆិកា ឆ្នាំ ២០១១)

203 ធនាគារអភិវឌ្ឍន៍អាស៊ីADB,វិស័យថាមពលនៅឡាវ, យោយលេខ៖ *SAP: LAO 2010-42,* ការវាយតម្លៃកម្មវិធីកិច្ចសង្គ្រោះ, ខែតុលា ឆ្នាំ២០១០ (ទំព័រ ១៤-១៥)

204 ធនាគារអភិវឌ្ឍន៍អាស៊ីADB, សង្ខេបនៃកិច្ចប្រជុំពិភាក្សាពិសេសនៃគណៈកម្មាធិការសម្របសម្រួលការធ្វើពាណិជ្ជកម្មថាមពលថ្នាក់តំបន់ *(RPTCC-9A),*ក្រុងបាងកក, ប្រទេសថៃ, ខែធ្នូ ថ្ងៃទី១៤-១៥ ឆ្នាំ២០១០(កថាខ័ណទី៩)




ផែនទីការភ្ជាប់គំរោងទំនប់អគ្គិសនីទៅនឹងបណ្តាញ Ban Sok-Pleiku
ប្រភព៖ អគ្គិសនីប្រទេសឡាវ

ដូចគ្នានឹងការអង្កេតរបស់ធនាគារ ADB នៅក្នុងករណីសិក្សាក្នុងតំបន់ទន្លេបី(3S) និន្នាការពេលបច្ចុប្បន្នលើការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីក្នុងតំបន់ ធ្វើឲ្យមានការគម្រាមកំហែងធ្ងន់ធ្ងរដល់ទីជរាល និងលំហូរទឹកទៅផ្នែកខាងក្រោម ហើយការពិគ្រោះយោបល់ជាសាធារណៈ មានភាពមិនគ្រប់គ្រាន់ ដូចគ្នានឹងការគិតគូរពីផលប៉ះពាល់ឆ្លងដែន។ ទោះជាយ៉ាងណាក៏ដោយ ការគាំទ្រជាគោលការណ៍ ចំពោះការបែងចែកថាមពលនៅថ្នាក់តំបន់របស់ធនាគារ ADB ជាក់ស្តែង បានសម្របសម្រួលឲ្យមានការបន្តពង្រីកបន្ថែមនូវគម្រោងវារីអគ្គិសនី ជាពិសេសនៅក្នុងតំបន់ភាគខាងត្បូងប្រទេសឡាវ។ ជាការពិត បណ្តាញបញ្ជូនចរន្ត មិនចាំបាច់ទាល់តែសោះ ប្រសិនបើមិនមានការពង្រីក ការអភិវឌ្ឍន៍ទំនប់ វារីអគ្គិសនីក្នុងតំបន់ភាគខាងត្បូងប្រទេសឡាវ ហើយដូចគ្នានេះដែរ ប្រសិនបើមិនមានបណ្តាញបញ្ជូនចរន្ត ដែលមានកម្លាំងវ៉ុលត៍ខ្ពស់នោះទេ ស្ថានីយផលិតថាមពលវារីអគ្គិសនីតាមការគ្រោងទុក ក៏មិន អាចធ្វើទៅបានដែរ។ ដូចដែលបានឃើញនៅក្នុងផែនទីខាងលើ ដែលផលិតដោយ *អគ្គិសនីប្រទេសឡាវ* សម្រាប់ផែនការអភិវឌ្ឍន៍វិស័យថាមពលក្នុងប្រទេសដល់ឆ្នាំ២០២០ មានផែនការតភ្ជាប់បណ្តាញជា ច្រើនពី

ស្ថានីយផលិតថាមពលអគ្គិសនី ទៅកាន់បណ្តាញបញ្ជូនចរន្ត ឡាវ-វៀតណាម ដែលមានកម្លាំង វ៉ុលត៍ ៥00kv[205]។

ដូចមានបញ្ជាក់នៅខាងលើ ការតភ្ជាប់ពីស្ថានីយផលិតអគ្គិសនីមួយចំនួន ទៅនឹងបណ្តាញបញ្ជូនចរន្ត ធ្វើឲ្យការព្រួយបារម្ភជាខ្លាំក្នុងចំណោមសហគមន៍ងាយរងគ្រោះ និងអ្នកអង្កេត។ គម្រោងទំនប់សេកាម៉ាន១ ទំនងនឹងធ្វើឲ្យមានការប្រែប្រួលយ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធអេកូឡូស៊ីរបស់ទន្លេ ប៉ះពាល់ដល់មច្ឆជាតិ ការនេសាទត្រី និងកាត់បន្ថយគុណភាពទឹក។ ការសម្អាតផ្ទៃអាង និងកសាងផ្លូវចូល បានចាប់ផ្តើមមុនពេលដែលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវគេសិក្សាចប់សព្វគ្រប់ ឬ អនុម័តយល់ព្រមជាផ្លូវការ។ ដែលបានរំលោភបំពានលើច្បាប់ប្រទេសឡាវ។ មានរាយការណ៍ថា ទំនប់វារីអគ្គិសនីចំនួន៣ផ្សេងទៀត ដែលគ្រោងភ្ជាប់ទៅបណ្តាញបញ្ជូនចរន្តនេះ ហាក់ដូចជាមានផល ហេតុប៉ះពាល់ធ្ងន់ធ្ងរទៅលើបរិស្ថាន និងសង្គម។ ទំនប់វារីអគ្គិសនីសេកុង៤ នឹងក្លាយជាទំនប់ធំជាងគេបំផុងតនៅភាគខាងត្បូងនៃប្រទេសឡាវ ហើយនិងបង្សាំងចរាចរត្រីទាំងស្រុង ដែលការណ៍នេះ បង្កឲ្យ មានផលប៉ះពាល់ជាច្រើនដល់ប្រជាជនរាប់រយពាន់នាក់។ ផលប៉ះពាល់ពីទំនប់វារីអគ្គិសនីសេកុង៤ និង សេកុង៥ នឹងជះឥទ្ធិពលអាក្រក់មកដល់ផ្នែកខាងក្រោមនៃទំនប់ គឺប្រទេសកម្ពុជា តែទោះជាយ៉ាងណា ក៏ដោយ យោងតាមអង្គការទន្លេអន្តរជាតិ (IR) បានឲ្យដឹងថាមិនទាន់មានការចុះពិនិត្យ ឬអង្កេតណា មួយកើតឡើងនៅឡើយទេក្នុងប្រទេសកម្ពុជានោះ។ អង្គការទន្លេអន្តរជាតិ បានអះអាងថា លក្ខខ័ណ្ឌ នៃការតាំងទីលំនៅថ្មី និងការស្តារជីវភាពឡើងវិញ មិនទាន់គ្រប់គ្រាន់សមល្មមទេសម្រាប់ប្រជាជន ចំនួន ៥,000នាក់ដែលត្រូវរើចេញទៅតាំងទីលំនៅថ្មីនោះ។ ទំនប់វារីអគ្គិសនីណាមខង១ នឹងរាំងខ្ទប់ ចរាចរត្រី ហើយនឹងប៉ះពាល់ដល់ជនជាតិដើមភាគតិច *ព្រៅ* ដ៏ច្រើនសន្ធឹកសន្ធាប់។ សហគមន៍រងគ្រោះ ជាច្រើននាក់ ទទួលបានព័ត៌មានតិចតួចបំផុតពីគម្រោង និងមានក្តីបារម្ភយ៉ាងខ្លាំងដល់ផលប៉ះពាល់ ដែលនឹងកើតមានដល់ផ្នែកខាងក្រោម ដែលផលប៉ះពាល់ទាំងនេះ ហាក់ដូចជាមិនអាចកាត់បន្ថយបាន ឬទទួលបានសំណងគ្រប់គ្រាន់ ហើយគម្រោងនោះ នឹងបង្កឲ្យមានផលប៉ះពាល់ច្រើនដល់ទន្លេសេកុងក្នុងប្រទេសកម្ពុជា ដែលមិនអាចប៉ាន់ស្មានបាន។[206]

គម្រោងទាំងអស់របស់ធនាគារ ADB ត្រូវតែអនុវត្តការស្ទាបស្ទង់មើលជាមុន មុនធ្វើប្រតិបត្តិការបន្ទាប់មកធ្វើការតាមដានគ្រប់ដំណាក់កាលដើម្បីធ្វើឲ្យប្រាកដថា គម្រោងទាំងអស់ បានដើរស្របតាមគោលនយោបាយបង្ការរបស់ធនាគារ ADB។ ប្រសិនបើធនាគារ ADB ធ្វើការគាំទ្រដោយផ្ទាល់លើការសាងសង់បណ្តាញបញ្ជូនចរន្ត នោះគោលនយោបាយបង្ការរបស់ពួកគ នឹងគ្របដណ្តប់លើការសាងសង់បណ្តាញបញ្ជូនចរន្ត និងការសាងសង់អនុស្ថានីយ៍ដែរ។ ឧទាហរណ៍ថា ផលប៉ះពាល់អវិជ្ជមានលើផ្នែក

---

205 គេហទំព័ររបស់ *Electricité du Laos*: http://www.edl.com.la/en/download/EDL_Network_PDP_Up9_06_2011.pdf (ផ្សាយក្នុងខែវិច្ឆិកា ឆ្នាំ២០១១)

206 អង្គការទន្លេអន្តរជាតិ, ថាមពលកើតឡើង៖ ផលប៉ះពាល់នៃការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីយ៉ាងលឿនក្នុងប្រទេសឡាវ, ខែកញ្ញា ឆ្នាំ២០០៨

បរិស្ថាន គួរតែបញ្ចៀស ឬកាត់បន្ថយ ហើយការតាំងទីលំនៅថ្មី ចាំបាច់ត្រូវតែអនុវត្តឲ្យស្របតាមគោលនយោបាយរបស់ធនាគារ ADB ។ ផ្នែកមួយនៅក្នុងឯកសារបច្ចេកទេស គឺរៀបចំបណ្តាញបញ្ជូនថាមពលដោយរួមបញ្ចូលទាំងការសិក្សាពីផលប៉ះពាល់របស់គម្រោង និងការសម្របសម្រួលរបស់ក្រុមការងារគម្រោង ធ្វើដូចនេះដើម្បីកំណត់ឲ្យច្បាស់ពី **«ការតភ្ជាប់បណ្តាញបញ្ជូនថាមពលរបស់ស្ថានីយ៍ *បានសុក* ទៅស្ថានីយ៍ទំនប់វារីអគ្គិសនី *សេកាម៉ាន១ សេកុងក្រោម៣ សេកុងលើ៣* និងទំនប់ *ដាក់ អ៊ីមួល*»**[207] ។ មិនមានការលើកឡើងពីការគិតគូរទៅលើផលប៉ះពាល់ដល់បរិស្ថាន និងសង្គម ពីគម្រោង ទំនប់វារីអគ្គិសនី ដែលនឹងតភ្ជាប់ទៅស្ថានីយដែលឋិតនៅទីតាំងទំនប់នោះទេ។

ទោះជាយ៉ាងណាក៏ដោយ បណ្តាញបញ្ជូនចរន្ត មិនមែនជាហេតុចំបងធ្វើឲ្យសហគមន៍ និងសង្គមស៊ីវិលមានក្តីបារម្ភនោះទេ តែគឺទំនប់វារីអគ្គិសនីដែលភ្ជាប់ទៅខ្សែបណ្តាញនោះទៅវិញទេ ដែលជាក្តីបារម្ភរបស់សហគមន៍ និងសង្គមស៊ីវិល។ វាមិនមានភាពច្បាស់លាស់ទេកន្លងមក ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារ ADB ដើម្បីឲ្យប្រាកដថា គម្រោងរបស់ខ្លួន មិនបានលើកទឹកចិត្តការអភិវឌ្ឍន៍ទាំងឡាយណាដែលមិនបំពេញតាមស្តង់ដាអប្បរមា និងគោលនយោបាយការពាររបស់ធនាគារ ADB ហើយក្នុងករណីខ្លះអាចមានរហូតដល់រំលោភលើច្បាប់ជាតិទៅទៀត។ យុទ្ធសាស្ត្ររបស់ធនាគារ ADB នៅប្រទេសឡាវបញ្ជាក់ថា **«ខ្លួននឹងបន្តដាក់បញ្ចូលការគ្រប់គ្រងបរិស្ថានដ៏ត្រឹមត្រូវ ទៅក្នុងប្រតិបត្តិការទាំងអស់ តាមរយៈការដាក់បញ្ចូលគោលនយោបាយសុវត្ថិភាពសង្គម និងបរិស្ថាន និងតាមរយៈការជជែកពិភាក្សាគោលនយោបាយផ្សេងៗ ហើយធនាគារ ADB ក៏លើកទឹកចិត្តរដ្ឋាភិបាល ឲ្យទទួលយកនូវស្តង់ដារប្រហាក់ប្រហែលគ្នា សម្រាប់អនុវត្តលើគ្រប់គម្រោងវិនិយោគធំៗលើវិស័យធនធានធម្មជាតិ»** ផងដែរ។ ទោះជាយ៉ាណាក៏ដោយ បើគម្រោងដែលបានគ្រោង បានដើរទៅមុខ ហើយដើររហូតទៅដល់ទំបន់វារីអគ្គិសនីដែលមិនឆ្លើយតបតាមលក្ខណៈស្តង់ដាររបស់ធនាគារ ADB ឬច្បាប់ជាតិនោះ ការអះអាងទាំងនេះ អាចនឹងត្រូវបានចោទជាសំណួរ។ ធនាគារ ADB បានថ្លែងនៅក្នុងទំនាក់ទំនងជាមួយម្ចាស់គំរោងថា នៅពេលដែលការអភិវឌ្ឍន៍គម្រោងទំនប់វារីអគ្គិសនី និងបណ្តាញបញ្ជូនថាមពល ត្រូវបានទទួលធ្វើដោយអ្នកអភិវឌ្ឍន៍ឯកជន គំរោងទាំងអស់នោះ មិនចាំបាច់គោរពតាមគោលនយោបាយសុវត្ថិភាពរបស់ធនាគារ ADB ឡើយ។ កន្លងមក ធនាគារ ADB បានប្រឹងប្រែងអនុវត្តនូវគម្រោង ពាក់ព័ន្ធមួយចំនួន បើទោះបីជាតម្រូវកាឲ្យគោរពតាមស្តង់ដាររបស់ធនាគារ ក្នុងគម្រោងបណ្តាញបញ្ជូនចរន្តនេះ មិនចាំបាច់ក៏ដោយ។ ឧទាហរណ៍ នៅក្នុងគម្រោងបណ្តាញបញ្ជូនចរន្ត ដែលផ្តល់មូលនិធិ ដោយធនាគារ ADB នៅក្នុងខេត្តយូណាន ប្រទេសចិន ធនាគារបានខិតខំប្រឹងប្រែងអនុវត្តនូវគម្រោងថាមពលវារីអគ្គិសនីមួយ បន្ទាប់ពីកង្វល់ជាច្រើនត្រូវបានលើកឡើងជុំវិញការតាំងទីលំនៅថ្មី និងក្នុង

207 ធនាគារអភិវឌ្ឍន៍អាស៊ី ADB, គម្រោង៤១៤៥០គម្រោង៤១៤៥៩៖ គម្រោងរៀបចំបណ្តាញថាមពលបានសុកផ្លេគូ នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ, ខែសីហា ឆ្នាំ២០០៨ (កថាខ័ណ្ឌទី១៤)

ចំណោមបញ្ហាផ្សេងៗទៀតជាច្រើន[208]។ គេសង្ឃឹមថា ការសិក្សាវាយតម្លៃស្រដៀងគ្នានេះ នឹងត្រូវធ្វើឡើងនៅតំបន់ទន្លេទាំងបី ប្រសិនបើធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានអនុម័តគាំទ្រដល់គម្រោងសាងសង់បណ្តាញបញ្ជូនចរន្តក្នុងតំបន់នេះ។

ខណៈពេលដែលគម្រោងនេះ នៅតែឋិតក្រោមការពិភាក្សា គឺនៅក្នុងដំណាក់កាលផ្សព្វផ្សាយនៅឡើយ ទិសដៅចុងក្រោយនៃបណ្តាញបញ្ជូនចរន្ត នៅមានភាពមិនប្រាកដប្រជានៅឡើយ ហើយវានៅមិនទាន់ច្បាស់ថា តើបណ្តាញបញ្ជូនចរន្តនេះ នឹងភ្ជាប់ទៅកាន់ទំនប់វារីអគ្គិសនីមួយណា? ហើយការសាងសង់នេះ នឹងទទួលបានមូនិធិដោយវិធីណា?

នៅក្នុងខែមីនា ឆ្នាំ២០១២នេះ ធនាគារ ADB បានអនុម័តលើកម្ចីនូវទឹកប្រាក់ចំនួន៧៣០លានដុល្លារសហរដ្ឋអាមេរិក សម្រាប់វៀតណាម ក្នុងការអភិវឌ្ឍន៍បណ្តាញបញ្ជូនចរន្តនៅក្នុងស្រុក។ ប្រាក់កម្ចីនឹងត្រូវផ្តល់ជូនជា៤ដំណាក់កាល ដំណាក់កាលដំបូងគឺត្រូវអនុម័តក្នុងខែមីនា ឆ្នាំ២០១២។ [209] ផ្នែកមួយនៃផែនការរបស់ប្រទេសវៀតណាម បានបញ្ចូលការសាងសង់បណ្តាញបញ្ជូនថាមពល ដែល មានកម្លាំងវ៉ុលត៍៥០០kv ភ្ជាប់ពី *ផ្លេគូ* ទៅ *ម៉ាយកុក* និង *កៅបុង*។ យោងតាមការថ្លែងរបស់សារ ព័ត៌មានរបស់វៀតណាមបានឲ្យដឹងថា បណ្តាញថាមពល "**នឹងនាំចូលថាមពលពីប្រទេសឡាវ ទៅ ប្រទេសវៀតណាម និងបង្កើតបណ្តាញថាមពលរវាងប្រទេសបី គឺប្រទេសឡាវ វៀតណាម និងប្រទេសកម្ពុជា។**"[210]

## កិច្ចសង្គ្រោះបច្ចេកទេស(TA) ផ្សេងទៀតលើពាណិជ្ជកម្មថាមពលក្នុងតំបន់

ធនាគារ ADB បានផ្តល់ទុនសម្រាប់កិច្ចសង្គ្រោះបច្ចេកទេសជាក់លាក់មួយ ដល់ការធ្វើជំនួញលើវិស័យថាមពលក្នុងថ្នាក់តំបន់។ ចាប់តាំងពីឆ្នាំ២០០៧មក SIDA ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ រដ្ឋាភិបាលស៊ុយអែត បានផ្តល់មូលនិធិមួយដល់កិច្ចសង្គ្រោះបច្ចេកទេសតាមរយៈធនាគារ ADB ផ្តោតលើ "**ការសម្របសម្រួលពាណិជ្ជកម្មថាមពល និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីក្នុង មហាអនុតំបន់ទន្លេមេគង្គប្រកបដោយនិរន្តរភាពបរិស្ថាន**"។[211] គម្រោងមាន២ផ្នែកសំខាន់ៗ៖ គឺសម្រប សម្រួលពាណិជ្ជកម្មថាមក្នុងតំបន់ កសាងសមត្ថភាពសម្រាប់គ្រប់គ្រងផលប៉ះពាល់ដែលកើតមានពី គម្រោងថាមពល។ កិច្ចសង្គ្រោះនេះ រាប់បញ្ចូលទាំងការគាំទ្រដល់ការបញ្ចប់ផែនការមេថ្នាក់តំបន់ សម្រាប់ការត

208 Asian Development Bank, *Project Completi on Report on the Yunnan Dachaoshan Power Transmission Project (Loan1644-PRC) in the People's Republic of China*, August 2005, htt p://www2.adb.org/Documents/PCRs/PRC/pcr-prc-30474.pdf (accessed April 2012). (page 43, para 2)

209 គេហទំព័ររបស់ADBព័ត៌មានគម្រោង ៤២០០៣៩៖ ការវិនិយោគលើកម្មវិធីបណ្តាញចែកចាយថាមពលអគ្គិសនី, http://www2.adb.org/Projects/project.asp?id=42039 (ចុះផ្សាយខែមេសា ឆ្នាំ២០១២)។

210 Nhan Dan Online, ៨២០កោដដុង ចុងកិច្ចសន្យាសម្រាប់គម្រោងថាមពល, ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២

211ធនាគារអភិវឌ្ឍន៍អាស៊ី ADB,គម្រោង៤១០៤៨៖ ការសម្របសម្រួលពាណិជ្ជកម្មថាមពលថ្នាក់តំបន់ និងនិរន្តរភាពនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនីលើបរិស្ថានក្នុងមហាអនុតំបន់ទន្លេមេគង្គ, ខែវិច្ឆិកា ឆ្នាំ២០០៧

ភ្ជាប់បណ្តាញថាមពលផង ធ្វើការកំណត់គម្រោងតភ្ជាប់បណ្តាញជាអាទិភាពដើម្បីអភិវឌ្ឍ ក្នុងតំបន់ដែលនៅក្បែរគម្រោងផង និងធ្វើការសិក្សាពីសក្តានុពលថាមពលគម្រោងទាំងនេះផង។[212]

របាយការណ៍ចុងក្រោយសម្រាប់ជំនួយបច្ចេកទេស ត្រូវបានគេលើកយកមកពិភាក្សានៅក្នុង គណៈកម្មការសម្របសម្រួលពាណិជ្ជកម្មថាមពលថ្នាក់តំបន់ (RPTCC) កាលពីខែតុលា ឆ្នាំ២០១០ និងបានផ្សព្វផ្សាយជាសាធារណៈក្នុងខែវិច្ឆិកា ឆ្នាំ២០១១។ របាយការណ៍នេះ បានធ្វើបច្ចុប្បន្នភាព លើផែនការតភ្ជាប់បណ្តាញថាម ពលថ្នាក់តំបន់ ប៉ុន្តែមិនបានបញ្ជាក់លំអិតលើគម្រោងជាក់លាក់។ ផែនការមេដែលបានកែសម្រួលរួច បានទទួលស្គាល់ពីសក្តានុពលនៃការភ្ជាប់បណ្តាញថាមពល រវាងតំបន់ភាគខាងត្បូង ប្រទេសឡាវ និងកម្ពុជា ទៅប្រទេសវៀតណាម៖ «**ដោយសារតែមានចំនួនគម្រោងទំនប់វារីអគ្គិសនីក្នុងប្រទេសឡាវខាងត្បូង មានលក្ខណៈភូមិសាស្ត្រ ជិតគ្នា ចំណែកប្រទេសកម្ពុជា គឺនៅផ្នែកម្ខាង ហើយម្ខាងទៀត នៅខាងត្បូង និងតំបន់កណ្តាល វៀតណាម ក៏មានលក្ខណៈភូមិសាស្ត្រប្រគាកប្រកិតគ្នា ដែលសម្រួលដល់ការភ្ជាប់តំបន់គ្នា ទាំងនេះទើបធ្វើឲ្យមានការតភ្ជាប់បណ្តាញ ថាមពលកាន់តែងាយស្រួលរវាងតំបន់ទាំងបួន**»។ ទោះជាយ៉ាងណាក៏ដោយ របាយការណ៍នេះ បានបន្តបញ្ជាក់ ទៀតថា ៖ «**ការស៊ើបអង្កេតលំអិត និងការសិក្សាចំចំនុចជាក់លាក់ គឺចាំបាច់ដើម្បីវាយ តម្លៃពីលទ្ធភាព ផ្សេងៗ ដែលភាគច្រើនពឹងផ្អែកទៅលើការអភិវឌ្ឍន៍ប្រព័ន្ធចែកចាយអគ្គិសនីជាតិ និងគម្រោងវារីអគ្គិសនីដែលបានជ្រើសរើសសម្រាប់ធ្វើការអភិវឌ្ឍន៍។**»[213]

របាយការណ៍ចុងក្រោយសម្រាប់ជំនួយបច្ចេកទេស បានរកឃើញគម្រោងភ្ជាប់បណ្តាញថាមពលចំនួន៧គម្រោង ក្នុងនោះ គម្រោងចំនួន២នឹងបង្កឲ្យមានផលប៉ះពាល់ដោយផ្ទាល់លើតំបន់ទន្លេបី (3S)។ គម្រោងទាំង២ដែលរកឃើញនេះ គឺបណ្តាញបញ្ជូនថាមពលរបស់ឡាវភាគខាងត្បូង និង វៀតណាម «**ដោយសារតែសក្តានុពលថាមពលវារីក្នុងប្រទេសឡាវភាគខាងត្បូង** (3.5 GW **នៅខាងត្បូង**) **និងដោយសារគម្លាតតម្លៃធំពេករវាងប្រទេសទាំង២**» និងការតភ្ជាប់បណ្តាញថាមពលរវាងប្រទេសកម្ពុជា និងវៀតណាម សម្រាប់ការនាំចេញនូវថាមពលអគ្គិសនីពីទំនប់សេសានក្រោម២។ គម្រោងតភ្ជាប់ដែលមានសក្តានុពលចំនួន៣ទៀត តម្រូវឲ្យមានការសិក្សាបន្ថែម។ គម្រោងទាំងបីនេះគឺបណ្តាញថាមពល ឡាវ កម្ពុជា និងវៀតណាម។[214] យោងតាមឯកសារដែលដាក់ផ្សាយនៅក្នុងគេហទំព័ររបស់ពួកគេ ក្រុមហ៊ុន ធីម (*TEAM Consulting and Management (Cambodia) Co. Ltd.*) បានធ្វើការសិក្សាពី សក្តានុពលដែលអាចធ្វើទៅបាន សម្រាប់ការតភ្ជាប់បណ្តាញបញ្ជូនចរន្តក្នុងរង្វង់ប្រទេសបី គឺឡាវ កម្ពុជា និងវៀតណាម។ ការសិក្សានេះ គ្របដណ្តប់ទាំងការរៀបចំបច្ចេកទេស សេដ្ឋកិច្ច និងថវិកា ដែល

212 អាយប៊ីត *Ibid*. (កថាខ័ណ្ឌទី១២)

213 Asian Development Bank, *RETA 6440: Facilitating Regional Power Trading and Environmentally Sustainable Development of Electricity Infrastructure in the Greater Mekong Subregion*, Final report - Component 1, Module 1: Update of the GMS Regional Master Plan, executive summary, 15 October 2010 (p43).

214 *Ibid*. (p72).

ត្រូវចំណាយសម្រាប់គម្រោង ព្រមទាំងការសិក្សាពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ឯកសារ ភស្តុតាង ឯកសារដេញថ្លៃ ផែនការថវិកា និងកាលវិភាគនៃការអនុវត្ត។[215] នៅពេលត្រូវបានគេទាក់ទង ធនាគារ ADB មិនមានព័ត៌ជុំវិញការសិក្សាពីសក្តានុពលលើគម្រោងនេះទេ។

ដូចបានលើកឡើងខាងលើ បណ្តាញបញ្ជូនថាមពលទាំងនេះ គឺពិតជាបង្កើតឡើងឲ្យស៊ីគ្នាទៅនឹងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅក្នុងប្រទេសឡាវ ប្រសិនបើគ្មានទំនប់វារីអគ្គិសនីទាំងនោះទេ គឺមិនចាំបាច់បង្កើតឲ្យមានបណ្តាញបញ្ជូនថាមពលទាំងនេះ ហើយប្រសិនបើគ្មានបណ្តាញបញ្ជូនថាមពលទេ សក្តានុពលសម្រាប់គម្រោងវារីអគ្គិសនី នឹងអាចត្រូវបានចោទជាសំណួរជាមិនខាន។ ជាការពិតណាស់ របាយការណ៍ចុងក្រោយ ស្តីពីជំនួយបច្ចេកទេសលើការធ្វើពាណិជ្ជកម្មថាមពលរបស់ធនាគារ ADB បានបង្ហាញថា៖ «**យន្តការចំបងសម្រាប់គម្រោងផ្លាស់ប្តូរថាមពលនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ នឹងផ្អែកលើការនាំចេញនូវម៉ាស៊ីនដើរដោយថាមពលទឹកខ្នាតធំ។**» ការពិភាក្សាលើបណ្តាញបញ្ជូនថាម ពលទាំងនេះ ត្រូវបានបន្តពិភាក្សាទៅមុខច្រើនឆ្នាំទៀត ស្របជាមួយគ្នានោះដែរ ការសិក្សាពីតំបន់ ទន្លេបីរបស់ធនាគារ ADB ដែលធ្លាប់បានពិភាក្សារួចមកហើយនោះ បានរកឃើញថា «**ការអភិវឌ្ឍន៍ ដែលមិនមានការសម្របសម្រួលត្រឹមត្រូវ នឹងបង្កឲ្យមានវិនាសកម្មយ៉ាងធំធេងដល់អាងទន្លេទាំងឡាយ ដែលមានសោភ័ណ្ឌភាពស្រស់បំព្រង។**»[216] ធនាគារ ADB នៅមិនទាន់បានបង្ហាញពីឆន្ទៈរបស់ខ្លួនជា សាធារណៈនៅឡើយទេ ក្នុងការគាំទ្រទៅលើគម្រោងសាង សង់បណ្តាញបញ្ជូនថាមពល ដែលបាន លើកឡើងជាសង្ខេបនេះ ប៉ុន្តែសង្ឃឹមថា ប្រសិនបើមានសេចក្តី សម្រេចចិត្តឲ្យធ្វើដូច្នេះមែន នោះ គម្រោងទាំងអស់ នឹងមិនចាំបាច់ផ្តោតតូចចង្អៀតតែទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នៃបណ្តាញបញ្ជូន ចរន្តដែលខុសពីនិន្នាការអភិវឌ្ឍន៍ដ៏ទូលំទូលាយ ដែលបច្ចុប្បន្ននេះ កំពុងតែពង្រឹងការអភិវឌ្ឍន៍ទំនប់ វារីអគ្គិសនីនៅក្នុងតំបន់ទន្លេបី (3S)។

## ៣.២. ធនាគារពិភពលោក

ធនាគារពិភពលោក ក៏មានការគាំទ្រលើគម្រោងដែលមាននៅក្នុងកម្មវិធី ជីអឹមអេស (GMS)ដែរ ក្នុងគោលបំណងដើរតួនាទីជា «**អ្នកជួយគាំទ្របន្ថែម បន្ថែមកម្លាំងដល់ការសម្របសម្រួលរបស់ធនាគារ ADB។**» បច្ចុប្បន្ន ធនាគារពិភពលោក កំពុងតែធ្វើការកំណត់អាទិភាពក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលរួមបញ្ចូលទាំងការអភិវឌ្ឍន៍លើពាណិជ្ជកម្មថាមពល និងការគ្រប់គ្រងធនធានទឹក។[217] គម្រោងចំនួន២ដែលបានលើកមកពិភាក្សាខាងក្រោមនេះ មានគម្រោងមួយត្រូវបានបោះបង់ ឬលុបចោល

215 *TEAM Consulting and Management (Cambodia)* website: http://www.team-cambodia.com/projects_detail.php?projectID=2 (accessed November 2011).

216 Asian Development Bank, *Technical Assistance Report: Project 40082, Sesan, Sre Pok, and Sekong River Basins Development Study in Kingdom of Cambodia, Lao People's Democratic Republic, and Socialist Republic of Vietnam*, December 2006 (para 9).

217 World Bank, Southeast Asia Country Management Unit, *Strategy Note on World Bank Regional Support for the Greater Mekong Sub-Region*, October 2007 (executive summary).

ដោយរដ្ឋាភិបាលកម្ពុជា និងគម្រោងមួយទៀតត្រូវបានអនុម័តនាពេលថ្មីៗនេះហើយ។ ធនាគារពិភពលោក គាំទ្រដល់ការបង្កើតបណ្តាញបញ្ជូនថាមពលកម្ពុជា និងឡាវ។

ក្នុងឆ្នាំ២០០៦ ប្រទេសកម្ពុជា និងប្រទេសឡាវ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ស្តីពីការអនុញ្ញាតឲ្យប្រទេសឡាវនាំថាមពលអគ្គិសនីទៅប្រទេសកម្ពុជា[218] ហើយក្នុងខែធ្នូ ឆ្នាំ២០០៧ ក្រុមហ៊ុនអគ្គិសនីកម្ពុជាហៅកាត់ថា អឺដេសេ *(EdC)* និងក្រុមហ៊ុនអគ្គិសនីឡាវ *(EdL)* បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី ដែលអគ្គិសនីឡាវ ត្រូវផ្គត់ផ្គង់ថាមពលប្រមាណជា១០ម៉េហ្គាវ៉ាត់ពីកន្លែងផលិតថាមពលភាគខាងត្បូងរបស់ខ្លួន ទៅដល់តំបន់ទល់ដែនក្នុងប្រទេសកម្ពុជា។ ប្រទេសទាំង២ ក៏បានយល់ព្រមលើកិច្ចព្រមព្រៀងមួយទៀតសម្រាប់ការផ្គត់ផ្គង់ថាមពលអគ្គិសនី ២០០ MW ពីប្រទេសឡាវ ទៅប្រទេសកម្ពុជានៅឆ្នាំ២០២០។[219] ប្រទេសឡាវ បាននឹងកំពុងនាំចេញនូវថាមពល អគ្គិសនីក្នុងបរិមាណមួយតិចតួចទៅប្រទេសកម្ពុជា តាមរយៈបណ្តាញបញ្ជូនថាមពលដែលមានស្រាប់កម្លាំង ២២គីឡូវុលត៍ (kV) ហើយក្នុងឆ្នាំ២០០៧ ធនាគារពិភពលោក យល់ព្រមផ្តល់ទុនទៅដល់ ការបង្កើតបណ្តាញបញ្ជូនថាមពលដែលមានកម្លាំងវុលត៍ខ្ពស់សម្រាប់ប្រទេសទាំង២ និងដើម្បីបង្កើនកម្លាំងថាមពលអគ្គិសនី ដែលនាំចេញពីប្រទេសឡាវមកប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ កាលពីដំបូង គម្រោងត្រូវបានទទួលរងនូវការរំខាន និងរិះគន់ ជាមួយនឹងការស្នើរសុំឲ្យពន្យាពេល ហើយនៅចុងឆ្នាំ២០១១ រដ្ឋាភិបាលកម្ពុជាបានលុបចោលគម្រោងនេះ។[220] សកម្មភាពខ្លះ ត្រូវបានបញ្ចប់នៅក្នុងប្រទេសឡាវ ប៉ុន្តែការងារលើបណ្តាញបញ្ជូនថាមពលគឺមិនមានសកម្មភាពទេ។ បច្ចុប្បន្ននេះ វានៅតែមិនច្បាស់ថា ខ្សែបណ្តាញនោះត្រូវបានបោះបង់ចោល ឬក៏អ្នកផ្តល់ទុននឹងបង្វែរមកផ្តល់ទុនគាំទ្រគម្រោងនេះឬយ៉ាងណា។ ខាងក្រោមនេះ ជាការសង្ខេបខ្លីៗពីគម្រោង ដែលវានៅតែមានការទាក់ទងការបោះជំហ៊ានចូលពីអ្នកផ្តល់ទុនថ្មី។

ការគាំទ្ររបស់ធនាគារពិភពលោកចំពោះការបង្កើតបណ្តាញបញ្ជូនថាមពល ត្រូវបែងចែកជា២គម្រោងផ្សេងគ្នា មួយគម្រោងសម្រាប់ប្រទេសនីមួយៗ។[221] ការប៉ាន់ប្រមាណការចំណាយសម្រាប់គម្រោងទាំង២ គឺ៣៨.៨លានដុល្លារសហរដ្ឋអាមេរិក ក្នុងនោះ ធនាគារពិភពលោក បានផ្តល់ទុនចំនួន ៣៣.៥លានដុល្លារសហរដ្ឋអាមេរិក។[222] ខ្សែបណ្តាញបញ្ជូនថាមពល ដែលមានកម្លាំង ២៣០គីឡូវុលត៍

218 Vientiane Times, *Laos to export electricity to Cambodia*, 12 June 2006.
219 http://www.poweringprogress.org/index.php?option=com_content&view=article&id=49&Itemid=53 (accessed November 2011).
220 Personal communication with World Bank, November 2011.
221 *GMS Power Trade (Cambodia) Project, P105329* http://web.worldbank.org/external/projects/main?pagePK=64283627&piPK=73230&theSitePK=40941&menuPK=228424&Projectid=P105329 and *GMS Power Trade (Lao PDR) Project, P105331* http://web.worldbank.org/external/projects/main?pagePK=64283627&piPK=73230&theSitePK=40941&menuPK=228424&Projectid=P105331 (accessed November 2011).
222 See project information on World Bank website: http://web.worldbank.org/external/projects/main?Projectid=P105329&theSitePK=40941&piPK=64290415&pagePK=64283627&menuPK=64282134&Type=Overview; and

មានប្រវែង២៧គីឡូម៉ែត្រ ត្រូវបានគ្រោងនឹងរត់កាត់ពីស្ថានីយ៍ *បានហាត់* ទៅព្រំដែនប្រទេសឡាវ និងកម្ពុជា បន្ទាប់មក៤៧គីឡូម៉ែត្រពីព្រំដែនទៅទីរួមខេត្តស្ទឹងត្រែងប្រទេសកម្ពុជា។ ធនាគារពិភពលោក បានអនុម័តផ្តល់ទុនសម្រាប់បណ្តាញបញ្ជូនថាមពលកម្លាំង១១៥គីឡូវ៉ុលត៍ និងស្ថានីយ៍ក្នុងឆ្នាំ២០០៧ តែទោះជាយ៉ាងណាក៏ដោយ គម្រោងត្រូវបានពន្យាពេលបន្ទាប់ពីប្រទេសឡាវ និងកម្ពុជាបានធ្វើការស្នើសុំក្នុងឆ្នាំ២០១០ ដើម្បីបង្កើនសមត្ថភាពបណ្តាញបញ្ជូនថាមពល ដែលបានគ្រោងនោះពី១១៥-២៣០គីឡូវ៉ុលវិញ។ ការធ្វើដូចនេះ តម្រូវឲ្យរៀបចំគម្រោង និងធ្វើការសិក្សាពីផលប៉ះពាល់លើផ្នែកបរិស្ថានឡើងវិញ។[223] យោងតាមការទំនាក់ទំនងជាមួយធនាគារពិភពលោក គម្រោងនៅមិនទាន់ បានធ្វើយុត្តកម្មទៅលើគម្រោងទំនប់វារីអគ្គិសនី នៅក្នុងប្រទេសឡាវនៅឡើយទេ ហើយក៏មិនមានផែន ការភ្ជាប់ទៅបណ្តាញបញ្ជូនថាមពល នៃទំបន់វារីអគ្គិសនីណាមួយនៅក្នុងប្រទេសឡាវ ឬប្រទេសកម្ពុជា នៅឡើយដែរ ទំនងគម្រោងនឹងមានបំណងតភ្ជាប់ថាមពលទៅប្រទេសទាំង២ និងអនុញ្ញាតឲ្យប្រទេស ឡាវ បាននាំចេញនូវថាមពលអគ្គិសនីរបស់ខ្លួន។[224]

គម្រោងជាច្រើននៅក្នុងប្រទេសឡាវ មានផែនការបង្កើតបណ្តាញបញ្ជូនថាមពល២ខ្សែ ខ្សែទី១ ភ្ជាប់ទៅស្ថានីយ៍ *បានហាត់* ទៅព្រំដែនប្រទេសកម្ពុជា និងមួយខ្សែទៀតភ្ជាប់ទៅបណ្តាញបញ្ជូនថាមពល ដែលមានស្រាប់របស់ទំនប់វារីអគ្គិសនី *សេសិត* ទៅ *សាវ៉ាវ៉ាន់*។ គម្រោងរបស់ឡាវរួមបញ្ចូលទាំងការគាំទ្រដល់ការសិក្សាពីសក្តានុពលលើគម្រោងទំនប់វារីអគ្គិសនី *ហួយឡាមផានញ៉ៃ* នៅភាគខាងត្បូងផងដែរ។ គម្រោងនេះ នឹងប្រតិបត្តិការដោយអគ្គិសនីឡាវ *(EdL)* ហើយខណៈពេលដែលសកម្មភាពមួយចំនួនត្រូវបានបញ្ចប់ ឬឋិតនៅក្នុងដំណើរការឆ្ពោះទៅមុខ ដោយឡែកសកម្មភាសាងសង់បណ្តាញបញ្ជូនថាមពលទៅប្រទេសកម្ពុជា នៅមិនទាន់ចាប់ផ្តើមនៅឡើយទេ។[225]

ដូចដែលមានចែងនៅក្នុងគោលនយោបាយរបស់ធនាគារពិភពលោក គម្រោងតបានឆ្លងកាត់ការវាយតម្លៃបរិស្ថានដំបូង (IEE) នៅក្នុងប្រទេស២ គឺឡាវ និងកម្ពុជា។ យោងតាមការវាយតម្លៃទាំង២ បានរកឃើញថា ផលប៉ះពាល់អវិជ្ជមាន ត្រូវបានរឹតបន្តឹងដោយមានការផ្លាស់ប្តូរទីលំនៅថ្មីតិចតួចបំផុត ទោះបីជាប្រជាជនមួយចំនួន អាចនឹងទទួលបានសំណងសម្រាប់ការបាត់បង់ដីបង្ក បង្កើនផលក៏ ដោយ។ ខ្សែបណ្តាញបញ្ជូនថាមពលនៅក្នុងប្រទេសឡាវ តំបន់ខ្លះតម្រូវឲ្យកាត់រំលំដើមឈើមួយចំនួន ហើយខ្សែបណ្តាញនេះ អូសតាមដងវិថីដែលជាតំបន់ព្រៃឈើរិចរិលស្រាប់។[226] ផលប៉ះពាល់បរិស្ថាន

---

http://web.worldbank.org/external/projects/main?Projectid=P105331&theSitePK=40941&piPK=64290415&pagePK=64283627&menuPK=64282134&Type=Overview (accessed November 2011).

223 World Bank, *Status of Projects in Execution (SOPE) 2010: East Asia and Pacific Region, Lao PDR*, 3 October 2010.

224 According to discussions with World Bank project staff, September 2011; see also: http://www.poweringprogress.org/index.php?option=com_content&view=article&id=49&Itemid=53 (accessed November 2011).

225 World Bank, *Implementation Status & Results, Lao People's Democratic Republic, GMS Power Trade (Laos) Project (P105331)*, March 2011.

226 Electricité du Laos, *Initial Environment Examination (IEE) for Ban Hat to Lao-Cambodia Border 230 kV Transmission Line Project*, February 2011.

និងសង្គមនៅក្នុងប្រទេសកម្ពុជា ក៏កំពុងធ្វើការវិនិច្ឆ័យឲ្យនៅក្នុងកម្រិតអប្បរមា ទោះបីជាគេបានរកឃើញថាមាន៣០គ្រួសារ មានទីលំនៅក្នុងតំបន់គម្រោងក៏ដោយ។[227] គ្រួសារទាំងនោះ ដែលទទួលរងផលប៉ះពាល់ពីគម្រោងនេះ នឹងមានសិទ្ធិទទួលបាននូវការការពារពីច្បាប់របស់ប្រទេសឡាវ និងប្រទេសកម្ពុជា និងគោលនយោបាយបង្ការរបស់ធនាគារពិភពលោក តែទោះជាយ៉ាងណាក៏ដោយ ដូចកិច្ចពិភាក្សាខាងលើ រដ្ឋាភិបាលកម្ពុជា បានបោះបង់ចោលនូវគម្រោងធ្វើពាណិជ្ជកម្មថាមពល នៅក្នុងប្រទេសកម្ពុជា។

ប្រសិនបើមានជម្រើស ដែលមានការផ្តល់ហិរញ្ញប្បទានដល់គម្រោងបណ្តាញបញ្ជូនចរន្ត ការព្រួយបារម្ភមួយនឹងកើតមានឡើង គឺលទ្ធភាពរបស់ខ្សែបណ្តាញនាពេលអនាគត ដែលនឹងតភ្ជាប់ ទៅទំនប់ដទៃទៀតនៅតំបន់មេគង្គក្រោម។ ដូចអ្នកអាចមើលឃើញនៅក្នុងផែនទីខាងក្រោម ដែលដកស្រង់ចេញពីផែនទីបង្ហាញខាងលើក្នុងផ្នែកទី៣.១ ដែលបង្ហាញពីផែនការអភិវឌ្ឍន៍សម្រាប់ឆ្នាំ២០១០-២០២០របស់អគ្គិសនីឡាវ ដែលប្រទេសឡាវ មានផែនការតភ្ជាប់បណ្តាញបញ្ជូនថាមពលទៅទំនប់ វារីអគ្គិសនី *ដនសាហុង* នៅឆ្នាំ២០១០។ គម្រោងសាងសង់ទំនប់ដនសាហុង គឺជាគម្រោងមួយដែល ជាក្តីបារម្ភរបស់អង្គការសង្គមស៊ីវិល ដែលកំពុងអនុវត្តសកម្មភាពនៅក្នុងតំបន់ ដោយសារតែទំនប់មួយនេះនឹងបង្កឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ចរាចរត្រី ដែលមិនត្រឹមតែកើតមាននៅក្នុងប្រទេសឡាវប៉ុណ្ណោះទេ ប៉ុន្តែវាក៏នឹងកើតមានដល់ប្រទេសកម្ពុជា ប្រទេសវៀតណាម និងប្រទេសថៃផងដែរ។[228] ទំនប់ដែលសង់លើដងទន្លេមេគង្គមេ បានធ្វើឲ្យមានការព្រួយបារម្ភយ៉ាងខ្លាំងជុំវិញផលប៉ះពាល់ដល់ធនធានជលផល រហូតដល់ឆ្នាំ២០១០ គណៈកម្មាធិការទន្លេមេគង្គ បានចេញរបាយការណ៍មួយ ដោយផ្តល់អនុសាសន៍ ឲ្យផ្អាករយៈពេល១០ឆ្នាំសិន មិនឲ្យមានការអនុម័តរាល់គម្រោងសាងសង់ទំបន់វារីអគ្គិសនីលើដងទន្លេមេ។[229]

227 MIME (prepared by KEPCO), *Initial Environmental Evaluation and Environmental Management Plan for GMS Subregion Power Project – Ban Hat to Stung Treng*, December 2010.
228 For more information see: International Rivers, *Factsheet: The Don Sahong Hydropower Project*, September 2008. Available at http://www.internationalrivers.org/files/Don%20Sahong%20Fact%20sheet%20Sept%202008%20ENGLISH.pdf (accessed November 2011).
229 World Bank, *World Bank Group Welcomes Strategic Environmental Assessment of Mekong Mainstream Dams: Confirms that it will not finance investments in mainstream hydro projects*, 22 October 2010 http://web.worldbank.org/WBSITE/EXTERNAL/COUNTRIES/EASTASIAPACIFICEXT/CAMBODIAEXTN/0,,contentMDK:22740418~menuPK:293875~pagePK:2865066~piPK:2865079~theSitePK:293856,00.html (accessed November 2011).




ដកស្រង់ពីផែនការអភិវឌ្ឍន៍ថាមពលអគ្គិសនីប្រទេសឡាវ២០១០-២០២០[230]

## ការគាំទ្ររបស់ធនាគារពិភពលោកចំពោះការគ្រប់គ្រងចម្រុះនូវធនធានទឹកទន្លេមេគង្គ

ចាប់ពីឆ្នាំ២០០០-២០០៧ គណៈកម្មការជាតិទន្លេមេគង្គ បានអនុវត្តនូវកម្មវិធីប្រើប្រាស់ទឹក (WUP) ដោយមានការគាំទ្រហិរញ្ញប្បទានពីធនាគារពិភពលោក រួមជាមួយម្ចាស់ជំនួយផ្សេងៗទៀតជាច្រើន។ គណៈកម្មការទន្លេមេគង្គ បានបង្កើតគម្រោងរួមគ្នាគ្រប់គ្រងធនធានទឹកទន្លេមេគង្គ (M-IWRM) ដើម្បីតាមដានកម្មវិធីការប្រើប្រាស់ធនធានទឹកទន្លេមេគង្គ(WUP)[231] ។

គម្រោងរួមគ្នាគ្រប់គ្រងធនធានទឹកទន្លេមេគង្គ (M-IWRM) បានផ្តោតសំខាន់លើទំនប់ទន្លេបឹ ហើយគោលបំណងរបស់គម្រោងនេះគឺ «**បង្កើតឲ្យមានជាឧទាហរណ៍មួយដ៏ល្អ សម្រាប់ការអនុវត្តន៍លើការគ្រប់គ្រងធនធានទឹកនៅក្នុងតំបន់ទន្លេមេគង្គក្រោម** (LMB) **នៅក្នុងថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជម្រុញឲ្យមានការអភិវឌ្ឍន៍ឲ្យកាន់តែមាននិរន្តរភាពថែមទៀត នៅក្នុងតំបន់ទន្លេមេគង្គក្រោម។**» កាលដំបូងឡើយ គម្រោងនេះ នឹងត្រូវប្រតិបត្តិការដោយគណៈកម្មការជាតិទន្លេមេគង្គ និងភ្នាក់ងារពាក់ព័ន្ធ ស្របទៅនឹងរដ្ឋបាលធនធានទឹក និងបរិស្ថាន (WREA) ក្នុងប្រទេសឡាវ ព្រមទាំងរដ្ឋបាលជលផលក្នុងប្រទេសកម្ពុជា។ គម្រោង មានគោលបំណងគាំទ្រដល់សកម្មភាពខុសៗគ្នាទាំងក្នុងប្រទេសឡាវ និងកម្ពុជានៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ក្រៅពីធ្វើការដើម្បីជួយ គាំទ្រ និងក

230 http://www.edl.com.la/en/download/EDL_Network_PDP_Up9_06_2011.pdf (accessed November 2011).
231 Mekong River Commission Vietnam website news update, *National Consultation Meeting on Mekong Integrated Water Resource Management Project* , August 2010.

សាងការតស៊ូតមិ ព្រមទាំងសមត្ថភាពក្នុងកិច្ចសហប្រតិបត្តិការរបស់គណៈកម្មការទន្លេ មេគង្គ និងគណៈកម្មការជាតិទន្លេមេគង្គ គម្រោងក៏បានគាំទ្រការអភិវឌ្ឍន៍ស្ថាប័ន និងការអនុវត្ត ឧបករណ៍**ការគ្រប់គ្រងចម្រុះនូវធនធានទឹកទន្លេមេគង្គ** (IWRM) និងការតាក់តែងច្បាប់ថ្មី (ប្រទេសឡាវ) ដើម្បីបង្កើតគម្រោងសាកល្បងក្នុងការគ្រប់គ្រងតំបន់លិចទឹក និងការគ្រប់គ្រងធនធានជលផលនៅក្នុង ទន្លេមេគង្គមេ ព្រមទាំង **«តំបន់មានសក្តានុពលផ្សេងៗទៀត។»**[232] យោងតាមឯកសារវាយតម្លៃរបស់ធនាគារពិភពលោកក្នុងឆ្នាំ២០១០ បានឲ្យដឹងថា តំបន់គម្រោងរាប់បញ្ចូលទាំងផ្នែកខាងក្រោមនៃទន្លេសេកុង ក្នុងប្រទេសឡាវ និងប្រទេសកម្ពុជា។[233]

យ៉ាងណាក៏ដោយ នៅក្នុងឆ្នាំ២០១១ ដោយសារការមិនចុះសម្រុងគ្នាជុំវិញបញ្ហាតាំងទីលំនៅថ្មីដែលពាក់ព័ន្ធជាមួយគម្រោងចុះបញ្ជីដីធ្លីដែលគាំទ្រថវិកាដោយធនាគារពិភពលោក ធនាគារនេះ បានផ្អាកការផ្តល់ហិរញ្ញប្បទានដល់ប្រទេសកម្ពុជា។[234] គម្រោងរួមគ្នាគ្រប់គ្រងធនធានទឹកទន្លេមេគង្គ (M-IWRM) ត្រូវបានជាប់គាំងនៅក្នុងស្ថានភាពមួយដែលមិនប្រាកដប្រជា។ ក្នុងខែមីនា ឆ្នាំ២០១២ ធនាគារពិភពលោក បានប្រកាសឲ្យដឹងថា ធនាគារទីបំផុតបានអនុម័តលើ**ការគ្រប់គ្រងចម្រុះនូវធនធានទឹកទន្លេមេគង្គ** (M-IWRM) និងផ្តល់ប្រាក់កម្ចីដល់សមាគមអភិវឌ្ឍន៍អន្តរជាតិ នូវទឹកប្រាក់ចំនួន២៦លានដុល្លារសហរដ្ឋអាមេរិក ដើម្បីគាំទ្រដល់គម្រោងនេះ។ សេចក្តីប្រកាសរបស់ធនាគារនេះ បង្ហាញថាគម្រោងនៅតែគ្របដណ្តប់លើបញ្ហាឆ្លងដែនដដែល ទោះជាប្រទេសកម្ពុជា មិនទាន់មានសកម្មភាពជាក់លាក់ណាមួយដែលមានក្នុងគម្រោងនេះក៏ដោយ។[235] ឯកសាររបស់គម្រោងបានបញ្ជាក់ថា អ្នកប្រតិបត្តិគម្រោងក្នុងដំណាក់កាលដំបូង នឹងអាចជារដ្ឋាភិបាលឡាវ និងគណៈកម្មការទន្លេមេគង្គ។ ប្រទេស កម្ពុជា និងវៀតណាម បានសម្តែងនូវឆន្ទៈរបស់ខ្លួនក្នុងការចូលរួមក្នុងដំណាក់កាលទី២ នៃគម្រោង ដែលនឹងចាប់ផ្តើមនៅពេលក្រោយជាមួយនឹងការគាំទ្រពីប្រទេសជប៉ុន។[236]

ក្រៅពីកសាងសមត្ថភាពស្ថាប័ន និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ហើយនោះ គម្រោងក៏មានបំណងគាំទ្រការអភិវឌ្ឍន៍ដល់ការគ្រប់គ្រងតំបន់ដែលត្រូវលិចទឹក និងធ្វើការកែលម្អរឡើងវិញនូវទ្វាគ្រប់គ្រងទឹកដែលមានស្រាប់ ព្រមទាំងបង្កើតប្រព័ន្ធធារាសាស្រ្ត ដើម្បីផ្គត់ផ្គង់ដល់ការធ្វើកសិកម្មដំណាំស្រូវ និងការពារជម្រកត្រីពងកូន។ ចំពោះផ្នែកដែលផ្តោតលើការគ្រប់គ្រងធនធានជលផល មានគោលបំណងគាំទ្រដល់សហគមន៍ក្នុងការគ្រប់គ្រងធនធានជលផល។ ការគាំទ្រទាំងនេះ រាប់បញ្ចូលទាំងការ

232 World Bank, Project Information Document (PID), Appraisal Stage, Mekong Integrated Water Resource Management Project, 13 February 2011.

233 World Bank, Mekong Integrated Water Resource Management Project, Initial Environmental and Social Examination, August 2010 (p2).

234 The Guardian, *World Bank suspends new lending to Cambodia over eviction of landowners*, 10 August 2011.

235 World Bank press release, *Effective Water Resource Management Practices - Key to Sustainable River Basin Development in the Lower Mekong Basin*, 8 March 2012. http://web.worldbank.org/WBSITE/EXTERNAL/NEWS/0,,contentMDK:23137258~menuPK:34463~pagePK:34370~piPK:34424~theSitePK:4607,00.html (accessed April 2012).

236 World Bank, *Project Information Document: Mekong Integrated Water Resources Management Project*, 15 February 2012.

គាំទ្រដល់ផែនការដោយមានការចូលរួម ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងធនធានជលផល និងការងារអភិរក្ស បង្កើតជីវភាពរស់នៅដ៏ល្អបំផុត ព្រមទាំងបង្កើតផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់។ គម្រោងក៏មានគោលបំណងពង្រឹងការគ្រប់គ្រងធនធានជលផលដល់ជាសាធារណៈជន ដោយផ្តល់ការគាំទ្រដល់ស្ថានប័នជលផលថ្នាក់ខេត្ត និងថ្នាក់ស្រុក ជាមួយនឹងការចងក្រងនូវទិន្នន័យនៃការតាមដាន និងប្រមូលផលត្រី ព្រមទាំងគាំទ្រដល់ជនជាតិដើមភាគតិច ក្នុងការចិញ្ចឹមសត្វតាមរយៈការជួយផ្តល់ជាបច្ចេកទេសក្នុងការភ្ញាស់កូនត្រី ឬមាន់ និងធ្វើដំណើរទស្សនៈកិច្ចសិក្សាជាមួយអ្នកនេសាទផ្សេងៗទៀត។[237]

មានការទទួលស្គាល់យ៉ាងទូលំទូលាយលើបរិមាណត្រីនៅក្នុងអាងទន្លេមេគង្គ ដែលកំពុងទទួលរងនូវសម្ពាធយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលមកពីហេតុផលជាច្រើន ដោយរាប់បញ្ចូលទាំងការចាប់ត្រីហួសប្រមាណ ការបំពុល និងការផ្លាស់ប្តូរនូវប្រព័ន្ធជលសាស្ត្រ ព្រមទាំងលំហូរដីភក់ ឬដីល្បាប់ដែលបង្កឡើងដោយគម្រោងទំនប់វារីអគ្គិសនី។ កិច្ចការពារអន្លង់ជ្រៅៗ និងកន្លែងត្រីពងកូន ត្រូវបានគេមើលឃើញថាមានសារៈសំខាន់ណាស់ សម្រាប់ធ្វើឲ្យទន្លេមានសុខភាពល្អ និងបង្កើនជីវភាពរស់នៅប្រចាំថ្ងៃសម្រាប់មនុស្សទាំងឡាយ ដែលពឹងផ្អែកលើធនធានទាំងនេះ និងគាំទ្រការគ្រប់គ្រងដោយសហគមន៍ ហើយការតស៊ូមតិឆ្លងដែនលើការគ្រប់គ្រងលំហូរទឹក គឺមានសារៈសំខាន់ណាស់។ យ៉ាងណាក៏ដោយការពិភាក្សាកន្លង បានបញ្ជាក់ថា ផែនការពេលបច្ចុប្បន្នសម្រាប់គម្រោងអភិវឌ្ឍន៍ទំបន់វារីអគ្គិសនីខ្នាតធំលើដងទន្លេមេគង្គ និងការគម្រាមកំហែងលើដៃទន្លេដែលហូរចូលទន្លេនេះ បានរីកធំឡើងៗ ដែលធ្វើឲ្យខូចប្រយោជន៍ដល់ចរាចរត្រី និងលំហូរដីភក់ ឬដីល្បាប់ ហើយប្រសិនបើទិសដៅអភិវឌ្ឍន៍នៅតែ បន្តក្នុងតំបន់ទន្លេបី នោះគម្រោង**ការគ្រប់គ្រងចម្រុះនូវធនធានទឹកទន្លេមេគង្គ** (M-IWRM) នឹងប្រឈម នូវបញ្ហាធំដែលត្រូវ ពុះពារទប់ទល់ និងធ្វើឲ្យប្រសើរឡើងវិញនូវធនធានជលផល។

## ៣.៣. ការផ្តួចផ្តើមគំនិតថ្នាក់តំបន់ និងទ្វេភាគី

### *ការអភិវឌ្ឍន៍តំបន់ត្រីកោណសម្រាប់ប្រទេសកម្ពុជា លាវ និងវៀតណាម (DTA-CLV)*

ការអភិវឌ្ឍន៍តំបន់ត្រីកោណសម្រាប់ប្រទេសកម្ពុជា លាវ និងវៀតណាម (ហៅកាត់ថា DTA) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៤ ហើយបង្កើតឡើងសម្រាប់ខេត្តចំនួន១៣។ ការអភិវឌ្ឍន៍តំបន់ត្រីកោណសម្រាប់ប្រទេសកម្ពុជា លាវ និងវៀតណាមនេះ គ្របដណ្តប់ខេត្តចំនួន៤ក្នុងតំបន់ភូមិភាគឦសាននៃប្រទេសកម្ពុជា ដូចជាខេត្តស្ទឹងត្រែង ក្រចេះ រតនគិរី និងខេត្តមណ្ឌលគិរី៖ កន្ទុំ យ៉ាឡាយ ដាកឡាក ដាណុង និងប៊ិញ ភុង ក្នុងប្រទេសវៀតណាម ហើយសេកុង អាតាពឺ សាវ៉ាវ៉ាន់ និងខេត្តចំប៉ាសាក់ក្នុងប្រទេសឡាវ។ ការអភិវឌ្ឍន៍តំបន់ត្រីកោណសម្រាប់ប្រទេសកម្ពុជា លាវ និងវៀតណាមនេះ

237 World Bank, Mekong Integrated Water Resource Management Project, Cambodia: Environment and Social Management Framework, August 2010 (p5).

គ្របដណ្តប់លើផ្ទៃដីជាង១៤៣,០០០គីឡូម៉ែត្រការ៉េ រួមនឹងប្រជាជនចំនួន៦.៧លាននាក់ ដែល ភាគច្រើនជាជនជាតិដើមភាគតិច[238]។ DTA ទទួលបានការគាំទ្រខ្ពស់ និងត្រូវបង្កើតឡើងដោយនាយក រដ្ឋមន្ត្រី៣រូប គឺនាយករដ្ឋមន្ត្រីកម្ពុជា ឡាវ និងនាយករដ្ឋមន្ត្រីវៀតណាម ក្នុងគោលបំណងធ្វើឲ្យជឿន លឿននូវសេដ្ឋកិច្ចក្នុងតំបន់ ព្រមទាំងលើកទឹកចិត្តកិច្ចសហប្រតិបត្តិការលើការងារអភិវឌ្ឍន៍ រវាងខេត្ត ជិតខាង។ យោងតាមលទ្ធផលនៃការកែសម្រួលផែនការមេរបស់ DTA នោះនឹងចាប់ផ្តើមអនុវត្តនូវ ៖

> បង្កើនការប្រើប្រាស់ឲ្យបានពេញលេញ នូវគុណសម្បត្តិរបស់ភាគីនីមួយៗ ដើម្បីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដោយផ្តោតលើការប្រើប្រាស់គុណសម្បត្តិរបស់ប្រទេសឡាវ និងប្រទេស កម្ពុជា ពាក់ព័ន្ធនឹងដីធ្លីសម្រាប់គម្រោងវិនិយោគ ជាប្រទេសទីបីផ្តល់ទីផ្សារ ពាក់ព័ន្ធធនធានរ៉ែ ពាក់ព័ន្ធទំនប់វារីអគ្គិសនី រីឯគុណសម្បត្តិរបស់ប្រទេសវៀតណាមវិញ គឺធនធានមនុស្ស ដើម ទុនសម្រាប់វិនិយោគ ព្រមទាំងបច្ចេកវិទ្យាតាមជំនាញ និងតាមវិស័យមួយចំនួន ដូចជាវិស័យកសិកម្ម ទំនប់វារីអគ្គិសនី និងបង្កើតឧស្សាហកម្ម។[239]

ផែនការមេដំបូងស្តីពី DTA ត្រូវបានពង្រាងក្នុងឆ្នាំ២០០៤ និងធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ២០១០។ ផែនការអភិវឌ្ឍន៍គ្របដណ្តប់លើផ្នែកផ្សេងៗជាច្រើន និងតំបន់អាទិភាពរបស់វា រាប់បញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធ (វិស័យដឹកជញ្ជូន ថាមពល ទូរគមនាគមន៍ ធារាសាស្ត្រ និងការផ្គត់ផ្គង់ទឹក) កសិកម្ម សេវាកម្ម (រាប់បញ្ចូលទាំងវិស័យទេសចរណ៍) ឧស្សាហកម្ម បញ្ហាសង្គម (ដូចជា វិស័យអប់រំ និងសុខភាព) ការគ្រប់គ្រង និងការការពារបរិស្ថានធម្មជាតិ ការការពារសុវត្ថិភាព ព្រមទាំងការធ្វើវិនិយោគ និងធ្វើពាណិជ្ជកម្ម។[240] សម្រាប់ផែនការមេដែលរៀបចំឡើងក្នុងឆ្នាំ២០០៤នោះ ដាក់បញ្ចូលនូវអំណះអំណាងជាច្រើនទៅក្នុងផែនការអភិវឌ្ឍន៍របស់ប្រទេសចំនួនបី ទៅលើការអភិវឌ្ឍន៍ទំបន់វារីអគ្គិសនី និងពង្រីកការចែករំលែកថាមពលអគ្គិសនី។[241] ផែនការមេបានចែងថា “**ប្រទេសទាំង៣ នឹងចូលរួមក្នុងការគាំទ្រ ជម្រុញ និងសហប្រតិបត្តិការក្នុងការអភិវឌ្ឍន៍ទំបន់វារីអគ្គិសនី។ វៀតណាម អាចចូលរួមជាមួយកម្ពុជា និងឡាវក្នុងដំណើរការនៃការអភិវឌ្ឍន៍តំបន់ត្រីកោណ ក្នុងការរៀបចំគំរូប្លង់បែបបច្ចេកទេស សម្រាប់បង្កើតគម្រោងទំនប់វារីអគ្គិសនីខ្នាតតូច និងខ្នាតមធ្យម។**”[242] ផែនការមេមានអំណះអំណាងជាក់ លាក់ដើម្បីធ្វើការសិក្សាពីលទ្ធភាពដែលអាចធ្វើទៅបាន លើការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី តាមដងទន្លេ សេសាន[243] និងដាក់ទំនប់វារីអគ្គិសនីសេសានក្រោម២ជាគម្រោងអាទិភាពក្នុងការអភិវឌ្ឍន៍។[244]

238 CLV-DTA, *Report on Reviewing, Adjusting and Supplementing the Master Plan for Socio-Economic Development in Cambodia-Laos-Vietnam Development Triangle Area Up to 2020*, November 2010 (p77-78).
239 *Ibid*.
240 *Ibid*. (p79)
241 CLV-DTA, *Socio-economic Development Master Plan for Cambodia-Laos-Vietnam Development Triangle*, November 2004.
242 *Ibid*. (p157)
243 *Ibid*. (p155)

ឯកសារយោងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី និងការចែកចាយថាមពល នៅស្ថិតក្នុងផែនការមេបច្ចុប្បន្នកម្មឆ្នាំ២០១០ដដែរ ហើយការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដោយរួមបញ្ចូលទាំងការផ្គត់ផ្គង់ថាមពលអគ្គិសនី គឺជាវិស័យមួយក្នុងចំណោមវិស័យអាទិភាព ដែលត្រូវធ្វើការអភិវឌ្ឍន៍។ របាយការណ៍នេះបានបញ្ជាក់ថា ការវិនិយោគបន្ថែមលើថាមពលអគ្គិសនី ជាតម្រូវការដ៏ចាំបាច់ ពិសេសលើ "**គម្រោងសហការរួមគ្នាក្នុងចំណោមប្រទេសក្នុងតំបន់អភិវឌ្ឍន៍ត្រីកោណ រួមមានប្រទេស ឡាវ កម្ពុជា និង វៀតណាម** (DTA)" ទោះបីជារបាយការណ៍នេះ បានរៀបរាប់ថា គួរតែមានការប្រឹងប្រែងបន្ថែមទៀត "**ដើម្បីកាត់បន្ថយដល់អប្បរមានូវផលប៉ះពាល់អវិជ្ជមាន បណ្តាលពីគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីទៅលើបរិស្ថាន។**"[245]

របាយការណ៍នេះ បានទទួលស្គាល់ថា ការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា កំពុងតែដើរថយក្រោយ ដោយសារតែខ្វះខាតថាមពលអគ្គិសនីដែលអាចជឿទុកចិត្តបានសម្រាប់ប្រើប្រាស់ ហើយដែលប្រទេសនេះ ចាំបាច់ត្រូវតែបង្កើតគម្រោងថាមពលអគ្គិសនីដោយខ្លួនឯង។ ទំរាំតែគម្រោងទាំងនោះបានចាប់ផ្តើមឡើង និងដំណើរការនោះ ប្រទេសនេះចាំបាច់ត្រូវកែលម្អរអាគារ និងទីកន្លែងមួយចំនួន ដើម្បីនាំចូលថាមពលអគ្គិសនី។ ស្របពេលជាមួយគ្នានេះដែរ បណ្តាញចែកចាយអគ្គិសនី គួរតែបង្កើតឡើងដើម្បីឲ្យស្ថានីយផលិតថាមពលអគ្គិសនីរបស់ប្រទេសឡាវ និងកម្ពុជា អាចភ្ជាប់ទៅប្រព័ន្ធចែកចាយ អគ្គិសនីជាតិវៀតណាមបាន ធ្វើដូច្នេះ ថាមពលអគ្គិសនី អាចនឹងលក់ចេញទៅប្រទេសវៀតណាមបាន នាពេលអនាគត។[246] ផែនការមេ បានលើកឡើងពីគម្រោងអាទិភាពវិនិយោគរួមគ្នា ដែលរួមបញ្ចូលនូវគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម១ ឬសេសានក្រោម៥ សេសានក្រោម២ សេសានក្រោម៣ ព្រែកលាង១ និងព្រែកលាង២ (គម្រោងទាំង២នេះ គ្រោងនឹងសាងសង់នៅ *អូរតាប៉ូក* ជាដៃទន្លេសេសាន)។ តារាងគម្រោងអាទិភាព ដែលរួមមានគម្រោងកសាងប្រព័ន្ធចែកចាយថាមពល អគ្គិសនី ដែលភ្ជាប់ពីស្ថានីយ៍ផលិតថាមពលវារីអគ្គិសនីក្នុងប្រទេសឡាវ និងកម្ពុជាទៅស្ថានីយ៍អគ្គិសនីជាតិវៀតណាមដើម្បីលក់ថាមពលអគ្គិសនីទៅឲ្យពួកគេ ហើយក៏ដើម្បីទទួលយកអគ្គិសនី ពីប្រទេស វៀតណាម ត្រឡប់មកកាន់ប្រទេសឡាវ និងកម្ពុជាវិញដែរ។ ក្រោមគម្រោងការនេះ ឡាវបានឲ្យ អាទិភាពទៅលើគម្រោងទំនប់វារីអគ្គិសនីចំនួន១០ ដោយរាប់បញ្ចូលគម្រោងទំនប់វារីអគ្គិសនី សេកុង៤ និងសេកុង៥។[247] គម្រោងក៏មានផែនការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ នៅចន្លោះឆ្នាំ ២០១២-២០១៧ ផងដែរ ហើយទំនប់សេសានក្រោម១ ឬសេសានក្រោម៥ និងទំនប់ព្រែកលាងនឹងចាប់ផ្តើមនៅចន្លោះឆ្នាំ២០១៥-២០២០។[248]

244 *Ibid*. (p166)
245 CLV-DTA, *Report on Reviewing, Adjusting and Supplementing the Master Plan for Socio-economic Development in Cambodia-Laos-Vietnam Development Triangle Area Up to 2020*, November 2010 (p79).
246 *Ibid*. (p87-88)
247 *Ibid*. (p88)
248 *Ibid*. (p178)

ផែនការមេ DTA បានគូសបញ្ជាក់ថា ការសិក្សាពីហេតុប៉ះពាល់បរិស្ថាន និងសង្គមចាំបាច់ត្រូវតែសិក្សា ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ដែលបង្កឡើងដោយសារគម្រោងទាំងនេះ ហើយការសិក្សាបន្ថែមផ្សេងៗទៀត ក៏ត្រូវតែធ្វើផងដែរដើម្បីធ្វើឲ្យប្រាកដថា សេដ្ឋកិច្ចមានរីកចំរើន ដោយសារ តែគម្រោងទាំងនេះក្នុងបរិបទជួយអភិវឌ្ឍន៍ប្រទេសកម្ពុជា។[249] ជាទូទៅ របាយការណ៍បានអះអាងថា ចាំបាច់ត្រូវកាត់បន្ថយឲ្យដល់អប្បរមានូវផលប៉ះពាល់បរិស្ថាន និងចាំបាច់ត្រូវការពារប្រព័ន្ធជីវចំរុះ នៅក្នុងតំបន់។ ជាការពិតណាស់ «**កិច្ចការពារបរិស្ថានធម្មជាតិ និងការគ្រប់គ្រងដីធ្លីឲ្យមានប្រសិទ្ធិភាព**» គឺមានត្រូវបានចាត់ទុកជាចំនុចអភិវឌ្ឍន៍អាទិភាពក្នុងតំបន់ DTA។[250] របាយការណ៍បានបញ្ជាក់ថា ភ្នាក់ងារអនុវត្តគួរតែ «**ភ្ជាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមទៅនឹងកិច្ចការពារបរិស្ថានធម្មជាតិ ជាពិសេសក្នុងការធ្វើឧស្សាហកម្មថាមអគ្គិសនី។ល។**» សារសំខាន់ក្នុងដំណើរការសិក្សា EIA ត្រូវបានកត់សំគាល់ ហើយក៏បានទទួលស្គាល់ផងដែរថា ត្រូវចាត់វិធានការណ៍យ៉ាងណាដើម្បីធ្វើឲ្យដំណើរនៃការសិក្សា EIA មានភាពប្រសើរជាងមុន ជាពិសេសសម្រាប់គម្រោងមួយចំនួន ដូចជាគម្រោងទំនប់វារីអគ្គិសនីជាដើម។ ដើម្បីសម្រេចឲ្យបាននូវចំនុចនេះ ចាំបាច់ត្រូវតែពង្រឹងសមត្ថភាពដល់មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន ជុំវិញជំនាញ EIA។[251] របាយការណ៍ ក៏មានបង្ហាញនូវសកម្មភាពអាទិភាពមួយចំនួនផ្សេងទៀតផងដែរ ដែលបានលើកឡើងដោយ ប្រទេសសមាជិក ហើយសំណើរគម្រោងរបស់ប្រទេសកម្ពុជា មានសកម្មភាពមួយចំនួនវិជ្ជមាន ទាក់ទងនិងកិច្ចការពារបរិស្ថានធម្មជាតិ។ ក្រៅពីការកសាងសមត្ថភាពដល់មន្ត្រី រដ្ឋាភិបាលពីជំនាញ EIA សំណើរគម្រោងរបស់កម្ពុជា ក៏មានបញ្ចូលនូវការសិក្សា ស្ដីពីការវាយតម្លៃ ហេតុប៉ះពាល់បរិស្ថានឆ្លងដែន ក្នុងខេត្តចំនួនបួនផងដែរ ដោយធ្វើការពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃ លើរបាយការណ៍ EIA ព្រមទាំងធ្វើឲ្យប្រសើរឡើងដល់ផែនការគ្រប់គ្រងបរិស្ថានធម្មជាតិ សម្រាប់ គម្រោងផ្សេងៗទៀតផងដែរ។[252]

ចំនុចគន្លឹះមួយផ្សេងទៀត ដែលផែនការមេ DTA ផ្ដោតចំពោះនោះ គឺការអភិវឌ្ឍន៍ឧស្សាហកម្មទេសចរណ៍ ជាពិសេសការលើកកម្ពស់ការអភិវឌ្ឍន៍អេកូទេសចរណ៍ធម្មជាតិ។ ផែនការមេនេះ ក៏បានកំណត់ពីតម្រូវការក្នុងការការពារ និងថែរក្សាតំបន់ឧទ្យានជាតិ និងតំបន់ការពារនានា ដោយរួមបញ្ចូលតំបន់ដែនជម្រកសត្វព្រៃក្នុងស្រុកលំផាត់ ពីព្រោះវាជា «**ទ្រព្យសម្បត្តិសម្រាប់បង្កើតតំបន់អេកូទេសចរណ៍ ធម្មជាតិ និងធានាបាននូវលំនឹងបរិស្ថានភូមិសាស្រ្តក្នុងតំបន់។**»[253] វាគឺជាការពិតដែលថា ផែនការមេនេះ បានអំពាវនាវឲ្យមានការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅក្នុងតំបន់ ដែលអាចបង្កឲ្យមានផលប៉ះពាល់ យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និងប្រព័ន្ធជីវៈចម្រុះក្នុងតំបន់។ នេះក៏រាប់បញ្ចូលគម្រោងសាង

249 *Ibid*. (p87-88)
250 *Ibid*. (p79)
251 *Ibid*. (p142-143)
252 *Ibid*. (p194)
253 *Ibid*. (p142)

សង់ទំបន់ វារីអគ្គិសនី *ព្រែកលាង* ផងដែរ ដែលមានទីតាំងនៅក្នុងឧទ្យានជាតិវិរៈជ័យ ហើយត្រូវបានកំណត់ជា គម្រោងអភិវឌ្ឍន៍អាទិភាពមួយនៅក្នុងផែនការមេ DTA។ របាយការណ៍ក៏បានលើកឡើងផងដែរថា គួរ តែ **"ធ្វើឲ្យប្រសើរឡើង"** ដល់ទន្លេមេគង្គ ទន្លេសេកុង ទន្លេសេសាន និងទន្លេស្រែពក ព្រោះទន្លេទាំងនេះ មានសក្តានុពលក្នុងការដឹកជញ្ជូន និងទាក់ទាញភ្ញៀវទេសចរណ៍។[254]ម្តងទៀត ទាំងនេះបានបង្កឲ្យមាន ជម្លោះចំពោះការអំពាវនាវឲ្យមានការអិវឌ្ឍន៍ទំបន់វារីអគ្គិសនីខ្ទាតលើដងទន្លេទាំងបីរបស់ផែនការមេ ដែលនឹងបង្កឲ្យមានមហន្តរាយយ៉ាងធ្ងន់ធ្ងរដល់គុណភាព និងបរិមាណទឹក តាមដងទន្លេទាំងនេះ។ ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីលើដងទន្លេទាំងបី ក៏បានគម្រាមកំហែង និងបង្អាក់ដល់ការគោរពប្រតិបត្តិ នូវទំនៀមទំលាប់វប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច នៅក្នុងតំបន់ ដែលវាជាទ្រព្យធនទាក់ ទាញអេកូទេសចរណ៍ដ៏សំខាន់ ជាពិសេសនៅក្នុងខេត្តរតនគិរី។



រូបភាព Oxfam-Brett Eloff ៖ ការសាងសង់ស្ពានកាត់ទន្លេសេកុងក្នុងខេត្តស្ទឹងត្រែង

របាយការណ៍ផែនការមេឆ្នាំ២០១០ បង្ហាញថា សមិទ្ធផលរបស់ DTA **"នៅមានកំរិត និងយឺតៗ ដោយមិនអាចរកឃើញច្រកចេញសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៃតំបន់ត្រីកោណបាន និងបានភ្ជាប់គម្លាតការអភិវឌ្ឍន៍របស់ពួកគេទៅនិងការអភិវឌ្ឍន៍កម្រិតមធ្យមរបស់ប្រទេសនីមួយៗ"**។ គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរួមគ្នា ត្រូវបានពន្យារ ហើយផែនការមេនេះ ទំនងជាមិនកំពុងអភិវឌ្ឍន៍ដោយឈរលើមូលដ្ឋានថ្នាក់តំបន់ ប៉ុន្តែបែជាអនុវត្តតាមរយៈ "កិច្ចព្រមព្រៀងសហប្រតិបត្តិការទ្វេភាគី

254 *Ibid*. (p83)

នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានតាមបន្ទាត់ព្រំដែនទៅវិញ ដោយមិនមានការសម្របសម្រួលរួមគ្នាច្បាស់លាស់ក្នុងចំណោមប្រទេស ទាំងបី។”[255] កង្វះខាតនៃការសម្របសម្រួលគ្នានេះ រិតតែច្បាស់ នៅពេលដែលមានប្រទេសតែមួយធ្វើការអង្កេតមើលផែនទីអភិវឌ្ឍន៍ក្នុងតំបន់។ ផែនទីខាងក្រោមនេះ បង្ហាញពីព្រំប្រទល់ដែនសម្បទានកសិកម្មដែលបានស្គាល់ (កំណត់ដោយពណ៌ក្រហម) ហើយតំបន់រុករករ៉ែ (ពណ៌ខៀវ) នៅក្នុងភូមិភាគឦសាននៃប្រទេសកម្ពុជា។ ដូចដែលបានឃើញ គម្រោងជាច្រើន ជាន់គ្នាហើយតំបន់ព្រៃការពារ (ពណ៌បៃតង) និងតំបន់ជាច្រើនទៀត នឹងត្រូវលិចទឹកទាំងអស់ ប្រសិនបើកម្ពុជានៅតែជម្រុញទៅមុខនូវផែនការអភិវឌ្ឍន៍ទំបន់វារីអគ្គិសនីនេះ។ ទោះបីជាគម្រោងវិនិយោគដែលបានអនុម័តទាំងអស់ ទំនងជាមិនលេចចេញជាផ្លែផ្កាក៏ដោយ រូបភាពនេះ បានបង្ហាញពីភាពកង្វះការសម្របសម្រួលការអភិវឌ្ឍន៍ក្នុងតំបន់ និងបង្ហាញពីគំរូមួយដែលមិនមាននិរន្តរភាព៖

255 *Ibid*. (p72-73)




ផែនទីបង្ហាញពីគម្រោងអភិវឌ្ឍន៍ដែលអនុម័តរួចក្នុងតំបន់ភូមិភាគឦសាននៃប្រទេសកម្ពុជា
ប្រភព៖ អង្គការ Licadho[256]

256 Provided by local Cambodian NGO, Licadho.

## ក្រុមការងារទ្វេភាគីទន្លេសេសាន និងស្រែពក

ក្នុងឆ្នាំ២០០២ នៅកិច្ចប្រជុំក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គលើកទី៧ គណៈកម្មាធិការគ្រប់គ្រងទន្លេសេសានកម្ពុជា វៀតណាម ត្រូវបានបង្កើតឡើង។ គណៈកម្មាធិការនេះ រៀបចំឡើងដើម្បីដោះស្រាយជម្លោះ ដែលកើតចេញពីផលប៉ះពាល់ភាគខាងក្រោមនៃទំនប់វារីអគ្គិសនី *យ៉ាលី* របស់អ៊ីវីអ៊ិន (EVN's) នៅប្រទេសវៀតណាមកណ្តាល[257] ទោះបីជាការផ្តោតរបស់ក្រុម បានបញ្ចូលទាំងទន្លេស្រែពកក៏ដោយ។ ក្រុមការងារនេះ បានជួបប្រជុំគ្នាមិនសូវបានញឹកញាប់ប៉ុន្មាននោះទេ បន្ទាប់ពីក្រុមនេះបានបង្កើតមក តែទោះបីជាយ៉ាងនេះក្តី វាមានលក្ខណៈសកម្មគួរសម នៅក្នុងការចរចាររកវិធានការបន្ធូរ បន្ថយផលប៉ះពាល់ឆ្លងដែនពីទំនប់វារីអគ្គិសនី *យ៉ាលី* ដែលនៅចុងក្រោយ បានឈានទៅដល់ការសិក្សា EIA នៅតំបន់រងផលប៉ះពាល់ផ្នែកខាងក្រោម ទាំងនៅប្រទេសកម្ពុជា និងវៀតណាម។ គណៈកម្មាធិការក៏បានពិភាក្សាពីបញ្ហាបណ្តាលពីទំនប់ *សេសាន៤*A ដែលជាទំនប់ទប់លំនឹងទឹកហូរក្នុងប្រទេសវៀតណាម និងវឌ្ឍនភាពនៃការសិក្សាពីលទ្ធភាពដែលអាចធ្វើទៅបានរបស់ក្រុមហ៊ុនភីអ៊ីស៊ីស៊ី១ (PECC1) និងការធ្វើផែនការ EIA សម្រាប់ទំនប់វារីអគ្គិសនីសេសានក្រោម២ និងសេសានក្រោម១/៥ផងដែរ។[258] ចាប់តាំងពីការបង្កើតក្នុងឆ្នាំ២០០២មក ក្រុមការងារបានជួបប្រជុំគ្នាតែ៤ដងប៉ុណ្ណោះ ដែលការជួបប្រជុំចុងក្រោយនោះ ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០០៨។

ចំពោះសហគមន៍ជាច្រើន ដែលរងទុក្ខដោយសារផលប៉ះពាល់ពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅក្នុងប្រទេសវៀតណាម និងចំពោះក្រុមអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការលើបញ្ហាទំនប់វារី អគ្គិសនីនេះ មានភាពអស់ សង្ឃឹមចំពោះក្រុមការងារគណៈកម្មាធិការនេះ។ ក្នុងរយៈពេលជិត១០ឆ្នាំ មកនេះ ចាប់តាំងពីបង្កើត ក្រុមការងារនេះ បានជួបប្រជុំគ្នាយូរៗម្តង និងមានរយៈពេលដ៏សែនខ្លី ហើយផលប៉ះពាល់អវិជ្ជមានជាច្រើន ដែលក្រុមនេះថានឹងចាត់វិធានការណ៍ដោះស្រាយ នៅតែបន្តកើតមានដែលធ្វើឲ្យសហគមន៍ ដែលរស់នៅផ្នែកខាងក្រោម ក្នុងតំបន់ភូមិភាគឦសាននៃប្រទេសកម្ពុជារងទុក្ខវេទនា ជារហូតមក។ ទោះបីជាមានសិក្សាច្រើនក៏ពិតមែន ដូចជាការសិក្សាដោយគណៈកម្មការខ្លួនឯងដែលបានទទួលស្គាល់នូវផលប៉ះពាល់ផ្នែកខាងក្រោមដ៏ធ្ងន់ធ្ងរដែលបង្កដោយទំនប់ *យ៉ាលី* ក៏ពុំមាននរណាម្នាក់ បានទទួលសំណងលើការបាត់បង់ជីវិត រងរបួស ឬបាត់បង់ទ្រព្យសម្បត្តិ និងសំភារៈ ផ្សេងៗ។ កង្វះខាតនេះ បានបង្ហាញជាក់ច្បាស់ពីឆន្ទៈនយោបាយទាំងសងខាង ហើយទោះបីជាមាន ភស្តុតាងច្រើនជាងនេះទៀតបង្ហាថា ទំនប់វារីអគ្គិសនី *យ៉ាលី* នៅពីក្រោយការរងទុក្ខវេទនារបស់ សហគមន៍នៅភាគខាងក្រោមក៏ដោយ ក្រុមហ៊ុន ទំនងជានៅមិនទទួលខុសត្រូវ ដោយសារទំនាក់ទំនង ជិតស្និត

257 Hirsch, P. & Wyatt, A. *Negotiating local livelihoods: Scales of conflict in the Se San River Basin*. Asia Pacific Viewpoint, Vol. 45, No. 1. Victoria University of Wellington, 2004 (p51–68).

258 Minutes of the 4th meeting between Cambodia and Vietnam Committees for the Management of the Se San and Sre Pok Rivers, 4-5 March 2008.

របស់ពួកគេជាមួយរដ្ឋាភិបាល។ ការដែលអ៊ីវីអ៊ិន (EVN's) ខ្វះឆន្ទៈ ឬអសមត្ថភាពក្នុងការរក ថ្នាំព្យាបាល ឬដោះស្រាយនូវអន្តរាយ ដែលបង្កឡើងដោយគម្រោងខ្លួនក្នុងប្រទេសវៀតណាមនោះ គឺ មិនមែនជាប្រផ្នូលល្អ សម្រាប់ផលប៉ះពាល់ដែលកើតមានឡើងពីគម្រោងដែលបានគ្រោងក្នុងប្រទេសកម្ពុជានោះទេ។

## សេចក្តីសន្និដ្ឋាន

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ សេដ្ឋកិច្ចបានរីកចំរើនឡើងៗនៅក្នុងប្រទេសថៃ វៀតណាម និងប្រទេសកម្ពុជា ហើយប្រទេសឡាវ ឋិតនៅក្នុងកំរិតមួយដែលមានលំនឹងគួរសម។ ការរីកចំរើននេះ បានធ្វើឲ្យកើនឡើងនូវតម្រូវការថាមពលអគ្គិសនី ព្រោះសេដ្ឋកិច្ចលូតលាស់កាន់តែខ្លាំងនៅក្នុងប្រទេសថៃ និងប្រទេសវៀតណាម ត្រូវតែមានការផ្តល់ថាមពលដល់ឧស្សាហកម្មរបស់ពួកគេ ហើយដូចជាប្រទេស កម្ពុជា និងប្រទេសឡាវ ដែលត្រូវបំពេញតាមតម្រូវការប្រជាជនរបស់ពួកគេ និងត្រូវជម្រុញឲ្យមាន ការវិនិយោគ។ នៅពេលដែលប្រទេសវៀតណាម និងប្រទេសថៃ ធ្វើការតស៊ូដើម្បីផលិតថាមពល អគ្គិសនីដើម្បីឆ្លើយតបទៅនិងសេចក្តីត្រូវការការប្រើប្រាស់ថាមពលក្នុងស្រុក ពួកគេបានចុះហត្ថលេខា លើកិច្ចព្រមព្រៀងជាច្រើនជាមួយប្រទេសជិតខាង ដើម្បីនាំចេញថាមពលអគ្គិសនី។ ជាច្រើនឆ្នាំមកនេះ ប្រទេសឡាវបានពិភាក្សាពីទស្សនៈវិស័យរបស់ខ្លួនដើម្បីក្លាយជា **"ធុងអាគុយនៃតំបន់អាស៊ីអាគ្នេយ៍"** ហើយឥឡូវ ប្រទេសកម្ពុជា មានមហិច្ឆតាធ្វើផែនការអភិវឌ្ឍទំនប់វារីអគ្គិសនីខ្នាតធំជាបន្តបន្ទាប់ ដែលអាចផលិតថាមពល អគ្គិសនីបានច្រើនលើសលប់ លើសតម្រូវការរបស់ប្រជាជនខ្លួន ដែលមានចំនួនដ៏តិចតួច។ ប្រទេសទាំង២ មានក្តីសង្ឃឹមថា នឹងអភិវឌ្ឍន៍ឧស្សាហកម្មថាមពលអគ្គិសនីរបស់ពួកគេ ក្នុងគោលបំណងឆ្លើយតប តម្រូវការថាមពលក្នុងស្រុកក្នុងរយៈពេល១០ឆ្នាំទៀត ហើយនឹងលក់ថាមពលអគ្គិសនីដែលលើសនោះទៅឲ្យប្រទេសជិតខាង។ ចំនួននៃការអភិវឌ្ឍន៍នេះ ត្រូវបានផ្តោតលើតំបន់ទន្លេបី។

អារម្មណ៍ខ្វាយខ្វល់ជុំវិញការអភិវឌ្ឍន៍គម្រោងទាំងនេះ មិនងាយរលាយបាត់ទេ ដោយសារការពិតដែលថា មានមន្ទិលសង្ស័យជាច្រើន ពាក់ព័ន្ធជាមួយផលប៉ះពាល់ដ៏ធំធេងលើសង្គម និងបរិស្ថាន។ មិនមានគម្រោងហេដ្ឋារចនាសម្ព័ន្ធឯណា ដែលមិនបង្កឲ្យមានផលប៉ះពាល់អវិជ្ជមាននោះទេ ហើយជាញឹកញាប់ វាជាការពិតដែលថា ខណៈពេលដែលមានការគម្រាមកំហែងដល់មនុស្ស និងបរិស្ថាន ខណៈពេលនោះ ក៏មាផលចំនេញដែលគម្រោងនាំត្រឡប់មកវិញដែរ។ ទោះជាយ៉ាងណាក៏ដោយ តុល្យភាពនេះ ចាំបាច់ត្រូវមានលក្ខណៈច្បាស់លាស់ និងត្រូវផ្អែកលើការវិភាគដ៏ត្រឹមត្រូវអំពីផលប៉ះ ពាល់អវិជ្ជមានទាំងឡាយ ទល់និងផលចំនេញដែលទទួលបាន។ ករណីទំនប់វារីអគ្គិសនីក្នុងតំបន់ទន្លេបី វាគឺច្បាស់ណាស់ថា ការសិក្សាស្រាវជ្រាវកន្លងមក មិនបានគាំទ្រឲ្យមានការវិភាគបែបនេះទេ។ ដោយ សារបញ្ហាបន្ទាន់ ការសិក្សាបន្ថែមជាច្រើនទៀត ត្រូវបានធ្វើឡើង ដើម្បីស្វែងរកផលប៉ះពាល់របស់គម្រោងដែលចេះតែបន្តកើនឡើង ពិសេសលើផលប៉ះពាល់ ដែលបណ្តាលឲ្យមានការប្រែប្រួលដ៏គង្គុក ទៅលើលំហូរទឹក ដែលនឹងប៉ះពាល់ដល់បំលាស់ទីរបស់ត្រី និងតំបន់ទីជំរាល។

បុព្វហេតុចំបងមួយដែលនាំឲ្យមានការបារម្ភ គឺខ្វះការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ អំពីផែនការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនី។ ដំណើរការដែលឈានដល់ការអនុម័តគាំទ្រ លើគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវបានពិពណ៌នាថាខ្វះតម្លាភាព ហើយមនុស្សជាច្រើនមានអារម្មណ៍ថា

ពួកគេមិនបាន បញ្ជូនកង្វល់របស់ពួកគេទៅដល់ដៃអ្នកធ្វើសេចក្ដីសម្រេចចិត្ត។ សូម្បីតែពេលបច្ចុប្បន្ននេះ ក្រោយពីគម្រោងត្រូវបានអនុម័ត មានសេចក្ដីថ្លែងការណ៍ដ៏ចម្រូងចម្រះជាច្រើន អំពីថាតើថាមពលអគ្គិសនីដែលផលិតបាន នឹងត្រូវប្រើប្រាស់នៅកន្លែងណាខ្លះ ហើយប៉ុន្មានភាគរយនៃថាមពល ដែល ផលិតបាននោះ ត្រូវប្រើប្រាស់ក្នុងស្រុក និងប៉ុន្មានភាគរយទៀត ដែលត្រូវធ្វើការលក់ទៅឲ្យប្រទេសក្រៅ? មិនមានការផ្សព្វផ្សាយព័ត៌មានច្រើនទេ ទាក់ទងនិងគម្រោងដែលគ្រោងសាងសង់នៅតំបន់ទន្លេបី ដូចជាកង្វះខាតការពិគ្រោះយោបល់ជាមួយមនុស្សក្នុងតំបន់ រហូតដល់ដំណាក់កាលនៃការសិក្សា EIA ហើយជាទូទៅ មានព័ត៌មានតិចតួចបំផុត ត្រូវបានចេញផ្សាយ ក្នុងពេលធ្វើការសិក្សាពីលទ្ធភាពដែលអាចធ្វើបានរបស់គម្រោង។ មិនមានព័ត៌មានច្បាស់លាស់អំពីថាតើគម្រោងទាំងនេះ នឹងត្រូវកាត់បន្ថយការចំណាយរបស់អ្នកប្រើប្រាស់ថាមពលអគ្គិសនីដែរ ឬក៏អត់នោះទេ? ហើយក្នុងប្រទេសមួយដែលមានបញ្ហាខ្វះតម្លាភាព និងអភិបាលកិច្ចល្អ ដូចជាប្រទេសកម្ពុជានេះជាដើម បានធ្វើឲ្យនៅតែមានកង្វល់ថាតើត្រូវទទួលខុសត្រូវលើប្រាក់ចំណូលដូចម្ដេច? និងថាតើប្រាក់ចំណូលប៉ុន្មាន ត្រូវចូលជាថវិកាជាតិ?

កង្វះខាតផ្នែកបច្ចេកទេសក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងខ្វះការពិគ្រោះយោបល់ ជាសាធារណៈ ទំនងជាធ្វើឲ្យមានការខ្វាយខ្វល់ចិត្តជាច្រើន អំពីផលប៉ះពាល់នៃការអភិវឌ្ឍន៍។ ពួកគេ ក៏បានលើកឡើងពីការព្រួយបារម្ភជាច្រើនទៀត អំពីសមត្ថភាព និងឆន្ទៈរបស់អ្នកអភិវឌ្ឍន៍ទាំងនោះ ក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានរបស់គម្រោង និងពីឆន្ទៈរបស់រដ្ឋាភិបាល ក្នុងការរិតបន្តឹងការ អនុវត្តបញ្ញត្តិផ្សេងៗទាក់ទងនិងបរិស្ថាន។ ក្នុងប្រទេសកម្ពុជា ការអភិវឌ្ឍន៍លើវិស័យថាមពលអគ្គិសនី បានបន្តកើតមានយ៉ាងលឿន ហើយមិនមានការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ទាក់ទងនិងការដេញថ្លៃការសិក្សាពីលទ្ធភាពដែលអាចធ្វើបាន និងតម្លាភាពនៃការប្រើប្រាស់សេដ្ឋកិច្ច។ ជាទូទៅ ការ អភិវឌ្ឍន៍ត្រូវបានធ្វើនៅពីក្រោយទ្វាដែលបិទជិត។ ជាទូទៅ គេទទួលស្គាល់ថា នៅក្នុងកែវភ្នែករបស់ អ្នកអភិវឌ្ឍន៍ និងសូម្បីមន្ត្រីរដ្ឋាភិបាលខ្លួនឯងផ្ទាល់ក៏ដោយ តែងយល់ថា ការធ្វើ EIA គឺជាជំហ៊ានមួយ ដែលងាយស្រួលក្នុងការឈានទៅរកការទទួលបាននូវការយល់ព្រម ឬការអនុម័ត ជាជាងធ្វើការថ្លឹងថ្លៃ ពីទំងន់នៃផលប៉ះពាល់ទល់និងផលចំនេញ និងជាជាងការស្វែងរកមតិយោបល់ពីអ្នកជំនាញ និងពី សាធារណៈជនទូទៅ មុនធ្វើសេចក្ដីសម្រេចចិត្តអនុម័តឲ្យ ឬបដិសេធលើគម្រោងដែលបានគ្រោង។ មានករណីជាច្រើន ស្តែងឡើងយ៉ាងច្បាស់ថា ការសិក្សា EIA មិនទាន់ចប់ពេញលេញផង ប៉ុន្តែគម្រោង ត្រូវបានអនុម័ត ឬ រហូតដល់ប្រតិបត្តិការគម្រោង បានចាប់ផ្ដើមហើយក៏មាន។

វាបានបង្ហាញយ៉ាជាក់ច្បាស់ថា រដ្ឋាភិបាលនៃប្រទេសកម្ពុជា ឡាវ និងវៀតណាម មិនមានភាពអំណត់ ក្នុងការធ្វើដំណើរទៅមុខជាមួយការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅក្នុងតំបន់ទន្លេបី ឬហួសពីនេះ ពីព្រោះកង្វះខាតថាមពលអគ្គិសនី បានធ្វើឲ្យអ្នកវិនិយោគធ្លាក់ទឹកចិត្ត ព្រមទាំងមានចិត្តរេរាថែមទៀត។

កង្វះខាតនូវភាពម៉ត់ចត់ក្នុងការធ្វើ EIA និងការពិគ្រោះយោបល់ជាសាធារណៈ ព្រមទាំងអវត្តមានការសិក្សាអំពីផលប៉ះពាល់យូរអង្វែងដែលចេះតែបន្តកើតមាន បណ្តាលពីការអភិវឌ្ឍន៍ទាំងនេះ គឺជាសញ្ញាបង្ហាញពីការប្រញាប់ប្រញាលជម្រុញ ការអភិវឌ្ឍន៍ឲ្យដើរទៅមុខ។ មិនត្រឹមតែប៉ុណ្ណោះ វាក៏បានបង្ហាញយ៉ាងជាក់ច្បាស់ថា មានទន្លេមួយចំនួនបានទទួលរងនូវការបំផ្លាញយ៉ាងធ្ងន់ធ្ងររួចបាត់ទៅហើយ ដោយសារតែការធ្វើអាជីវកម្មលើទន្លេទាំងនោះ។ នេះគឺជាការពិតមួយ ដែលកើតឡើងលើដងទន្លេសេសាន។ ជាឧទាហរណ៍៖ មន្ត្រីរដ្ឋាភិបាលកម្ពុជាមួយរូប បានលើកឡើងកាលពីឆ្នាំ២០០៧ថា ទន្លេសេសានបានទទួលរងនូវការខូចខាតយ៉ាងដំណំរួចបាត់ហើយ ដោយសារទំនប់វារីអគ្គិសនីនៅភាគខាងលើ ក្នុងប្រទេសវៀតណាម ទើបអ្នកស្រុកសង្ឃឹមថា អ្វីដែលទទួលបានត្រឡប់មកវិញនោះ គឺថាមពលអគ្គិសនីពីទំនប់វារីអគ្គិសនីមកកាន់ប្រទេសកម្ពុជា។ គាត់បាននិយាយថា **«ទន្លេត្រូវបានបំផ្លាញរួចទៅហើយ»។ ប្រជាជនកម្ពុជា មានសិទ្ធិទទួលបានផលចំនេញខ្លះពីទំនប់ដែលអាចផ្តល់ឲ្យ»**[259] ចំនុចនៃឃ្លានេះ មានន័យថា បើធ្វេសប្រហែស ផលប៉ះពាល់ដែលកើតឡើងពីទំនប់ដែលបានគ្រោងក្នុងប្រទេសកម្ពុជា អាចនឹងជះឥទ្ធិពលលើបរិស្ថាន សេដ្ឋកិច្ច និងសង្គមមិនខាន។

ការធ្វើអាជីវកម្មលើធនធានទឹក អាចបង្កឲ្យមានគ្រោះមហន្តរាយដល់តំបន់ និងមនុស្សដែលរស់នៅក្នុងតំបន់ផងដែរ។ ជាជាងឆ្លើយតបទៅលើការខូចខាត ដែលកើតមានតាមដងទន្លេក្នុងតំបន់ ដោយសារការធ្វើអាជីវកម្មនោះ ចាំបាច់ត្រូវខិតខំធ្វើយ៉ាងណា ដើម្បីពង្រឹងការការពារនូវធនធានទាំងអស់នេះ។ មិនមែនមានតែតំបន់ទន្លេបីប៉ុណ្ណោះទេ ដែលមានបញ្ហារសើបខ្លាំងចំពោះប្រព័ន្ធជីវៈចម្រុះ និងទទួលរងនូវការបំផ្លាញ ប៉ុន្តែមានមនុស្សរាប់ពាន់នាក់ សុទ្ធតែអាស្រ័យលើទន្លេសម្រាប់ការរស់នៅ។ ដើម្បីទទួលស្គាល់បញ្ហានេះ សកម្មភាពថ្មីៗជាច្រើននៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ បាន និងកំពុងដំណើរការអស់រយៈពេលជាច្រើនឆ្នាំ ដើម្បីការពារ និងធ្វើឲ្យប្រសើរឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដែលបានទទួលរងនូវការបំផ្លាញ។ ទោះជាយ៉ាងណាក៏ដោយ ផែនការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីក្នុងតំបន់ទន្លេបី បានគម្រាមដល់សកម្មភាពអស់ទាំងនេះ ដែលអនុវត្តដោយភ្នាក់ងារផ្សេងៗ រួមមានស្ថាប័ននៅថ្នាក់ជាតិ ថ្នាក់តំបន់ នាយកដ្ឋានរដ្ឋាភិបាល សង្គមស៊ីវិល និងអង្គការសហគមន៍មូលដ្ឋានជាច្រើន ដែលធ្វើការការពារបរិស្ថាន និងបង្កើនការប្រើប្រាស់ប្រកបដោយនិរន្តរភាពនូវធនធានក្នុង តំបន់។

មិនត្រឹមតែគោលនយោបាយរបស់ប្រទេសក្នុងតំបន់ទន្លេបីទេ ដែលសំខាន់សម្រាប់ការអភិវឌ្ឍន៍នៅពេលអនាគតនោះ តួរអង្គនៅខាងក្រៅផ្សេងៗទៀត ត្រូវតែចូលខ្លួនឲ្យគេបានត្រួតពិនិត្យដែរ ដើម្បីឲ្យប្រាកដថា ពួកគេមិនបានចូលរួមគាំទ្រនិន្នាការអភិវឌ្ឍន៍ ដែលបង្កវិនាសកម្មធ្ងន់ធ្ងរ។ ជាពិសេស ធនាគារ អភិវឌ្ឍន៍អាស៊ី ADB ដែលបានចំណាយពេលជាច្រើនឆ្នាំ រួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យ

---

259 The Cambodia Daily, *Vietnam Offers To Build Two Hydropower Dams in Ratanakiri*, 20 July 2007.

ថាមពលអគ្គិសនី ក្នុងតំបន់ ហើយគាំទ្រដល់ករណីសិក្សាធំៗចំនួន២លើកនៅក្នុងតំបន់ទន្លេបី លើកទី១ គឺក្នុងឆ្នាំ១៩៩៩ និងលើកបន្ទាប់ក្នុងឆ្នាំ២០០៨។ ករណីសិក្សាទាំងពីរលើកនេះ បានរកឃើញពីតម្រូវការឲ្យមាន ការសិក្សាបន្ថែមពីផលប៉ះពាល់រយៈពេលវែងនៃការអភិវឌ្ឍន៍ទំនប់វារីអគ្គីសនី ក្នុងតំបន់ទន្លេបីរបស់ប្រទេសទាំងបី ក៏ដូចគ្នានឹងតម្រូវការឲ្យមានកិច្ចសហប្រតិបត្តិការរួមគ្នាឲ្យកាន់តែប្រសើរជាងមុន ក្នុងការអភិវឌ្ឍន៍ធនធានក្នុងតំបន់។ ទោះយ៉ាងនេះក្តី ខណៈដែលការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី ត្រូវបានរុញឲ្យដើរទៅមុខ លទ្ធផលនៃការសិក្សាជាច្រើន នៅមិនត្រូវបានយកទៅអនុវត្តនៅឡើយ។ ចំនុចនេះ មិនបានធ្វើឲ្យមានការសង្ស័យទៅដល់ការស្នាក់ស្ទើររបស់ធនាគារ ADB ក្នុងការចូលរួមក្នុងគម្រោងសាងសង់ទំនប់វារីអគ្គិសនីជាលាក់ណាមួយនៅក្នុងតំបន់ទេ ប៉ុន្តែធនាគារនេះ បែរជាមិនធ្លាក់ទឹកចិត្ត និងបន្តការគាំទ្ររបស់ខ្លួនទៀត ដល់គម្រោងចែកចាយថាមពលអគ្គិសនី ក្នុងមហាអនុតំបន់ទន្លេមេគង្គ ដែលរួមមានគម្រោងបណ្តាញបញ្ជូនចរន្ត ដែលតភ្ជាប់ទៅកាន់ទំនប់វារីអគ្គិសនី ដែលបានគ្រោងក្នុងតំបន់ទន្លេបី។

ទោះបីជារបាយការណ៍នេះ បានផ្តោតសំខាន់លើការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី ខាងក្នុងប្រទេសកម្ពុជាក៏ដោយ ការព្រួយបារម្ភសំខាន់ៗជាច្រើនដែលបានលើកឡើង មិនត្រូវបានគេមើលឃើញថា ជាបញ្ហាដាច់ដោយឡែកតែឯងនោះទេ ប៉ុន្តែវាជាផ្នែកមួយដែលលាតត្រដាងរូបភាពដ៏ទូលំទូលាយ នៃ ការអភិវឌ្ឍន៍ដ៏គង្អុក នៅក្នុងតំបន់ទន្លេបី។ ការអភិវឌ្ឍន៍នេះ កំពុងតែបន្តក្នុងស្ថានភាពមួយដែលមានគណនេយ្យភាពទាប និងការពិគ្រោះយោបល់មិនបានគ្រប់គ្រាន់ ជុំវិញផលប៉ះពាល់ឆ្លងដែន។ ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី លើដងទន្លេ សេសានក្នុងប្រទេសវៀតណាម តម្រូវឲ្យមានការសិក្សាវាយតម្លៃផលប៉ះពាល់ និងមានយន្តការបន្ធូរបន្ថយច្បាស់លាស់។ ទោះយ៉ាងណាក៏ដោយ វានៅតែមិនទាន់ច្បាស់លើអ្វីដែលយើងរៀនសូត្របានកន្លងមក ហើយប្រសិនបើគ្មានការ ផ្លាស់ប្តូរអ្វីសោះលើការគ្រប់គ្រងធនធានក្នុងតំបន់ នោះអនាគតរបស់អាងទន្លេបី និងមនុស្សដែលរស់នៅក្នុងតំបន់នោះ នៅតែមិនច្បាស់លាស់។

**ឯកសារយោង**

**របាយការណ៍ និងអត្ថបទផ្សេងៗ**

អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង (3SPN) ជាអង្គការសង្គមស៊ីវិលដែលធ្វើការឆ្លុះបញ្ចាំងលើអតិតភាព និងបច្ចុប្បន្នភាពនៃការអភិវឌ្ឍន៍គម្រោងទំនប់វារីអគ្គិសនីក្នុងតំបន់ទន្លេបី និងលើកឡើងពីក្តីបារម្ភសម្រាប់ផែនការអនាគត់លើការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី, ៣១ ខែឧសភា ឆ្នាំ ២០១០

ករណីសិក្សាពង្រាងរួមគ្នារបស់(3SPN) និង (PRCF) លើផលប៉ះពាល់ដែលអាចកើតឡើងពីទំនប់វារីអគ្គិសនីសេសានក្រោម៣ក្នុងខេត្តរតនគិរី ប្រទេសកម្ពុជា ខែមិថុនា ឆ្នាំ២០១០។

**របាយការណ៍Baird *et al* ឆ្នាំ២០០៣**

ករណីសិក្សារបស់លោកអៀនប៊ីត ឆ្នាំ២០០៩ ពីការអនុវត្តដ៏ល្អបំផុតក្នុងការរើតាំងទីលំនៅថ្មី និងការផ្តល់សំណងសម្រាប់ទំនប់វារីអគ្គិសនីខ្នាតធំ៖ ករណីសិក្សាលើផែនការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ក្នុងតំបន់ភូមិភាគឦសាន្តនៃប្រទេសកម្ពុជា។ សម្ព័ន្ធទន្លេកម្ពុជា, ទីក្រុងភ្នំពេញ។

**របាយការណ៍Baird *et al* ឆ្នាំ២០០៥**

អវសានលើបរិស្ថានធម្មជាតិ និងសេវាកម្មអភិវឌ្ឍន៍, ធនាគារអភិវឌ្ឍន៍អាស៊ី ADB គាំទ្រសម្រាប់ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី និងបណ្តាញចែកចាយថាមពលអគ្គិសនី និងកម្មវិធីរបស់ ADB និងកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ។

សមាគមពិគ្រោះយោបល់លើការបង្កើនសក្តានុពលនៃការចែកចាយថាមពលអគ្គិសនី៖ ករណីសិក្សាលើការបង្កើតបណ្តាញចែកចាយថាមពលអគ្គិសនី និងការធ្វើពាណិជ្ជកម្ម, ខែមករា ឆ្នាំ២០១០

គ្រីសិន ស៊ី និង ហ្វុតនើ ជេ Greancen, C &Footner, J. ការធ្វើវិមជ្ឈការថាមពលថៃ៖ ឆ្ពោះទៅកាន់និរន្តរភាពថាមពលអគ្គិសនី។ Greenpeace Thailand & Palang Thai ខែវិច្ឆិកា ឆ្នាំ២០០៦

Hirsch, P. & Wyatt, A. ការចរចារលើជីវភាពរស់នៅក្នុងតំបន់៖ ទំហំជម្លោះក្នុងតំបន់តាមដងទន្លេសេសាន។ ចំនុចបង្ហាញ៖ វ៉ុល៤៥, លេខ១, សាកលវិទ្យាល័យវិចតូរីយ៉ា នៃទីក្រុងវិលលិងតុន ២០០៤ (ទំព័រ៥១-៦៨)។

កញ្ចប់ព័ត៌មានរបស់អង្គការទន្លេអន្តរជាតិ៖ គម្រោងទំនប់វារីអគ្គិសនីដនសាហុង, ខែកញ្ញា ឆ្នាំ ២០០៨។ កញ្ចប់ព័ត៌មានសីុសីុ KCC លើទំនប់វារីអគ្គិសនីសេសានក្រោម២, កិច្ចប្រជុំ*NGO*ខែមិថុនា ឆ្នាំ ២០០៨។

អង្គការទន្លេអន្តរជាតិ, ការផ្ដល់យោបល់ជាអន្តរជាតិលើគម្រោងទំនប់វារីអគ្គិសនី ថងកន្ទូម (វៀតណាម) ទៅគម្រោងវ៉ាលីដេទ័រ *Validator, TÜV NORD CERT GmbH (Former RWTÜV Systems GmbH)*, ថ្ងៃ២ ខែមិថុនា ឆ្នាំ២០១១។

អង្គការទន្លេអន្តរជាតិ, ការកើនឡើងនូវថាមពលអគ្គិសនី៖ ផលប៉ះពាល់នៃការអភិវឌ្ឍន៍ទំនប់ វារីអគ្គិសនីក្នុងប្រទេសឡាវ, ខែកញ្ញា ឆ្នាំ២០០៨។

គូមូអិម វ៉ារិស អូរ និងរ៉ាសានិន ធី Kummu, M., Varis, O. & Räsänen, T. ក្រុមសិក្សាស្រាវជ្រាវពីធនធានទឹក និងការអភិវឌ្ឍន៍, សាកលវិទ្យាល័យអាល់តូ, ហ្វាំងឡង់, ការបញ្ចូលឧស្ម័នផ្ទះកញ្ចក់ពីអាងទឹក-ករណីប្រទេសកម្ពុជា (របាយការណ៍ពង្រាង), ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០

ការត្រួតពិនិត្យលើរបាយការណ៍EIAនៃទំនប់វារីអគ្គិសនីសេសានក្រោម២, អង្គការវេទិកាមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា, ខែសីហា ឆ្នា២០០៩

ការអង្កេតអន្តរជាតិលើការកែលំអរទន្លេសេសាន, ធ្វើឲ្យប្រសើរឡើងវិញនូវលំហូរធម្មជាតិដោយធ្វើការផ្លាស់ប្ដូរដំណើរការទំនប់វារីអគ្គិសនី, ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៨។

អនុសាសន៍របស់សម្ព័ន្ធទន្លេកម្ពុជា លើរបាយការណ៍ពង្រាងពីហេតុប៉ះពាល់បរិស្ថាននៃគម្រោងទំនប់សេសានក្រោម២ ជំពូក៨ ដោយអ្នកពិគ្រោះយោបល់ក្នុងប្រទអេសកម្ពុជាសំខាន់ៗ, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨។

រុតកូយ អ៊ី អិតអល Rutkow, E. et al. ទន្លេក្រោម៖ លទ្ធផលនៃទំនប់វារីអគ្គិសនីលើដងទន្លេសេសានក្នុងប្រទេសវៀតណាមលើអាយុជីវិតប្រទេសកម្ពុជា ហើយអត្ថន័យក្នុងច្បាប់អន្តរជាតិ, អង្គការវេទិការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា, ខែធ្នូ ឆ្នាំ២០០៥។

លោក សែម ចំរើ ការអិវឌ្ឍន៍ធនធានទឹក៖ ការពិនិត្យលើគោលនយោបាយដែលមានស្រាប់ និងគម្រោងនីបញ្ញត្តិ, ឆ្នាំ២០០៧

ដាប់បិលយូដាប់បិលយូអេហ្វ WWF មេគង្គក្រោម -កម្មវិធីប្រទេស, របាយការណ៍ពិគ្រោះយោបល់ ៖ ការអង្កេតលើភាពសម្បូណ៌នៃធនធានត្រី និងការបញ្ចូលប្រព័ន្ធតាមដានធនធានត្រីក្នុងទន្លេស្រែពក,ខែមិថុនា ឆ្នាំ២០០៨

Ziv, G., Baran, E., Nam, S., Rodriguez-Iturbe, I. & Levin, S. A., ការធ្វើពាណិជ្ជកម្មលើជីវៈចម្រុះត្រី, សន្តិសុខស្បៀង និងទំនប់វារីអគ្គិសនីក្នុងតំបន់ទន្លេមេគង្គ, ការផ្ដល់យោបល់ដោយអ្នកសិក្សាវិទ្យាសាស្ត្រជាតិ, USA, ឆ្នាំ២០១២

**ឯកសារធនាគារអភិវឌ្ឍន៍អាស៊ី ADB**

ធនាគារអភិវឌ្ឍន៍អាស៊ីADB, ឯកសារគម្រោង, *TA6481*, រៀបចំបង្កើតបណ្ដាញចែកចាយថាមពលអគ្គិសនីបានសុកផ្លេគូ ក្នុងតំបន់មហាអនុតំបន់ទន្លេមេគង្គ។

ការចេញផ្សាយសេចក្ដីសង្ខេបកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ របស់ធនាគារ ADB-GMS, ឆ្នាំ ២០១០

ផែនការសកម្មភាព និងផែនការយុទ្ធសាស្ត្រ សម្រាប់មហាអនុតំបន់ទន្លេមេគង្គ, ឆ្នាំ២០១០

អត្ថបទបច្ចេកទេសរបស់ធនាគារ ADB RETA ៤០០៨២, ប្រធានបទទី៥ ស្ដីពីធនធានធម្មជាតិ និងជីវៈចម្រុះ

អត្ថបទបច្ចេកទេសរបស់ធនាគារ ADB RETA ៤០០៨២, ប្រធានបទទី៧ ស្ដីពីមនុស្ស និងជីវភាពរស់នៅ, ៨a ការអភិវឌ្ឍន៍ទំបន់វារអគ្គិសនី

អត្ថបទបច្ចេកទេសរបស់ធនាគារ ADB RETA ៤០០៨២, ប្រធានបទទី៨ ស្ដីពីការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ទន្លេបី, ៨a ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី

ធនាគារអភិវឌ្ឍន៍អាស៊ី ADB វិស័យថាមពលអគ្គិសនីក្នុងប្រទេសឡាវ ឯកសារយោង៖ SAP៖ LAO 2010-42, កម្មវិធីវាយតម្លៃលើផ្នែកជំនួយបច្ចេកទេស, ខែតុលា ឆ្នាំ២០១០

របាយការណ៍ចុងក្រោយរបស់ធនាគារ ADB៖ TA៦៣៦៧ករណីសិក្សាពីការអភិវឌ្ឍន៍ក្នុងតំបន់ទន្លេសេសាន, ស្រែពក និងសេកុងក្នុងប្រទេសកម្ពុជា ឡាវ និងប្រទេសវៀតណាម, ខែកក្កដា ឆ្នាំ ២០១០

គម្រោងរបស់ADBលេខ៤១០១៨៖ សម្របសម្រួលការធ្វើពាណិជ្ជកម្មថាម និងនិរន្តរភាពនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័នថាមពលអគ្គិសនីក្នុងមហាអនុតំបន់ទន្លេមេគង្គ, ខែវិច្ឆិកា ឆ្នាំ២០០៨

គម្រោងរបស់ADBលេខ៤១៤៥០៖ ការរៀបចំគម្រោងបណ្តាញចែកចាយថាមពលអគ្គិសនីក្នុងមហាអនុតំបន់ទន្លេមេគង្គ ខែសីហា ឆ្នាំ២០០៨

របាយការណ៍ចុងក្រោយលើទំនប់វារីអគ្គិសនីពីធនាគារ ADB លើទំនប់សេកុង, សេសាន និងណាមធឿនក្នុងឆ្នាំ១៩៩៩។

កិច្ចសង្ខេបលើការពិភាក្សាពិសេសមួយរបស់ធនាគារ ADB របស់គណៈកម្មាធិការរៀបសម្របសម្រួលពាណិជ្ជកម្មថាមពលអគ្គិសនីក្នុងតំបន់ (RPTCC-9A), បាងកក, ប្រទេសថៃ, ខែធ្នូ ថ្ងៃទី១៤-១៥ ឆ្នាំ២០១០

របាយការណ៍ចុងក្រោយរបស់ធនាគារ ADB៖ TA៦៣៦៧ករណីសិក្សាពីការអភិវឌ្ឍន៍ក្នុងតំបន់ទន្លេសេសាន ស្រែពក និងសេកុងក្នុងប្រទេសកម្ពុជា ឡាវ និងប្រទេសវៀតណាម។ ព័ត៌មាន គម្រោង។

របាយការណ៍កិច្ចសង្គ្រោះបច្ចេកទេសរបស់ធនាគារ ADB T6367-REG៖ ទន្លេសេសាន ស្រែពក និងទន្លេសេកុង ករណីសិក្សាការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម ខែសីហា ឆ្នាំ២០១១

របាយការណ៍កិច្ចសង្គ្រោះបច្ចេកទេសរបស់ធនាគារ ADB, គម្រោងលេខ៤០០៨២, ទន្លេសេសាន, ស្រែពក និងសេកុង, ករណីសិក្សាពីការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា, ឡាវ និងវៀតណាម

បទបង្ហាញរបស់យុងភិង ហៃ្យ Yongping Zhai, គោលការណ៍អ្នកទេសថាមពលអគ្គិសនី, ផ្នែកហេដ្ឋារចនាសម្ព័ន្ធ, ស្ថាប័នអាស៊ីអាគ្នេយ៍របស់ធនាគារ ADB, ការពិគ្រោះយោបល់ថ្នាក់តំបន់លើកម្មវិធីទំនប់វារីអគ្គិសនីរបស់គណៈកម្មការទន្លេមេគង្គ, តម្លៃទីផ្សារថាមពលក្នុងមហាអនុតំបន់ទន្លេមេគង្គ និងការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី, ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨

**<u>ធនាគារពិភពលោក</u>**

លទ្ធផលនៃការអនុវត្តន៍របស់អនាគារពិភពលោកក្នុងប្រទេសឡាវ, ពាណិជ្ជកម្មថាមពលអគ្គិ-សនីក្នុងមហាអនុតំបន់ទន្លេមេគង្គ(P១០៥៣៣១), ខែមីនា ឆ្នាំ២០១១

គម្រោងរួមគ្នាការពារធនធានទឹករបស់ធនាគារពិភពលោក, ការពិនិត្យលើបរិស្ថាន និងសង្គមដំបូង, ខែសីហា ឆ្នាំ២០១០

ព័ត៌មានវាយតម្លៃគម្រោងរបស់ធនាគារពិភពលោក លើគ្រោងរួមគ្នាការពារគ្រប់គ្រងធនធានទឹកទន្លេមេគង្គ, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១១

ព័ត៌មានវាយតម្លៃគម្រោងរបស់ធនាគារពិភពលោក លើគ្រោងរួមគ្នាការពារគ្រប់គ្រងធនធានទឹកទន្លេមេគង្គ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២

ផ្នែកគ្រប់គ្រងប្រទេសអាស៊ីអាគ្នេយ៍, ការរៀបរាប់ពីយុទ្ធសាស្ត្រលើការគាំទ្ររបស់ធនាគារពិភពលោក ដល់មហាអនុតំបន់, ខែតុលា ឆ្នាំ២០០៧

ឯកសារលទ្ធផលសម្រេចបានរបស់គម្រោងធ(SOPE) 2010៖ តំបន់អាស៊ីអាគ្នេយ៍ និងតំបន់ប៉ាស៊ីភិច, ប្រទេសឡាវ, ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១០

ក្រុមការងារធនាគារពិភពលោក ការសិក្សាលើយុទ្ធសាស្ត្របរិស្ថាននៃទំនប់លើដងទន្លេមេ៖ បានបញ្ជាក់ថា វានឹងមិនមានប្រាក់សម្រាប់វិនិយោគដល់គម្រោងទំនប់វារីអគ្គិសនីដលើដងទន្លេមេ, ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០

## ឯកសាររបស់រដ្ឋាភិបាល និងបទបង្ហាញផ្សេងៗ

គណៈកម្មការធិការមេគង្គជាតិកម្ពុជា (បានរៀបចំដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល), ការពិនិត្យថ្នាក់ជាតិលើទំនប់វារីអគ្គិសនី, ខែមិថុនា ឆ្នាំ២០០៣។

របាយការណ៍ត្រួតពិនិត្យ CLV-DTA, លើការកែសម្រួលបន្ថែមលើផែនការមេសម្រាប់ផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងប្រទេសកម្ពុជា ឡាវ និវៀតណាម, ការអភិវឌ្ឍន៍តំបន់ត្រីកោណរហូតដល់ឆ្នាំ២០២០, ខែវិច្ឆិកា ឆ្នាំ២០១០

CLV-DTA,ផែនការមេលើការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងតំបន់ត្រីកោណសម្រាប់ប្រទេសកម្ពុជា ឡាវ វៀតណាសម, ខែវិច្ឆិកា ឆ្នាំ២០០៤

គណៈកម្មាធិការសម្រាប់គ្រប់គ្រងទន្លេសេសាន និងទន្លេស្រែពក, កំណត់ហេតុកិច្ចប្រជុំលើទី៤ រវាងគណៈកម្មាធិការកម្ពុជា និងវៀតណាមសម្រាប់ការងារគ្រប់គ្រងទន្លេសេសាន និងទន្លេស្រែពក, 4-5 ខែមីនា ឆ្នាំ២០០៨

ច្បាប់ព្រៃឈើឆ្នាំ២០០២ ប្រទេសកម្ពុជា

លិខិតរបស់នាយករដ្ឋមន្ត្រី ហ៊ុនសែនលេខ៣១៖ឆ្លើយតបដល់សំណើររបស់ឯកឧត្តម ស៊ុន ឆាយ, ទីក្រុងភ្នំពេញ, រដ្ឋសភា, លើការសុំពន្យាពេលអនុវត្តគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ របស់ក្រុមហ៊ុនវៀតណាម (EVN) សហការជាមួយក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប កម្ពុជា, ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០០៧

បទបង្ហាញសិក្ខាសាលាក្នុងស្រុកមួយរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងJICA, ករណីសិក្សាផែនការមេលើការអភិវឌ្ឍន៍ទំនប់វារិអគ្គិសនីក្នុងប្រទេសកម្ពុជា, ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០០៧

បទបង្ហាញដោយជា ពិសិដ្ឋ នាយកដ្ឋានថាមពលអគ្គិសនីនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល លើថាមពលអគ្គិសនីជាតិ និងផែនការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីក្នុងប្រទេសកម្ពុជា, ១៦-១៧ កក្កដា ឆ្នាំ២០០៩

បទបង្ហាញដោយផល្លាន ប៉ាន, អគ្គនាយករងនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ,ផ្នែកថាមពល ក្នុងប្រទេសកម្ពុជា, ខែកញ្ញា ឆ្នាំ២០០៩

បងបង្ហាញដោយវិចតូ ចូណា អគ្គនាយដ្ឋានថាមពលនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ថាមពលអគ្គិសនីក្នុងប្រទេសកម្ពុជា និងការអភិវឌ្ឍន៍, ១៦ ខែមីនា ឆ្នាំ២០១១

ការធ្វើបច្ចុប្បន្នភាព២០០៩-២០១៣លើផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល កម្ពុជា

អនុក្រឹតលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩

**<u>ធនធានដែលទទួលបានពីសារព័ត៌មាន</u>**

ព័ត៌មានរបស់ BBC ធនាគារពិភពលោកបានផ្អាកការផ្តល់កម្ចីដោយជម្លោះបឹងកក់, ថ្ងៃទី៩ ខែ សីហា ឆ្នាំ២០១១

កាសែតខេមបូឌាដេលី, ការតស៊ូមតិសម្រាប់ទន្លេបី, ១០-១១ ខែកញ្ញា ឆ្នាំ២០១១

កាសែតខេបូឌាដេលី, VNបានសុំឲ្យមានការយល់ព្រមលើគម្រោងទំនប់, ខែវិច្ឆិកា ថ្ងៃទី១៦ ឆ្នាំ ២០១០

បណ្តាញសារព័ត៌មានចិន ឡូកាបោន Low-Carbon, ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងទំនប់ ស្រែពកវវាងកម្ពុជា និងវូ បាគូ (Wu Baoguo), ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១០

ក្រុមហ៊ុនថាមពលអគ្គិសនីចិន, ហ៊ុឌាន ខុបផើរេស៊ិន បានចូលមកដល់កម្ពុជាដើម្បីធ្វើការសិក្សាលើគម្រោងទំនប់វារីអគ្គិសនីស្រែពក, ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១១

ក្រុមហ៊ុនអន្តរជាតិដានត្រិ, តំបន់ខ្ពង់រាបកំពុងប្រឈមនឹងគ្រោះរាំងស្ងួត, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១១

សារព័ត៌មានអិចស្ពត អិមផត បែង Export-Import Bank of India, បានចុះផ្សាយធនាគារអ៊ិចសិម *Exim Bank* បានចូលរួមក្នុងគម្រោងបង្កើតបណ្តាញបណ្តាញចែកចាយថាមពលអគ្គិសនីក្នុងប្រទេស កម្ពុជា, ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១០

សារព័ត៌មានពីក្លូបលថែម ឆៃណាហ៊ុឌាន Global Times, *China Huadian*, អេជខេ *HK*សង់ស្ថានីយ៍ទំបន់អគ្គិសនីក្នុងប្រទេសកម្ពុជា, ថ្ងៃទី១ ខែមេសា ឆ្នាំ២០១០

ខូរាននិត Koreanet, ប្រធានក្រុមហ៊ុនលីរ៉េប អាប់ ស្តេត *Lee Wraps Up State*បានមកទស្សនៈកិច្ចប្រទេសកម្ពុជា, ថ្ងៃទី២៣ ខែតុលា ឆ្នាម២០០៩

ព័ត៌មានដែលបានចុះផ្សាយក្នុងគេហទំព័ររបស់គណៈកម្មការទន្លេមេគង្គ វៀតណាម, កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើគម្រោងរួមគ្នាគ្រប់គ្រងធនធានទឹកទន្លេមេគង្គ, ខែសីហា ឆ្នាំ២០១០

ភ្នំពេញប៉ុស្តិ៍, ការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ជិតចាប់ផ្តើម, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១

ភ្នំពេញប៉ុស្តិ៍, ការនាំចេញថាមពលអគ្គិសនីទៅក្រៅនឹងចាប់ផ្តើមក្នុងឆ្នាំ២០១៦, សម្តីមន្ត្រីរដ្ឋាភិបាល, ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩

ភ្នំពេញប៉ុស្តិ៍, ថាមពលអគ្គិសនីគឺសម្រាប់វៀតណាម, ថ្ងៃទី១ខែមិថុនា ឆ្នាំ២០១១

ភ្នំពេញប៉ុស្តិ៍,ទំនប់វារីអគ្គិសនីសេសាននៅចាប់ផ្តើមសាងសង់ក្នុងឆ្នាំនេះ, ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១

ភ្នំពេញប៉ុស្តិ៍, ក្រុមហ៊ុនកូរ៉េ ខេធីស៊ី ខេបល *KTC Cable*វិនិយោគទឹកប្រាក់ចំនួន៧០០លានដុល្លារសម្រាប់គម្រោងទនប់វារីអគ្គិសនីក្នុងខេត្តរតនគិរី, ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៩

ភ្នំពេញប៉ុស្តិ៍,ធនាគារកូរ៉េខាងត្បូងចាប់ផ្តើមដំណើរក្នុងប្រទេសកម្ពុជា, ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៩

ក្រុមហ៊ុនវ៉ូធើវៀតណាម ចេញសេចក្តីបញ្ជាក់មួយថា ជួបវិបត្តិធំ, ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១

សារព័ត៌មានសាយហ្គុនដេលី, តំបន់ខ្ពង់រាបតាមដងទន្លេជិតខូចទាំងស្រុងហើយ, ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១

សារព័ត៌មានសាយហ្គុន ផុង ដេលី, ទំនប់វារីអគ្គិសនីធ្វើឲ្យទន្លេហិនហោច, ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១១

សារព័ត៌មានសាយហ្គុន ផុង ដេលី, វៀតណាមជួបបញ្ហាថាមពលថយចុះក្នុងរដូវប្រាំង, អ៊ីវីអ៊ិន EVN និយាយក្នុងថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១

សារព័ត៌មានសាយហ្គុន ផុង ដេលី, អាងស្តុកទឹកទំនប់ចុះទាប, អ៊ីវីអ៊ិន EVN និយាយក្នុងថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១

សារផៃណាម៉ូនីងប៉ុស៏South China Morning Post, គម្រោងរបស់ចិនកំពុងមានសម្ពាធដល់សាធារណៈ, ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១១

ព័ត៌មានថាញ់នានThanh Nien News, អគ្គិសនីវៀតណាម *EVN*សុំតម្លើងថ្លៃថាមពលអគ្គិសនី, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១១

ព័ត៌មានថាញ់នានThanh Nien News,វៀតណាមនឹងប្រឈមនូវប្រើប្រាស់ថាមពលក្នុងរយៈពេលខ្លី ឬបើភ្លើងបានខ្លី និងមិនគ្រប់គ្រាន់ក្នុងឆ្នាំ២០១៣, ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១០

កាសែតខែមបូឌាដេលី, ការរើតាំងទីលំនៅថ្មីគឺដើម្បីគេចពីគម្រោងថាមពលអគ្គិសនី, ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១១

កាសែតខែមបូឌាដេលី,វៀតណាមនឹងសាងសង់ទំនប់វារីអគ្គិសនីចំនួន២គម្រោងក្នុងខេត្តរតនគិរី, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧

សារព័ត៌មានសាយហ្គុនធែម The Saigon Times, អគ្គិសនីវៀតណាម *EVN* បានប្រាប់ថា ចាប់ផ្តើមនិយាយពីពីការនាំចូលថាមពលអគ្គិសនីក្នុងរយៈពេលវែង, ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១០

សារព័ត៌មានសាយហ្គុនធែម The Saigon Times, ទំនប់វារីអគ្គិសនីសេសានក្រោម២ដើរក្រោយការគ្រោង, ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១១

សារព័ត៌មានសាយហ្គុនធែម The Saigon Times, ខ្សែបណ្តាញចែកចាយថាមពលអគ្គិសនីវៀតណាម ឡាវ នឹងបញ្ចប់ក្នុងឆ្នាំ២០១៥, ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០

សារព័ត៌មានវៀតចាន់ធែម, Vientiane Times,ឡាវនាំចេញថាមពលអគ្គិសនីទៅប្រទេសកម្ពុជា, ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៦

សារព័ត៌មានវៀងចាន់ថៃម, Vientiane Times, គម្រោងទំនប់វារីអគ្គិសនីជាច្រើនទៀតតំរូវឲ្យធ្វើការព្យាករណ៍ពីការទាមទារផ្សេងៗ, ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១

ការពិនិត្យឡើងវិញលើថវិកាវៀតណាម, ការប្រើប្រាស់អគ្គិសនីបានពេលខ្លី,ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១

ព័ត៌មានពាណិជ្ជកម្មវៀតណាម, ការវិនិយោគវៀតណាមទៅកម្ពុជាមានការកើនឡើង,ខែមេសា ឆ្នាំ២០១១

ភ្នាក់ងារសារព័ត៌មានវៀតណាម, *EVN* ទាញយកផលចំណេញីថាមពលអគ្គិសនីក្នុងប្រទេសកម្ពុជា, ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១

ភ្នាក់ងារសារព័ត៌មានវៀតណាម, *EVN* ពន្លឿនការងារទាក់ទងនឹងទំនប់នៅក្នុងប្រទេសឡាវ កម្ពុជា, ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១១

សារព័ត៌មានវៀតណាម, *EVN*ការងារបានចាប់ផ្តើមលើទំនប់ក្នុងប្រទេសឡាវ, ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១

ក្រុមហ៊ុនវៀតណាម ទូទ្រីនូ ភិតត្រវៀតណាម, Vietnam Tuoitrenews, *PetroVietnam* បានជម្រុញឲ្យ *EVN*សងប្រាក់បំណុល, ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១

VietnamNetBridge, *Giant EVN* ព្យាយាមចរចារលើកាសងបំណុលរបស់ខ្លួន, ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១

VNA, *EVN* ពន្លឿនការងារទាក់ទងនឹងទំនប់នៅក្នុងប្រទេសឡាវ កម្ពុជា, ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១១

VNBusinessNews, គម្រោងទំនប់វារីអគ្គិសនីសេសាន៥បានផ្អាក់បណ្តោះអាសន្ន, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩

Voice of Vietnam News, *EVN* បានជម្រុញឲ្យមានការឆ្លើយតបនូវតម្រូវការថាមពលអគ្គិសនី, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១០

Wall Street Journal Online, ផែនការវៀតណាមគ្រោងទឹកប្រាក់ចំនួន ៤៨,៨កោដដុល្លារ សម្រាប់គម្រោងថាមពលអគ្គិសនីក្នុងឆ្នាំ២០១១-២០២០, ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១១

Xinhua,កម្ពុជាចំណាយថវិកាចំនួន៥៩លានដុល្លារក្នុងការនាំចូលថាមពលអគ្គិសនីក្នុងឆ្នាំ២០០៩, ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១០

Xinhua, ក្រុមហ៊ុនចិនធ្វើសិក្សាពីលទ្ធផលដែលអាចធ្វើបានក្នុងការសាងសង់ទំនប់ក្នុងប្រទេសកម្ពុជា, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៨

**ព័ត៌មានគម្រោង**

Electricité du Laos, ការពិនិត្យលើបរិស្ថានដំបូង *(IEE)*សម្រាប់គម្រោងបណ្តាញថាមពល អគ្គិសនីបានហាត*Ban Hat*ភ្ជាប់ទៅព្រំដែនឡាវ និងកម្ពុជាដែលមានកម្លាំងវុល២៣០គីឡូវ៉ុល, ខែកុម្ភៈ, ឆ្នាំ២០១១

របាយការណ៍សង្ខេបរបស់ EVN៖ គម្រោងទំនប់សេសានក្រោម១ ឬទំនប់សេសាន៥ , ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០

EVN, របាយការណ៍សង្ខេប៖ គម្រោងទំនប់សេសានក្រោម២, ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១០

EVN, របាយការណ៍សង្ខេប៖ ការវិនិយោគលើគម្រោងភ្ជាប់បណ្តាញចែកចាយថាមពលអគ្គិសនីសេសាន១ ឬសេសាន៥ ទៅបណ្តាញថាមពលធំ, ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១០

Huot, V. et al., មហាវិទ្យាល័យជលផលនៃសាកលវិទ្យាល័លកសិកម្មជាតិ, ការសិក្សាលើធនធានជលផលសម្រាប់គម្រោងទំនប់វារីអគ្គិសនីសេសាន២, ខែសីហា ឆ្នាំ២០០៩

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (រៀបចំដោយ KEPCO), គម្រោងអនុតំបន់បានហាត ភ្ជាប់ទៅខេត្តស្ទឹងត្រែង, ខែធ្នូ ឆ្នាំ២០១០

PECC1 & KCC, ការប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថាន សម្រាប់ការសិក្សាលទ្ធភាព ដែលអាចធ្វើបាននៃគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២, ខេត្តស្ទឹងត្រែង, ប្រទេសកម្ពុជា, ខែតុលា ឆ្នាំ២០០៨

PECC1 & KCC, ការប៉ាន់ប្រមាណផលប៉ះពាល់បរិស្ថានសម្រាប់ទំនប់វារីអគ្គិសនីសេសានក្រោម២, ខែតុលា ឆ្នាំ២០០៨

3 S Rivers Protection Network

INTERNATIONAL RIVERS
people • water • life



# ទន្លេបីកំពុងរងការគំរាមកំហែង